រាជរដ្ឋាភិបាលកម្ពុជា

# កម្មវិធីកែទម្រង់
# ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
# ដំណាក់កាលទី២

## លើមូលដ្ឋាននៃថវិកាដែលអាចជឿទុកចិត្តបាន
## ឆ្ពោះទៅ
## ការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុឱ្យកាន់តែប្រសើរឡើង

ខែធ្នូ ឆ្នាំ ២០០៨

# រាជរដ្ឋាភិបាលកម្ពុជា

# កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

# ដំណាក់កាលទី ២

## លើមូលដ្ឋាននៃថវិកាដែលអាចជឿទុកចិត្តបាន

## ឆ្ពោះទៅ

## ការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុឱ្យកាន់តែប្រសើរឡើង

ខែធ្នូ ឆ្នាំ ២០០៤

# មាតិកា


- បុព្វកថារបស់នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- អារម្ភកថារបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

១. ការពិនិត្យឡើងវិញលើចក្ខុវិស័យរួមនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ១

២. ការពិនិត្យឡើងវិញលើយុទ្ធសាស្ត្ររួមនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ៤

៣. សមិទ្ធផល និង បញ្ហាប្រឈមនៃជំហានទី ១ ក្នុងដំណាក់កាលទី ១ ៨

៤. ការបង្ហាញអំពីដំណើរការរៀបចំផែនការសកម្មភាពដំណាក់កាលទី ២: គោលបំណង យុទ្ធសាស្ត្រ និង ផែនការសកម្មភាពរួម ២៣

៥. ក្របខ័ណ្ឌគ្រប់គ្រងកម្មវិធី ៤០

៦. ឧបសម្ព័ន្ធ ៤២

ឧបសម្ព័ន្ធទី ១ ផែនការសកម្មភាពរួម ៤៣

ឧបសម្ព័ន្ធទី ២ យន្តការដឹកនាំ និងសម្របសម្រួល ៩៧

ឧបសម្ព័ន្ធទី ៣ យន្តការសម្រាប់ការចូលរួមរបស់ក្រសួង ស្ថាប័ន ១០១

ឧបសម្ព័ន្ធទី ៤ ការកែលម្អការប្រើប្រាស់ទីប្រឹក្សាបច្ចេកទេសក្នុងដំណាក់កាលទី ២ ១២៥

ឧបសម្ព័ន្ធទី ៥ យុទ្ធសាស្ត្រសម្រាប់ការអនុវត្ត ១៣៤

៥.១ ការអភិវឌ្ឍសមត្ថភាពដើម្បីគាំទ្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ១៣៥

៥.២ ទម្រង់ផែនការកសាងសមត្ថភាពក្រសួង-ស្ថាប័ន ១៦២

៥.៣ គោលនយោបាយប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ ១៦៤

ឧបសម្ព័ន្ធទី ៦ តម្រូវការធនធានដើម្បីគាំទ្រកម្មវិធីជំហានទី ២/ដំណាក់កាលទី២ ១៩៧

ឧបសម្ព័ន្ធទី ៧ យន្តការពិនិត្យតាមដាន ២០៩

ឧបសម្ព័ន្ធទី ៨ យន្តការដើម្បីធានាភាពស៊ីសង្វាក់ជាមួយកំណែទម្រង់ដទៃ ២២២

ឧបសម្ព័ន្ធទី ៩ ការចូលរួមរបស់ដៃគូអភិវឌ្ឍន៍ ២២៥

ឧបសម្ព័ន្ធទី ១០ ការគ្រប់គ្រងហានិភ័យ ២៣២

# អារម្ភកថា

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានគូសបញ្ជាក់ជាថ្មីឡើងវិញថា **អភិបាលកិច្ចល្អ** នៅតែជាស្នូលនៃ **យុទ្ធសាស្ត្រចតុកោណ *ដំណាក់កាលទី ២*** ដែលត្រូវបន្តផ្តោតការយកចិត្តទុកដាក់លើកំណែទម្រង់បួនគឺ (១) ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ (២) កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ (៣) កំណែទម្រង់រដ្ឋបាលសាធារណៈ ដែលរួមមានទាំងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង កម្មវិធីវិមជ្ឈការ និងវិសហមជ្ឈការផង និង (៤) កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ ។ លើសពីនេះទៅទៀត **យុទ្ធសាស្ត្រចតុកោណ *ដំណាក់កាលទី ២*** ដែលជា «**របៀបវារៈគោលនយោបាយសង្គម-សេដ្ឋកិច្ច**» នៃ «**កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី ៤ នៃរដ្ឋសភា**» មានគោលដៅ ***«ធានាឱ្យបាននូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពក្នុងអត្រាប្រមាណ ៧% ក្នុងមួយឆ្នាំ នៅលើមូលដ្ឋានទូលាយជាងមុន និងមានសមត្ថភាពប្រកួតប្រជែងខ្ពស់ជាងមុន នៅក្នុងបរិការណ៍អត្រាអតិផរណាក្នុងកម្រិតតួលេខមួយខ្ទង់ ព្រមទាំងធានាសម្រេចឱ្យបាននូវការកាត់បន្ថយអត្រានៃភាពក្រីក្រឱ្យបានលើស ១% ក្នុងមួយឆ្នាំ»*** ។

ពិតជាមិនមែនជារឿងចៃដន្យទេ ដែលស្របគ្នានឹង **យុទ្ធសាស្ត្រចតុកោណ** ឈានទៅដំណាក់កាលទី ២ **កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** ដែលជាស្នូលនៃកំណែទម្រង់រដ្ឋបាលសាធារណៈ ក៏បានបញ្ចប់ជាសារវន្តប្រកបដោយជោគជ័យ នូវគោលបំណងដំណាក់កាលទី ១ គឺ **ការរង្កើនភាពជឿទុកចិត្តលើថវិកា** ហើយឈានទៅចាប់ផ្តើមអនុវត្តផែនការសកម្មភាពដំណាក់កាលទី ២ ដែរនោះ ។ ដំណាក់កាលទី ២ នេះ មានគោលបំណង **បង្កើនគណនេយ្យភាពហិរញ្ញវត្ថុ** សំដៅបង្កើនភាពស័ក្តិសិទ្ធិក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមរយៈការធ្វើឱ្យមន្ត្រីសាធារណៈគ្រប់លំដាប់ថ្នាក់ អាចទទួលយកការទទួលខុសត្រូវចំពោះការប្រើប្រាស់ និងការគ្រប់គ្រងធនធានសាធារណៈ ដោយផ្តល់សិទ្ធិអំណាចសមស្របសម្រាប់ការបំពេញការទទួលខុសត្រូវប្រកបដោយភាពស័ក្តិសិទ្ធិ និង បង្កើតឱ្យមាន និងប្រើប្រាស់ប្រកបដោយភាពស័ក្តិសិទ្ធិនូវឧបករណ៍សម្រាប់ជំរុញឱ្យមានគណនេយ្យភាព ។ បន្ទាប់មក ជាបណ្តើរៗនឹងឈានទៅ **បង្កើនការផ្សារភ្ជាប់រវាងថវិកាទៅនឹងគោលនយោបាយ** ដែលជាគោលបំណង នៃដំណាក់កាលទី ៣ តាមរយៈការអនុវត្តឱ្យបានពេញលេញនូវ **ផែនការយុទ្ធសាស្ត្រថវិកា** និង **ថវិកាតាមកម្មវិធី** សំដៅបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ធនធានសាធារណៈ និងធានាថាថវិកាពិតជាដើរតួជាឧបករណ៍នៃគោលនយោបាយយ៉ាងពិតប្រាកដ ។ ទីបញ្ចប់ **គណនេយ្យភាពចំពោះសមិទ្ធកម្ម** របស់អ្នកគ្រប់គ្រងថវិកាដែលជាគោលបំណងនៃដំណាក់កាលទី ៤ អាចនឹងត្រូវបានបង្កើន ក្នុងគោលដៅធានាភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីឈានទៅបង្កើនកម្រិតស្តង់ដារនៃការគ្រប់គ្រងហិរញ្ញវត្ថុ

សាធារណៈរបស់កម្ពុជាឱ្យស្របទៅនឹងស្តង់ដារអន្តរជាតិ ដែលជាចក្ខុវិស័យរយៈពេលវែងរបស់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងដែលមានគោលដៅធ្វើឱ្យបានសម្រេចនៅក្នុងឆ្នាំ ២០១៥ ។

ចក្ខុវិស័យរយៈពេលវែងរបស់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនេះ គឺពិតជាប្រកបដោយមហិច្ឆិតា និងសុទិដ្ឋិនិយមមែន ។ ប៉ុន្តែបើយើងពិនិត្យមើលលើសេចក្តីត្រូវការចាំបាច់ និងបន្ទាន់ទាំងឡាយ ដើម្បីសម្រេចបានតាមគោលដៅរបស់ ***យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី ២*** ខាងលើ នោះយើងប្រាកដជាគិតថាចក្ខុវិស័យនេះ គួរតែមានមហិច្ឆិតា និងសុទិដ្ឋិនិយមធំធេងជាងនេះទៅទៀត ។ លើសពីនេះទៅទៀត ដំណាក់កាលទី ២ នេះមានលក្ខណៈកាន់តែស៊ីជម្រៅ និងស្មុគ្រស្មាញជាងមុន ហើយវិសាលភាពរបស់វាក៏មានលក្ខណៈទូលំទូលាយជាងមុនដែរ ។ ផ្ទុយពីដំណាក់កាលទី ១ ដែលការងារភាគច្រើនប្រមូលផ្តុំតែនៅក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយដែលផ្តោតទៅលើតែការកែលម្អយន្តការ និងបរិបទអនុវត្តមួយចំនួនប៉ុណ្ណោះ ការងារនៅក្នុងដំណាក់កាលទី ២ ខាងមុខនេះ ទន្ទឹមនឹងការពង្រីកវិសាលភាពទៅគ្រប់ក្រសួង-ស្ថាប័ន ត្រូវផ្តោតទៅលើការកែលម្អរចនាសម្ព័ន្ធស្ថាប័ន ផ្លាស់ប្តូរវិធីសាស្ត្រគ្រប់គ្រង ឥរិយាបថ និងទស្សនៈ ព្រោះវានឹងពាក់ព័ន្ធដល់ការកំណត់តួនាទី និងមុខងាររបស់អង្គភាពនៅក្នុងក្រសួង-ស្ថាប័ននីមួយៗឡើងវិញឱ្យបានច្បាស់លាស់ និងការកំណត់បរិបទការងារថ្មី នៅក្នុងក្របខ័ណ្ឌនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមួយដែលមានកម្រិតស្តង់ដារខ្ពស់ជាងមុន ។ម្យ៉ាងទៀត ការបង្កើនយន្តការ និងការសម្របសម្រួលរវាងគ្រប់ការដ្ឋានកំណែទម្រង់ទាំងអស់កាន់តែសំខាន់ និងចាំបាច់ ពិសេសការផ្សារភ្ជាប់រវាងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីវិមជ្ឈការ និងវិសហមជ្ឈការ និង កំណែទម្រង់រដ្ឋបាលសាធារណៈ ដើម្បីធានាសង្គតិភាព ភាពរលូនក្នុងការអនុវត្ត និងជោគជ័យនៃកំណែទម្រង់រដ្ឋបាលសាធារណៈនេះ ដែលជាស្នូលនៃអភិបាលកិច្ចល្អ ។

បញ្ហាប្រឈម និងការងារជាច្រើនពិតជាស្ថិតនៅចំពោះមុខយើងមែន ប៉ុន្តែបើយើងក្រឡេកមើលសមិទ្ធផលដែលយើងសម្រេចបានកន្លងមកវាក៏មានទំហំធំធេងគួរជាទីលើកទឹកចិត្តដែរ ។ ការបង្កើនបានភាពជឿទុកចិត្តលើថវិកា តាមរយៈការបង្កើនចំណូល និងវិចារណកម្មចំណាយ ពិសេស ការប្រែក្លាយស្ថានភាពអនុវត្តថវិកា ***ពីភាពរាំរ៉ៃនៃនិនភាពសាច់ប្រាក់មកមានអតិរេកសាច់ប្រាក់*** បានអនុញ្ញាតឱ្យរាជរដ្ឋាភិបាល អាចបង្កើនបៀវត្សជូនមន្ត្រីរាជការ គ្រូបង្រៀន កងកម្លាំងប្រដាប់អាវុធ និងនគរបាល បានកាន់តែប្រសើរជាងមុនពីមួយឆ្នាំទៅមួយឆ្នាំ អាចបង្កើនចំណាយវិនិយោគសាធារណៈលើហេដ្ឋារចនាសម្ព័ន្ធសង្គម-សេដ្ឋកិច្ច ក្នុងគោលបំណងពង្រឹង និងពង្រីកសេវាសាធារណៈ និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ព្រមទាំងអាចដោះស្រាយទប់ទល់នឹងគ្រោះធម្មជាតិ វិបត្តិសេដ្ឋកិច្ច សង្គម និង សន្តិសុខ ជាយថាហេតុបានថែមទៀតផង ។ លើសពីនេះទៅទៀត ឈរលើគោលការណ៍ដ៏ពិសិដ្ឋស្តីពី**រដ្ឋទោល** ឬ **ឯកត្តរដ្ឋ** នៃព្រះរាជាណាចក្រកម្ពុជា និងគោលការណ៍ **សង្គតិភាព សាកលភាព សមាគតភាព បូរណភាពនៃថវិកា** យើងបានកសាង **ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ** មួយដែលមានលក្ខណៈ

ប្រទាក់ក្រឡា ស៊ីសង្វាក់ មានសង្គតិភាព និងបំរើឱ្យការអនុវត្ត **ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ** និង **ច្បាប់ស្តីពីការគ្រប់គ្រង ឃុំ-សង្កាត់** ។ ម្យ៉ាងទៀត យន្តការ និងការសម្របសម្រួលរវាងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកំណែទម្រង់រដ្ឋបាលសាធារណៈក៏ត្រូវបានពង្រឹង និងពង្រីក ពិសេសតាមរយៈការកែលម្អក្របខ័ណ្ឌបៀវត្សរ៍ ការផ្តល់ព័ត៌មានអំពីការគ្រប់គ្រងក្របខ័ណ្ឌមន្ត្រីរាជការសម្រាប់ការរៀបចំថវិកា ព្រមទាំងការអនុវត្តកន្សោមអាទិភាព និងការអនុវត្តការផ្តល់លាភការតាមលទ្ធផលការងារជាដើម ។

លើសពីនេះទៅទៀត យើងក៏បានរៀបចំរួចជាស្រេចផងដែរនូវក្របខ័ណ្ឌ និងយន្តការដើម្បីពង្រឹង និងពង្រីកភាពជាម្ចាស់ ការទទួលខុសត្រូវ និង សូចនាករសមិទ្ធកម្ម ព្រមទាំងប្រព័ន្ធត្រួតពិនិត្យតាមដានវឌ្ឍនភាពជាប្រចាំដែលមាន ៣ ប្រភេទ និង ៣ កម្រិត ថែមទៀតផង ។ ដូច្នេះទន្ទឹមនឹង ការរៀបចំនូវផែនការសកម្មភាពរួម និង ផែនការសកម្មភាពរបស់នាយកដ្ឋាននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គ្រប់ក្រសួង-ស្ថាប័នទាំងអស់ ក៏បានរៀបចំផែនការសកម្មភាពរបស់ខ្លួនផងដែរ ដើម្បីចូលរួមក្នុងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅក្នុងដំណាក់កាលទី ២ នេះ ។ ម្យ៉ាងទៀត យន្តការត្រួតពិនិត្យតាមដាននឹងត្រូវធ្វើជាប្រចាំខែ ត្រីមាស និងឆ្នាំ ដោយផ្អែកលើសកម្មភាពការងារដំណាក់កាលទី ២ នីមួយៗ របស់នាយកដ្ឋាននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័ន ដោយផ្អែកលើសូចនាករសមិទ្ធកម្មសម្រាប់ដំណាក់កាលទី ១ ដែលត្រូវបន្តត្រួតពិនិត្យ និង ដោយផ្អែកលើចំណុចគោលនៃសូចនាករសមិទ្ធកម្មសម្រាប់ដំណាក់កាលទី ២ ។

ដំណើរការនៃការអនុវត្តដំណាក់កាលទី ១ ដែលពោរពេញដោយឆន្ទះមោះមុត ភាពជាម្ចាស់ និងការទទួលខុសត្រូវខ្ពស់ និងការធ្វើបណ្តើររៀនសូត្របណ្តើរ បានធ្វើឱ្យយើងកាន់តែយល់ច្បាស់ពីបញ្ហា កាន់តែរៀបចំ ផែនការសកម្មភាពបានគ្រប់ជ្រុងជ្រោយ និងស័ក្តិសិទ្ធិ និងកាន់តែមានភាពជឿជាក់ ។ សមិទ្ធផល ដំណាក់កាលទី ១ និងឯកសារ ***កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ២ «លើមូលដ្ឋាននៃថវិកាដែលអាចជឿទុកចិត្តបានឆ្ពោះទៅការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុឱ្យកាន់តែប្រសើរឡើង»*** នេះ បានមកដោយសារការប្រមូលផ្តុំនូវបទពិសោធន៍ក្នុងការអនុវត្តដំណាក់កាលទី ១ ការខិតខំប្រឹងប្រែងយ៉ាងសកម្ម និងការប្រឹក្សាយ៉ាងទូលាយពីសំណាក់ ថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងពីគ្រប់ក្រសួង-ស្ថាប័ន ព្រមទាំងដៃគូអភិវឌ្ឍន៍ទាំងអស់ ។ លើសពីនេះ ឯកសារនេះមិនត្រឹមតែកំណត់យ៉ាងច្បាស់លាស់នូវយុទ្ធសាស្ត្រ និងផែនការសកម្មភាពរួមដែលត្រូវអនុវត្តសម្រាប់កសាងជំហានទី ២ សម្រាប់បន្តពង្រឹងជំហានទី ១ និងត្រៀមលក្ខណៈសម្រាប់បណ្តាជំហានបន្ទាប់ប៉ុណ្ណោះទេ តែថែមទាំងកំណត់ពីយន្តការដឹកនាំ សម្របសម្រួល និងត្រួតពិនិត្យតាមដានយ៉ាងល្អិតល្អន់ និងគ្រប់ជ្រុងជ្រោយទៀតផង ។ ទោះជាយ៉ាងណា ត្រូវចាត់ទុកឯកសារនេះជា «**ឯកសាររស់**» ដែល

អនុញ្ញាតឱ្យយើងកែសម្រួលទៅតាមបទពិសោធន៍ដែលទទួលបានក្នុងពេលអនុវត្ត តាមរយៈយន្តការនៃក្របខ័ណ្ឌត្រួតពិនិត្យតាមដាន ពិសេស ការត្រួតពិនិត្យប្រចាំឆ្នាំ ស្ថិតក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្ររួម និងដើម្បីធានារក្សាឱ្យបាននូវគោលដៅនៃចក្ខុវិស័យរយៈពេលវែង ។

ដំណាក់កាលទី ២ នេះ គឺជាដំណាក់កាលដ៏សំខាន់បំផុតក្នុងចំណោមដំណាក់កាលទាំងបួននៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់យើង ហើយក៏អាចចាត់ទុកថាជោគជ័យនៃដំណាក់កាលទី ២ គឺជាកត្តាកំណត់ជោគជ័យនៃកំណែទម្រង់ទាំងមូលផងដែរ ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងនៅតែដើរតួជាអ្នកនាំមុខក្នុងតួនាទីជាអ្នកត្រួសត្រាយផ្លូវ ផ្តល់ការណែនាំ ផ្តល់ជំនួយបច្ចេកទេស និងសម្របសម្រួល ក្នុងនាមជាកាតាលីករ ។ ទោះជាយ៉ាងណា ពិសេសក្នុងដំណាក់កាលទី ២ នេះ គ្រប់ក្រសួង- ស្ថាប័នទាំងអស់មិនអាចដើរតួត្រឹមតែជាអ្នកចូលរួមអនុវត្តប៉ុណ្ណោះទេ តែត្រូវដើរតួជាតួអង្គគន្លឹះនៅក្នុងការអនុវត្ត ។ ដូច្នេះ ជោគជ័យនៃដំណាក់កាលទី ២ នេះ គឺអាស្រ័យដោយការចូលរួមប្រកបដោយភាពជាម្ចាស់ និងការទទួលខុសត្រូវខ្ពស់ និងការខិតខំប្រឹងប្រែងពុះពារគ្រប់ឧបសគ្គព្រមគ្នារបស់គ្រប់ក្រសួង- ស្ថាប័នទាំងអស់ ព្រមទាំងការដឹកនាំ សម្របសម្រួលប្រកបដោយភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពខ្ពស់ រវាងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាមួយនឹងកំណែទម្រង់រដ្ឋបាលសាធារណៈ និងកម្មវិធីវិមជ្ឈការ និងវិសហមជ្ឈការ ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមគោរពថ្លែងអំណរគុណដ៏ជ្រាលជ្រៅបំផុត ជូនចំពោះ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលបានផ្តល់ការគាំទ្រ និងលើកទឹកចិត្តចំពោះកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដ៏មានសារៈសំខាន់ និង ដែលជាស្នូលនៃកំណែទម្រង់រដ្ឋបាលសាធារណៈនេះ ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងនាមជាសេនាធិការតែមួយរបស់សម្តេចនាយករដ្ឋមន្ត្រី ដែលជាអគ្គមេបញ្ជាការតែមួយក្នុងការគ្រប់គ្រងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ប្តេជ្ញាបន្តនាំមុខក្នុងការអនុវត្តឱ្យបានហ្មឺងម៉ាត់ និងហ្មត់ចត់ជាទីបំផុតនូវ ***កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ: ដំណាក់កាលទី ២*** នេះ ឱ្យសម្រេចបានជោគជ័យតាមការរំពឹងទុក ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០០៨*

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

# បុព្វកថា

នៅក្នុងចំណោមសមិទ្ធផលសំខាន់ៗទាំង ៩ ចំណុច របស់រាជរដ្ឋាភិបាល នីតិកាលទី ៣ កន្លងទៅ ដូចត្រូវបានគូសបញ្ជាក់នៅក្នុងឯកសារ «***យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ២***» ការអនុវត្ត ***«កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ»*** ជំហានទី ១ ដំណាក់កាលទី ១ គឺជាចំណុចលេចធ្លោដ៏គួរឱ្យកត់សម្គាល់បំផុត ។ លទ្ធផលជាវិជ្ជមាននៃការអនុវត្តកម្មវិធីកែទម្រង់នេះ ត្រូវបានឆ្លុះបញ្ចាំងឡើងជាពិសេសតាមរយៈការកែលម្អចំណូលថវិកាជាតិ ដែលបានកើនឡើង ជាមធ្យម ២៦% ក្នុងមួយឆ្នាំ ។ ក្នុងរយៈពេលដ៏ខ្លី រាជរដ្ឋាភិបាលបានកែប្រែស្ថានភាពនៃការអនុវត្តថវិកា ***«ពីភាពរ៉ាំរ៉ៃនៃឱនភាពសាច់ប្រាក់ មកជាមានអតិរេកសាច់ប្រាក់»*** ។ ប្រការនេះ បានអនុញ្ញាតឱ្យរាជរដ្ឋាភិបាលធ្វើវិចារណកម្មចំណាយថវិកាជាតិឱ្យកាន់តែប្រសើរឡើង តាមរយៈការបង្កើនបៀវត្សជូនគ្រូបង្រៀន មន្ត្រីរាជការ និង កងកម្លាំងប្រដាប់អាវុធ គ្រប់ប្រភេទ ឱ្យបានកាន់តែច្រើនឡើង ពីមួយឆ្នាំទៅមួយឆ្នាំ និងជាពិសេស តាមរយៈការបង្កើនទុនវិនិយោគសាធារណៈលើហេដ្ឋារចនាសម្ព័ន្ធសង្គម-សេដ្ឋកិច្ច ក្នុងគោលដៅពង្រឹង និង ពង្រីកសេវាសាធារណៈ និង កាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។

ជោគជ័យនេះ មិនមែនគ្រាន់តែបង្ហាញឱ្យឃើញអំពីចម្ងាយផ្លូវដែលកម្ពុជាបានឆ្លងកាត់ក្នុងរយៈពេលដ៏ខ្លីនោះ ទេ ក៏ប៉ុន្តែ វាបានឆ្លុះបញ្ចាំងជាពិសេសអំពីសមិទ្ធកម្មកាន់តែប្រសើរឡើងរបស់រាជរដ្ឋាភិបាល ដែលកើតចេញមកពីចក្ខុវិស័យ គោលនយោបាយ និង យុទ្ធសាស្ត្រដ៏ត្រឹមត្រូវ ពីឆន្ទៈដ៏មោះមុត និង ការខិតខំប្រឹងប្រែងពុះពារគ្រប់ឧបសគ្គដោយឥតរាថយ និង ពីការគាំទ្រយ៉ាងពេញទំហឹង និង ការចូលរួមយ៉ាងសកម្ម ព្រមទាំងពីភាពជាម្ចាស់ និង ការទទួលខុសត្រូវខ្ពស់ របស់គ្រប់ក្រសួង-ស្ថាប័ន និង មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃរាជរដ្ឋាភិបាលទាំងមូល នៅក្នុងការអនុវត្តកំណែទម្រង់ដ៏មានសារៈសំខាន់នេះ ។ ពិតណាស់ ដៃគូអភិវឌ្ឍន៍ទាំងឡាយរបស់កម្ពុជា ក៏មានចំណែកប្រកបដោយមោទនភាព នៅក្នុងជោគជ័យដ៏សំខាន់នេះផងដែរ ។ ដូច្នេះ ឆ្លៀតឱកាសដ៏វិសេសវិសាលនេះ ខ្ញុំសូមសំដែងនូវការវាយតម្លៃខ្ពស់ និង ការដឹងគុណដ៏ជ្រាលជ្រៅ ចំពោះការចូលរួមវិភាគទានប្រកបដោយសុឆន្ទៈ របស់គ្រប់ដៃគូពាក់ព័ន្ធទាំងអស់ ដែលបានជួយជំរុញ និង ធានាឱ្យការអនុវត្ត ***«កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ»*** ជំហានទី ១ ដំណាក់កាលទី ១ របស់យើង សម្រេចបាននូវលទ្ធផលគួរជាទីគាប់ចិត្ត មកទល់ពេលនេះ ។

យ៉ាងណាក៏ដោយ ជាមួយនឹងសមិទ្ធផលដ៏គួរជាទីមោទនៈនេះ រាជរដ្ឋាភិបាលទទួលស្គាល់ថា ដំណើររបស់យើងតទៅមុខ នៅវែងឆ្ងាយណាស់ ហើយក៏នៅមានបញ្ហាប្រឈម និង ឧបសគ្គច្រើនរាប់មិនអស់ទៀតដែរ ដែលយើងត្រូវរួមគ្នាជំនះ ដើម្បីឈានទៅដល់គោលដៅចុងក្រោយនៃកំណែទម្រង់នេះ ។ ជាក់ស្តែង «***យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ២***» បានគូសរំលេចឱ្យឃើញនូវបញ្ហាប្រឈមចម្បងៗ ១៧ ចំណុច ដែលកម្ពុជាត្រូវបន្តពុះពារជំនះឱ្យខាងតែបាន ដើម្បីឈានទៅសម្រេចបាននូវគោលដៅជាយុទ្ធសាស្ត្រទាំង ៤ យ៉ាង ដែលស្តែងចេញតាមរយៈបាវចនា ***កំណើន ការងារ សមធម៌*** និង ***ប្រសិទ្ធភាព*** ។ នៅក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាល តាមរយៈ «***យុទ្ធសាស្ត្រ***

***ចតុកោណ- ដំណាក់កាលទី ២»*** បានដាក់ចេញ និង ប្ដេជ្ញាជំរុញអនុវត្តឥតរាថយ នូវយុទ្ធសាស្ត្រកែទម្រង់ និង វិធានការគោលនយោបាយជាកញ្ចប់ ដែលមានលក្ខណៈជាប្រព័ន្ធស៊ីសង្វាក់ ប្រទាក់ក្រឡាគ្នា និង យោងគ្នាទៅវិញទៅមក សំដៅជំនះឱ្យបាននូវបណ្ដាឧបសគ្គ និង បញ្ហាប្រឈមដ៏មុតស្រួចទាំងឡាយ នៅលើមាគ៌ានៃការអភិវឌ្ឍកម្ពុជា ពិសេស សំដៅធានាសម្រេចឱ្យបាននូវគោលដៅជាអាទិភាពប្រកបដោយមហិច្ឆតា ៤ យ៉ាង ក្នុងនីតិកាលទី ៤ នេះ ពោលគឺ ÷

***ទី១.*** ការធានាឱ្យបាននូវចីរភាពនៃសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និង សណ្ដាប់ធ្នាប់សង្គម សំដៅលើកស្ទួយនីតិរដ្ឋ ការពារសិទ្ធិ និង សេចក្ដីថ្លៃថ្នូររបស់មនុស្ស និង លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ។

***ទី២.*** ការធានាឱ្យបាននូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ក្នុងអត្រាប្រមាណ ៧% ក្នុងមួយឆ្នាំ នៅលើមូលដ្ឋានទូលាយជាងមុន និង មានសមត្ថភាពប្រកួតប្រជែងជាងមុន នៅក្នុងបរិការណ៍អត្រាអតិផរណាទាបក្នុងកម្រិតតួលេខមួយខ្ទង់ ។

***ទី៣.*** ការធានាសម្រេចឱ្យបាននូវការកាត់បន្ថយភាពក្រីក្រ ក្នុងអត្រាលើស ១% ក្នុងមួយឆ្នាំ និង ការធានាកែលម្អសូចនាករសំខាន់ៗ ក្នុងវិស័យសង្គមកិច្ច ជាពិសេស ក្នុងវិស័យអប់រំ សុខាភិបាល និង សមភាពយេនឌ័រ ។

***ទី៤.*** ការធានាបង្កើនវិសាលភាព ប្រសិទ្ធភាព និង គុណភាព នៃសេវាសាធារណៈ ឱ្យកាន់តែប្រសើរឡើង ហើយទទួលបាននូវការជឿទុកចិត្ត ។

គ្មានការសង្ស័យទេថា ដោយផ្អែកលើបទពិសោធន៍ជាអន្តរជាតិ និង ជាពិសេស បទពិសោធន៍ជាវិជ្ជមានរបស់កម្ពុជាខ្លួនឯងផ្ទាល់ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដែលបង្ហាញយ៉ាងច្បាស់ថា ***«ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រកបដោយប្រសិទ្ធភាព និង ភាពស័ក្តិសិទ្ធិ គឺជាមូលដ្ឋានគ្រឹះដ៏ចាំបាច់មិនអាចខ្វះបាន សម្រាប់ការជំរុញអភិវឌ្ឍប្រទេសជាតិ និង កាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ពិសេសតាមរយៈការធានានូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និង ការបង្កើនប្រសិទ្ធភាពក្នុងការផ្ដល់សេវាសាធារណៈជូនដល់ប្រជាពលរដ្ឋ»*** រាជរដ្ឋាភិបាល នីតិកាលទី ៤ នេះ នៅតែបន្តដាក់ «**កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**» នៅក្នុងលំដាប់ជួរទីមួយនៃបញ្ជីអាទិភាព របស់ខ្លួនដដែល ។

អាទិភាពនៃការជំរុញអនុវត្ត «**កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**» រឹតតែមានបច្ចុប្បន្នភាព និង សារៈសំខាន់របស់ខ្លួនខ្លាំងឡើងថែមទៀត នៅក្នុងដំណាក់កាលចំពោះមុខនេះ ដែលពិភពលោកកំពុងតែទទួលនូវវិបត្តិកលិយុគហិរញ្ញវត្ថុ ហើយដែលវិបត្តិនេះ កំពុងតែជះឥទ្ធិពលអវិជ្ជមានមកលើសេដ្ឋកិច្ចនៃពិភពលោកទាំងមូល ។ កម្ពុជាដែលជាកោសិកាមួយនៃសាកលភូបនីយកម្ម ពិតជាមិនអាចគេចផុតពីផលវិបាកនេះបានទេ ។ យើង ច្បាស់ជាត្រូវទទួលរងនូវផលប៉ះពាល់អាក្រក់ពីវិបត្តិកលិយុគនេះ ក្នុងកម្រិតណាមួយ គ្រាន់តែអាចតិច ឬក៏ច្រើន តែប៉ុណ្ណោះ ។ យ៉ាងណាក៏ដោយ អ្វីដែលយើងប្រាកដក្នុងចិត្តនោះ គឺថា ការកែលម្អ និង ពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នឹងជួយពង្រឹងសមត្ថភាពរបស់យើងក្នុងការទប់ទល់នឹងបញ្ហាប្រឈមទាំងអស់នេះ ហើយនិងអាចជួយកាត់បន្ថយនូវឥទ្ធិពលអវិជ្ជមានពីវិបត្តិនេះ មកលើលទ្ធភាពនៃការជំរុញអនុវត្តគោលនយោបាយអភិវឌ្ឍរបស់រាជរដ្ឋាភិបាល និង លើ

លទ្ធភាពនៃការផ្ដល់សេវាសាធារណៈជូនដល់ប្រជាជន ។ ដូច្នេះ នៅក្នុងល័ក្ខខ័ណ្ឌមិនអំណោយផលបែបនេះ ការពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ពិសេស ការពង្រឹងប្រសិទ្ធភាពក្នុងការគ្រប់គ្រងថវិកាជាតិ ដែលជាឧបករណ៍គន្លឹះក្នុងការអនុវត្តគោលនយោបាយអភិវឌ្ឍរបស់រាជរដ្ឋាភិបាល ពិតជាមានសារៈសំខាន់ជាងពេលណាៗទាំងអស់ ។

វាពិតជាមិនមែនជាការចៃដន្យនោះទេ ដែល «**កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**» បានឈានដល់ដំណាក់កាលទី ២ របស់ខ្លួន ស្របគ្នានឹង «**យុទ្ធសាស្ត្រចតុកោណ- ដំណាក់កាលទី ២**» របស់រាជរដ្ឋាភិបាល ។ ក្រោយពីការធានាបានជាមូលដ្ឋាន នូវ ***«ភាពជឿទុកចិត្តបាននៃថវិកា»*** នៅក្នុងដំណាក់កាលទី ១ **កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ - ដំណាក់កាលទី ២** នេះ ត្រូវបន្តឈានឡើង ដោយផ្អែកលើមូលដ្ឋាននៃដំណាក់កាលទី ១ ហើយផ្ដោតទៅលើការគ្រប់គ្រង និង សមិទ្ធកម្មរបស់គ្រប់ក្រសួង- ស្ថាប័នទាំងអស់ ដែលទាមទារឱ្យមានការចូលរួមកាន់តែទូលាយជាងមុន និង មានភាពជាម្ចាស់ ការទទួលខុសត្រូវ និង គណនេយ្យភាពកាន់តែខ្ពស់ជាងមុនផងដែរ ។ ជាងនេះទៅទៀត ដូចជាសមិទ្ធផលនៃដំណាក់កាលទី ១ ដែលកំពុងតែដើរតួនាទីជាមូលដ្ឋានសម្រាប់ការឈានឡើងតទៅមុខទៀតនៃដំណាក់កាលទី ២ នេះដូច្នោះដែរ ជោគជ័យនៃដំណាក់កាលទី ២ នេះនឹងដើរតួជាកត្តាកំណត់ជោគជ័យនៃកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងដំណាក់កាលបន្តបន្ទាប់ទៅមុខទៀត រហូតដល់កម្ពុជាអាចឈានទៅបង្កើនកម្រិតស្តង់ដារនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ខ្លួន ឱ្យស្របទៅនឹងស្តង់ដារអន្តរជាតិ ប្រកបដោយភាពរលូន សង្គតិភាព និង ប្រសិទ្ធភាព នៅក្នុងឆ្នាំ ២០១៥ តាមរយៈការអនុវត្តយុទ្ធសាស្ត្រជាជំហានៗ រួមមាន ពីការបង្កើនភាពជឿទុកចិត្តលើថវិកា- ទៅការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ ពីការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ- ទៅការបង្កើនការផ្សារភ្ជាប់រវាងថវិកា និង គោលនយោបាយ និងជាទីបញ្ចប់ ពីការបង្កើនការផ្សារភ្ជាប់រវាងថវិកា និង គោលនយោបាយ- ទៅកាន់ការបង្កើនគណនេយ្យភាពចំពោះសមិទ្ធកម្ម ។

បន្ថែមពីលើនេះទៀត «**កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**» ក៏មានសារៈសំខាន់យ៉ាងខ្លាំងផងដែរ សម្រាប់ការដ្ឋានកែទម្រង់គន្លឹះៗផ្សេងទៀតរបស់រាជរដ្ឋាភិបាល រួមមាន កំណែទម្រង់រដ្ឋបាលសាធារណៈ និង កម្មវិធីវិមជ្ឈការ និង វិសហមជ្ឈការ ជាដើម ។ ដូច្នេះ ជោគជ័យនៃ «**កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**» ដែលជាកម្មវិធីស្នូលមួយដ៏សំខាន់ នៅក្នុងចំណោមបណ្ដាកម្មវិធីកែទម្រង់ជាស្នូលទាំងឡាយនៃ «**យុទ្ធសាស្ត្រចតុកោណ- ដំណាក់កាលទី ២**» នឹងចូលរួមចំណែកយ៉ាងសំខាន់ ក្នុងការកំណត់ជោគជ័យនៃការ- អនុវត្តយុទ្ធសាស្ត្រនេះទាំងមូល ។ ក្នុងស្មារតីនេះ ខ្ញុំសូមជំរុញលើកទឹកចិត្តឱ្យក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បន្តដើរតួជាអ្នកនាំមុខយ៉ាងសកម្មតទៅទៀត នៅក្នុងការជំរុញអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញសាធារណៈដ៏មានសារៈសំខាន់នេះ ។ ទន្ទឹមនឹងនេះដែរ អំណើះតទៅ គ្រប់ក្រសួង- ស្ថាប័នទាំងអស់ ត្រូវចូលរួមជាតួអង្គគន្លឹះនៅក្នុងកម្មវិធីកែទម្រង់នេះ ក្នុងភាពជាម្ចាស់ និង ក្នុងការទទួលខុសត្រូវខ្ពស់បំផុត ហើយត្រូវរួមគ្នាជាមួយនឹងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ប្រឹងប្រែងពុះពារជំនះរាល់គ្រប់ឧបសគ្គ និង បញ្ហាប្រឈមនានា ក្នុងស្មារតីនៃកិច្ច-

សហការ និង ការសម្របសម្រួល ប្រកបដោយភាពស័ក្តិសិទ្ធិ និង ប្រសិទ្ធភាពខ្ពស់ ដើម្បីធានាជោគជ័យក្នុងការអនុវត្ត «**កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ - ដំណាក់កាលទី ២**» នេះ ក៏ដូចជាដើម្បីធាននូវដំណើរប្រព្រឹត្តិទៅដោយរលូន និង ក្នុងសង្គតិភាពជាមួយគ្នា រវាង **កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** និង កំណែទម្រង់សំខាន់ៗផ្សេងទៀតរបស់រាជរដ្ឋាភិបាល ពិសេស **កំណែទម្រង់រដ្ឋបាលសាធារណៈ និង កម្មវិធីវិមជ្ឈការ និង វិសហមជ្ឈការ** ។

ជាថ្មីម្តងទៀត ក្នុងនាមជាប្រមុខនៃរាជរដ្ឋាភិបាល ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះការចូលរួមយ៉ាងសស្រាក់-សស្រាំរបស់ថ្នាក់ដឹកនាំ និង មន្ត្រីរាជការគ្រប់ជាន់ថ្នាក់ របស់គ្រប់ក្រសួង- ស្ថាប័ន ក្នុងការជំរុញអនុវត្ត «**កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**» ក្នុងរយៈពេលកន្លងមក ប្រកបដោយសុឆន្ទៈ ក្នុងភាពជាម្ចាស់ និង ការទទួលខុសត្រូវខ្ពស់ ដែលធ្វើឱ្យដំណាក់កាលទី ១ នៃកម្មវិធីកែទម្រង់នេះ សម្រេចបានជោគជ័យគួរជាទីលើកទឹកចិត្ត ។ ទន្ទឹមនឹងនេះ ខ្ញុំសូមថ្លែងអំណរគុណដោយស្មោះ ជូនចំពោះគ្រប់ដៃគូអភិវឌ្ឍន៍ទាំងអស់ ដែលបានរួមចំណែកផ្តល់នូវហិរញ្ញប្បទាន និង ការគាំទ្រខាងផ្នែកបច្ចេកទេស ជាមួយនឹងការសម្របសម្រួលដ៏ល្អ តាមរយៈអភិក្រមគ្របដណ្តប់ទូទាំងវិស័យ ក្នុងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនេះ ។ ខ្ញុំសូមប្រសិទ្ធិពរឱ្យសុឆន្ទៈ ភាពជាម្ចាស់ ការទទួលខុសត្រូវ កិច្ចខិតខំប្រឹងប្រែង និង ការរួមចំណែក ព្រមទាំងកិច្ចសហប្រតិបត្តិការដ៏ល្អទាំងនេះ កាន់តែរីកដុះដាលរឹងមាំឡើងជាលំដាប់ថែមទៀត ដើម្បីធានាជំរុញអនុវត្ត «**កម្មវិធីកែទម្រង់ការគ្រប់-គ្រងហិរញ្ញវត្ថុសាធារណៈ - ដំណាក់កាលទី ២**» នេះ ក៏ដូចជាកំណែទម្រង់ពាក់ព័ន្ធផ្សេងៗទៀត ឱ្យសម្រេចបានជោគជ័យតាមការរំពឹងទុក ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨*

**នាយករដ្ឋមន្ត្រី**



**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

## ១. ការពិនិត្យឡើងវិញលើចក្ខុវិស័យរួមនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

**១-១-** យុទ្ធសាស្ត្រកែទម្រង់ត្រូវបានរៀបចំដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងត្រូវបានអនុម័តដោយសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ ២០០៤ ។ យុទ្ធសាស្ត្រនេះបានផ្តល់នូវក្របខ័ណ្ឌច្បាស់លាស់សម្រាប់ការកែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា និងបានបញ្ជាក់ផងដែរនូវចរិតលក្ខណៈនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ។ ចរិតលក្ខណៈទាំងនេះមានដូចជា ៖

***ចរិតលក្ខណៈនៃការរៀបចំថវិកា***

ដំណើរឆ្ពោះទៅរកការរៀបចំថវិកាដោយផ្តោតលើការបង្កើនគុណភាពសេវាសាធារណៈ និងការសម្រេចតាមគោលបំណងនៃគោលនយោបាយ ជាពិសេសគឺ ៖

- ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានរៀបចំឡើងដើម្បីឆ្ពោះទៅរក ***សមិទ្ធកម្ម*** ទាំងលើការប្រើប្រាស់ធនធានសាធារណៈ និងការសម្រេចបានតាមគោលបំណងនៃគោលនយោបាយតាមរយៈប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសមស្រប ។ ប្រព័ន្ធគ្រប់គ្រងនេះជាបណ្តើរៗនឹងធានាផ្តល់ជាអតិបរមានូវតម្លៃនៃប្រាក់ (Value for Money) ដែលកើតចេញពីការប្រើប្រាស់ធនធានសាធារណៈ ។ ប្រព័ន្ធនេះក៏នឹងផ្តល់ផងដែរនូវការលើកទឹកចិត្តចំពោះសមិទ្ធកម្មល្អ និងដាក់ទណ្ឌកម្មចំពោះការប្រព្រឹត្តខុស ។
- ប្រព័ន្ធគ្រប់គ្រងនេះ ***បែងចែកមុខងារ*** ក្នុងក្របខ័ណ្ឌច្បាប់ និង អំណាចហិរញ្ញវត្ថុសាធារណៈយ៉ាងច្បាស់លាស់ សម្រាប់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយស្ថិតនៅក្នុងប្រព័ន្ធថវិកាឯកភាពមួយដែលគ្របដណ្តប់គ្រប់ស្ថាប័ន មុខងារ កម្មវិធី និង គម្រោងរបស់រដ្ឋាភិបាល ។
- ***ក្របខ័ណ្ឌវិភាគ*** ប្រកបដោយសង្គតិភាព និង ប្រទាក់ក្រឡាគ្នាលើគ្រប់វិស័យ ដែលគ្រប់ប្រតិបត្តិការថវិកាត្រូវបានធ្វើចំណាត់ថ្នាក់ទៅតាមរដ្ឋបាល សេដ្ឋកិច្ច មុខងារ និងកម្មវិធី ព្រមទាំងឆ្លុះបញ្ចាំងនូវចំណាយសម្រាប់កាត់បន្ថយភាពក្រីក្រ និង ដែលគាំទ្រការតម្រង់ទិសការគ្រប់គ្រងចំណាយសាធារណៈ ឆ្ពោះទៅរកការសម្រេចបាននូវលទ្ធផលស្របតាមគោលនយោបាយ ។
- ថវិកាត្រូវរៀបចំប្រកបដោយភាពប្រាកដនិយម និង ចីរភាព ក្នុង ***ក្របខ័ណ្ឌពហុឆ្នាំ*** ហើយដែលគ្របដណ្តប់ទាំងការរៀបចំកម្មវិធីពហុឆ្នាំ ។
- ថវិកាត្រូវមាន ***លក្ខណៈគ្រប់ជ្រុងជ្រោយ*** ដោយមានការបញ្ចូលគ្រប់ទិដ្ឋភាពនៃប្រតិបត្តិការសាធារណៈ ដែលរួមមានការគ្រោងហិរញ្ញប្បទានថវិការយៈពេលកាន់តែវែងជាងមុន ការរៀបចំ

ផែនការគ្រប់គ្រងបំណុល និង ការរៀបចំផែនការ ធនធានដែលរួមបញ្ចូលទាំងអចលនទ្រព្យ ធនធានហិរញ្ញវត្ថុ ទ្រព្យសម្បត្តិដទៃទៀត និងទ្រព្យអកម្មរបស់រដ្ឋ ។

- ការរៀបចំថវិកាមាន **លក្ខណៈឆ្លើយតប** ទៅនឹងគោលនយោបាយ និងកម្មវិធី របស់រដ្ឋាភិបាល ដែលអាចជះឥទ្ធិពលលើសមាសភាព ការលើកទឹកចិត្ត ទំហំ ការបណ្តុះបណ្តាល ការពង្រាយមន្ត្រីរាជការ និងទៅលើការគ្រប់គ្រងមន្ត្រី ។ ម្យ៉ាងទៀត ប្រព័ន្ធថវិកាក៏ត្រូវធានាផងដែរថា រាល់ឥណទានចំណាយបន្ថែម ក្រោយការអនុម័តថវិកាត្រូវតែមានប្រភពហិរញ្ញប្បទានឱ្យបានពេញលេញ ។

***ចរិតលក្ខណៈនៃការអនុវត្តថវិកា***

នីតិវិធី និងដំណើរការអនុវត្តថវិកាដែលមានប្រសិទ្ធភាព និងផ្តល់សេវាសាធារណៈក្នុងតម្លៃសមស្រប (Cost Effective) និងទាន់ពេលវេលា ជាពិសេសគឺ ៖

- **ធ្វើលទ្ធកម្មប្រកបដោយប្រសិទ្ធភាពលើទំនិញ និងសេវា** តាមតម្រូវការក្នុងតម្លៃសមស្រប ។ ការទិញ ការបែងចែក ការប្រើប្រាស់ ការជម្រះធនធានដែលបានប្រើប្រាស់ដោយរដ្ឋាភិបាល និងការដាក់ពង្រាយធនធានមនុស្សត្រូវមានលក្ខណៈជាចំហ ដោយប្រកួតប្រជែង មានតម្លាភាព និង មិនរើសអើង ។ រដ្ឋាភិបាលត្រូវរៀបចំ និងជំរុញឱ្យអនុវត្តនូវវិធានច្បាស់លាស់ ដើម្បីជួយបង្កើនតម្លៃនៃប្រាក់សម្រាប់លទ្ធកម្មទំនិញ និង សេវា រួមទាំងការធ្វើឯកជនភាវូបនីយកម្ម ការធ្វើកិច្ចសន្យានិងដំណើរការគ្រប់គ្រងសេវាសាធារណៈជាមួយវិស័យឯកជន ការជ្រើសរើស ការពង្រាយ និងតម្លើងឋានៈមន្ត្រី ។
- **មានលក្ខណៈឆ្លើយតប** មានប្រតិកម្មរហ័ស ច្បាស់លាស់ និងជាសាធារណៈ ចំពោះបញ្ហាទាំងឡាយដែលកើតចេញក្នុងដំណើរការនៃការអនុវត្តថវិកា ។ របាយការណ៍បច្ចុប្បន្នភាពប្រចាំខែស្តីពីវឌ្ឍនភាពនៃការអនុវត្តថវិកាត្រូវផ្តល់ជាសាធារណៈ រួមទាំងការត្រួតពិនិត្យការអនុវត្តថវិកាពាក់កណ្តាលឆ្នាំគ្រប់ជ្រុងជ្រោយ ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអាចផ្តល់អនុសាសន៍ដល់រដ្ឋាភិបាលនូវវិធានការកែតម្រូវ ប្រសិនបើការអនុវត្តផែនការជួបប្រទះបញ្ហា ដូចជា ការប្រមូលចំណូលមិនគ្រប់តាមផែនការ ឬមានតម្រូវការជាយថាហេតុដែលតម្រូវឱ្យមានចំណាយបន្ថែម ។
- មាន**ព័ត៌មាន**ដែលទុកចិត្តបាន និង ទាន់ពេលវេលា ។ ប្រព័ន្ធព័ត៌មានគ្រប់គ្រងថវិកា និងប្រព័ន្ធគណនេយ្យត្រូវរៀបចំតាមប្រព័ន្ធកុំព្យូទ័រមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងមានសមាហរណកម្ម ។ ប្រព័ន្ធនេះនឹងជួយផ្តល់នូវរបាយការណ៍ស្តីពីប្រតិបត្តិការហិរញ្ញវត្ថុរបស់ស្ថាប័ន

រដ្ឋាភិបាលបានទៀងទាត់និងទាន់ពេលវេលា និងអាចផ្ទៀងផ្ទាត់ទិន្នន័យហិរញ្ញវត្ថុជាមួយនឹងគណនីរបស់រដ្ឋាភិបាល ។

***ចរិតលក្ខណៈនៃការត្រួតពិនិត្យ និង តាមដាន***

ដំណើរការត្រួតពិនិត្យ និងតាមដានដែលធានាតម្លាភាព និងផ្តល់ជាមូលដ្ឋានសម្រាប់ជាមេរៀនដ៏ស័ក្តិសិទ្ធិ និងសកម្មភាពកែតម្រូវនៅពេលបញ្ហាកើតមាន ។

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ កំណត់ ***ស្តង់ដា*** (Standard) ផ្តល់ការណែនាំ និងតាមដានការគ្រប់គ្រងហិរញ្ញវត្ថុនៅតាមក្រសួង-ស្ថាប័ន និង អង្គភាពចំណាយដែលរួមទាំងការកំណត់ស្តង់ដារសវនកម្មផ្ទៃក្នុង ។
- យន្តការដ៏មានប្រសិទ្ធភាពត្រូវបានរៀបចំឡើងដើម្បីផ្តល់លទ្ធភាពដល់អ្នកគ្រប់គ្រងអាច ***ត្រួតពិនិត្យជាលក្ខណៈប្រព័ន្ធ*** លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ ក្រសួង-ស្ថាប័ន និង អង្គភាពចំណាយនីមួយៗ ត្រូវបង្កើតឱ្យមានអង្គភាពសវនកម្មផ្ទៃក្នុងដើម្បី (១) ដឹកនាំការរៀបចំ និងការគ្រប់គ្រងផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ និង (២) ពិនិត្យមើល និងគាំទ្រដំណើរការសវនកម្ម ។
- ***សវនកម្មឯករាជ្យ*** ពីខាងក្រៅត្រូវផ្តល់របាយការណ៍សវនកម្មឱ្យទាន់ពេលវេលា និងបង្ហាញជាសាធារណៈ ហើយរដ្ឋាភិបាលត្រូវឆ្លើយតបយ៉ាងឆាប់រហ័សចំពោះអនុសាសន៍ដែលមាននៅក្នុងរបាយការណ៍សវនកម្ម ។

**១-២** បទពិសោធន៍នៃការអនុវត្តដំណាក់កាលទី១ បានបង្ហាញថាចក្ខុវិស័យ និងចរិតលក្ខណៈទាំងឡាយខាងលើនេះនៅតែមានតម្លៃ និងជាមគ្គុទ្ទេសក៍ដ៏រឹងមាំមួយសម្រាប់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ។ ទោះជាយ៉ាងណា រដ្ឋាភិបាលយល់ឃើញថាការរៀបចំស្ថាប័នគឺជាផ្នែកដ៏សំខាន់ដែលត្រូវបន្ថែមសម្រាប់គាំទ្រប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលមានចរិតលក្ខណៈទាំងអស់ខាងលើនេះ ។ លើសពីនេះ បទពិសោធន៍បានបង្ហាញអំពីសារៈសំខាន់នៃការផ្សារភ្ជាប់រវាងការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងចរិតលក្ខណៈដទៃទៀតនៃកំណែទម្រង់អភិបាលកិច្ច ( សូមអានឧបសម្ព័ន្ធទី៨ ) ។ ចរិតលក្ខណៈបន្ថែមមានដូចខាងក្រោម ៖

- រចនាសម្ព័ន្ធស្ថាប័ន ការគ្រប់គ្រងបុគ្គលិក និងការលើកទឹកចិត្តដែលពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវផ្តោតជាសំខាន់ទៅលើការសម្រេចនូវចរិតលក្ខណៈនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រកបដោយប្រសិទ្ធភាព និងមានលក្ខណៈសមាហរណកម្ម ។

ចក្ខុវិស័យ ដែលបានបន្ថែមចរិតលក្ខណៈដូចបានស្នើឡើងខាងលើ នឹងបន្តផ្តល់ជាមគ្គុទ្ទេសក៍ដល់យុទ្ធសាស្ត្រកំណែទម្រង់ ។

## ២. ការពិនិត្យឡើងវិញលើយុទ្ធសាស្ត្ររួមនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

*សេចក្តីសង្ខេបយុទ្ធសាស្ត្ររួម*

**២-១** យុទ្ធសាស្ត្រសម្រាប់ឆ្ពោះទៅរកចក្ខុវិស័យ ដែលបានគូសបញ្ជាក់ក្នុងឯកសារឆ្នាំ ២០០៤ បានបង្ហាញនូវសមាសធាតុគន្លឹះ៣ ។

**២-២** សមាសធាតុទីមួយ ភាពជាអ្នកដឹកនាំក្នុងដំណើរការរៀបចំ និង អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ត្រូវបានកសាងយ៉ាងរឹងមាំនៅក្នុងរាជរដ្ឋាភិបាលកម្ពុជា ។ សារៈសំខាន់នៃការគាំទ្រផ្នែកនយោបាយ និងភាពជាអ្នកដឹកនាំត្រូវបានលេចឡើងយ៉ាងប្រត្យក្សនៅក្នុងការអនុវត្តកម្មវិធីកែទម្រង់ ។ យន្តការសម្របសម្រួល និង ការបែងចែកការទទួលខុសត្រូវនៅក្នុងការគ្រប់គ្រងការអនុវត្តសកម្មភាពការងារផ្សេងៗគ្នាត្រូវបានយកចិត្តទុកដាក់ខ្ពស់ ។ លើសពីនេះ ការបង្កើតយន្តការធ្វើការងារជាមួយដៃគូអភិវឌ្ឍន៍ប្រកបដោយភាពច្បាស់លាស់ជាវិជ្ជមាន និងមានប្រសិទ្ធភាពបានផ្តល់ការគាំទ្រដល់ដំណើរការកែទម្រង់ទាំងផ្នែកធនធាន និង ផ្នែកប្រឹក្សាយោបល់ ។

**២-៣** សមាសធាតុទីពីរ លំដាប់លំដោយនៃផែនការសកម្មភាពកំណែទម្រង់គឺជាប្រការសំខាន់ដែលត្រូវបានយកចិត្តទុកដាក់ ។ ត្រូវទទួលស្គាល់ថា អ្វីៗគ្រប់យ៉ាងមិនអាចសម្រេចបាននៅក្នុងពេលតែមួយនោះទេ ប៉ុន្តែត្រូវតែចាប់ផ្តើមធ្វើការងារស្នូល និងជាមូលដ្ឋានមួយចំនួនជាមុន ទើបសកម្មភាពការងារដទៃទៀតអាចអនុវត្តទៅបានប្រកបដោយប្រសិទ្ធភាព ។ លំដាប់លំដោយនៃផែនការសកម្មភាពកម្មវិធីកំណែទម្រង់មិនអាចរៀបចំ ដោយផ្អែកតែទៅលើសារៈសំខាន់នៃការកែលម្អផ្នែកបច្ចេកទេសក្នុងសកម្មភាពការងារដាច់ដោយឡែកៗពីគ្នានោះទេ ។ ក្នុងការរៀបចំលំដាប់លំដោយនៃកម្មវិធីកែទម្រង់សកម្មភាពការងារដែលត្រូវបំពេញត្រូវបានចងក្រងជាក្រុមទៅតាមជំហាន (Platform) ដែលជំហាននីមួយៗបង្ហាញនូវការកែលម្អជាក់ស្តែង និងអាចវាយតម្លៃបាននៅក្នុងសមិទ្ធកម្មនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ហើយក៏បង្កើតបានជាឈ្នាន់សម្រាប់ជំហានបន្ទាប់ផងដែរ ។ បណ្តាជំហានទាំងនោះត្រូវបានរៀបចំឡើងដូចមានបង្ហាញក្នុងគំនូសបំព្រួញខាងក្រោមនេះ ៖

# លំដាប់លំដោយនៃជំហានទាំងបួន

- ផ្តល់រង្វាន់ចំពោះសមិទ្ធកម្មព្រមទាំងវិន័យ
- មានមូលដ្ឋានសម្រាប់វិសហមជ្ឈការកាន់តែស៊ីជម្រៅ
- មានតម្លាភាពផ្នែកក្រៅកាន់តែប្រសើរឡើង

**ជំហានទី ៤**

សមាហរណកម្មគណនេយ្យភាព និង ការពិនិត្យឡើងវិញ ទាំងផ្នែកហិរញ្ញវត្ថុ និង សមិទ្ធកម្ម

កតពីកេរ

គណនេយ្យភាពចំពោះសមិទ្ធកម្ម

**ជំហានទី៣**

កែលម្អការផ្សារភ្ជាប់រវាងអាទិភាព និងគោលដៅសេវាទៅនឹងការធ្វើផែនការ និងការអនុវត្តថវិកា

-កាលានុវត្តភាពដើម្បីប្រសិទ្ធភាព
-ការតម្រែតម្រង់ឡើងវិញនូវធនធានជាមួយនឹងអាទិភាព
-វិសាលភាពត្រួតពិនិត្យឡើងវិញដោយស៊ីជម្រៅ

កតពីកេរ

មានសកម្មភាពច្បាស់លាស់ចំពោះការប្រើប្រាស់ថវិកា

- ឈានទៅរកស្តង់ដារក្នុងតំបន់
- បង្កើនថវិកាគាំទ្រដោយដៃគូអភិវឌ្ឍន៍

**ជំហានទី២**

ការកែលម្អជាបឋមផ្នែកត្រួតពិនិត្យផ្ទៃក្នុង និងធ្វើឱ្យអ្នកគ្រប់គ្រងថវិកាមានគណនេយ្យភាព

កតពីកេរ

មូលដ្ឋានសម្រាប់គណនេយ្យភាព

- ទិន្នន័យចាំបាច់អាចទុកចិត្តបាន
- វិន័យប្រកបដោយភាពស័ក្តិសិទ្ធិ
- មូលដ្ឋានផ្តល់រង្វាន់និងទណ្ឌកម្ម
- តម្លាភាពផ្ទៃក្នុងកាន់តែប្រសើរ

**ជំហានទី១**

ថវិកាកាន់តែអាចជឿទុកចិត្តបាន ដោយអ្នកគ្រប់គ្រងថវិកា ទទួលបានធនធានដែលអាចព្យាករណ៍ និងជឿជាក់បាន

- ផ្តល់ធនធានស្របតាមពេលវេលានៃតម្រូវការជាក់ស្តែង
- គ្រប់គ្រងបំណុលកកស្ទះ
- មូលដ្ឋានកាន់តែប្រសើរដើម្បីប្រសិទ្ធភាពលទ្ធកម្ម

**២-៤** សមាសធាតុទីបី ផែនការសកម្មភាពដើម្បីអនុវត្តជំហាននីមួយៗ ត្រូវតែគ្របដណ្តប់មិនត្រឹមតែការអភិវឌ្ឍផ្នែកបច្ចេកទេស និង របៀបរបបអនុវត្តការងារ (Technical and Process Developments) ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងត្រូវរួមបញ្ចូលទាំងការកសាងស្ថាប័ន ការកសាងសមត្ថភាព និងការលើកទឹកចិត្ត ។ ដូច្នេះប្រសិនបើទិដ្ឋភាពខុសៗគ្នាខាងលើនេះមិនត្រូវបានយកចិត្តទុកដាក់ និងមិនបានជួយគាំទ្រគ្នាទៅវិញទៅមកនោះទេ នោះជំហាននីមួយៗមិនត្រឹមតែមិនអាចក្លាយជាឈ្នាន់ដ៏រឹងមាំដើម្បីឈានទៅជំហានបន្ទាប់បានប៉ុណ្ណោះទេ ការកំណែទម្រង់ថែមទាំងពុំមានភាពស៊ីជម្រៅ និងអាចជួបប្រទះនូវភាពថមថយ ។

រដ្ឋាភិបាលបានសម្រេចថា ផែនការសកម្មភាពលម្អិតសម្រាប់កម្មវិធីកែទម្រង់ទាំងមូលមិនត្រូវរៀបចំឱ្យហើយក្នុងពេលតែមួយនោះទេ ។ ដោយហេតុថា ការអនុវត្តកម្មវិធីកែទម្រង់ទាំងមូលទាមទារនូវពេលវេលាយូរ ( យ៉ាងហោចណាស់ហួតដល់ពាក់កណ្តាលទសវត្សក្រោយ ) នោះការព្យាយាមរៀបចំផែនការសកម្មភាពសម្រាប់កម្មវិធីកែទម្រង់ទាំងមូលតែម្តងនឹងនាំឱ្យបាត់បង់ភាពប្រាកដនិយម មានភាពរឹងត្អឹង និង មិនបានជួយដល់ដំណើរការអនុវត្តកំណែទម្រង់ឡើយ ។ ដូច្នេះហើយបានជាផែនការសកម្មភាពលម្អិតនៅក្នុងក្របខ័ណ្ឌនៃយុទ្ធសាស្ត្ររួម បានផ្តោតតែទៅលើជំហានទី១ប៉ុណ្ណោះ ។ លើសពីនេះទៀត ការចូលរួមពីមន្ត្រីរាជការនៅគ្រប់កម្រិតមានសារៈសំខាន់ណាស់នៅក្នុងការអនុវត្តកម្មវិធីកំណែទម្រង់ ។ កិច្ចការនេះត្រូវបានសម្រេចដោយសារការប្រើប្រាស់វិធីសាស្ត្ររួមគ្នារវាង “វិធីសាស្ត្រពីលើចុះក្រោម” (Top Down Approach) នៅក្នុងការកំណត់ផែនការសកម្មភាពរួម និង “វិធីសាស្ត្រពីក្រោមឡើងលើ” (Bottom Up Approach) សម្រាប់ផែនការសកម្មភាពលម្អិតរបស់នាយកដ្ឋាននីមួយៗដែលត្រូវអនុវត្ត។

ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ សកម្មភាពការងារជំហានបន្ទាប់មួយចំនួនត្រូវការពេលវេលាយូរដើម្បីអនុវត្តឱ្យចប់សព្វគ្រប់ ។ អាស្រ័យហេតុនេះ ការរៀបចំយុទ្ធសាស្ត្រការងារដើម្បីត្រៀមលក្ខណៈ ឬការងារសាកល្បងសម្រាប់ជំហានបន្តបន្ទាប់ដែលអាចកំណត់បានជាមុន ចាំបាច់ត្រូវចាប់ផ្តើមអនុវត្តជាបណ្តើរៗ ។ សកម្មភាពការងារនៅក្នុងជំហានទី១ រួមជាមួយសកម្មភាពការងារសម្រាប់គាំទ្រដល់ជំហានបន្ទាប់ បង្កើតបានជាដំណាក់កាល១ (Stage 1) នៃកម្មវិធីកែទម្រង់ ហើយត្រូវបានអនុវត្ត និងតាមដានស្របពេលជាមួយគ្នា ។

ជាងនេះទៀត ដៃគូអភិវឌ្ឍន៍បានខិតខំប្រឹងប្រែងដើម្បីសម្របសម្រួលផ្តល់ហិរញ្ញប្បទាន និងសហប្រតិបត្តិការដោយផ្អែកលើក្របខ័ណ្ឌកែទម្រង់ហិរញ្ញវត្ថុសាធារណៈ ។ រាជរដ្ឋាភិបាលបានកំណត់យកការរៀបចំអភិក្រមគ្របដណ្តប់លើវិស័យទាំងមូល (SWAp) សម្រាប់អនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រង

ហិរញ្ញវត្ថុសាធារណៈដែលត្រូវបានគាំទ្រ និងផ្តល់ហិរញ្ញប្បទានសម្របសម្រួលជាទ្វេភាគី និងពហុភាគី ( សូមមើលឧបសម្ព័ន្ធទី៩ ) ។

យុទ្ធសាស្ត្រដែលបានកែសម្រួលសម្រាប់ដំណាក់កាលបន្ទាប់នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនេះ គឺផ្អែកលើការត្រួតពិនិត្យដោយម៉ត់ចត់នូវវឌ្ឍនភាពមកដល់ពេលបច្ចុប្បន្ននៃដំណាក់កាលទី១ និងការកំណត់នូវតម្រូវការសម្រាប់សម្រេចគោលបំណងជំហានទី២ ព្រមទាំងការងារត្រៀមលក្ខណៈសម្រាប់ជំហានបន្ទាប់ ។ យុទ្ធសាស្ត្រដែលបានកែសម្រួលនេះ ឆ្លុះបញ្ចាំងនូវការធ្វើឱ្យប្រសើរឡើងលើវិធីសាស្ត្រដែលមានស្រាប់ដោយផ្អែកលើបទពិសោធន៍ដែលទទួលបានមកដល់ពេលបច្ចុប្បន្នព្រមទាំងបរិបទបច្ចុប្បន្ន និងនិន្នាការទៅថ្ងៃអនាគតក្នុងការអភិវឌ្ឍការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

## ៣. សមិទ្ធផល និង បញ្ហាប្រឈមនៃជំហានទី១ ក្នុងដំណាក់កាលទី១

### *វឌ្ឍនភាពដែលទទួលបាននៅដំណាក់កាលទី១ ក្នុងការសម្រេចគោលបំណងជំហានទី១*

**៣.១.** ខ្លឹមសារសំខាន់នៃដំណាក់កាលទី១ គឺការសម្រេចបាននូវគោលបំណងជំហានទី១ ដែលជាមូលដ្ឋានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ មូលដ្ឋាននេះជាចំណុចចាប់ផ្តើមដើម្បីសម្រេចគោលបំណងរបស់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងការរួមចំណែកដល់ការគ្រប់គ្រងធនធានប្រកបដោយភាពស័ក្តិសិទ្ធិ ការអនុវត្តគោលនយោបាយ និងការផ្តល់សេវាសាធារណៈ ។ ថវិកាដែលជាធាតុស្នូលនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវតែធ្វើឱ្យមានលក្ខណៈកាន់តែអាចជឿទុកចិត្តបាន ពោលគឺត្រូវមានភាពជាក់ស្តែង ។ ជាពិសេស ការកៀរគរធនធានគួរតែរឹងមាំ ការរៀបចំថវិកាត្រូវតែមានភាពគ្រប់ជ្រុងជ្រោយ និងជាក់ស្តែង ហើយដំណើរការអនុវត្តថវិកាគួរតែទទួលបានលទ្ធផលដូចដែលបានគ្រោងទុក ។

**៣.២.** យន្តការតាមដានវឌ្ឍនភាព ត្រូវបានដាក់ឱ្យដំណើរការ ដើម្បីពិនិត្យតាមដានការអនុវត្តក្នុងកម្រិតសកម្មភាពនៃផែនការសកម្មភាពការងារ ។ ទោះជាយ៉ាងណា ការវាយតម្លៃវឌ្ឍនភាពក្នុងកម្រិតខ្ពស់ជាងត្រូវបានទទួលស្គាល់ថាចាំបាច់ដើម្បីវាស់វែងការអនុវត្តផែនការសកម្មភាពទាំងនោះ ថាតើបានរួមចំណែកដល់ការសម្រេចគោលបំណងរួមនៃជំហានទី១ និង ការផ្លាស់ប្តូរពីជំហានមួយទៅជំហានមួយដែលត្រូវបានកំណត់ក្នុងក្របខ័ណ្ឌសមិទ្ធកម្មរួមនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងមូលដែរឬទេ ។ យន្តការវាស់វែងទាំងនេះមានភាពជាក់លាក់ ស្របទៅតាមស្ថានភាពនៅកម្ពុជា និងបានដកស្រង់ចេញពីសូចនាករដែលបានកំណត់ដោយក្របខ័ណ្ឌគណនេយ្យភាពហិរញ្ញវត្ថុ និងចំណាយសាធារណៈ (Public Expenditure and Financial Accountability - PEFA) ដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិថាជាលក្ខខណ្ឌវិនិច្ឆ័យ (Benchmark) សម្រាប់គ្រប់គ្រងសមិទ្ធកម្មនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ យន្តការវាស់វែងខាងលើនេះត្រូវបានរៀបចំតាមឋានានុក្រមនៃការត្រួតពិនិត្យប្រចាំខែ ប្រចាំត្រីមាស និង ប្រចាំឆ្នាំ ដើម្បីធានាការផ្សារភ្ជាប់គ្នាយ៉ាងច្បាស់លាស់រវាងសមិទ្ធកម្មក្នុងកម្រិតសកម្មភាព និងគោលបំណងរួមនៃកម្មវិធីកំណែទម្រង់ ។

**៣.៣.** លើសពីនេះទៅទៀត យន្តការត្រួតពិនិត្យពីខាងក្រៅជាប្រចាំលើវឌ្ឍនភាពត្រូវបានអនុវត្តដើម្បីធានាឱ្យមានការដកខ្លួនដើម្បីត្រួតពិនិត្យឡើងវិញ និង ទទួលបាននូវការត្រួតពិនិត្យដោយសត្យានុម័ត (Objectivity) ។ ផ្អែកលើសូចនាករសមិទ្ធកម្មកម្រិតខ្ពស់ សម្រាប់វាយតម្លៃការសម្រេចបាននូវថវិកាដែលកាន់តែជឿទុកចិត្តបាន ។ តារាងទី១ សង្ខេបនូវសមិទ្ធកម្មរហូតមកដល់ពេលបច្ចុប្បន្នក្នុងការអនុវត្តឱ្យបានសម្រេចនូវលទ្ធផល និង គោលបំណងជំហានទី១ ៖

| តារាងទី១ ៖ សមិទ្ធកម្មដំណាក់កាលទី១ | | | |
|---|---|---|---|
| ការវាស់វែងតាមផ្នែក | ឆ្នាំគោល (២០០៤) | លទ្ធផលចុងឆ្នាំ ២០០៧ | យោបល់លើផលប៉ះពាល់លើគោលបំណងជាយុទ្ធសាស្ត្រ |
| ការគ្រប់គ្រងធនធាន | | | |
| លទ្ធផលប្រមូលចំណូលកាន់តែខិតទៅរកគោលដៅថវិកាដែលបានអនុម័ត ។ | ចំណូលក្នុងស្រុកទទួលបានជាមធ្យម ៩២%នៃផែនការចំណូលដែលបានគ្រោង នៅឆ្នាំ ២០០១-២០០៣។ | ចំណូលក្នុងស្រុកនៅឆ្នាំ ២០០៧ ៖ ២២.៥% លើសពីគោលដៅថវិកា ដែលបានអនុម័ត (ជាមធ្យមកំណើនចំណូលក្នុងស្រុកមាន ១៧.៥% ក្នុងមួយឆ្នាំ ចាប់ពីឆ្នាំ ២០០៥-២០០៧)។ | បញ្ហាកើតមានជុំវិញការប៉ាន់ប្រមាណទាបពេក ដែលបញ្ហានេះអាចគ្រប់គ្រងបានហើយកំពុងតែបន្តកែលម្អការព្យាករណ៍ចំណូលដោយរៀបចំឱ្យមានគោលនយោបាយចំណូលរយៈពេលមធ្យម កែលម្អវិធីសាស្ត្រព្យាករណ៍ចំណូល និង សម្របសម្រួលជាមួយស្ថាប័ន/អង្គភាពប្រមូលចំណូលទាំងអស់ ដើម្បីបង្កើនសុក្រឹតភាពនៃការព្យាករណ៍ចំណូល ។ |
| ធ្វើឱ្យប្រសើរឡើងទិន្នផលប្រមូលចំណូលពីមូលដ្ឋានចំណូល ( សារពើពន្ធ និង មិនមែនសារពើពន្ធ) តាមរយៈការកែលម្អប្រសិទ្ធភាពនៃការប្រមូល ។ | កំណើនពិតនៃចំណូលមិនមែនសារពើពន្ធប្រចាំឆ្នាំមាន [១២%] ។<br><br>កំណើនពិតនៃចំណូលសារពើពន្ធពីឆ្នាំ២០០១-២០០៣<br>-ពន្ធផ្ទាល់ [៣%]<br>-ពន្ធប្រយោល [៩%] | កំណើនពិតចំណូលប្រចាំឆ្នាំ ២០៥-២០០៧ ៖<br>-ចំណូលមិនមែនសារពើពន្ធ ៖ ១៦.៩%<br>-ពន្ធផ្ទាល់ ៖ ៣៩.៤%<br>-ពន្ធប្រយោល ៖ ២៨.៣% | ទិន្នផលប្រមូលចំណូលត្រូវបានកែលម្អគួរជាទីកត់សម្គាល់ តាមរយៈគោលនយោបាយសារពើពន្ធ និង ប្រព័ន្ធប្រមូលចំណូល ដែលបង្កើតបានមូលដ្ឋានសារពើពន្ធកាន់តែទូលាយ ដើម្បីធានាស្ថិរភាពថវិកា និង ឆ្លើយតបទៅនឹងអាទិភាពគោលនយោបាយ ។ ប៉ុន្តែ |

| | | | |
|---|---|---|---|
| | | | ចំណូលមិនមែនសារពើពន្ធអាចប្រែប្រួលដោយសាររយៈពេលកំណត់នៅក្នុងកិច្ចសន្យា ។ ក្នុងឆ្នាំ ២០០៨ កិច្ចសន្យាមួយចំនួនត្រូវបានបន្តជាថ្មី ដែលនាំឱ្យចំណូលមិនមែនសារពើពន្ធកើនឡើងប្រមាណ ៤០% ។ |
| **ភាពប្រាកដនិយម និងភាពគ្រប់ជ្រុងជ្រោយនៃថវិកា** | | | |
| ដំណើរការរៀបចំថវិកាឯកភាពតែមួយ និងមាន លំដាប់លំដោយតាមប្រតិទិនប្រកបដោយភាពស៊ីសង្វាក់ដែលអាចបង្កើតបានជាផែនការថវិកាដ៏ល្អ និងមានលក្ខណៈសមាហរណកម្ម ។ | ដំណើរការរៀបចំថវិកាពុំទាន់មានការឯកភាព ពោលគឺ ថវិកាចរន្ត និង មូលធនត្រូវបានរៀបចំដាច់ដោយឡែកពីគ្នា ។ គ្មានការពិភាក្សាស៊ីជម្រៅពីអាទិភាព និង អំណះអំណាង (Justification) នៃថវិកា ។ វដ្តថវិកាចាប់ផ្តើមនៅខែមិថុនា និង បញ្ចប់នៅខែធ្នូ ។ គ្មានការផ្សព្វផ្សាយជាសាធារណៈអំពីសេចក្តីសង្ខេបនៃថវិកា ។ | ចំណាត់ថ្នាក់សេដ្ឋកិច្ចថ្មី និងផែនការយុទ្ធសាស្ត្រថវិកា (BSP) ត្រូវបានចាប់ផ្តើមអនុវត្តនៅឆ្នាំ ២០០៧ ។ ផ្អែកលើ BSP និងកម្មវិធីវិនិយោគសាធារណៈ (PIP) ការបង្ហាញថវិកាមូលធននៅក្នុងឯកសារថវិកាត្រូវបានកែលម្អ ។ វដ្តថវិកា ត្រូវចាប់ផ្តើមនៅខែ មីនា និង បញ្ចប់នៅខែធ្នូ ដោយចែកជាបីដំណាក់កាលច្បាស់លាស់ (ផែនការយុទ្ធសាស្ត្រថវិកា ការរៀបចំកញ្ចប់ថវិកា និង ការអនុ-ម័តថវិកា) ។ ថវិកាសង្ខេបប្រចាំឆ្នាំ ២០០៧ ត្រូវបានបង្កើត ។ | ដំណើរការរៀបចំថវិកាត្រូវបានកែលម្អគួរជាទីកត់សម្គាល់ ដែលធ្វើឱ្យការគិតគូរផ្នែកគោលនយោបាយកាន់តែមានកម្រិតទូលំទូលាយឡើង ។ បន្តកែលម្អនិងអនុវត្តចំណាត់ថ្នាក់ថវិកានិងផែនការយុទ្ធសាស្ត្រថវិកាក្នុងដំណាក់កាលទី២ ។ ការធ្វើសមាហរណកម្ម ដំណើរការរៀបចំថវិកាមូលធននិងថវិកាចរន្តតាមរយៈ BSP គឺជាគោលដៅសំខាន់នៅក្នុងដំណាក់កាលទី២ ។ |

| | | | |
|---|---|---|---|
| ចំណូល និងចំណាយសាធា-រណៈធំៗ ទាំងអស់ ត្រូវបញ្ចូលទៅក្នុងថវិកា និងគណនីរបស់រាជរដ្ឋាភិបាល | ចំណូល និងចំណាយសាធារណៈធំៗដែលមិនបានដាក់បញ្ចូល ៖<br>-ចំណាយវិនិយោគ ដែលផ្តល់ហិរញ្ញប្បទានដោយផ្ទាល់ពីបំណុល និងពីទីភ្នាក់ងារផ្តល់ហិរញ្ញប្បទានពីខាងក្រៅ<br>-ចំណាយដែលបានពីចំណូលមិនឆ្លងកាត់រតនាគារជាតិ | -បង្កើតគណនីទោលរតនា-គារ (TSA)<br>-ផែនការយុទ្ធសាស្ត្រថវិកា (BSP)<br>-ការប្រមូលផ្តុំគណនីទាំងអស់របស់រដ្ឋាភិបាលទាំងអស់នេះនឹងរួមចំណែកដល់ការកែលម្អការបញ្ចូលចំណូល និងចំណាយទៅក្នុងគណនីទោលរដ្ឋាភិបាល ។ បង្កើត និងកែលម្អប្រព័ន្ធទិន្នន័យដែលអាចកត់ត្រា និងតាមដានហិរញ្ញប្បទានពីខាងក្រៅត្រូវបានរៀបចំឱ្យមានបេសសកម្មជាប្រចាំ ដើម្បីត្រួតពិនិត្យ និងស្រាវជ្រាវចំណូល/ចំណាយដែលមិនបានឆ្លងកាត់រតនាគារ។ | ថវិកាត្រូវបានកែលម្អគួរជាទីកត់សម្គាល់ និង មានភាពគ្រប់ជ្រុងជ្រោយ ដែលធ្វើឱ្យកាន់តែងាយស្រួលក្នុងការប្រើប្រាស់ថវិកាជាឧបករណ៍គាំទ្រពិតប្រាកដ ។ បន្តកែលម្អនៅក្នុងដំណាក់កាលទី ២ ដោយកំណត់ឱ្យបានច្បាស់ពីតួនាទី និង ការទទួលខុសត្រូវរវាងកសហវ និង ក្រសួង-ស្ថា-ប័ន នានា និងរវាង នាយក-ដ្ឋាន អង្គភាពនានា នៅក្នុងក្រសួង-ស្ថាប័ននីមួយៗ ព្រមទាំងរៀបចំឱ្យមានប្រព័ន្ធ និង/ឬ យន្តការច្បាស់លាស់ ។ |
| ថវិកាមានឥទ្ធិពលដោយផ្ទាល់ទៅលើតារាងបៀវត្សបុគ្គលិក ( ប្រព័ន្ធតាមដានក្របខ័ណ្ឌបុគ្គលិក ) | ព័ត៌មានស្តីពីបុគ្គលិកមិនមានគ្រប់គ្រាន់ និងអាចប្រើប្រាស់បានដោយ កសហវ ដើម្បីកំណត់ឱ្យសុក្រឹតនូវថវិកាបៀវត្សមន្ត្រីរាជការ។ ក្រុមប្រឹក្សាកំណែទម្រង់ រដ្ឋបាល (CAR) មិនបាន ធ្វើការពិចារណាទៅលើព័ត៌មានស្តីពីថវិកា ដើម្បី | រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈបានបូកសរុបសំណើជ្រើសរើសមន្ត្រីថ្មីពីគ្រប់ក្រសួង-ស្ថាប័ន និងបានផ្ញើទៅក្រុមប្រឹក្សាកែទម្រង់រដ្ឋបាលដើម្បីធ្វើការសម្រេចជាចុងក្រោយ និងបានចម្លងជូន កសហវ ដើម្បីរៀបចំថវិកាសម្រាប់ | សមាហរណកម្មត្រូវធ្វើកាន់តែប្រសើររវាងការរៀបចំមន្ត្រីរាជការនិងការត្រួតពិនិត្យផ្នែកថវិកា ។ បន្តការកែលម្អនៅដំណាក់កាលបន្តបន្ទាប់ទៀត ជាមួយនឹងកម្មវិធីកំណែទម្រង់រដ្ឋបាលស៊ីវិល ។ |

| | | | |
|---|---|---|---|
| | សម្រេចថាតើត្រូវអនុម័តទៅលើការផ្លាស់ប្តូរចំនួនមន្ត្រី និងតួនាទីរបស់មន្ត្រី ។ | មន្ត្រីថ្មីទាំងនោះ ។ ការចែករំលែកព័ត៌មាន និង ទំនាក់ទំនងការងាររវាង កសហវ និង ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល (CAR) ត្រូវបានកែលម្អក្នុងការអនុម័តទៅលើការផ្លាស់ប្តូរចំនួនមន្ត្រី និង តួនាទីរបស់មន្ត្រី ។ | |
| បង្កើតប្រព័ន្ធមួយដើម្បីធានាថាសំណើសុំឥណទានថវិកាបន្ថែមត្រូវមានភ្ជាប់មកជាមួយនូវរបាយការណ៍របស់ កសហវ ស្តីពីជម្រើសនៃប្រភពហិរញ្ញប្រទានសម្រាប់ឥណទានបន្ថែមនោះ ។ | ចំណាយលើសថវិកាច្រើននៅក្នុងឆ្នាំ ២០០១-២០០៣ ។<br>គ្មានប្រព័ន្ធសម្រាប់ធានាថាសំណើសុំចំណាយបន្ថែមបានបញ្ជាក់ពីប្រភពហិរញ្ញ-ប្បទាន ។ | ការស្នើសុំឥណទានថវិកាបន្ថែម ត្រូវបានផ្អែកលើអាទិភាព និង ការងារបន្ទាន់ ហើយការផ្តល់ឥណទាននេះត្រូវបានរក្សាក្នុងកម្រិតឥណទានត្រៀមបម្រុងរបស់រាជរដ្ឋាភិបាល និង ប្រភពហិរញ្ញប្បទានផ្សេងទៀតដែលមាន ។ BSP ក៏បានជួយកាត់បន្ថយចំណាយជាយថាហេតុផងដែរ ។ | ការគ្រប់គ្រងថវិកាបន្ថែមត្រូវបានកែលម្អគួរជាទីកត់សម្គាល់ដែលនាំឱ្យមានលំនឹងថវិកាប្រចាំឆ្នាំ ។ |
| ធ្វើការត្រួតពិនិត្យថវិកាពាក់កណ្តាលឆ្នាំ ហើយប្រើប្រាស់លទ្ធផលនៃការត្រួតពិនិត្យនេះសម្រាប់កែលម្អការអនុវត្តឆមាសទី ២ នៃឆ្នាំ និង ការរៀបចំថវិកាឆ្នាំបន្ទាប់ ។ | ការត្រួតពិនិត្យពាក់កណ្តាលឆ្នាំនៅក្នុងឆ្នាំ ២០០៤ ៖<br>-ធ្វើឡើងនៅចុងឆ្នាំ<br>-លទ្ធផលមិនត្រូវបានប្រើប្រាស់<br>-សមត្ថកិច្ច និងដំណើរការនៃការត្រួតពិនិត្យមិនមានភាពច្បាស់លាស់ | ការត្រួតពិនិត្យពាក់កណ្តាលឆ្នាំត្រូវបានធ្វើក្នុងខែ កក្កដា ឆ្នាំ ២០០៧ ហើយលទ្ធផលត្រូវបានប្រើប្រាស់សម្រាប់កែលម្អការអនុវត្តឆមាសទី ២ ។ | ការត្រួតពិនិត្យពាក់កណ្តាលឆ្នាំបានជួយឱ្យមានការកែលម្អការកំណត់អាទិភាពដើម្បីឆ្លើយតបនឹងសម្ពាធថវិកាក្នុងឆ្នាំ ។ |

| | | | |
|---|---|---|---|
| កែលម្អវិមជ្ឈការហិរញ្ញវត្ថុប្រកបដោយភាពច្បាស់លាស់ អាចគ្រប់គ្រង និងវាស់វែងបាន ។ | | ក្រុមការងារវិមជ្ឈការ និង វិសហមជ្ឈការអមគណៈ-កម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញ-វត្ថុសាធារណៈ បានផ្តល់ធាតុចូលដល់សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង និងស្រុក ខណ្ឌ លើផ្នែកវិមជ្ឈការហិរញ្ញវត្ថុដែលទាក់ទងនឹងការចែករំលែកចំណូលពន្ធ ប្រភពចំណូលផ្ទាល់ ការផ្ទេរធនធានពីថ្នាក់ជាតិទៅថ្នាក់ក្រោមជាតិ និង ការគ្រប់គ្រងហិរញ្ញវត្ថុ ។<br><br>ក្រុមការងារនេះ បានរៀបចំសេចក្តីព្រាងច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ រដ្ឋបាលថ្នាក់ក្រោមជាតិ ។<br><br>ផែនការសកម្មភាព វិមជ្ឈការ និង វិសហមជ្ឈការហិរញ្ញវត្ថុសម្រាប់ដំណាក់កាលទី២ ត្រូវបានរៀបចំ ។ | ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋ-បាលរាជធានី ខេត្ត ក្រុង និងស្រុក ខណ្ឌ ត្រូវបានអនុម័តហើយក្របខ័ណ្ឌគតិយុត្តនឹងត្រូវបន្តរៀបចំក្នុងជំហានទី ២ ។ |

| ការអនុវត្តថវិកាកាន់តែស័ក្តិសិទ្ធិជាងមុន | | | |
|---|---|---|---|
| គ្មានការកើតឡើងនូវ បំណុលកកស្ទះថ្មី និង កាត់បន្ថយបំណុលកកស្ទះជាបណ្តើរៗ | បំណុលកកស្ទះសរុប (អាណត្តិមិនទាន់ទូទាត់ ដោយមិនគិតប័ណ្ណ<br>រតនាគារ និង ប្រភេទបំណុលផ្សេងទៀត) នៅឆ្នាំ ២០០៤ មានចំនួន ៥៥៤ ពាន់លានរៀល | ការតាមដានបំណុលកកស្ទះតាមអាយុកាល និង តាមក្រសួង-ស្ថាប័ន ត្រូវបានអនុវត្តដោយប្រព័ន្ធគណនេយ្យកុំព្យូទ័រសម្រាប់ប្លង់គណនីថ្មីដែលបានដាក់ឱ្យដំណើរការក្នុងឆ្នាំ ២០០៧ ។<br><br>បំណុលកកស្ទះត្រូវបានលុបបំបាត់ទាំងស្រុង | ការលុបបំបាត់បំណុលកកស្ទះបានកែលម្អការត្រួតពិនិត្យថវិកាប្រចាំឆ្នាំ និង អាចផ្តល់មូលនិធិសម្រាប់ផ្នែកជាអាទិភាព ។ |
| អណាប័កកាន់តែមាន លទ្ធភាពបញ្ជាចំណាយ ស្របទៅតាមការព្យាករណ៍ ថវិកា និង លំហូរសាច់ប្រាក់ | ការទូទាត់ជាមធ្យមឆ្នាំ ២០០១-២០០៣ សម្រាប់ចំណាយមិនមែនប្រាក់បៀវត្សជាភាគរយ នៃថវិកានៅចុងត្រីមាស នីមួយៗ ៖<br>ត្រីមាសទី១ [៧%]<br>ត្រីមាសទី២ [១៨%]<br>ត្រីមាសទី៣ [៣៦%]<br>ត្រីមាសទី៤ [៦៤%]<br><br>គ្មានតម្លាភាពចំពោះការចេញអាណត្តិ និង គ្មានផែនការក្នុងការធ្វើវិមជ្ឈការធានាចំណាយ និង ទូទាត់ ។ | ត្រីមាសទី១ [១២.៨%]<br>ត្រីមាសទី២ [៣៥.៨%]<br>ត្រីមាសទី៣ [៦១.៩%]<br>ត្រីមាសទី៤ [៩៧.៣%]<br><br>ការកាត់បន្ថយនិតិវិធីចំណាយនៅដំណាក់កាល ទី១ ត្រូវបានអនុវត្តចាប់តាំងពីខែមករា ឆ្នាំ ២០០៧ ក្រសួង-ស្ថាប័នចំនួន ២៣ បានបង្កើត អង្គភាពសវន | បន្តកែលម្អនៅក្នុងដំណាក់កាលទី២ ដោយកំណត់ពីអង្គភាពថវិកា និងការអនុវត្ត FMIS |

| | | | |
|---|---|---|---|
| | អង្គភាពសវនកម្មផ្ទៃក្នុងត្រូវបានបង្កើតឡើងតែនៅក្នុងពីរក្រសួងប៉ុណ្ណោះ ។<br><br>ភាគរយនៃការទូទាត់ទៅឥណទាយក និង មន្ត្រីរាជការតាមប្រព័ន្ធធនាគារមានតិចជាង៥%<br><br>ការប្រមូលចំណូលសារពើពន្ធតាមធនាគារមាន ២% | កម្មផ្ទៃក្នុង ដែលក្នុងនោះ ១១ ក្រសួងបានដំណើរការ<br><br>ភាគរយនៃការទូទាត់ទៅទៅឥណទាយក និង មន្ត្រីរាជការតាមប្រព័ន្ធធនាគារមាន ៧២.៥%<br><br>ការប្រមូលចំណូលសារពើពន្ធតាមធនាគារមាន ៩២% | |
| អង្គភាពផ្តល់សេវា ( សាលារៀន មណ្ឌលសុខភាព ) ទទួលបានការបើកផ្តល់ថវិកាទាន់ពេលវេលា និង មានសមាមាត្រកើនឡើងធៀបនឹងគោលដៅ (មធ្យោបាយទំនិញ និង សេវាត្រូវបានផ្គត់ផ្គង់ ) ។ | ថវិកាដែលត្រូវវិភាជន៍ទៅដល់អង្គភាពផ្តល់សេវា មិនត្រូវបានឆ្លុះបញ្ចាំងនៅក្នុងថវិការួម ។<br><br>ការទូទាត់ជាមធ្យមនៅឆ្នាំ ២០០១-២០០៣ សម្រាប់ចំណាយមិនមែនប្រាក់បៀវត្សទៅឱ្យសាលារៀន និងមន្ទីរពេទ្យជាភាគរយនៃថវិកានៅចុងត្រីមាសនីមួយៗ មិនអាចកំណត់បាន ( ជាទូទៅ គណនីត្រូវបានបិទក្រោយថ្ងៃ ៣១ ខែ ធ្នូ ) | មានការពិភាក្សា រវាងក្រសួងអប់រំ យុវជន និង កីឡា ក្រសួង សុខាភិបាល ដៃគូអភិវឌ្ឍន៍ និង កសហវ ដើម្បីកំណត់ពីសញ្ញាណបង្ហាញ **(Proxy)** អំពីសមាមាត្រនៃការបើកផ្តល់ថវិកាដល់អង្គភាពផ្តល់សេវា ប៉ុន្តែមិនទាន់មានការឯកភាពណាមួយនៅឡើយ ។ ក្រុមការងារមួយ ត្រូវបានបង្កើតឡើងរវាង កសហវ និង ក្រសួងពាក់ព័ន្ធដើម្បីកំណត់ និង ឯកភាពទៅលើការបង្កើត **Proxy** និង ក្របខ័ណ្ឌតាមដានសម្រាប់ឆ្នាំ ២០០៧ ។ | បន្តអនុវត្តនៅជំហានទី ២ ដែលជាផ្នែកមួយនៃការចូលរួមរបស់ក្រសួង-ស្ថាប័ន និងការវិភាគទៅលើអង្គភាពថវិកា និង លំហូរនៃកិច្ចប្រតិបត្តិការ ។ |

| | | | |
|---|---|---|---|
| កិច្ចលទ្ធកម្មសាធារណៈផ្អែកលើវិធានច្បាស់លាស់ត្រូវបានពង្រឹងប្រសិទ្ធភាព និងគ្មានការពន្យារពេល ក្នុងដំណើរការលទ្ធកម្ម និងការទូទាត់ | គ្មានការប្រកាសដេញថ្លៃ និងការចែកចាយឯកសារដេញថ្លៃដែលមានលក្ខណៈជាប្រព័ន្ធ ។ ការប្រគល់សម្ភារៈមិនបំពេញតាមលក្ខខណ្ឌតម្រូវ ។ ទំនិញដែលត្រូវធ្វើលទ្ធកម្ម មិនមាននៅលើទីផ្សារ ហើយមិនអាចជំនួសទំនិញទាំងនោះជាមួយទំនិញប្រហាក់ប្រហែលបាន<br><br>គណៈកម្មាធិការកំណត់បុរេលក្ខណៈសម្បត្តិ វាយតម្លៃ និងប្រគល់កិច្ចសន្យា (PEAC) មិនបានវាយតម្លៃគ្រប់ជ្រុងជ្រោយ ។<br><br>ការទូទាត់មិនបានគោរពតាមកិច្ចសន្យាដោយសារការខ្វះសាច់ប្រាក់។<br><br>យន្តការត្រួតពិនិត្យកិច្ចដំណើរការលទ្ធកម្មនៅ កសហវ នៅមានភាព ទន់ខ្សោយ ។<br><br>តម្លៃជាមធ្យមនៃកិច្ចសន្យាលទ្ធកម្មសាធារណៈខ្ពស់ជាងតម្លៃទីផ្សារ ២០% ។ | វិធាន និងគោលនយោបាយលទ្ធកម្មត្រូវបានកែលម្អតាមរយៈការធ្វើវិសោធនកម្មអនុក្រឹត្យ លេខ៦០ ( អនុក្រឹត្យលេខ ១០៥ ) និងប្រកាសលេខ ០៤៥ ស្តីពីវិមជ្ឈការលទ្ធកម្ម ។<br><br>យន្តការរាយការណ៍ នីតិវិធីត្រួតពិនិត្យជាក្រោយ និងផែនការលទ្ធកម្មត្រូវបានដាក់ឱ្យដំណើរការ ។<br>សៀវភៅណែនាំស្តីពីលទ្ធកម្មត្រូវបានចេញផ្សាយនៅថ្ងៃទី ២៣ ខែមករា ឆ្នាំ ២០០៧ | ដំណើរការនៃកិច្ចលទ្ធកម្មត្រូវបានធ្វើឱ្យកាន់តែប្រសើរ ហើយអាណាប័កកាន់តែងាយស្រួលក្នុងការចាត់ចែងថវិការបស់ខ្លួនតាមផែនការ ។<br>បន្តកែលម្អ និងពង្រឹងកិច្ចលទ្ធកម្ម ជាពិសេសការរៀបចំច្បាប់លទ្ធកម្ម |

| | | | |
|---|---|---|---|
| សមាសធាតុចំណាយតាមប្រភេទ ( បៀវត្ស និង មិនមែនបៀវត្ស ) ទទួលបានលទ្ធផលខិតជិតថវិកាដែលបានអនុម័ត | សមាមាត្រនៃចំណាយថវិកានៅឆ្នាំ ២០០១-២០០៣ ៖<br>-បៀវត្ស ៩២%<br>-ទំនិញនិងសេវា ៨១%<br>-មូលធន ៣៥% | សមាមាត្រនៃចំណាយឆ្នាំ ២០០៥-២០០៧ ៖<br><br>-បៀវត្ស ៩២%<br>-ទំនិញនិងសេវា ១០៤%<br>-មូលធន ៨៦% | តុល្យភាពផ្នែកចំណាយជាពិសេសលើទំនិញ/សេវា និងមូលធនត្រូវបានកែលម្អ និងមានភាពកាន់តែប្រសើរឡើង ។<br>កែលម្អការរៀបចំថវិកា ជាពិសេសការរៀបចំថវិកាតាមកម្មវិធី និង បន្តជួយកែលម្អលទ្ធផលនៃចំណាយ ។ |
| ព័ត៌មានស្តីពីប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈកាន់តែមានភាពត្រឹមត្រូវនិងច្បាស់លាស់ជាងមុន (TOFE) ដោយផ្អែកលើការកែលម្អប្រព័ន្ធដែលមានស្រាប់ក្នុងពេលរង់ចាំការចាប់ផ្តើមអនុវត្ត FMIS | គ្មានក្របខ័ណ្ឌច្បាប់ច្បាស់លាស់សម្រាប់ការផ្តល់ទិន្នន័យដល់ កសហវ ។ ទិន្នន័យគណនេយ្យពុំមានភាពពេញលេញ ។ អសង្គតិភាពរវាង TOFE ប្រចាំឆ្នាំ ( ដែលត្រូវរៀបចំនៅពាក់កណ្តាលឆ្នាំបន្ទាប់ ) និង របាយការណ៍បណ្តោះអាសន្នដែលត្រូវបានរៀបចំឡើងនៅដំណាច់ឆ្នាំថវិកា ។ ក្នុងឆ្នាំ ២០០១-២០០៣ ការរៀបចំ TOFE ប្រចាំខែមានការយឺតយ៉ាវប្រមាណ ៣-៤ សប្តាហ៍ ។ | ជាទូទៅ ការរៀបចំ TOFE ប្រចាំខែ មិនអាចបញ្ចប់ក្នុងរយៈពេល២ សប្តាហ៍នៃខែបន្ទាប់<br><br>គ្មានការត្រួតពិនិត្យមើលឡើងវិញពីនាយកដ្ឋានសវនកម្មផ្ទៃក្នុង ។ | បន្តអនុវត្តនៅក្នុងជំហានទី ២ និងការរៀបចំ FMIS |
| ការព្យាករណ៍លំហូរសាច់ប្រាក់ប្រចាំឆ្នាំត្រូវបានរៀបចំ និងធ្វើបច្ចុប្បន្នភាពជាប្រចាំ ( ផ្អែកលើការព្យាករណ៍ចំណូលបានត្រឹមត្រូវ និងផែនការអនុវត្តថវិកាដ៏ល្អ ) | ពុំទាន់មានផែនការលំហូរសាច់ប្រាក់ | កម្មវិធីចំណូល និងចំណាយប្រចាំត្រីមាសបានក្លាយជាការងារប្រចាំថ្ងៃ ។<br><br>អង្គភាពគ្រប់គ្រងសាច់ប្រាក់បាន និងកំពុងដំណើរការ ។ | ការរៀបចំផែនការលំហូរសាច់ប្រាក់បានធ្វើឱ្យការបើកផ្តល់ថវិកាកាន់តែអាចព្យាករណ៍ទុកជាមុនបាន ។ |

៣.៤. លើសពីនេះទៅទៀត ការរៀបចំយុទ្ធសាស្ត្រ ការងារត្រៀមលក្ខណៈ និង ការសាកល្បង ត្រូវបាន ចាប់ផ្តើមអនុវត្តដើម្បីធានាចីរភាពនៃសមិទ្ធផលជំហានទី១ និងជាការត្រៀមរៀបចំសម្រាប់ជំហាន បន្ទាប់ ។ សកម្មភាពសំខាន់ៗមួយចំនួនត្រូវបានបង្ហាញនៅក្នុងតារាងទី២ខាងក្រោម ៖

| តារាងទី២ ៖ ការរៀបចំយុទ្ធសាស្ត្រ ការងារត្រៀមលក្ខណៈ និង ការសាកល្បង | | |
|---|---|---|
| **សកម្មភាព** | **ការរួមចំណែកដល់ជំហានបន្ទាប់** | **សមិទ្ធផល** |
| ការរៀបចំយុទ្ធសាស្ត្រចំណូលរយៈពេលវែង | បង្កើតឱ្យមានក្របខ័ណ្ឌ និង ទិសដៅដើម្បីកំណត់វិធានការសម្រាប់ការកែលម្អទិន្នផលចំណូល និងប្រសិទ្ធភាពនៃប្រព័ន្ធពន្ធដារក្នុងវិស័យសេដ្ឋកិច្ច និង សង្គម ។ | • កំណត់វិធានការដើម្បីគាំទ្រដល់កំណើនទិន្នផលពន្ធក្នុងផលិតផលក្នុងស្រុកសរុប ( ផសស-GDP )<br>• កំណត់វិធានការពង្រីកមូលដ្ឋានពន្ធ<br>• បង្កើតឱ្យមានតុល្យភាពរវាងពន្ធផ្ទាល់ និង ពន្ធប្រយោល<br>• កំណត់វិធានការដើម្បីបង្កើនតុល្យភាពនៃពន្ធប្រយោល ឱ្យស្របតាមកាតព្វកិច្ចជាអន្តរជាតិ |
| សាកល្បងការធ្វើអង្កេតតាមដានចំណាយនៅក្នុងវិស័យអប់រំ និងសុខាភិបាល | បង្កើតឱ្យមានមធ្យោបាយតាមដានថាធនធានប្រើប្រាស់ សម្រាប់ការផ្តល់សេវាត្រូវបានទទួលនៅតាមទីដៅដែលផ្តល់សេវា | • ការសិក្សាសាកល្បងត្រូវបានបញ្ចប់នៅក្រសួងអប់រំ និង សុខាភិបាល<br>• ទទួលបានបទពិសោធន៍ពីការវាំងស្ទះនៃលំហូរនិងការបែងចែកមូលនិធិ |
| ការបង្កើតអង្គភាពសវនកម្មផ្ទៃក្នុង | បង្កើតឱ្យមាន និងពង្រឹងជាបណ្តើរៗអង្គភាពសវនកម្មផ្ទៃក្នុង | • នាយកដ្ឋានសវនកម្មផ្ទៃក្នុងបានចាប់ដំណើរការនៅ កសហវ<br>• ក្រសួងចំនួន ១២ បានបង្កើតឱ្យមានអង្គភាពសវនកម្មផ្ទៃក្នុង ប៉ុន្តែមិនទាន់បានដំណើរការទាំងអស់នៅឡើយទេ |
| ការរៀបចំសាកល្បងថវិកាតាមកម្មវិធី | ធ្វើការពិសោធន៍ និង ទទួលបានមេរៀនពីការអនុវត្តសាកល្បង បច្ចេកទេសរៀបចំផែនការចំណាយថវិកាស្របតាមកម្មវិធី និងគោលបំណង | • បង្កើតក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រថវិកាសម្រាប់ក្រសួង-ស្ថាប័ន<br>• រៀបចំថវិកាតាមកម្មវិធីសម្រាប់ក្រសួង ៧<br>• ទទួលបានបទពិសោធន៍ពីការពិភាក្សាថវិកាដោយផ្អែកតាមកម្មវិធី |

| | | |
|---|---|---|
| | | • បង្កើតជាបឋមនូវបច្ចេកទេសជាមូលដ្ឋានសម្រាប់គណនេយ្យកត់ត្រាចំណាយជាក់ស្តែងដោយផ្អែកតាមកម្មវិធី |
| ការរៀបចំផែនការលទ្ធកម្ម និងផែនការអនុវត្ត FMIS | រៀបចំវិធីសាស្ត្រ និងមធ្យោបាយដើម្បីអនុវត្ត FMIS នៅជំហានទី ២ ។ បំពេញលក្ខខណ្ឌចាំបាច់ និងការកសាងសមត្ថភាពជាមូលដ្ឋានដើម្បីគាំទ្រការរៀបចំប្រព័ន្ធ FMIS | • បានរៀបចំយថាប្រភេទនៃផ្នែកទន់ (Software Specification) សម្រាប់ FMIS<br>• កិច្ចលទ្ធកម្មបានចាប់ផ្តើម<br>• បានកសាងសមត្ថភាពព័ត៌មានវិទ្យាបឋម |
| ការរៀបចំផែនការកសាងសមត្ថភាពដ៏ទូលំទូលាយ | បង្កើតផែនការកសាងសមត្ថភាពក្នុងរដ្ឋបាលសាធារណៈឱ្យស្របទៅតាមក្របខ័ណ្ឌបច្ចេកទេសនៃការងារកែទម្រង់ដែលកំពុងអនុវត្ត | • បានបង្កើតផែនការកសាងជំនាញបច្ចេកទេស ការរៀបចំស្ថាប័ន និងការលើកទឹកចិត្តដើម្បីបំពេញបន្ថែមលើតម្រូវការផ្នែកបច្ចេកទេស<br>• បានរៀបចំផែនការបណ្តុះបណ្តាលឱ្យស្របតាមតម្រូវការបច្ចេកទេស<br>• បានរៀបចំមូលដ្ឋានក្នុងការកសាងក្របខ័ណ្ឌអ្នកគ្រប់គ្រង និងអ្នកដឹកនាំក្នុងវិស័យគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសម្រាប់រយៈពេលវែង |

**៣.៥.** គោលបំណងនៃយុទ្ធសាស្ត្រនិងការអនុវត្តកន្លងមកគឺដើម្បីបន្តកែលម្អសមត្ថភាពគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីជំនះភាពប្រឈមផ្នែកគោលនយោបាយដែលរាជរដ្ឋាភិបាលកម្ពុជាកំពុងតែជួបប្រទះ ។ បញ្ហាប្រឈមសំខាន់ៗនៅក្នុងដំណាក់កាលទី១ មានដូចជា ៖

- សមត្ថភាពផ្នែកពន្ធដែលបានកែលម្អត្រូវបានប្រើប្រាស់ប្រសើរជាងមុនដើម្បីគាំទ្រដល់ការចំណាយសាធារណៈឱ្យបានសមស្រប ។
- ការប្រើប្រាស់ធនធានសាធារណៈដែលមាន ប្រកបដោយវិន័យ ដើម្បីជៀសវាងភាពមិនអាចគ្រប់គ្រងបាននៃការប្រើប្រាស់ធនធាន អស្ថិរភាពម៉ាក្រូហិរញ្ញវត្ថុរបស់រដ្ឋាភិបាល និងផលប៉ះពាល់ដល់សេដ្ឋកិច្ចទាំងមូល ។
- កែលម្អផែនការចំណាយ ឱ្យឆ្លើយតបទៅនឹងគោលនយោបាយ និងវិស័យអាទិភាព ។

**៣.៦.** ផែនការអនុវត្ត FMIS និងការកសាងសមត្ថភាពដែលជាសមាសធាតុដ៏សំខាន់នៃការងារកែទម្រង់ជំហានបន្ទាប់ត្រូវបានរៀបចំឡើងដូចមានបង្ហាញនៅក្នុងឧបសម្ព័ន្ធទី៥ ។ FMIS នឹងក្លាយទៅជាចំណុច

ស្នូលនៃប្រព័ន្ធព័ត៌មានវិទ្យា និងប្រព័ន្ធត្រួតពិនិត្យ ។ ផែនការកសាងសមត្ថភាពនៃកម្មវិធីកំណែទម្រង់ទទួលស្គាល់ថា ធនធានមនុស្សគឺជាកត្តាសំខាន់ក្នុងការសម្រេចការងារដែលបានគ្រោងទុក ។

## *ការវាយតម្លៃជារួមលទ្ធផលដំណាក់កាលទី១ និងការរួមចំណែកក្នុងការសម្រេចគោលបំណងជាយុទ្ធសាស្ត្រ*

**៣.៧.** ការវាយតម្លៃជារួមត្រូវបានធ្វើឡើងនៅក្នុងឆ្នាំ ២០០៧ ។ ទោះបីសកម្មភាពទាំងអស់ដែលបានកំណត់នៅក្នុងជំហានទី១ មិនត្រូវបានបញ្ចប់ទាំងស្រុងក៏ដោយ ក៏វឌ្ឍនភាពដ៏សមស្របនៃគោលបំណងរួមជំហានទី១ ត្រូវបានសម្រេចឡើងគួរជាទីកត់សម្គាល់ ហើយដែលអាចជួយឱ្យផែនការជំហានទី២ អាចចាប់ផ្តើមដំណើរការ ។ សមិទ្ធផលសំខាន់ៗមាននៅក្នុងផ្នែកប្រមូលចំណូល និងការបង្កើតវិសាលភាពហិរញ្ញវត្ថុ ។ ភាពជឿទុកចិត្តបានជារួមនៃថវិកាត្រូវបានកែលម្អ តាមរយៈការបើកផ្តល់ថវិកាឱ្យកាន់តែប្រសើរឡើងទៅតាមពេលវេលា និងការគ្រោងទុកស្របតាមផែនការថវិកា និងការរៀបចំផែនការ និងការគ្រប់គ្រងសាច់ប្រាក់ ។ ការគ្រប់គ្រងវដ្តថវិកាត្រូវបានកែលម្អ ចំណាយសម្រាប់វិស័យសំខាន់ៗមួយចំនួនបានធ្វើសមាហរណកម្មទៅក្នុងដំណើរការថវិកា និង ការត្រួតពិនិត្យការអនុវត្តថវិកាពាក់កណ្តាលឆ្នាំត្រូវបានអនុវត្ត ។ ការរៀបចំ និងការអនុវត្តសាកល្បងយុទ្ធសាស្ត្រកន្លងមក បានសម្រេចកិច្ចការត្រៀមលក្ខណៈមួយចំនួន និងបានផ្តល់នូវបទពិសោធន៍ដ៏ល្អដើម្បីឆ្ពោះទៅការសម្រេចគោលបំណងរយៈពេលវែងក្នុងការកែលម្អ ការបែងចែកធនធាននិងការផ្តល់សេវាតាមរយៈការដាក់ឱ្យអនុវត្តផែនការយុទ្ធសាស្ត្រថវិកា ។ សកម្មភាពក្នុងជំហានទី១ ដែលត្រូវបន្តអនុវត្តឱ្យកាន់តែស៊ីជម្រៅនឹងត្រូវបញ្ចូលទៅក្នុងផែនការសកម្មភាពដំណាក់កាលទី២ដែលនឹងត្រូវចាប់ផ្តើមអនុវត្តបន្ទាប់ពីការប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការក្នុងឆ្នាំ២០០៨។

**៣.៨.** បទពិសោធន៍ដែលទទួលបានពីការអនុវត្តផែនការសកម្មភាពជំហានទី១/ដំណាក់កាលទី១ មានដូចខាងក្រោម ៖

- សារៈសំខាន់នៃការកសាងភាពជាម្ចាស់នៅគ្រប់កម្រិតក្នុងកិច្ចប្រឹងប្រែងសម្រាប់កម្មវិធីកំណែទម្រង់ត្រូវបានពង្រឹងបន្ថែម ។
- ផែនការសកម្មភាពសម្រាប់ជំហាននីមួយៗ មិនអាចអនុវត្តបានចប់សព្វគ្រប់ទាំងស្រុងនោះទេ ពោលគឺការងារមួយចំនួននៅតែត្រូវបន្តដើម្បីធានាភាពរឹងមាំរបស់ជំហាននីមួយៗ ។ ហេតុដូច្នេះ ការបន្តវាយតម្លៃជាប្រចាំគឺជាការចាំបាច់ដើម្បីធានាថាវឌ្ឍនភាពនៃជំហានកំពុងអនុវត្ត អាចអនុញ្ញាតឱ្យជំហានបន្ទាប់ចាប់ផ្តើមដំណើរការប្រកបដោយសុវត្ថិភាព ។

- ការញែកឱ្យដាច់ពីគ្នានូវសកម្មភាពលម្អិតជាគន្លឹះដែលចាំបាច់សម្រាប់ការសម្រេចជំហានទាំងមូលគឺជាប្រការសំខាន់ណាស់ ។
- ផ្នែកខ្លះនៃសកម្មភាពការងារមានការយឺតយ៉ាវ និងជះឥទ្ធិពលដល់ការអនុវត្តការងារផ្សេងទៀត ។ ឧទាហរណ៍ ដូចជាការកសាងសមត្ថភាពជាដើម ។ អាស្រ័យហេតុនេះ ការជំរុញការអនុវត្តលើផ្នែកទាំងនោះគឺជាប្រការសំខាន់ដើម្បីកុំឱ្យរាំងស្ទះដល់យុទ្ធសាស្ត្រកំណែទម្រង់រយៈពេលវែង ។
- ក្នុងការគ្រប់គ្រងកម្មវិធីដែលមានទ្រង់ទ្រាយធំ និងប្រកបដោយភាពស្មុគ្រស្មាញបែបនេះ ការយកចិត្តទុកដាក់ខ្ពស់លើក្របខ័ណ្ឌត្រួតពិនិត្យតាមដាន និងប្រព័ន្ធរបាយការណ៍វឌ្ឍនភាព គឺជាប្រការចាំបាច់ ។

## *សមិទ្ធផលដែលសម្រេចបានកន្លងមក នឹងផ្តល់លទ្ធភាពសម្រាប់អនុវត្តជំហានបន្ទាប់*

**៣.៩.** ការផ្លាស់ប្តូរមួយជំហាននៅក្នុងក្របខ័ណ្ឌសមិទ្ធកម្មរួមនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺថាជំហានទី១បានផ្តល់នូវភាពកាន់តែច្បាស់លាស់ថាធនធាននឹងសម្រេចបានតាមការរំពឹងទុក និងបើកផ្តល់ទាន់ពេលវេលាទៅដល់អ្នកអនុវត្តគោលនយោបាយ និងអ្នកផ្តល់សេវា ។ ថវិកាបានក្លាយទៅជាឧបករណ៍កាន់តែគួរឱ្យទុកចិត្តបានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ ។

**៣.១០.** ជាលទ្ធផលនៃការផ្លាស់ប្តូរនេះ មូលដ្ឋានមួយចំនួនដែលបានបង្កើតក្នុងដំណាក់កាលទី១ បានផ្តល់លទ្ធភាពដល់ការចាប់ផ្តើមប្រកាសដាក់ឱ្យអនុវត្តយុទ្ធសាស្ត្រដំណាក់កាលទី២នៃកម្មវិធីកែទម្រង់ការគ្រប់-គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ។

- ជំរុញឱ្យមានការចូលរួមកាន់តែច្រើនថែមទៀតពីអ្នកទទួលខុសត្រូវក្នុងការប្រើប្រាស់ធនធានថវិកានៅក្នុងដំណាក់កាលបន្ទាប់នៃដំណើរការអនុវត្តកម្មវិធីកំណែទម្រង់ **ដោយហេតុថា**ក្របខ័ណ្ឌនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈត្រូវបានកែលម្អនៅក្នុងជំហានទី ១ ។
- ជំរុញអ្នកទទួលខុសត្រូវក្នុងការប្រើប្រាស់ធនធានថវិកា ឱ្យកាន់តែមានគណនេយ្យភាព **ដោយហេតុថា** កង្វះខាតក្នុងការគ្រប់គ្រងធនធាន ការព្យាករណ៍ប្រភព និងលំហូរធនធានមិនបានត្រឹមត្រូវ និងកង្វះខាតនូវយន្តការអនុវត្តថវិកាក្នុងពេលកន្លងទៅ ត្រូវបានកែលម្អក្នុងកម្រិតខ្ពស់ ដែលនាំឱ្យអ្នកទទួលខុសត្រូវក្នុងការប្រើប្រាស់ថវិកាមិនអាចយកធ្វើជាសម្អាងដើម្បីគេចវេសពីការទទួលខុសត្រូវ ។
- ផ្តល់សិទ្ធិអំណាចកាន់តែធំជាងមុន ផ្អែកតាមគោលការណ៍សម្រិតសម្រាំង ដល់អ្នកទទួលខុសត្រូវក្នុងការប្រើប្រាស់ធនធានថវិកា **ដោយហេតុថា** អ្នកគ្រប់គ្រងថវិកាកាន់តែមានលទ្ធភាពក្នុងការ

បង្កើតយន្តការគ្រប់គ្រងធនធានផ្ទៃក្នុងរបស់ខ្លួន ដែលឥឡូវនេះកង្វះខាតលើនីតិវិធីនៅថ្នាក់កណ្តាលដែលធ្លាប់មានពីមុនមកត្រូវបានដោះស្រាយ ។

- អ្នកទទួលខុសត្រូវក្នុងការប្រើប្រាស់ធនធានថវិកាត្រូវមានលក្ខណៈកាន់តែបើកចំហ និង មានតម្លាភាពក្នុងការបំពេញមុខងារ **ដោយហេតុថា** ប្រព័ន្ធលំហូរ និងវិភាគទិន្នន័យត្រូវបានកែលម្អជាបឋមហើយមូលដ្ឋានគ្រឹះផ្សេងៗទៀតត្រូវបានបង្កើតឡើងផងដែរ សម្រាប់ការបន្តកែលម្អប្រព័ន្ធទាំងនេះបន្ថែមទៀត ។

## ៤. ការបង្ហាញអំពីដំណើរការរៀបចំផែនការសកម្មភាពដំណាក់កាលទី២ ៖ គោលបំណង យុទ្ធសាស្ត្រ និង ផែនការសកម្មភាពរួម

***ដំណើរការនៃការរៀបចំដំណាក់កាលទី២ ៖***

៤.១ ក្នុងការរៀបចំផែនការសកម្មភាពសម្រាប់ជំហានទី២/ដំណាក់កាលទី២ គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបានប្រកាន់យកនូវការងារជាលំដាប់លំដោយដូចខាងក្រោម ៖

<u>ការងារទី១ ៖ *យុទ្ធសាស្ត្ររួមនៅតែមានតម្លៃសម្រាប់បន្តអនុវត្ត*</u>

ផ្អែកតាមបទពិសោធន៍នៃការអនុវត្តជំហានទី១/ដំណាក់កាលទី១ គួរពិចារណាថា តើយុទ្ធសាស្ត្ររួមចាំបាច់ត្រូវធ្វើការផ្លាស់ប្តូរ ឬកែសម្រួលឬទេ ។ ជាការសន្និដ្ឋាន យុទ្ធសាស្ត្ររួមនៅតែរឹងមាំ ហើយលំដាប់លំដោយនៃផែនការសកម្មភាពដែលបានរៀបចំជា ៤ ជំហាន នៅតែមានតម្លៃសម្រាប់បន្តអនុវត្ត ប៉ុន្តែបទពិសោធន៍មួយចំនួនចាំបាច់យកមកពិចារណាក្នុងការឈានទៅជំហានបន្ទាប់ ។ បទពិសោធន៍ដ៏សំខាន់ៗទាំងនោះ រួមមាន ៖

- ប្រសិទ្ធភាពនៃការចូលរួមរបស់អង្គភាពថវិកានៅតាមក្រសួង-ស្ថាប័ន មានសារៈសំខាន់សម្រាប់អនុវត្តការកែទម្រង់នៅក្នុងដំណាក់កាលបន្តបន្ទាប់ ។
- កិច្ចខិតខំប្រឹងប្រែងកសាងសមត្ថភាពត្រូវតែពង្រឹង និងរៀបចំឱ្យកាន់តែល្អប្រសើរថែមទៀត ពីព្រោះការកែទម្រង់នៅក្នុងដំណាក់កាលបន្តបន្ទាប់ទៀត មិនពឹងផ្អែកតែទៅលើ កសហវ ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាស្រ័យលើការចូលរួម និង ការទទួលខុសត្រូវពីអង្គភាពថវិការបស់ក្រសួង-ស្ថាប័ន ទាំងអស់ ។
- ការអនុវត្តកម្មវិធីកំណែទម្រង់នៅក្នុងជំហាននីមួយៗមិនអាចបញ្ចប់បានទាំងស្រុងនោះទេ ប្រការសំខាន់គឺត្រូវបន្តអនុវត្តឱ្យកាន់តែស៊ីជម្រៅ និងបន្តពង្រឹងការងារកែទម្រង់មួយចំនួនដែលបានអនុវត្តនៅក្នុងជំហានទី១ ។
- ការងារសាកល្បងមួយចំនួនសម្រាប់ជំហានបន្ទាប់ត្រូវបន្តយកចិត្តទុកដាក់អនុវត្តឱ្យបានខ្លាំងក្លាថែមទៀតនៅពេលទទួលបានបទពិសោធន៍គ្រប់គ្រាន់ ដូចជាការបន្តពង្រីកការអនុវត្តថវិកាតាមកម្មវិធី ។
- ការរៀបចំ និងការគ្រប់គ្រង FMIS នឹងទាមទារឱ្យមានការយកចិត្តទុកដាក់កាន់តែខ្លាំងឡើងជាងអ្វីដែលបានគិតទុកពីមុន ដោយសារតែកម្ពុជាខ្វះខាតបទពិសោធន៍ក្នុងការរៀបចំប្រព័ន្ធដែលមានទ្រង់ទ្រាយធំនៅក្នុងរដ្ឋបាលសាធារណៈ ។

បណ្តាបទពិសោធន៍ទាំងអស់នេះ ត្រូវបានប្រើប្រាស់ជាធាតុចូលក្នុងការរៀបចំដំណាក់កាលទី២។

***ការងារទី២ ៖ ការកំណត់នូវការងារចាំបាច់ដែលត្រូវបន្តពង្រឹងនៅក្នុងជំហានទី១***

ដោយបានសន្និដ្ឋានថា សកម្មភាពការងារមួយចំនួនត្រូវតែបន្តដើម្បីពង្រឹង និងធ្វើឱ្យកាន់តែស៊ីជម្រៅនូវកំណែទម្រង់ជំហានទី១ ទន្ទឹមនឹងការចាប់ផ្តើមជំហានទី២ ការត្រួតពិនិត្យឡើងវិញនូវវឌ្ឍនភាពនៃសកម្មភាពការងារជំហានទី១ ត្រូវបានធ្វើឡើង ហើយបណ្តាសកម្មភាពគន្លឹះក៏ត្រូវបានកំណត់សម្រាប់ការបន្តពង្រឹងនៅក្នុងដំណាក់កាលទី២ ។

***ការងារទី៣ ៖ ការកំណត់គោលបំណងជំហានទី២***

សេចក្តីលម្អិតនៃគោលបំណងជំហានទី២ ត្រូវបានរៀបចំ និងលើកមកពិភាក្សា ។ កិច្ចការនេះត្រូវបានផ្តោតទៅលើការកំណត់នូវប្រភេទនៃសកម្មភាពផ្សេងៗដែលចាំបាច់ត្រូវអនុវត្តដើម្បីសម្រេចតាមគោលដៅនៃជំហានទី២ ។

***ការងារទី៤ ៖ ការកំណត់សកម្មភាពការងារសាកល្បងចាំបាច់សម្រាប់ជំហានបន្ទាប់***

ការងារមួយចំនួនសម្រាប់ជំហានបន្ទាប់ ដែលបានចាប់ផ្តើមអនុវត្តនៅក្នុងដំណាក់កាលទី១ ត្រូវបានរៀបចំបញ្ចូលក្នុងផែនការសកម្មភាពជំហានទី២ ។ ប៉ុន្តែសកម្មភាពការងារមួយចំនួននៃសកម្មភាពទាំងនេះក៏នឹងមិនអាចបញ្ចប់នៅក្នុងជំហានទី២នេះ ហើយអាចនឹងត្រូវបន្តទៅបណ្តាជំហានក្រោយៗទៀត ។ ដូច្នេះការកំណត់សកម្មភាពការងារសាកល្បងចាំបាច់សម្រាប់ជំហានបន្ទាប់នេះ ត្រូវបានពិចារណាឡើងវិញថាតើសកម្មភាពការងារសម្រាប់បណ្តាជំហានបន្ទាប់ក្នុងដំណាក់កាលទី១ នៅតែសមស្របសម្រាប់ដំណាក់កាលទី២ ឬត្រូវការបន្ថែម ឬកំណត់ឡើងវិញក្នុងករណីចាំបាច់ ។

***ការងារទី៥ ៖ ការរៀបចំសកម្មភាពគន្លឹះ***

បន្ទាប់ពីបានកំណត់សកម្មភាពជំហានទី១ ដែលត្រូវបន្តពង្រឹង, បណ្តាគោលបំណងជំហានទី២ និងសកម្មភាពការងារសម្រាប់ជំហានបន្ទាប់ ទស្សនៈរួមតាមរបៀប “ពីលើចុះក្រោម” លើបណ្តាសកម្មភាពចាំបាច់ដែលត្រូវសម្រេចឱ្យបាននូវបណ្តាសកម្មភាពការងារ និងគោលបំណងដែលបានកំណត់ខាងលើ ត្រូវបានគណៈកម្មាធិការកែទម្រង់យកមករៀបចំ និងពិភាក្សា ។ គណៈកម្មាធិការកែទម្រង់បានធ្វើការជជែកពិភាក្សា និងបានធ្វើការកែលម្អចំណុចមួយចំនួនដែលចាំបាច់ ។ បណ្តាគោលបំណង និងសកម្មភាពនៃដំណាក់កាលទី២ ដែលបានរៀបចំឡើង បង្កើតបានជាផែនការសកម្មភាពរួមដែលជាស្នូលនៃដំណើរការសម្រាប់ការរៀបចំផែនការសកម្មភាពដំណាក់កាលទី២ ។

***ការងារទី៦ ៖ ការរៀបចំផែនការសកម្មភាពលម្អិត***

នៅពេលដែលក្របខ័ណ្ឌរួមនៃសកម្មភាពត្រូវបានរៀបចំ និង ពិភាក្សានៅក្នុងគណៈកម្មាធិការកែទម្រង់ នាយកដ្ឋានទាំងអស់នៃ កសហវ ត្រូវបានអញ្ជើញឱ្យចូលរួមដើម្បីផ្តល់ជាគំនិត និងរៀបចំផែនការសកម្មភាពការងាររបស់នាយកដ្ឋានដើម្បីអនុវត្តផែនការសកម្មភាពរួម ។ ប៉ុន្តែដំណើរការនៃការរៀបចំផែនការសកម្មភាពរបស់នាយកដ្ឋាននិងផែនការសកម្មភាពរួមត្រូវបានពិនិត្យ និងកែលម្អជាច្រើនលើកទៅវិញទៅមកដើម្បីឱ្យស៊ីសង្វាក់គ្នា ។ ការកែសម្រួលសកម្មភាពទាំងឡាយត្រូវបានលើកយកមកពិភាក្សានៅក្នុងក្របខ័ណ្ឌគណៈកម្មាធិការកែទម្រង់ ។

***ការងារទី៧ ៖ ការរៀបចំគោលដៅសម្រាប់វាស់សមិទ្ធផល***

បន្ទាប់ពីបានកំណត់សកម្មភាព និងផែនការការងារ បណ្តាសូចនាករសម្រាប់វាស់វែងសមិទ្ធផល និងសម្រាប់វាស់វែងការរួមចំណែកនៃការអនុវត្តសកម្មភាព និងផែនការការងារទាំងនេះ ត្រូវបានបង្កើតដើម្បីវាយតម្លៃលើគោលបំណងជំហានទី២ ។ ដូចនៅក្នុងជំហានទី១ដែរ សូចនាករទាំងនេះត្រូវបានជ្រើសរើសដោយផ្អែកលើលទ្ធភាពនៃការផ្សារភ្ជាប់រវាងសកម្មភាពទៅនឹងលទ្ធផល ដែលអាចឆ្លុះបញ្ចាំងអំពីការកែលម្អសមិទ្ធកម្មនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលជាគោលដៅបានកំណត់សម្រាប់ជំហានទី ២ ។ ម្យ៉ាងទៀតនៅក្នុងជំហានទី១ សូចនាករទាំងនេះត្រូវបានកំណត់នៅក្នុងក្របខ័ណ្ឌសូចនាកររបស់គណនេយ្យភាពហិរញ្ញវត្ថុ និងចំណាយសាធារណៈ (PEFA) ដែលជាលក្ខខណ្ឌវិនិច្ឆ័យនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមានការទទួលស្គាល់ជាអន្តរជាតិ ។ ដូច្នេះ ការជ្រើសរើសសូចនាករទាំងនេះ តម្រូវឱ្យមានការត្រួតពិនិត្យឡើងវិញនូវភាពគ្រប់គ្រាន់នៃសកម្មភាពការងារដែលបានកំណត់ ដើម្បីធានាថាតម្រូវការកែលម្អនៃសមិទ្ធកម្មការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈអាចសម្រេចបាន ។

***ការងារទី៨ ៖ ការពិគ្រោះយោបល់ និងការចូលរួមក្នុងភាពជាដៃគូ***

ការងារពីទី១ ដល់ទី៧ ត្រូវបានអនុវត្តស្ទើរតែទាំងស្រុងដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (កសហវ) ។ ទោះជាយ៉ាងណាក៏ដោយ យន្តការពីរនៃការពិគ្រោះយោបល់ និងត្រួតពិនិត្យឡើងវិញត្រូវបានប្រកាន់យក ៖

១. ការចូលរួមរបស់ក្រសួង-ស្ថាប័ន និងអង្គភាពថវិកា ៖ បានធ្វើការបង្ហាញដល់ក្រសួង-ស្ថាប័ន និងអង្គភាពថវិកាអំពីផែនការ និងគោលបំណងនៃកម្មវិធីកំណែទម្រង់ ហើយបានស្នើឱ្យមានការចូលរួមផ្តល់យោបល់ពីក្រសួង-ស្ថាប័ន និងអង្គភាពទាំងនោះដើម្បីកែលម្អផែនការសកម្មភាព ។

២. ការចូលរួមរបស់ដៃគូអភិវឌ្ឍន៍ ៖ បានធ្វើការពិគ្រោះយោបល់ និងត្រួតពិនិត្យឡើងវិញ ជាមួយបណ្តាដៃគូអភិវឌ្ឍន៍ទាំងអស់ រួមទាំងបេសកកម្មរួមគ្នា ។

យន្តការទាំងពីរខាងលើនេះ បាននាំមកនូវការផ្តល់យោបល់បន្ថែម និងត្រូវបានយកមកពិចារណា ដើម្បីកែលម្អគោលបំណង សកម្មភាព និងផែនការការងារនៅក្នុងករណីដែលសមស្រប ។

ជាលទ្ធផលនៃដំណើរការខាងលើនេះ ផែនការសកម្មភាពរួមនៃដំណាក់កាលទី២ ត្រូវបានរៀបចំឡើងជាបីផ្នែក ៖

- ផែនការសកម្មភាពជំហានទី១ ដែលត្រូវបន្តពង្រឹងនៅក្នុងដំណាក់កាលទី២
- ផែនការសកម្មភាពជំហានទី២ ដែលត្រូវអនុវត្តនៅក្នុងដំណាក់កាលទី២
- ផែនការសកម្មភាពសម្រាប់ជំហានបន្ទាប់ដែលត្រូវចាប់ផ្តើមជាបណ្តើរៗ

## ផែនការសកម្មភាពជំហានទី១ ដែលត្រូវបន្តពង្រឹងនៅក្នុងដំណាក់កាលទី២

**៤.២** ទន្ទឹមនឹងវឌ្ឍនភាពដ៏ល្អប្រសើរសម្រេចបានក្នុងជំហានទី១ ផ្នែកមួយចំនួនទាមទារឱ្យមានការបន្តពង្រឹង និងអនុវត្តឱ្យកាន់តែស៊ីជម្រៅថែមទៀត ។ បណ្តាគោលបំណងដែលត្រូវបានជ្រើសរើសដើម្បីផ្តោតទៅលើការបន្តពង្រឹងសមិទ្ធផល ជំហានទី១ មានដូចខាងក្រោម ៖

| តារាងទី ៣ ៖ បណ្តាគោលបំណងជំហានទី ១ | |
|---|---|
| **គោលបំណងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** | **សូចនាករគន្លឹះ** |
| **១១.**បន្តកែលម្អរដ្ឋបាល និងគោលនយោបាយចំណូល | គោលនយោបាយចំណូលត្រូវបានប្រើប្រាស់ពេញលេញជាមគ្គុទ្ទេសក៍ក្នុងការកំណត់ថវិកា និង ដំណើរការប្រមូលចំណូល ។ |

| | |
|---|---|
| **ការផ្សារភ្ជាប់ជាយុទ្ធសាស្ត្រ**<br>គោលបំណងនេះ សំដៅគាំទ្រគោលបំណងនៃគោលនយោបាយរួមសម្រាប់ការកែលម្អឱ្យកាន់តែប្រសើរឡើងនូវការកៀរគរចំណូល ដែលរួមមាន ៖ (១) ការពង្រីកមូលដ្ឋានចំណូល (២) ការពង្រឹងវិសាលភាពនៃកំណែទម្រង់ចំណូលដែលកំពុងអនុវត្តនៅក្នុងអគ្គនាយកដ្ឋានពន្ធដារ និង (៣) ការរៀបចំគោលនយោបាយចំណូលពីប្រេង/ឧស្ម័ន/រ៉ែ និងការបង្កើតយន្តការគ្រប់គ្រងលំហូរចំណូលទាំងនេះ ។ | |
| **១២.**បន្តកែលម្អការគ្រប់គ្រងបំណុល | ក្របខ័ណ្ឌច្បាប់ ប្រព័ន្ធ និងក្របខ័ណ្ឌរបាយការណ៍សម្រាប់ការគ្រប់គ្រងបំណុលត្រូវបានអនុវត្ត ។ |
| **ការផ្សារភ្ជាប់ជាយុទ្ធសាស្ត្រ**<br>ផ្អែកលើវឌ្ឍនភាពដ៏ល្អប្រសើរក្នុងដំណាក់កាលទី១ គោលបំណងនេះសំដៅពង្រឹងមុខងារ និង សមត្ថភាពក្នុងការប្រើប្រាស់ទិន្នន័យបំណុល (DMFAS) ដើម្បីពង្រឹងការរៀបចំយុទ្ធសាស្ត្របំណុល ការគ្រប់គ្រងបំណុល គណនេយ្យ និងរដ្ឋបាល ។ | |
| **១៣.** បន្តកែលម្អការគ្រប់គ្រងសាច់ប្រាក់ និង ការគ្រប់គ្រងគណនីធនាគារ | យន្តការគណនីទោលរតនាគារត្រូវបានអនុវត្ត |
| **ការផ្សារភ្ជាប់ជាយុទ្ធសាស្ត្រ**<br>គោលបំណងនេះ សំដៅជួយជំរុញវឌ្ឍនភាពនៃការប្រមូលផ្តុំគណនីរដ្ឋាភិបាល និងការពង្រឹងយន្តការគ្រប់គ្រងសាច់ប្រាក់ ដែលជាមូលដ្ឋានធានាប្រសិទ្ធភាពនៃការគ្រប់គ្រងសន្ទនីយភាព (Liquidity) របស់រដ្ឋាភិបាល ។ | |

| | |
|---|---|
| **១៤.** បន្តកែលម្អលទ្ធកម្មសាធារណៈ | ក្របខ័ណ្ឌច្បាប់វិសហមជ្ឈការលទ្ធកម្មសាធារណៈ ដែលបានកែលម្អត្រូវបានអនុវត្ត និងសមត្ថភាពត្រួតពិនិត្យត្រូវបានពង្រឹង |
| **ការផ្សារភ្ជាប់ជាយុទ្ធសាស្ត្រ**<br>គោលបំណងនេះ នឹងបន្តពង្រឹងតម្លាភាពនៃដំណើរការលទ្ធកម្មសាធារណៈ ព្រមទាំងការអភិវឌ្ឍសមត្ថភាព និងការរៀបចំវិធីសាស្ត្រចាំបាច់ ដើម្បីគាំទ្រក្របខ័ណ្ឌនៃការពង្រីកវិសហមជ្ឈការលទ្ធកម្មសាធារណៈថែមទៀត ។ | |

## ផែនការសកម្មភាពជំហានទី ២ ដែលត្រូវអនុវត្តនៅក្នុងដំណាក់កាលទី ២

**៤.៣** ផ្អែកលើលទ្ធផលនៃដំណើរការដូចបានរៀបរាប់ខាងលើ គោលបំណងរួមជំហានទី២ ត្រូវបានកំណត់ថា ៖ ធ្វើការកែលម្អគណនេយ្យភាពដើម្បីសម្រេចបាននូវការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រកបដោយប្រសិទ្ធភាព ។ ក្នុងន័យនេះ មន្ត្រីសាធារណៈនៅគ្រប់លំដាប់ថ្នាក់ត្រូវបានផ្តល់សិទ្ធិអំណាចឱ្យបំពេញមុខងារប្រកបដោយប្រសិទ្ធភាព ហើយត្រូវមានការទទួលខុសត្រូវចំពោះការគ្រប់គ្រង និងការត្រួតពិនិត្យហិរញ្ញវត្ថុសាធារណៈ ។ លើសពីនេះទៀត វិធានការប្រកបដោយភាពស័ក្តិសិទ្ធិដើម្បីឱ្យមន្ត្រីរាជការមានគណនេយ្យភាពក៏ត្រូវដាក់ឱ្យដំណើរការផងដែរ ។

**៤.៤** ដូច្នេះខ្លឹមសារសំខាន់នៃជំហានទី២ គឺការបង្កើនគណនេយ្យភាពរបស់អ្នកទទួលខុសត្រូវក្នុងការគ្រប់គ្រងធនធានសាធារណៈឱ្យមានប្រសិទ្ធភាព និង ភាពស័ក្តិសិទ្ធិ និងសុវត្ថិភាព ។ ជំហានទី១ បានដាក់ចេញក្របខ័ណ្ឌរួមសម្រាប់ការគ្រប់គ្រងធនធានសាធារណៈ ហើយបានដោះស្រាយបញ្ហាជាមូលដ្ឋានមួយចំនួននៅក្នុងប្រព័ន្ធរួមទាំងមូល ។ ជំហានទី២ តម្រូវឱ្យមានការចូលរួមពីគ្រប់អង្គភាពថវិកានិងអ្នកគ្រប់គ្រងថវិកាទាំងអស់ក្នុងការកែលម្អការគ្រប់គ្រងហិរញ្ញវត្ថុផ្ទៃក្នុងរបស់ខ្លួន នៅក្រោមក្របខ័ណ្ឌរួមនៃកម្មវិធីកំណែទម្រង់ ។ ផែនការសកម្មភាពត្រូវបានរៀបចំឡើងសំដៅឆ្ពោះទៅសម្រេចគោលបំណងនៃជំហានទី២ ខាងលើតាមរយៈការរួមបញ្ចូលគ្នានូវគំនិតផ្តួចផ្តើមស្តីអំពីការរៀបចំបទបញ្ញត្តិ ដំណើរការ និងការកសាងសមត្ថភាពជាមួយនឹងការផ្តល់ការលើកទឹកចិត្តសមស្របចំពោះសមិទ្ធកម្មល្អ និងទណ្ឌកម្មចំពោះសមិទ្ធកម្មមិនល្អ ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

**៤.៥** ជំហានទី២នេះនឹងចាប់ផ្តើមបង្កើនការផ្តល់សិទ្ធិអំណាចដល់អង្គភាពថវិកា និង អ្នកគ្រប់គ្រងថវិកា ។ ផ្អែកតាមបទពិសោធន៍នៅបណ្តាប្រទេសមួយចំនួន រាជរដ្ឋាភិបាលកម្ពុជាយល់ឃើញថា ការបង្កើនប្រតិភូកម្ម និង ការលុបរបាំងដែលជាឧបសគ្គដល់ការសម្រេចជោគជ័យនៃការផ្តល់សេវាសាធារណៈ និង គោលនយោបាយប្រកបដោយប្រសិទ្ធភាពគឺជាកត្តាសំខាន់ ។ រាជរដ្ឋាភិបាលជឿជាក់ថា ការបន្តផ្តល់សិទ្ធិអំណាចបន្ថែមទៀត គឺជាប្រការសំខាន់ដើម្បីសម្រេចជោគជ័យនៃបណ្តាជំហានបន្ទាប់ដែលផ្តោតលើរបៀបនៃការប្រើប្រាស់ថវិកាដើម្បីសម្រេចបានលទ្ធផល ។ ប៉ុន្តែក្នុងបរិការណ៍ទន់ខ្សោយនៃប្រព័ន្ធត្រួតពិនិត្យហិរញ្ញវត្ថុ ការផ្តល់សិទ្ធិអំណាចត្រូវធ្វើឡើងក្នុងលក្ខណៈប្រយ័ត្នប្រយែងបំផុត និងមានលក្ខណៈសម្រិតសម្រាំង ។ វិធានការខាងលើនេះត្រូវពង្រីកជាបណ្តើរៗ ដោយផ្អែកលើបទពិសោធន៍ ទំនុកចិត្ត និង ភាពជឿជាក់តាមរយៈការអនុវត្តជាជំហានៗ ។

៤.៦ គណនេយ្យភាពដែលត្រូវកែលម្អ និង ការផ្តល់សិទ្ធអំណាច នឹងត្រូវគាំទ្រដោយវិធានការនៃការបន្តកែលម្អប្រព័ន្ធព័ត៌មានវិទ្យា និងតម្លាភាពលើកាតព្វកិច្ចគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលកំពុងអនុវត្តជាក់ស្តែង ដោយអង្គភាពថវិកា និងអ្នកគ្រប់គ្រងថវិកា ។

៤.៧ ដើម្បីសម្រេចបានទិសដៅរួម គោលបំណងចំនួន៨ ត្រូវបានកំណត់ ។ តារាងទី ៤ ខាងក្រោមបង្ហាញពីគោលបំណងនីមួយៗ និងការរួមចំណែកនៃគោលបំណងទាំងនេះដើម្បីសម្រេចបានទិសដៅរួមជំហានទី២ ។

| តារាងទី ៤ ៖ គោលបំណងជំហានទី ២ | |
|---|---|
| **គោលបំណងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** | **លទ្ធផលរំពឹងទុក** |
| **២១.** កែលម្អបន្ទាត់គណនេយ្យភាពដោយកំណត់ឱ្យបានច្បាស់ពីតួនាទី មុខងារ និង ការទទួលខុសត្រូវរបស់ក្រសួង-ស្ថាប័ន គ្រប់កម្រិត និងរបស់អង្គភាពក្រោមឱវាទ | តួនាទី និង ការទទួលខុសត្រូវក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់កសហវ និងក្រសួង-ស្ថាប័នពាក់ព័ន្ធត្រូវបានកំណត់ ។ ក្របខ័ណ្ឌច្បាប់ និងការកសាងសមត្ថភាពត្រូវបានរៀបចំ និងអភិវឌ្ឍ ។ |
| **ការផ្សារភ្ជាប់ជាយុទ្ធសាស្ត្រ**<br>គោលបំណងនេះនឹងគាំទ្រជំហានទី២ ដោយកំណត់ឱ្យបានច្បាស់អ្នកទទួលខុសត្រូវ ព្រោះបើគ្មានការកំណត់ដូចនេះទេគណនេយ្យភាពប្រកបដោយប្រសិទ្ធភាពនឹងមិនអាចសម្រេចបានឡើយ ។ គោលបំណងនេះនឹងគាំទ្រដល់គោលនយោបាយរាជរដ្ឋាភិបាល នៅក្នុងការពង្រីកវិសហមជ្ឈការការទទួលខុសត្រូវ និង សិទ្ធិអំណាចដល់ក្រសួង-ស្ថាប័ន ជាមួយនឹងការកែលម្អសមត្ថភាពក្នុងការអនុវត្តការទទួលខុសត្រូវទាំងនេះ ហើយគោលបំណងនេះក៏មានសង្គតិភាពផងដែរទៅនឹងគោលបំណងរួមរយៈពេលវែងនៃការអនុវត្តអភិក្រមគ្រប់គ្រងធនធានផ្អែកលើសមិទ្ធកម្ម/លទ្ធផល និងការបង្កើនគណនេយ្យភាព ។ ការសម្រេចគោលបំណងនេះនឹងរួមចំណែកក្នុងការកំណត់ឱ្យកាន់តែច្បាស់លាស់ និងការពង្រឹងតួនាទីរបស់ក្រសួង-ស្ថាប័ននីមួយៗ នៅក្នុងកម្រិតថ្នាក់ជាតិ និងកម្រិតវិស័យក្នុងដំណើរការនៃការរៀបចំផែនការ និងថវិកាប្រចាំឆ្នាំ ។ កម្មវិធីនេះនឹងគាំទ្រដល់សកម្មភាពដែលជួយពង្រឹងសមត្ថភាពក្រសួង-ស្ថាប័ន តាមរយៈការផ្តល់ជំនួយបច្ចេកទេស និងធនធានចាំបាច់ ។ ដោយផ្អែកតាមគោលការណ៍ណែនាំរួមរបស់ កសហវ អង្គភាពថវិកានឹងទទួលបានការគាំទ្រក្នុងការវាយតម្លៃលើកម្រិតសមត្ថភាពផ្ទាល់របស់ខ្លួន ព្រមទាំងការរៀបចំផែនការ និងការជ្រើសរើសអភិក្រមសមស្របដើម្បីអភិវឌ្ឍសមត្ថភាព ។ | |

<table>
<tr><td>២២.កែលម្អឧបករណ៍ដែលជំរុញឱ្យមានការទទួលខុសត្រូវចំពោះការគ្រប់គ្រងហិរញ្ញវត្ថុ និងការពង្រឹងគណនេយ្យភាព</td><td>ប្រព័ន្ធលើកទឹកចិត្ត និងការដាក់ទណ្ឌកម្ម សម្រាប់ការគ្រប់គ្រងធនធានសាធារណៈប្រកបដោយភាពស័ក្តិសិទ្ធិត្រូវបានបង្កើត ហើយយន្តការត្រួតពិនិត្យឡើងវិញលើភាពត្រឹមត្រូវនៃការអនុវត្តត្រូវបានរៀបចំ ។</td></tr>
<tr><td colspan="2">ការផ្សារភ្ជាប់ជាយុទ្ធសាស្ត្រ<br>គោលបំណងនេះនឹងគាំទ្រជំហានទី២ នៅក្នុងការបញ្ជាក់ឱ្យបានច្បាស់អំពីបច្ច័យនៃការអនុវត្តការទទួលខុសត្រូវចំពោះអ្នកទទួលខុសត្រូវក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ គោលបំណងនេះនឹងរួមចំណែកបង្កើតឱ្យមានក្របខ័ណ្ឌលើកទឹកចិត្ត ការដាក់ទណ្ឌកម្ម និងប្រព័ន្ធត្រួតពិនិត្យតាមដាន ដើម្បីគាំទ្រ និងត្រួតពិនិត្យគណនេយ្យភាពដែលត្រូវបានបង្កើតឡើងក្នុងក្របខ័ណ្ឌគោលនយោបាយវិសហមជ្ឈការនៃការទទួលខុសត្រូវថវិការបស់រាជរដ្ឋាភិបាល ។ ក្របខ័ណ្ឌនេះនឹងត្រូវអនុវត្តចំពោះគ្រប់ក្រសួង-ស្ថាប័ន ដែលចង់ពង្រីកការទទួលខុសត្រូវប្រតិភូកម្មអំណាច វិធានការនៃការលើកទឹកចិត្ត និងដាក់ទណ្ឌកម្មជាក់លាក់ ព្រមទាំងការរៀបចំយន្តការត្រួតពិនិត្យតាមដានដែលបានឯកភាព ។</td></tr>
<tr><td>២៣. បន្តកែលម្អការអនុវត្តមាតិកាថវិកាថ្មី និងប្លង់គណនេយ្យថ្មី</td><td>ចំណាត់ថ្នាក់មាតិកាថវិកាត្រូវបានរៀបចំឱ្យមានសង្គតិភាពទៅនឹងស្តង់ដារចំណាត់ថ្នាក់មុខងាររបស់រដ្ឋាភិបាល (GFS/COFOG) ។ មូលដ្ឋានប្រព័ន្ធគណនេយ្យបញ្ចូលជាបណ្តើរៗនូវ សមាសធាតុដែលមានលក្ខណៈជាគណនេយ្យបង្គរ ( Modified Accrual Accounting)</td></tr>
<tr><td colspan="2">ការផ្សារភ្ជាប់ជាយុទ្ធសាស្ត្រ<br>គោលបំណងនេះនឹងគាំទ្រជំហានទី២ តាមរយៈការធានាឱ្យមានទិន្នន័យក្នុងទម្រង់សមស្របដែលអាចវិភាគបាន មានសង្គតិភាព និងសុក្រឹតភាពដែលជាមូលដ្ឋានសម្រាប់គណនេយ្យភាព ។ គោលបំណងនេះ សំដៅបន្តពង្រឹងក្របខ័ណ្ឌចំណាត់ថ្នាក់មាតិកាថវិកា ដែលជាមូលដ្ឋាននៃក្របខ័ណ្ឌថវិកា និងគណនេយ្យដែលជួយដល់ការរៀបចំ និង អនុវត្តគោលនយោបាយ ។ បញ្ហាគន្លឹះបច្ចុប្បន្ននេះគឺធានាការអនុវត្តយ៉ាងពេញលេញនូវចំណាត់ថ្នាក់មាតិកាថវិកា និង ប្លង់គណនេយ្យថ្មីនៅគ្រប់ក្រសួង-ស្ថាប័ន ។ លើសពីនេះទៅទៀត រាជរដ្ឋាភិបាលមានគម្រោងបន្តរៀបចំចំណាត់ថ្នាក់មាតិកាថវិកាដោយពង្រឹងលើផ្នែកចំណាត់ថ្នាក់រដ្ឋបាលនិងមុខងារ ព្រមទាំងបង្កើតជម្រើសសម្រាប់កត់ត្រាថវិកាតាមកម្មវិធី ។ ស្របជាមួយគ្នានេះដែរ ប្លង់គណនេយ្យនឹងត្រូវធ្វើបច្ចុប្បន្នភាពផងដែរ រួមមាន ចំណាត់ថ្នាក់មាតិកាថវិកាថ្មី</td></tr>
</table>

| | |
|---|---|
| ហើយ និងការបញ្ចូលជាបណ្ដើរៗនូវសមាសធាតុដែលមានលក្ខណៈជាគណនេយ្យបង្គរដែលអាចអនុវត្តបាននៅក្នុងរដ្ឋបាលសាធារណៈ ។ ដោយហេតុថាគណនេយ្យបង្គរមានលក្ខណៈស្មុគ្រស្មាញដែលពាក់ព័ន្ធទៅនឹងការរៀបចំថវិកាមានលក្ខណៈជាបង្គរ និងគណនេយ្យបង្គរសម្រាប់ទ្រព្យសម្បត្តិហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិមិនមែនហិរញ្ញវត្ថុ ដូច្នេះការងារនេះគឺជាការងារដែលត្រូវប្រើរយៈពេលវែង ។ | |
| **២៤.** កែលម្អដំណើរការ និងប្រតិបត្តិការអនុវត្តថវិកា<br>• កែលម្អប្រសិទ្ធភាពប្រព័ន្ធបច្ចុប្បន្ន<br>• អនុវត្ត **FMIS** | សមត្ថភាព និងក្របខ័ណ្ឌគ្រប់គ្រងហិរញ្ញវត្ថុ និងថវិកាផ្អែកលើប្រព័ន្ធព័ត៌មានវិទ្យា ដែលបានដាក់ឱ្យអនុវត្តនឹងធ្វើការកែលម្អប្រព័ន្ធរបាយការណ៍ប្រសិទ្ធភាពនៃប្រតិបត្តិការ បូរណភាព ភាពគ្រប់ជ្រុងជ្រោយនៃថវិកា ព្រមទាំងបង្កើតឱ្យមានមូលដ្ឋានត្រួតពិនិត្យប្រកបដោយភាពស័ក្ដិសិទ្ធិ និងសម្រាប់ការពង្រឹងការគ្រប់គ្រងធនធាន ។ |

**ការផ្សារភ្ជាប់ជាយុទ្ធសាស្ត្រ**

គោលបំណងនេះនឹងគាំទ្រជំហានទី២ ដោយការប្រើប្រាស់បច្ចេកវិទ្យាទំនើប និងអភិក្រមផ្សេងៗ ដើម្បីត្រួតពិនិត្យប្រព័ន្ធប្រកបដោយតម្លាភាព សុវត្ថិភាព និងភាពស័ក្ដិសិទ្ធិ ។ គោលបំណងនេះសំដៅ (១) បន្តកិច្ចប្រឹងប្រែងដើម្បីពង្រឹងភាពស័ក្ដិសិទ្ធិនៃដំណើរការប្រតិបត្តិការថវិកា និងប្រព័ន្ធគណនេយ្យបច្ចុប្បន្ននៅក្នុងពេលដែលមានការកែលម្អសមត្ថភាពបច្ចេកវិទ្យាព័ត៌មាន និង (២) អនុវត្តជាបណ្ដើរៗប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុបែបទំនើប ដើម្បីបានជាមូលដ្ឋានធានាចីរភាពនៃប្រសិទ្ធភាពដែលបានកែលម្អ ផ្ដល់នូវព័ត៌មានសម្រាប់ការកែលម្អការរៀបចំផែនការ/ការរៀបចំថវិកា ការពង្រឹងការត្រួតពិនិត្យផ្ទៃក្នុង និង គណនេយ្យភាពហិរញ្ញវត្ថុ ។ កិច្ចការនេះនឹងត្រូវបំពេញតាមរបៀបដូចខាងក្រោម ៖

- ធានាឱ្យមានការយល់ដឹង ភាពជាម្ចាស់ និង ការកសាងសមត្ថភាពនៅគ្រប់កម្រិតរបស់រដ្ឋាភិបាល
- កសាងជាបណ្ដើរៗនូវសមត្ថភាពគ្រប់គ្រងការផ្លាស់ប្ដូរ រួមមានការផ្ដល់ការបណ្ដុះបណ្ដាលផ្នែកព័ត៌មានវិទ្យា និងមន្ត្រីគាំទ្រការអនុវត្តផ្ទាល់
- ធានាឱ្យមានការរៀបចំការគាំទ្រផ្នែកព័ត៌មានវិទ្យាដល់ កសហវ ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងរតនាគារខេត្ត-ក្រុង
- រួមចំណែកធានានិរន្តរភាព

| | |
|---|---|
| **២៥.** កែលម្អប្រព័ន្ធគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុ ដើម្បីធានាតម្លាភាព | ប្រព័ន្ធគណនេយ្យ និងប្រព័ន្ធគ្រប់គ្រងដែលអាចផ្តល់នូវព័ត៌មានប្រកបដោយប្រសិទ្ធភាពក្នុងផ្នែកគ្រប់គ្រងធនធាន និងដែលអាចធ្វើជាមូលដ្ឋានសម្រាប់ពង្រឹងគណនេយ្យភាពនៅក្នុងការប្រើ-ប្រាស់ធនធានសាធារណៈ ត្រូវបានបង្កើត ។ |
| **ការផ្សារភ្ជាប់ជាយុទ្ធសាស្ត្រ**<br>គោលបំណងនេះនឹងគាំទ្រជំហានទី២ ដោយធានាឱ្យមានការទទួលបាននូវព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុទាន់ពេលវេលា និងត្រឹមត្រូវ ហើយព័ត៌មាននេះ ទាំងអ្នកដែលត្រូវមានគណនេយ្យភាព និងអ្នកជំរុញឱ្យមានគណនេយ្យភាពអាចស្វែងរកបានដោយងាយស្រួល ។ គោលបំណងនេះ ត្រូវបានរៀបចំឡើងដើម្បីសម្រេចគោលបំណងគោលនយោបាយនៃការអនុវត្តជាបណ្តើរៗ ក្របខ័ណ្ឌគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុដ៏សមស្រប ដែលមានសង្គតិភាពទៅនឹងស្តង់ដារគណនេយ្យរដ្ឋបាលសាធារណៈដែលទទួលស្គាល់ជាអន្តរជាតិ ហើយដែលក្របខ័ណ្ឌនេះបង្កើតបានជាមូលដ្ឋានសម្រាប់ការធ្វើរបាយ-ការណ៍ហិរញ្ញវត្ថុដោយទៀងទាត់ និងមានតម្លាភាពដោយរដ្ឋាភិបាល និងក្រសួង-ស្ថាប័នពាក់ព័ន្ធ ។ ក្របខ័ណ្ឌនេះនឹងជួយដល់អ្នកគ្រប់គ្រងដើម្បីផ្តល់របាយការណ៍គណនេយ្យភាពហិរញ្ញវត្ថុដល់រដ្ឋាភិបាល ហើយនឹងជួយផងដែរដល់រដ្ឋាភិបាល ដើម្បីផ្តល់របាយការណ៍ដល់ស្ថាប័ននីតិបញ្ញត្តិ/អ្នកជាប់ពន្ធ/ប្រជាពលរដ្ឋ ហើយនៅពេលដែលចាំបាច់ អាចផ្តល់របាយការណ៍ហិរញ្ញវត្ថុដល់ភ្នាក់ងារខាងក្រៅដទៃទៀត ដែលរួមមានដៃគូអភិវឌ្ឍន៍ ។ ការអនុវត្តក្របខ័ណ្ឌខាងលើនេះ នឹងជួយសម្រួលផងដែរដល់ការចាប់ផ្តើម គណនេយ្យបង្គរនៅពេលសមស្រប និងដែលអាចធ្វើទៅបាន ។ | |
| **២៦.**កែលម្អសវនកម្ម និងអធិការកិច្ច ព្រមទាំងឆ្លើយតប និងប្រើប្រាស់លទ្ធផលនៃរបាយការណ៍សវនកម្ម និងអធិការកិច្ច<br>• ការរៀបចំផែនការសវនកម្មផ្ទៃក្នុង<br>• ការរៀបចំវិធីសាស្ត្រសវនកម្មផ្ទៃក្នុង និងប្រព័ន្ធរបាយការណ៍ ដោយមានការប្រើប្រាស់ព័ត៌មានវិទ្យា<br>• ការអភិវឌ្ឍសមត្ថភាពសវនកម្មផ្ទៃក្នុង | បានដាក់ឱ្យដំណើរការកម្រងនីតិវិធីសវនកម្ម ដែលអាចកំណត់ និងផ្តល់យោបល់ដល់អ្នកគ្រប់គ្រងអំពីភាពចាំបាច់ដែលត្រូវដោះស្រាយ ចំពោះភាពទន់ខ្សោយក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ និងក៏អាចបង្ហាញឱ្យឃើញផងដែរនូវសកម្មភាពកេងបន្លំ ឬ អំពើខុសឆ្គង និងភាពមិនដំណើរការនៅក្នុងប្រព័ន្ធត្រួតពិនិត្យ ។ |

<table>
<tr><td colspan="2">ការផ្សារភ្ជាប់ជាយុទ្ធសាស្ត្រ<br>គោលបំណងនេះនឹងគាំទ្រជំហានទី២ ដោយខិតខំដាក់ឱ្យអនុវត្តនូវការរៀបចំសវនកម្ម និង ការត្រួតពិនិត្យដើម្បីឱ្យអ្នកដែលត្រូវមានគណនេយ្យភាពអាចទទួលបានយោបល់អំពីបញ្ហានៅក្នុងប្រព័ន្ធ ហើយក៏នឹងអាចគ្រប់គ្រងកិច្ចការក្នុងស្មារតីថា ប្រសិនបើពួកគេប្រព្រឹត្តមិនគប្បី ឬនៅតែបន្តឱ្យមានភាពទន់ខ្សោយកើតមាន នោះបញ្ហាទាំងនេះនឹងត្រូវបានរកឃើញ ។ គោលបំណងនេះនឹងខិតខំពង្រឹងឱ្យមានការពង្រីកវិសាលភាព និងសមត្ថភាពសវនកម្មផ្ទៃក្នុងនៅតាមក្រសួង-ស្ថាប័នពាក់ព័ន្ធ ។ រាជរដ្ឋាភិបាលនឹងស្នើឱ្យមានទំនើបភាវូបនីយកម្មនៃវិធីសាស្ត្រ របាយការណ៍ និង សមត្ថភាពផ្នែកសវនកម្មផ្ទៃក្នុង ។ រាជរដ្ឋាភិបាលក៏នឹងគាំទ្រផងដែរឱ្យមានអន្តរកម្ម និងកិច្ចសម្របសម្រួលកាន់តែជិតស្និទ្ធជាមួយនឹងអាជ្ញាធរសវនកម្មជាតិ ។</td></tr>
<tr><td>២៧. ពង្រឹង និង រៀបចំគោលនយោបាយ និង យុទ្ធសាស្ត្រវិមជ្ឈការហិរញ្ញវត្ថុ</td><td>បង្កើតកម្លាំងចលករ និង ជំហានបឋមដើម្បីឆ្ពោះទៅការពង្រីកវិមជ្ឈការក្នុងការផ្តល់សេវាសាធា-រណៈ ។</td></tr>
<tr><td colspan="2">ការផ្សារភ្ជាប់ជាយុទ្ធសាស្ត្រ<br>គោលបំណងនេះនឹងគាំទ្រជំហានទី២ ដើម្បីធានាថាគណនេយ្យភាពនឹងត្រូវបានយកចិត្តទុកដាក់នៅក្នុងក្របខ័ណ្ឌនៃការអនុវត្តយុទ្ធសាស្ត្រវិមជ្ឈការរបស់រាជរដ្ឋាភិបាល និងច្បាប់ស្តីពីការគ្រប់គ្រងរាជធានី ខេត្ត ក្រុង និងស្រុក ខណ្ឌ ។ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នឹងផ្តោតលើការគាំទ្រសកម្មភាពទាំងឡាយដែលទាមទារឱ្យមានការចូលរួមរបស់ កសហវ ។ ការគាំទ្រនេះរួមមាន ៖ (១) ការកែលម្អផ្នែកយុទ្ធសាស្ត្រ ប្រព័ន្ធរៀបចំបុគ្គលិក និង សមត្ថភាពក្នុងពេលបច្ចុប្បន្នក្រោមក្របខ័ណ្ឌវិសហមជ្ឈការដែលកំពុងអនុវត្ត (២) ដោះស្រាយបញ្ហាទាក់ទងទៅនឹងការផ្ទេរមូលនិធិ និងសមត្ថកិច្ចរវាងថ្នាក់រដ្ឋបាលផ្សេងៗ គោលការណ៍ និងបទដ្ឋានក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការរៀបចំរបាយការណ៍ និងការកសាងសមត្ថភាពក្នុងថ្នាក់រដ្ឋបាលផ្សេងៗ ក្រោមក្របខ័ណ្ឌវិមជ្ឈការថ្មីដែលបានគូសបញ្ជាក់នៅក្នុងច្បាប់រៀបចំអង្គការ និង (៣) កសាងសមត្ថភាពរបស់នាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃ កសហវ ដើម្បីត្រួតពិនិត្យតាមដាន ។</td></tr>
<tr><td>២៨. ការកសាងសមត្ថភាពស្ថាប័ន និង វិធានការលើកទឹកចិត្ត</td><td>ការបង្កើនភាពជឿទុកចិត្តសម្រាប់ការគ្រប់គ្រង នៅក្នុងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលត្រូវបានកែលម្អ ត្រូវបានអនុវត្តដោយផ្អែកលើការផ្តល់ជំនាញសមស្រប និងការលើកទឹកចិត្តដល់មន្ត្រីរាជការដើម្បីទទួលយកជំនាញទាំងនោះ ។</td></tr>
</table>

**ការផ្សារភ្ជាប់ជាយុទ្ធសាស្ត្រ**

គោលបំណងនេះនឹងគាំទ្រជំហានទី២ ដោយខិតខំផ្សារភ្ជាប់ការអភិវឌ្ឍបច្ចេកទេសដែលត្រូវបានគ្រោងនៅក្នុងកម្មវិធីកំណែទម្រង់ទាំងមូល ជាមួយនឹងសមត្ថភាពចាំបាច់នៅក្នុងការអនុវត្ត និង ការគ្រប់គ្រងប្រព័ន្ធដែលត្រូវកែទម្រង់ជាបណ្តើរៗ ។ គោលបំណងនេះ សំដៅដោះស្រាយកង្វះខាតផ្នែកសមត្ថភាពដែលជាមូលហេតុនាំឱ្យការអនុវត្តការទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុមានភាពទន់ខ្សោយ ។ ផែនការកសាងសមត្ថភាពបឋមដែលត្រូវបានអនុម័តដោយគណៈកម្មាធិការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុនៃកសហវ បង្ហាញអំពីជំនាញសមត្ថភាពស្ថាប័ន និងផ្នែកការលើកទឹកចិត្ត ។ ផែនការនេះត្រូវបានធ្វើការពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពប្រចាំឆ្នាំ ។ ផែនការនេះខិតខំផងដែរដើម្បីដោះស្រាយតម្រូវការរបស់ កសហវ នៅក្នុងការបង្កើនសមត្ថភាពធនធានមនុស្ស និងអង្គភាពបណ្តុះបណ្តាលដែលគាំទ្រដល់ការកសាងសមត្ថភាពនៅក្នុង កសហវ ទាំងមូល ។ អាទិភាពនៃកម្មវិធីនៅក្នុងដំណាក់កាលទី២ រួមមាន ៖

- បន្តអភិវឌ្ឍសមត្ថភាពវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងនាយកដ្ឋានបុគ្គលិកក្នុងការរៀបចំផែនការកសាងសមត្ថភាពដូចជាការជ្រើសរើសទីប្រឹក្សាផ្តល់យោបល់ ។
- ផ្តល់នូវវគ្គបណ្តុះបណ្តាលដែលបានកំណត់នៅក្នុងផែនការកសាងសមត្ថភាពដែលមានលក្ខណៈសមស្របសម្រាប់ដំណាក់កាលទី២ ទន្ទឹមនឹងការដកបទពិសោធន៍ពីការប្រើប្រាស់ប្រភពផ្សេងៗនៅក្នុងការផ្តល់សេវាបណ្តុះបណ្តាល
- ចាប់ផ្តើមអនុវត្តតាមទិដ្ឋភាពគ្រប់គ្រងធនធានមនុស្ស និងស្ថាប័ននៃផែនការកសាងសមត្ថភាពក្នុងរបៀបដែលមានជារចនាសម្ព័ន្ធកាន់តែរឹងមាំ ដូចដែលបានកំណត់នៅក្នុងផែនការកសាងសមត្ថភាព
- ចាប់ផ្តើមជួយសម្រួលឱ្យមានការរៀបចំផែនការកសាងសមត្ថភាពរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងរៀបចំដំណើរការត្រួតពិនិត្យផែនការទាំងនោះឡើងវិញ

**៤.៨** គោលបំណងទាំងអស់ខាងលើនេះ ត្រូវបានសម្រិតសម្រាំងដើម្បីបង្ហាញឱ្យឃើញនូវតុល្យភាពដ៏សមស្របរវាងសមាសធាតុទាំងឡាយនៃគោលដៅរួមជំហានទី២ ដែលតម្រូវឱ្យមានការកែលម្អគណនេយ្យភាព និងការរៀបចំដោយប្រុងប្រយ័ត្នក្នុងការបង្កើនការផ្តល់សិទ្ធិអំណាចដែលគាំទ្រដោយលំហូរព័ត៌មានដ៏ប្រសើរ និងមានតម្លាភាព ។

៤.៩ សកម្មភាពការងារដែលត្រូវបន្តដើម្បីពង្រឹងសមិទ្ធផលជំហានទី១ ៖

- បន្តកែលម្អគោលនយោបាយ និង ការគ្រប់គ្រងចំណូល
- បន្តកែលម្អការគ្រប់គ្រងចំណាយ
- បន្តកែលម្អការគ្រប់គ្រងសាច់ប្រាក់ និង ការគ្រប់គ្រងគណនីធនាគារ
- បន្តកែលម្អលទ្ធកម្មសាធារណៈ

**៤.១០** វឌ្ឍនភាពដ៏ល្អត្រូវបានសម្រេចនៅក្នុងគ្រប់ផ្នែកនៃសកម្មភាពការងារជំហានទី១ ប៉ុន្តែវឌ្ឍនភាពនេះចាំបាច់ត្រូវបន្តពង្រឹង និងអនុវត្តឱ្យកាន់តែស៊ីជម្រៅបន្ថែមទៀត ។ ការត្រួតពិនិត្យតាមដានសមិទ្ធផលជំហានទី១ នឹងត្រូវបន្តអនុវត្តដើម្បីធានាថាសមិទ្ធផលទាំងនោះមានចីរភាព និងត្រូវបានធ្វើឱ្យកាន់តែប្រសើរឡើង ។

**៤.១១** សកម្មភាពការងារត្រៀមលក្ខណៈសម្រាប់ជំហានបន្ទាប់ ផ្តោតលើ ៖

- ការកែលម្អ និង ការពង្រីកការអនុវត្តថវិកាតាមកម្មវិធី
- បន្តកែលម្អភាពគ្រប់ជ្រុងជ្រោយ និងសមាហរណកម្មថវិកា

**៤.១២** សកម្មភាពការងារបន្ត និងសាកល្បងនៅក្នុងផ្នែកទាំងឡាយខាងលើនេះ នឹងបង្កើតជាមូលដ្ឋានសម្រាប់ជំហានបន្ទាប់ដោយផ្អែកលើការផ្សារភ្ជាប់ធនធានទាំងអស់ដែលត្រូវប្រើប្រាស់ ទៅនឹងក្របខ័ណ្ឌកម្មវិធីដើម្បីសម្រេចបាននូវគោលដៅជាក់លាក់ ។

**៤.១៣** សកម្មភាពទាំងឡាយដែលបានស្នើឡើង ដើម្បីសម្រេចបានគោលបំណងទាំងអស់នេះ ត្រូវបានកំណត់នៅក្នុងផែនការសកម្មភាពរួម និងផែនការការងារគាំទ្រ ។

## សមិទ្ធផលរំពឹងទុកក្នុងការអនុវត្តផែនការសកម្មភាពជំហានទី២/ ដំណាក់កាលទី២

**៤.១៤** ការអនុវត្តជំហានទី២ ដូចដែលគ្រោងទុកនឹងជួយឱ្យបង្កើតបានបរិយាកាសនៃការទទួលខុសត្រូវសម្រាប់ការគ្រប់គ្រងធនធានសាធារណៈក្នុងរដ្ឋបាលនៅគ្រប់កម្រិត ។ ភាពខ្លាំង និងភាពខ្សោយនៃការគ្រប់គ្រងធនធានទាំងនេះនឹងត្រូវបានមើលឃើញ និង ញែកដាច់ពីគ្នា ។

**៤.១៥** ជាលទ្ធផលនៃដំណើរការផ្លាស់ប្តូរនេះ មូលដ្ឋានគ្រឹះនឹងត្រូវបានរៀបចំឡើង សម្រាប់កំណែទម្រង់នៅជំហានក្រោយៗទៀត ដែលរួមមានដូចខាងក្រោម ៖

| |
|---|
| កសាងចេញពីជំហានបឋម ដើម្បីឈានទៅការបង្កើនសិទ្ធិអំណាចដល់អ្នកគ្រប់គ្រងអង្គភាពថវិកាដើម្បីសម្រេចបានលទ្ធផលប្រសើរជាងមុន **ដោយហេតុថា** ការផ្តល់សិទ្ធអំណាច និងបទពិសោធន៍ទាំងឡាយនឹងទទួលបានពីក្របខ័ណ្ឌត្រួតពិនិត្យដែលនឹងត្រូវធ្វើការកែលម្អ ។ |

| |
|---|
| ខិតខំប្រឹងប្រែងដើម្បីសម្រេចឱ្យបាននូវប្រសិទ្ធភាពនៃការបែងចែកចំណាយ និងភាពត្រឹមត្រូវនៃចំណាយដែលមានជាបន្ត **ដោយហេតុថា** មូលដ្ឋានសម្រាប់អនុញ្ញាតឱ្យអ្នកគ្រប់គ្រងអង្គភាពថវិកាក្នុងការពិនិត្យមើលបញ្ហាទាំងអស់នោះ នឹងត្រូវបានកែលម្អដោយផ្អែកលើការធ្វើឱ្យប្រសើរឡើងនូវលំហូរព័ត៌មាន និងការអាចមើលឃើញនូវអ្វីដែលកំពុងតែកើតមានចំពោះធនធាននៅក្នុងការអនុវត្តជាក់ស្តែង ។ |
| ចាប់ផ្តើមកំណត់អំពីទំនាក់ទំនងរវាងការអនុវត្តគោលនយោបាយ និងការកែលម្អការផ្តល់សេវាសាធារណៈជាមួយនឹងតម្រូវការធនធានសម្រាប់ធ្វើការកែលម្អ **ដោយហេតុថា**មូលដ្ឋាននៃព័ត៌មាន និងការវិភាគលើរបៀបនៃការប្រើប្រាស់ធនធាននឹងត្រូវដាក់ឱ្យដំណើរការ ។ |
| ឈានទៅរកគណនេយ្យភាពសម្រាប់ការគ្រប់គ្រងលទ្ធផល **ដោយហេតុថា** ការកែលម្អគណនេយ្យភាពសម្រាប់ការគ្រប់គ្រងធនធានអាចនឹងគួរឱ្យជឿជាក់បាន ។ |

## ផែនការសកម្មភាពសម្រាប់ជំហានបន្ទាប់ដែលត្រូវចាប់ផ្ដើមជាបណ្ដើរៗ

**៤.១៦** សកម្មភាពការងារបន្ត និងសាកល្បងនៅក្នុងផ្នែកកែលម្អ និងការពង្រឹកការអនុវត្តថវិកាតាមកម្មវិធី និងការកែលម្អភាពគ្រប់ជ្រុងជ្រោយ និងសមាហរណកម្មថវិកានឹងបង្កើតជាមូលដ្ឋានសម្រាប់ជំហានបន្ទាប់ដោយផ្អែកលើការផ្សារភ្ជាប់ធនធានទាំងអស់ ដែលត្រូវប្រើប្រាស់ទៅនឹងក្របខ័ណ្ឌកម្មវិធីដើម្បីសម្រេចបាននូវគោលដៅជាក់លាក់ ។

សកម្មភាពការងារសម្រាប់ជំហានបន្ទាប់នៅក្នុងដំណាក់កាលទី២ នឹងផ្ដោតជាសំខាន់លើ ៖

| តារាងទី ៥ ៖ គោលបំណងជំហានបន្ទាប់ | |
|---|---|
| **គោលបំណងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** | **សូចនាករគន្លឹះ** |
| **៣១.** ការកែលម្អ និង ការពង្រឹកការអនុវត្តថវិកាតាមកម្មវិធី | សមត្ថភាព និងវិធីអនុវត្តថវិកាតាមកម្មវិធីនៅ កសហវ និង ក្រសួង-ស្ថាប័នពាក់ព័ន្ធត្រូវបានពង្រឹង |
| **ការផ្សារភ្ជាប់ជាយុទ្ធសាស្ត្រ**<br>គោលបំណងនេះសំដៅរៀបចំឱ្យ កសហវ និងក្រសួង-ស្ថាប័នពាក់ព័ន្ធប្រកាន់យកជាបណ្ដើរៗនូវវិធី-សាស្ត្ររៀបចំថវិកាផ្អែកលើលទ្ធផល ។ គោលបំណងនេះនឹងរួមចំណែកផងដែរដល់ការកែលម្អចំណាត់ថ្នាក់ថវិកា វិធីសាស្ត្ររៀបចំថវិកា និងវិភាជន៍ធនធានកាន់តែមានប្រសិទ្ធភាពនៅក្នុងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ។ | |
| **៣២.** បន្តកែលម្អភាពគ្រប់ជ្រុងជ្រោយ និង សមាហរណកម្មថវិកា | ក្របខ័ណ្ឌពហុឆ្នាំដែលមានការធ្វើសមាហរណកម្មថវិកាត្រូវបានអនុវត្តជាបណ្ដើរៗ |
| **ការផ្សារភ្ជាប់ជាយុទ្ធសាស្ត្រ**<br>វឌ្ឍនភាពដ៏ល្អប្រសើរនៅក្នុងដំណាក់កាលទី១ គឺបានធ្វើការកែលម្អដំណើរការរៀបចំថវិកា និងជាលទ្ធផលនាំឱ្យមានការកែលម្អភាពគ្រប់ជ្រុងជ្រោយ និងកម្រិតនៃសមាហរណកម្មថវិកា ។ ទោះជាយ៉ាងណា ក៏នៅមានបញ្ហាមួយចំនួនទៀតដែលទាក់ទងនឹងការរៀបចំឱ្យមានទំនាក់ទំនងល្អរវាងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមជាមួយនឹងថវិកាប្រចាំឆ្នាំ និងកម្មវិធីវិនិយោគសាធារណៈ ។ បច្ចុប្បន្ន ស្ថាប័នដែលពាក់ព័ន្ធនឹងចំណាយវិនិយោគសាធារណៈ មានដូចជាក្រសួងផែនការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា/គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា (CDC/CRDB) វេទិកាសម្រាប់សហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា (CDCF) ក្រសួង-ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងអង្គការក្រៅរដ្ឋា ភិបាល ។ គោលបំណងនេះ នឹងសំដៅសម្រេចឱ្យបានភាពច្បាស់លាស់ និងសនិទានកម្មដើម្បីគាំទ្រប្រសិទ្ធភាព និងភាពស័ក្ដិសិទ្ធិឱ្យកាន់តែប្រសើរឡើង ។ | |

**៤.១៧** សកម្មភាពដែលបានស្នើឡើងដើម្បីសម្រេចគោលបំណងខាងលើទាំងនេះ ត្រូវបានកំណត់នៅក្នុងផែនការសកម្មភាពរួម និង ផែនការសកម្មការងារលម្អិត ។

**៤.១៨** ការកែលម្អគណនេយ្យភាពហិរញ្ញវត្ថុ គឺជាជំហានដ៏សំខាន់ដើម្បីសម្រេចបាននូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមួយដែលឆ្លើយតបនឹងចក្ខុវិស័យរួមនៃការផ្តល់នូវសេវា និងការអនុវត្តគោលនយោបាយប្រកបដោយប្រសិទ្ធភាព។ គោលដៅនៃការផ្សារភ្ជាប់រវាងការប្រើប្រាស់ធនធានជាមួយនឹងកម្មវិធី គឺដើម្បីសម្រេចបានគោលដៅគោលនយោបាយ ហើយគោលដៅនោះ នឹងមិនអាចសម្រេចបានទេប្រសិនបើគណនេយ្យភាពហិរញ្ញវត្ថុមិនត្រូវបានកែលម្អ ។

## ៥. ក្របខ័ណ្ឌគ្រប់គ្រងកម្មវិធី

***យន្តការដែលបានស្នើឡើងសម្រាប់អនុវត្ត និងតាមដានវឌ្ឍនភាពនៅជំហានទី២/ ដំណាក់កាលទី២***

ការអនុវត្តផែនការសកម្មភាពជំហានទី១ បានផ្តល់បទពិសោធន៍មានតម្លៃជាច្រើនអំពីដំណើរការគ្រប់គ្រង និងសម្របសម្រួលលើការងារកំណែទម្រង់ ។ យន្តការទាំងឡាយត្រូវតែមានលក្ខណៈរស់រវើក និងជាក់ស្តែងដើម្បីឱ្យសកម្មភាពការងារដ៏ស្មុគ្រស្មាញក្នុងកម្មវិធីកំណែទម្រង់អាចដំណើរការទៅបានដោយរលូន ។ តាមរយៈបទពិសោធន៍កន្លងមក យន្តការគន្លឹះសម្រាប់អនុវត្តជំហានទី២/ដំណាក់កាលទី២ ត្រូវបានរៀបចំដូចខាងក្រោម និងមានលម្អិតច្រើនថែមទៀតនៅក្នុងឧបសម្ព័ន្ធទាំងឡាយនៃឯកសារនេះ ។

| | |
|---|---|
| **ផែនការសកម្មភាពរួម** | ជំហានទី២/ដំណាក់កាលទី២<br>• គោលបំណង<br>• សកម្មភាព<br>• ការវាយតម្លៃសមិទ្ធកម្ម |
| | ព័ត៌មានលម្អិតមាននៅក្នុងឧបសម្ព័ន្ធទី១ |
| **យន្តការដឹកនាំ និង សម្របសម្រួល** | ការដឹកនាំកម្រិតខ្ពស់ថ្នាក់រដ្ឋាភិបាល<br>ការសម្របសម្រួលកម្រិតរដ្ឋបាល<br>ការគ្រប់គ្រងការងារដែលប្រទាក់ក្រឡាគ្នា |
| | ព័ត៌មានលម្អិតមាននៅក្នុងឧបសម្ព័ន្ធទី២ |
| **យន្តការសម្រាប់ការចូលរួមរបស់ក្រសួង-ស្ថាប័ន** | ក្រុមការងារកំណែទម្រង់នៅតាមក្រសួង-ស្ថាប័ន<br>ផែនការសកម្មភាពរបស់ក្រសួង-ស្ថាប័ន ត្រូវស្របគ្នាទៅនឹងផែនការសកម្មភាពរួម |
| | ព័ត៌មានលម្អិតមាននៅក្នុងឧបសម្ព័ន្ធទី៣ |
| **ការប្រើប្រាស់ទីប្រឹក្សាបច្ចេកទេស** | ការជ្រើសរើសទីប្រឹក្សាបច្ចេកទេសស្នូល<br>ការជ្រើសរើសអ្នកជំនាញឯកទេស<br>ការផ្តល់ប្រឹក្សាបច្ចេកទេសដល់ក្រសួង-ស្ថាប័ន |
| | ព័ត៌មានលម្អិតមាននៅក្នុងឧបសម្ព័ន្ធទី៤ |

| | |
|---|---|
| **យុទ្ធសាស្ត្រសម្រាប់អនុវត្ត**<br>• **ការកសាងសមត្ថភាព ការអភិវឌ្ឍស្ថាប័ន និងការលើកទឹកចិត្ត**<br>• **ឯកសារគោលនយោបាយប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ** (FMIS) | រៀបចំផែនការកសាងសមត្ថភាព និងការអនុវត្តផែនការ<br>រៀបចំផែនការក្រសួង-ស្ថាប័ននិងពិនិត្យមើលឡើងវិញ<br>ឯកសារគោលនយោបាយ FMIS |
| | ព័ត៌មានលម្អិតមាននៅក្នុងឧបសម្ព័ន្ធទី ៥.១, ៥.២ និង ៥.៣ |
| **តម្រូវការធនធានដើម្បីគាំទ្រកម្មវិធី** | កំណត់ចំណាយសម្រាប់សកម្មភាពរួមជំហានទី២/ ដំណាក់កាលទី២<br>ចំណាយលម្អិត និងផែនការលទ្ធកម្មឆ្នាំ ២០០៨ |
| | ព័ត៌មានលម្អិតមាននៅក្នុងឧបសម្ព័ន្ធទី៦ |
| **យន្តការពិនិត្យតាមដាន** | ការរៀបចំផ្ទៃក្នុងសម្រាប់រាជរដ្ឋាភិបាល<br>សូចនាករសម្រាប់វាយតម្លៃសមិទ្ធផលកម្រិតខ្ពស់<br>សូចនាករសម្រាប់វាយតម្លៃសមិទ្ធកម្មកម្រិតសកម្មភាពដែលស្របតាមគណនេយ្យភាពហិរញ្ញវត្ថុនិងចំណាយសាធារណៈ (PEFA) |
| | ព័ត៌មានលម្អិតមាននៅក្នុងឧបសម្ព័ន្ធទី ៧ |
| **យន្តការដើម្បីធានាភាពស៊ីសង្វាក់ជាមួយកំណែទម្រង់ដទៃទៀត** | កំណែទម្រង់លើវិស័យផ្សេងទៀតដែលទាក់ទិនគ្នា និងយន្តការទំនាក់ទំនងរវាងកំណែទម្រង់នីមួយៗ |
| | ព័ត៌មានលម្អិតមាននៅក្នុងឧបសម្ព័ន្ធទី ៨ |
| **ការចូលរួមរបស់ដៃគូអភិវឌ្ឍន៍** | ការផ្តល់របាយការណ៍ និង ការពិភាក្សា<br>ការផ្តល់មូលនិធិ |
| | ព័ត៌មានលម្អិតមាននៅក្នុងឧបសម្ព័ន្ធទី ៩ |
| **ការគ្រប់គ្រងហានិភ័យ** | ហានិភ័យដែលអាចមាននៅពេលកម្មវិធីកំណែទម្រង់ឈានទៅជំហានទី២/ ដំណាក់កាលទី២<br>ការវាយតម្លៃលើហានិភ័យ និង វិធានការដើម្បីកាត់បន្ថយ និងគ្រប់គ្រងហានិភ័យ |
| | ព័ត៌មានលម្អិតមាននៅក្នុងឧបសម្ព័ន្ធទី ១០ |

## ៦- ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី ១ ផែនការសកម្មភាពរួម

ឧបសម្ព័ន្ធទី ២ យន្តការដឹកនាំ និងសម្របសម្រួល

ឧបសម្ព័ន្ធទី ៣ យន្តការសម្រាប់ការចូលរួមរបស់ក្រសួង-ស្ថាប័ន

ឧបសម្ព័ន្ធទី ៤ ការកែលម្អការប្រើប្រាស់ទីប្រឹក្សាបច្ចេកទេសក្នុងដំណាក់កាលទី ២

ឧបសម្ព័ន្ធទី ៥ យុទ្ធសាស្ត្រសម្រាប់ការអនុវត្ត

៥-១ ការអភិវឌ្ឍសមត្ថភាពដើម្បីគាំទ្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

៥.២ ផែនការកសាងសមត្ថភាពក្រសួង-ស្ថាប័ន

៥.៣ គោលនយោបាយប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ

ឧបសម្ព័ន្ធទី ៦ តម្រូវការធនធានដើម្បីគាំទ្រកម្មវិធីដំណាក់កាលទី២

ឧបសម្ព័ន្ធទី ៧ យន្តការពិនិត្យតាមដាន

ឧបសម្ព័ន្ធទី ៨ យន្តការដើម្បីធានាភាពស៊ីសង្វាក់ជាមួយកំណែទម្រង់ដទៃទៀត

ឧបសម្ព័ន្ធទី ៩ ការចូលរួមរបស់ដៃគូអភិវឌ្ឍន៍

ឧបសម្ព័ន្ធទី ១០ ការគ្រប់គ្រងហានិភ័យ

# ឧបសម្ព័ន្ធទី១

# ផែនការសកម្មភាពរួមដំណាក់កាលទី ២

# ផែនការសកម្មភាពរួមសម្រាប់ដំណាក់កាលទី២ (CAP2)

ផ្នែកទី១. ផែនការសកម្មភាពជំហានទី១ ដែលត្រូវបន្តពង្រឹងនៅក្នុងដំណាក់កាលទី២

ផ្នែកទី២. ផែនការសកម្មភាពជំហានទី ២ ដែលត្រូវអនុវត្តនៅក្នុងដំណាក់កាលទី២

ផ្នែកទី៣. ផែនការសកម្មភាពសម្រាប់បណ្តាជំហានបន្ទាប់ដែលត្រូវចាប់ផ្តើមជាបណ្តើរៗ

# ផ្នែកទី ១

# ផែនការសកម្មភាពជំហានទី ១ ដែលត្រូវបន្តពង្រឹងនៅក្នុងដំណាក់កាលទី ២

| គោលបំណង/សកម្មភាព | ពេលវេលា (ត្រីមាស) | | | | | | | | | | | | ក្រសួង-ស្ថាប័ន/អង្គភាព | សូចនាករគន្លឹះ | គោលដៅ | | | តម្រូវការធនធាន |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2008 | | | | 2009 | | | | 2010 | | | | | | 2008 | 2009 | 2010 | |
| | 1 | 2 | 3 | 4 | 1 | 2 | 3 | 4 | 1 | 2 | 3 | 4 | | | | | | |
| **គោលបំណងទី ១១ ៖ បន្តកែលម្អរដ្ឋបាល និង គោលនយោបាយចំណូល** | | | | | | | | | | | | | | | | | | |
| ១១.១. កែសម្រួល និង អនុវត្ត គោលនយោបាយចំណូលរយៈពេលមធ្យម | X | X | X | X | X | X | X | X | X | X | X | X | ក្រសួង-ស្ថាប័ន ក្រុមចំណូល, ក្រុមគោលនយោបាយ/គយ និង រដ្ឋាករ, ពន្ធដារ, ចំណូលមិនមែនសារពើពន្ធ, ទ្រព្យសម្បត្តិរដ្ឋ, ឧស្សាហកម្មហិរញ្ញវត្ថុ, គោលនយោបាយ | ចំណូលសរុបជា % នៃ ផ.ស.ស<br><br>ចំណូលក្នុងស្រុកស្មើ ឬ លើសពី ៩៧% នៃការព្យាករណ៍ (សូចនាករ PEFA ៣, ១៣-១៥)<br><br>របប | ១២% នៃ ផសស<br><br>ស្មើឬលើស ៩៧%<br><br>របបសារពើពន្ធត្រូវបានកំណត់ | ១២.៥% នៃ ផសស<br><br>ស្មើឬលើស ៩៧%<br><br>EITI ត្រូវបានអនុវត្តជាបឋម | ១៣% នៃ ផសស<br><br>ស្មើឬលើស ៩៧%<br><br>អនុវត្ត EITI | MDTF/ IDA/ PSD /TF |

| | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ១១.២.បង្កើត និង អនុវត្ត គោលនយោបាយចំណូលពីប្រេង/ឧស្ម័ន/រ៉ែ ។ បង្កើត និង អនុវត្តយន្តការគ្រប់គ្រងប្រកបដោយតម្លាភាពលើលំហូរចំណូលដោយរួមទាំង EITI ការវាយតម្លៃ និង សមត្ថភាពប្រមូលចំណូល | X | X | X | X | X | X | X | X | X | X | X | X | ក្រុមចំណូល | សារពើពន្ធលើប្រេង/ ឧស្ម័ន/រ៉ែ ត្រូវបានកំណត់ និង ក្របខ័ណ្ឌច្បាប់ ត្រូវបាន អនុម័ត និងចាប់ផ្តើមអនុវត្ត (សូចនាករ PEFA ៩) | ការសិក្សាពី EITI ត្រូវបាន បញ្ចប់<br>ជម្រើសគោលនយោបាយ គ្រប់គ្រង ចំណូលប្រេង/ ឧស្ម័ន/រ៉ែ ត្រូវបានរៀបចំ និង ឯកភាព | ក្របខ័ណ្ឌ គ្រប់គ្រង ចំណូលប្រេង/ ឧស្ម័ន/រ៉ែ ត្រូវបាន បង្កើត | អនុវត្តក្របខ័ណ្ឌច្បាប់ សម្រាប់ គ្រប់គ្រង ចំណូល ប្រេង/ ឧស្ម័ន/រ៉ែ | |
| ១១.៣. បន្តកែលម្អរដ្ឋបាល និង គោលនយោបាយពន្ធ គយ ( រួមទាំងវិធានការ កែលម្អការ | X | X | X | X | X | X | X | X | X | X | X | X | ក្រុមចំណូល, ក្រុមគោលនយោបាយ /គយ | | | | | |

| | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ផ្តល់ព័ត៌មាន និង តម្លាភាពដល់អ្នកជាប់ពន្ធ និងអ្នកបង់កម្រៃសេវា ) | | | | | | | | | | | | | និង រដ្ឋាករ, អាស៊ាន | | | | | |
| ១១.៤. បន្តកែលម្អរដ្ឋបាល និងគោលនយោបាយពន្ធដារ | X | X | X | X | X | X | X | X | X | X | X | X | ក្រុមចំណូល/ ពន្ធដារ, ឧស្សាហកម្ម ហិរញ្ញវត្ថុ | | | | | |
| ១១.៥. បន្តកែលម្អគោលនយោបាយ និងរដ្ឋបាលចំណូលមិនមែនសារពើពន្ធ រួមទាំងទ្រព្យសម្បត្តិរដ្ឋ | X | X | X | X | X | X | X | X | X | X | X | X | ក្រុមចំណូល/ ចំណូលមិនមែនសារពើពន្ធ, ទ្រព្យសម្បត្តិរដ្ឋ | | | | | |
| ១១.៦. ពង្រឹងការព្យាករណ៍ម៉ាក្រូសេដ្ឋកិច្ច និង ការព្យាករណ៍ចំណូល | | X | X | X | X | X | X | X | X | X | X | X | ក្រុមគោលនយោបាយ, ក្រុមចំណូល/ គោលនយោបាយគយនិងរដ្ឋាករ, ពន្ធដារ, ចំណូលមិន មែនសារពើពន្ធ, | ភាពប្រាកដនិយមនៃការព្យាករណ៍ ធនធានត្រូវបានកែលម្អ និងប្រើប្រាស់សម្រាប់ធ្វើផែនការចំណូល | បង្កើតម៉ូដែលសាមញ្ញសម្រាប់ព្យាករណ៍ចំណូល<br><br>កម្រិតលំអៀងនៃការព្យាករណ៍ចំណូលក្នុងរយៈ | កែលម្អម៉ូដែលសម្រាប់ព្យាករណ៍ចំណូល<br><br>កម្រិតលំអៀងនៃការព្យាករណ៍ | កែលម្អម៉ូដែលសម្រាប់ព្យាករណ៍ចំណូល កម្រិតលំអៀងនៃការ | |

| | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | | | | ទ្រព្យសម្បត្តិរដ្ឋ,<br>ឧស្សាហកម្ម<br>ហិរញ្ញវត្ថុ | - ម៉ូដែល<br>ព្យាករណ៍<br>ចំណូល<br>-លទ្ធផល<br>ប្រមូលចំណូល | ពេល ០៣ ឆ្នាំ<br>ធៀបនឹង<br>ការអនុវត្ត<br>+ ឬ - ១០% | ចំណូលក្នុង<br>រយៈពេល ០៣<br>ឆ្នាំ ធៀប នឹង<br>ការអនុវត្ត<br>+ ឬ - ៨% | ព្យាករណ៍<br>ចំណូល<br>ក្នុងរយៈ<br>ពេល០៣ឆ្នាំ<br>ធៀបនឹង<br>ការអនុវត្ត<br>+ ឬ -៥% | |

| គោលបំណង/សកម្មភាព | ពេលវេលា (ត្រីមាស) | | | | | | | | | | | | ក្រសួង-ស្ថាប័ន/អង្គភាព | សូចនាករគន្លឹះ | គោលដៅ | | | តម្រូវការធនធាន |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2008 | | | | 2009 | | | | 2010 | | | | | | 2008 | 2009 | 2010 | |
| | 1 | 2 | 3 | 4 | 1 | 2 | 3 | 4 | 1 | 2 | 3 | 4 | | | | | | |
| **គោលបំណងទី ១២ ៖ បន្តកែលម្អការគ្រប់គ្រងបំណុល** | | | | | | | | | | | | | | | | | | |
| ១២.១. ពិនិត្យឡើងវិញក្របខ័ណ្ឌច្បាប់ ក្របខ័ណ្ឌស្ថាប័ន និងតួនាទី//ការទទួលខុសត្រូវក្នុងការគ្រប់គ្រងបំណុល | | X | X | X | X | X | X | X | | | | | ក្រុមរៀបចំថវិកា/វិនិយោគ | ក្របខ័ណ្ឌច្បាប់ និង ក្របខ័ណ្ឌស្ថាប័នត្រូវបានត្រួតពិនិត្យឡើងវិញ និងអនុវត្ត | ក្របខ័ណ្ឌច្បាប់ និង ក្របខ័ណ្ឌស្ថាប័ន ត្រូវបានបង្កើត | ក្របខ័ណ្ឌច្បាប់ និង ក្របខ័ណ្ឌស្ថាប័នត្រូវបានអនុវត្ត | | ADB/ MDTF/ IDA |
| ១២.២. រៀបចំ និងអនុវត្តយុទ្ធសាស្ត្រគ្រប់គ្រងបំណុល | | | | X | X | X | X | X | X | X | X | X | ក្រុមរៀបចំថវិកា/វិនិយោគ | | | | | |
| ១២.៣.បង្កើនការប្រើប្រាស់ប្រព័ន្ធទិន្នន័យបំណុល | | X | X | X | X | X | X | X | X | X | X | X | ក្រុមរៀបចំថវិកា/វិនិយោគ | រៀបចំ យុទ្ធសាស្ត្រ គ្រប់គ្រង បំណុលប្រចាំឆ្នាំ<br><br>គុណភាពនៃ ការកត់ត្រា និង | ចាប់ផ្តើម រៀបចំ យុទ្ធសាស្ត្រ បំណុល ប្រចាំឆ្នាំ<br><br>បង្កើត របាយការណ៍ | យុទ្ធសាស្ត្រ បំណុលប្រចាំឆ្នាំត្រូវបាន រៀបចំ<br><br>បង្កើត របាយការណ៍ | ត្រួតពិនិត្យ ឡើងវិញ យុទ្ធសាស្ត្រ ដែលបាន បង្កើត<br><br>បង្កើតប្រព័ន្ធ ត្រួតពិនិត្យ | |

| | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | | | | | របាយការណ៍បំណុលក្នុងប្រទេស និងក្រៅប្រទេស ត្រូវបានកែលម្អ (សូចនាករ PEFA ៩ & ១៧) | តាមដានបំណុលប្រចាំ ត្រីមាសនិងប្រចាំឆ្នាំ | តាមដានបំណុលប្រចាំឆ្នាំ និងប្រចាំត្រីមាសដែលមានលក្ខណៈពេញលេញព្រមទាំងធ្វើបច្ចុប្បន្នភាពនិងផ្ទៀងផ្ទាត់ជាប្រចាំ | តាមដាននិងការគ្រប់គ្រងបំណុលពេញលេញជាមួយនឹងរបាយកាណ៍ស្ថិតិ និងរបាយកាណ៍គ្រប់គ្រងគ្រប់ជ្រុងជ្រោយ | |

| គោលបំណង/សកម្មភាព | ពេលវេលា (ត្រីមាស) | | | | | | | | | | | | ក្រសួង-ស្ថាប័ន/ អង្គភាព | សូចនាករគន្លឹះ | គោលដៅ | | | តម្រូវការធនធាន |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2008 | | | | 2009 | | | | 2010 | | | | | | 2008 | 2009 | 2010 | |
| | 1 | 2 | 3 | 4 | 1 | 2 | 3 | 4 | 1 | 2 | 3 | 4 | | | | | | |
| **គោលបំណងទី ១៣ ៖ បន្តកែលម្អការគ្រប់គ្រងសាច់ប្រាក់ និង ការគ្រប់គ្រងគណនីធនាគារ** | | | | | | | | | | | | | | | | | | |
| ១៣.១.បន្តប្រមូលផ្តុំគណនី ធនាគាររបស់រដ្ឋាភិបាល និង ពង្រឹងគណនីទោលរបស់រតនាគារ | X | X | X | X | | | | | | | | | ក្រសួង-ស្ថាប័ន ពាក់ព័ន្ធក្រុមអនុវត្តថវិកា/រតនាគារជាតិ, គ្រប់គ្រងសាច់ប្រាក់ | ពង្រីកការប្រមូលផ្តុំគណនីរដ្ឋាភិបាល និងតុល្យភាពសាច់ប្រាក់ត្រូវបានបង្កើន | កាត់បន្ថយ ៥០%នៃចំនួនគណនី រដ្ឋាភិបាល (មិនគិតគណនីរបស់ដៃគូ) | កាត់បន្ថយ ៧៥% នៃចំនួនគណនីរដ្ឋាភិបាល (មិនគិតគណនីរបស់ដៃគូ) | អនុវត្តពេញលេញនូវគណនីទោល រតនាគារ | IMF/ MDTF/ IDA |
| ១៣.២. បន្តពង្រីកការប្រើប្រាស់ប្រព័ន្ធធនាគារសម្រាប់ប្រតិបត្តិការចំណូល និងចំណាយសាធារណៈ | X | X | X | X | X | X | X | X | | | | | ក្រសួង-ស្ថាប័នពាក់ព័ន្ធក្រុមអនុវត្តថវិកា/រតនាគារជាតិ, គ្រប់គ្រងសាច់ប្រាក់ | កាត់បន្ថយចំនួនប្រតិបត្តិការជាសាច់ប្រាក់ | បន្តពង្រីកការប្រើប្រាស់គណនីទោលរតនាគារ | ធ្វើកិច្ចព្រមព្រៀងជាមួយធនាគារស្តីពីលក្ខខណ្ឌនៃការប្រើប្រាស់សេវាធនាគារ | | |
| ១៣.៣.ប្រមូលផ្តុំនិងបន្តកែលម្អផែនការសាច់ប្រាក់ (ចាប់ផ្តើមពីប្រចាំត្រីមាស / ប្រចាំខែ និង ចាប់ផ្តើមជាបណ្តើរៗទៅប្រចាំសប្តាហ៍ និង ប្រចាំថ្ងៃ ) | X | X | X | X | | | | | | | | | ក្រសួង-ស្ថាប័នពាក់ព័ន្ធក្រុមអនុវត្តថវិកា/គ្រប់គ្រងសាច់ប្រាក់ | ពង្រឹងការ | ការព្យាករណ៍ | ការព្យាករណ៍ | | |

| | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ១៣.៤. បន្តតាមដានបំណុលកកស្ទះ និង អាយុកាលរបស់វា | X | X | X | X | | | | | | | | | ក្រសួង-ស្ថាប័ន ពាក់ព័ន្ធ ក្រុមអនុវត្តថវិកា/ រតនាគារជាតិ, គ្រប់គ្រងសាច់ប្រាក់ | ព្យាករណ៍ សាច់ប្រាក់ និង ការបើកផ្តល់ សាច់ប្រាក់ ( សូចនាករ **PEFA** ១៦ និង ១៧ )<br><br>បង្កើត និង អនុវត្ត ប្រព័ន្ធកត់ត្រា បំណុលកកស្ទះ និង ប្រព័ន្ធទូទាត់ ( សូចនាករ **PEFA** ៤ ) | លំហូរសាច់ ប្រាក់ និង ការ បើកផ្តល់ សាច់ប្រាក់ ប្រចាំត្រីមាស (+ឬ -៥%)<br><br>បង្កើត យន្តការ តាម ដានបំណុល កកស្ទះដោយ ផ្អែកលើកាល បរិច្ឆេទ សក្ខីប័ត្រ របស់អ្នកផ្គត់ ផ្គង់ ។ បំណុលកក | លំហូរសាច់ ប្រាក់និងការ បើកផ្តល់សាច់ ប្រាក់ ប្រចាំខែ (+ ឬ - ៥%)<br><br>របាយការណ៍ តាមដាន បំណុលកកស្ទះ ប្រចាំត្រីមាស ត្រូវបាន បង្កើត។ បំណុលកកស្ទះ សរុបត្រូវតិច ជាង ២% នៃ ចំណាយសរុប | <br><br>ក្របខ័ណ្ឌត្រួត ពិនិត្យតាម ដានបំណុល កកស្ទះប្រចាំ ត្រីមាសត្រូវ បានអនុវត្ត ពេញលេញ។ បំណុលកក ស្ទះសរុបត្រូវ តិចជាង ២% | |

| | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | | | | | | ស្ទះសរុបត្រូវតិចជាង ២% នៃ ចំណាយសរុប | | នៃចំណាយសរុប | |

| គោលបំណង/សកម្មភាព | ពេលវេលា (ត្រីមាស) | | | | | | | | | | | | ក្រសួង-ស្ថាប័ន/ អង្គភាព | សូចនាករគន្លឹះ | គោលដៅ | | | តម្រូវការ ធនធាន |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2008 | | | | 2009 | | | | 2010 | | | | | | 2008 | 2009 | 2010 | |
| | 1 | 2 | 3 | 4 | 1 | 2 | 3 | 4 | 1 | 2 | 3 | 4 | | | | | | |
| **គោលបំណងទី ១៤ ៖ បន្តកែលម្អលទ្ធកម្មសាធារណៈ** | | | | | | | | | | | | | | | | | | |
| ១៤.១. កែលម្អក្របខ័ណ្ឌច្បាប់លទ្ធកម្មសាធារណៈ | X | X | X | X | X | X | X | X | | | | | ក្រសួង-ស្ថាប័នពាក់ព័ន្ធ ក្រុមអនុវត្តថវិកា/ លទ្ធកម្ម | ច្បាប់ បទបញ្ញត្តិ និង កម្រងនីតិវិធី ត្រូវបានបង្កើត | ក្របខ័ណ្ឌច្បាប់ត្រូវបានបង្កើត | ក្របខ័ណ្ឌច្បាប់ត្រូវបានបង្កើត | ក្របខ័ណ្ឌច្បាប់ត្រូវបានអនុវត្ត | MDTF/ IDA |
| ១៤.២. អនុវត្តអនុក្រឹត្យថ្មីស្តីពីលទ្ធកម្មសាធារណៈ និងវិធាន និងបទបញ្ញត្តិលទ្ធកម្មសាធារណៈ ដោយរួមទាំងឯកសារដេញថ្លៃជាស្តង់ដារនៅថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ | | | | X | | | | | | | | | ក្រសួង-ស្ថាប័នពាក់ព័ន្ធ ក្រុមអនុវត្តថវិកា/ លទ្ធកម្ម | វិធាន និង បទបញ្ញត្តិ ដោយរួមទាំងឯកសារដេញថ្លៃជាស្តង់ដារត្រូវបានអនុវត្តដោយអង្គភាពលទ្ធកម្ម | ២០%នៃអង្គភាពលទ្ធកម្មអនុវត្តវិធាន និងបទបញ្ញត្តិលទ្ធកម្មសាធារណៈ | ៥០% នៃអង្គភាពអនុវត្តលទ្ធកម្ម អនុវត្តវិធាន និងបទបញ្ញត្តិលទ្ធកម្មសាធារណៈ | ១០០% នៃអង្គភាពលទ្ធកម្មអនុវត្តវិធាននិងបទបញ្ញត្តិលទ្ធកម្មសាធារណៈ | |
| ១៤.៣. បន្តពង្រឹងសមត្ថភាពរបស់អង្គភាពលទ្ធកម្មនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដើម្បីអនុវត្ត | | | | | | X | X | X | | | | | ក្រសួង-ស្ថាប័នពាក់ព័ន្ធ ក្រុមអនុវត្ត | មន្ត្រីលទ្ធកម្មត្រូវ | ២០% នៃមន្ត្រី | ៥០% នៃមន្ត្រី | ១០០%នៃមន្ត្រី | |

| | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| អនុក្រឹត្យថ្មីស្តីពីលទ្ធកម្មសាធារណៈ និងវិធាន និងបទបញ្ញត្តិលទ្ធកម្មសាធារណៈ ដោយរួមទាំងឯកសារដេញថ្លៃជាស្តង់ដារ | | | | | | | | | | | | | ថវិកា/ លទ្ធកម្ម | បានផ្តល់ការបណ្តុះបណ្តាល | លទ្ធកម្មទទួលបានការបណ្តុះបណ្តាល | លទ្ធកម្មទទួលការបណ្តុះបណ្តាល | លទ្ធកម្មទទួលការបណ្តុះបណ្តាល | |
| ១៤.៤. ពង្រឹងសមត្ថភាពនាយកដ្ឋានលទ្ធកម្មសាធារណៈដើម្បីត្រួតពិនិត្យតាមដាន និងវាយតម្លៃសមិទ្ធកម្មនៃប្រព័ន្ធលទ្ធកម្មសាធារណៈ | X | X | X | X | X | X | X | X | | | | | ក្រសួង-ស្ថាប័នពាក់ព័ន្ធ ក្រុមអនុវត្តថវិកា/ លទ្ធកម្ម | នាយកដ្ឋានលទ្ធកម្មធ្វើការត្រួតពិនិត្យក្រោយកិច្ចលទ្ធកម្មជាប្រចាំ និងរៀបចំរបាយការណ៍អនុវត្តលទ្ធកម្មជាប្រចាំ | | ៥០% នៃអង្គភាពលទ្ធកម្មត្រូវបានត្រួតពិនិត្យ | ១០០%នៃ អង្គភាពលទ្ធកម្មត្រូវបានធ្វើការត្រួតពិនិត្យ | |
| ១៤.៥. បង្កើនភាពប្រកួតប្រជែង និងតម្លាភាពក្នុងដំណើរការលទ្ធកម្មតាមរយៈការបង្កើនការផ្សព្វផ្សាយជាសាធារណៈ និង ដោយចំហ | | X | X | X | X | X | X | X | | | | | ក្រសួង-ស្ថាប័ន ពាក់ព័ន្ធ ក្រុមអនុវត្តថវិកា/ លទ្ធកម្ម | | | | | |
| ១៤.៦.កំណត់ឱ្យបានច្បាស់ពីបន្ទាត់គណនេយ្យភាពក្នុងដំណើរការលទ្ធកម្ម | | | | X | X | X | X | X | X | | | | ក្រុមអនុវត្តថវិកា/ លទ្ធកម្ម, | គេហទំព័រសម្រាប់ដំណើរការកិច្ច លទ្ធកម្មត្រូវបាន បង្កើត | | គេហទំព័រត្រូវបានបង្កើត | ៥០% នៃការដេញថ្លៃ និងព័ត៌មានស្តីពី | |

| | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | | | | ក្រសួង-ស្ថាប័ន<br>ពាក់ព័ន្ធ | និងប្រើ ប្រាស់<br><br>បន្ទាត់គណនេយ្យភាពក្នុងការគ្រប់គ្រងកិច្ចលទ្ធកម្មត្រូវបានបង្កើត(សូចនាករ PEFA ១៩ ) | បន្ទាត់គណនេយ្យភាពត្រូវបានកំណត់ច្បាស់លាស់ | | ការប្រគល់កិច្ចសន្យាត្រូវបានបោះផ្សាយ | |

# ផ្នែកទី ២

# ផែនការសកម្មភាពជំហានទី២ ដែលត្រូវអនុវត្តនៅក្នុងដំណាក់កាលទី២

| គោលបំណង/សកម្មភាព | ពេលវេលា (ត្រីមាស) | | | | | | | | | | | | ក្រសួង-ស្ថាប័ន/ អង្គភាព | សូចនាករគន្លឹះ | គោលដៅ | | | តម្រូវការ ធនធាន |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2008 | | | | 2009 | | | | 2010 | | | | | | | | | |
| | 1 | 2 | 3 | 4 | 1 | 2 | 3 | 4 | 1 | 2 | 3 | 4 | | | 2008 | 2009 | 2010 | |
| **គោលបំណងទី ២១ ៖ កែលម្អបន្ទាត់គណនេយ្យភាពដោយកំណត់ឱ្យបានច្បាស់ពីតួនាទី មុខងារ និង ការទទួលខុសត្រូវរបស់ក្រសួង-ស្ថាប័ន គ្រប់កម្រិត និងរបស់អង្គភាពក្រោមឱវាទ** | | | | | | | | | | | | | | | | | | |
| ២១.១.ពិនិត្យឡើងវិញ និងធ្វើវិសោធនកម្មលើច្បាប់ និង បទបញ្ញត្តិដែលកំណត់ពីតួនាទី និងការទទួលខុសត្រូវក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់រដ្ឋាភិបាល | X | X | X | X | X | X | X | X | | | | | ក្រុមគោលន.បា ក្រុមរៀបចំថវិកា, ក្រុមអនុវត្តថវិកា/ ថវិកា, ហិរញ្ញកិច្ច, នីតិកម្ម | តួនាទី និងការទទួលខុសត្រូវ ថ្មី ចំពោះ គណនេយ្យភាព ហិរញ្ញវត្ថុត្រូវ បានកំណត់ និង អនុវត្ត | ក្របខ័ណ្ឌច្បាប់ ត្រូវបានរៀបចំ។ តួនាទីថ្មី ការទទួលខុសត្រូវ និង គណនេយ្យភាព ត្រូវបាន កំណត់ | ក្របខ័ណ្ឌច្បាប់ ថ្មីត្រូវបាន អនុម័ត | ក្របខ័ណ្ឌច្បាប់ ថ្មីត្រូវបាន ចាប់ផ្តើម អនុវត្តជា បណ្តើរៗ | MDTF/ IDA |
| ២១.២. កំណត់ឱ្យបានច្បាស់ពីបន្ទាត់គណនេយ្យភាពនៅក្នុងការរៀបចំថវិកាប្រចាំឆ្នាំ និង ក្នុងការរៀបចំកម្មវិធីវិនិយោគសាធារណៈ (PIP) និងកំណត់ពីការទទួលខុសត្រូវឱ្យបានច្បាស់លាស់រវាងក្រសួង-ស្ថាប័ន នីមួយៗ រួមមាន កសហវ ក្រសួងផែនការ និងក្រុម | X | X | X | X | X | X | X | X | | | | | ក្រុមរៀបចំថវិកា/ ថវិកា, វិនិយោគ, ដៃគូអភិវឌ្ឍន៍, ក្រសួង-ស្ថាប័ន ពាក់ព័ន្ធ | | | | | |

| | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | | | | | | | | | | | | | | បន្ទាត់គណនេយ្យភាពច្បាស់លាស់ ក្នុងការគ្រប់គ្រងឱ្យបានច្បាស់លាស់ត្រូវបានបង្កើត | កម្រងនីតិវិធីឯកសារបណ្ដុះបណ្ដាល និង វគ្គបណ្ដុះបណ្ដាលត្រូវបានរៀបចំ | តួនាទីនិងការទទួលខុសត្រូវ ថ្មីត្រូវបានផ្សព្វផ្សាយ ហើយការបណ្ដុះបណ្ដាលត្រូវបានផ្ដល់ដល់គ្រប់អ្នកគ្រប់គ្រងថវិកាទាំងអស់ | | |
| ២១.៣. កំណត់អង្គភាពថវិកា និងអ្នកគ្រប់គ្រងថវិកានៅរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | | | X | X | X | X | X | X | | | | | ក្រុមរៀបចំថវិកា/ ថវិកា, ក្រសួង-ស្ថាប័នពាក់ព័ន្ធ | | | | | |
| ២១.៤. កំណត់ពីការទទួលខុសត្រូវនៃការគ្រប់គ្រងនៅគ្រប់កម្រិត | | | | | X | X | X | X | | | | | ក្រុមរៀបចំថវិកា/ ថវិកា, ក្រសួង-ស្ថាប័នពាក់ព័ន្ធ | | | | | |
| ២១.៥. រៀបចំ និងចេញផ្សព្វផ្សាយកម្រងនីតិវិធីណែនាំដែលពន្យល់ពីការផ្ដល់សិទ្ធិអំណាច និងការទទួលខុសត្រូវដល់អង្គភាពថវិកា និងអ្នកគ្រប់គ្រងថវិកា ហើយផ្សព្វផ្សាយតាមរយៈវគ្គបណ្ដុះបណ្ដាល និងសិក្ខាសាលា | | | | | | | | X | X | X | X | X | ក្រុមរៀបចំថវិកា/ ថវិកា ក្រសួង-ស្ថាប័នពាក់ព័ន្ធ | | | | | |

| | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២១.៦. កែសម្រួលរចនាសម្ព័ន្ធស្ថាប័នឱ្យឆ្លើយតបទៅនឹងប្រព័ន្ធដំណើរការការងារថ្មីដែលត្រូវបានបង្កើតរួមទាំងការបន្តបញ្ជូនមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុទៅតាមក្រសួង-ស្ថាប័ន ដោយកំណត់ឱ្យបានច្បាស់ពីតួនាទីនៅក្នុងក្របខ័ណ្ឌវិមជ្ឈការ | | | | | | | | | | | | | ហិរញ្ញកិច្ច, ថវិកា<br>រតនាគារជាតិ | មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុត្រូវបានបញ្ជូនទៅគ្រប់ក្រសួង-ស្ថាប័ន<br><br>តួនាទីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុក្នុងក្របខ័ណ្ឌវិមជ្ឈការត្រូវបានកំណត់ | មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុដែលបានដាក់នៅតាមក្រសួងអាទិភាពទាំង ០៧ ត្រូវបានពង្រឹងជាបន្តបន្តបញ្ជូនមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុទៅក្រសួង-ស្ថាប័នឱ្យបានចំនួន២៥% | បន្តបញ្ជូនមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុទៅក្រសួង-ស្ថាប័នឱ្យបានចំនួន៦០% | បន្តបញ្ជូនមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុទៅក្រសួង-ស្ថាប័នឱ្យបាន១០០% | |

| គោលបំណង/សកម្មភាព | ពេលវេលា (ត្រីមាស) | | | | | | | | | | | | ក្រសួង-ស្ថាប័ន/ អង្គភាព | សូចនាករគន្លឹះ | គោលដៅ | | | តម្រូវការ ធនធាន |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2008 | | | | 2009 | | | | 2010 | | | | | | 2008 | 2009 | 2010 | |
| | 1 | 2 | 3 | 4 | 1 | 2 | 3 | 4 | 1 | 2 | 3 | 4 | | | | | | |
| **គោលបំណងទី ២២ ៖ កែលម្អឧបករណ៍ដែលជំរុញឱ្យមានការទទួលខុសត្រូវចំពោះការគ្រប់គ្រងហិរញ្ញវត្ថុ និងការពង្រឹងគណនេយ្យភាព** | | | | | | | | | | | | | | | | | | |
| ២២.១. បង្កើតឱ្យមានទណ្ឌកម្មសមស្របចំពោះកំហុសឆ្គង ឬ ការគ្រប់គ្រងធនធានសាធារណៈមិនសមស្រប និងគ្មានប្រសិទ្ធ-ភាព ។ ទណ្ឌកម្មនេះត្រូវចែងនៅក្នុងច្បាប់ និង ធ្វើការផ្សព្វផ្សាយ និងណែនាំឱ្យបានទូលំទូលាយ | X | X | X | X | X | X | X | X | X | X | X | X | ក្រុមគោលន.បា ក្រុមអនុវត្តថវិកា/ ហិរញ្ញកិច្ច, សវនកម្មផ្ទៃក្នុង, អគ្គាធិការដ្ឋាន, នីតិកម្ម | របបនៃការលើកទឹកចិត្ត/ ការដាក់ទណ្ឌកម្មត្រូវបានបង្កើត | លក្ខណៈវិនិច្ឆ័យត្រូវបានបង្កើត | យន្តការត្រួតពិនិត្យឡើងវិញ និងជំរុញការអនុវត្តត្រូវបានបង្កើត | ក្របខ័ណ្ឌថ្មីនៃការលើកទឹកចិត្តនិងការដាក់ទណ្ឌកម្មត្រូវបានអនុម័ត | MDTF/ IDA |
| ២២.២. រៀបចំឱ្យមានតារាងបញ្ជាក់អំពីសិទ្ធិអំណាច និងភាពទន់ភ្លន់ដែលនឹងផ្តល់ជូនអង្គភាពថវិកាដែលបានបំពេញលក្ខណៈវិនិច្ឆ័យដែលមានការឯកភាពសម្រាប់ប្រព័ន្ធគ្រប់គ្រងធនធានសាធារណៈដ៏ត្រឹមត្រូវ | | | X | X | X | X | X | X | | | | | ក្រុមរៀបចំថវិកា/ ថវិកា, ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ការត្រួតពិនិត្យពីភាពត្រឹមត្រូវត្រូវបានអនុវត្ត | | ២៥% នៃអង្គភាពថវិកាត្រូវបានត្រួតពិនិត្យពីភាពត្រឹមត្រូវ | ៥០% នៃអង្គភាពថវិកាត្រូវបានត្រួតពិនិត្យពីភាពត្រឹមត្រូវ | |

| | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២២.៣.ធ្វើការត្រួតពិនិត្យឡើងវិញជាប្រចាំលើលទ្ធផលនៃការគ្រប់គ្រងធនធានដែលសម្រេចបានដោយអង្គភាពថវិកានីមួយៗ ដើម្បីធ្វើជាមូលដ្ឋានក្នុងការពង្រីកការផ្តល់សិទ្ធិអំណាច និង ភាពទន់ភ្លន់ | | | X | | X | | X | | X | | X | | ក្រុមរៀបចំថវិកា, ក្រុមអនុវត្តថវិកា/ថវិកា, ហិរញ្ញកិច្ច, ក្រសួង-ស្ថាប័នពាក់ព័ន្ធ | | | | | |

| គោលបំណង/សកម្មភាព | ពេលវេលា (ត្រីមាស) | | | | | | | | | | | | ក្រសួង-ស្ថាប័ន/ អង្គភាព | សូចនាករគន្លឹះ | គោលដៅ | | | តម្រូវការ ធនធាន |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2008 | | | | 2009 | | | | 2010 | | | | | | 2008 | 2009 | 2010 | |
| | 1 | 2 | 3 | 4 | 1 | 2 | 3 | 4 | 1 | 2 | 3 | 4 | | | | | | |
| **គោលបំណងទី ២៣ ៖ បន្តកែលម្អការអនុវត្តមាតិកាថវិកាថ្មី និង ប្លង់គណនេយ្យថ្មី** | | | | | | | | | | | | | | | | | | |
| ២៣.១. ត្រួតពិនិត្យឡើងវិញ និង បន្តកែលម្អប្លង់គណនីថ្មី និង ចំណាត់ថ្នាក់ថវិកាថ្មីដើម្បីពង្រឹង និងអនុវត្តជាបណ្តើរៗ ចំណាត់ថ្នាក់សេដ្ឋកិច្ច មុខងារ និង រដ្ឋបាល | | X | X | X | X | X | X | X | X | X | X | X | ក្រុមគោលន.បា ក្រុមរៀបចំថវិកា, ក្រុមអនុវត្តថវិកា/ រតនាគារជាតិ , ថវិកា, វិនិយោគ, គោលនយោបាយ ក្រសួង-ស្ថាប័ន ពាក់ព័ន្ធ | ការរៀបចំ និង ការអនុវត្តថវិកា ផ្អែកលើចំណាត់ថ្នាក់រដ្ឋបាល សេដ្ឋកិច្ច និង មុខងារដោយ ប្រើប្រាស់ ស្តង់ដារ **GFS/ COFOG** ត្រូវ បានអនុវត្ត នៅ រដ្ឋបាលថ្នាក់ ជាតិ និងថ្នាក់ ក្រោមជាតិ ( សូចនាករ ***PEFA*** ៥ ) | ចំណាត់ថ្នាក់ រដ្ឋបាល និង សេដ្ឋកិច្ច ដោយ ប្រើប្រាស់ ស្តង់ដារ **GFS/ COFOG** ត្រូវ បានអនុវត្តនៅ រដ្ឋបាលថ្នាក់ ជាតិ និងថ្នាក់ ក្រោមជាតិ | រចនាសម្ព័ន្ធ ចំណាត់ថ្នាក់ ថវិកាតាម មុខងារនិងតាម កម្មវិធីត្រូវបាន បង្កើត | ចំណាត់ថ្នាក់ ថវិកាតាម មុខងារ និង តាមកម្មវិធី ត្រូវបានអនុវត្ត សាកល្បងនៅ កសហវ ក្រសួង-ស្ថាប័ន និង នៅ រដ្ឋបាលថ្នាក់ ក្រោមជាតិ | IMF France MDTF/ IDA |

| | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២៣.២. សិក្សា និងផ្តល់ជម្រើសចំណាត់ថ្នាក់តាមកម្មវិធី | | | | X | X | X | X | X | X | X | X | X | ក្រុមរៀបចំថវិកា, ក្រុមអនុវត្តថវិកា/ រតនាគារជាតិ, ថវិកា, ក្រសួង-ស្ថាប័នពាក់ព័ន្ធ | | | | | |
| ២៣.៣. សិក្សា និងផ្តល់ជម្រើសសម្រាប់ការឈានទៅប្រព័ន្ធគណនេយ្យបង្ករជាជំហានៗ | | X | X | X | X | X | X | X | X | X | X | X | ក្រុមអនុវត្តថវិកា/ រតនាគារជាតិ | ជាបណ្តើរៗ មូលដ្ឋានគណនីត្រូវរួមបញ្ចូលនូវគណនីត្រូវទូទាត់ /គណនីត្រូវទទួល និងទ្រព្យសកម្ម និងទ្រព្យអកម្ម | ផែនការអន្តរកាល ដើម្បីអនុវត្តជាជំហានៗនូវគណនីបង្ករត្រូវបានបង្កើត | ការកត់ត្រាគណនីត្រូវទូទាត់/គណនីត្រូវទទួល និងទ្រព្យសកម្ម និងទ្រព្យអកម្ម ត្រូវបានអនុវត្ត ក្នុងក្របខ័ណ្ឌនៃការអនុវត្តសាកល្បង **FMIS** (កសហវ ក្រសួង-ស្ថាប័នដែលត្រូវ សាក | បន្តពង្រីកការប្រើប្រាស់នៅតាមក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិផ្សេងៗទៀត | MDTF /IMF/ Fra nce |

| | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | | | | | | | ល្បង និង នៅ រដ្ឋបាលថ្នាក់ក្រោមជាតិ) | | |
| ២៣.៤. រៀបចំ និងផ្សព្វផ្សាយឯកសារណែនាំអំពីគណនេយ្យ | | | X | X | X | X | X | X | | | | | ក្រុមអនុវត្តថវិកា/រតនាគារជាតិ | ឯកសារណែនាំស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ ត្រូវបានរៀបចំ | ឯកសារណែនាំត្រូវបានផ្សព្វផ្សាយ និងផ្តល់ការបណ្តុះបណ្តាល | | | MDTF/<br>IMF/<br>France |

| គោលបំណង/សកម្មភាព | ពេលវេលា (ត្រីមាស) | | | | | | | | | | | | ក្រសួង-ស្ថាប័ន/អង្គភាព | សូចនាករគន្លឹះ | គោលដៅ | | | តម្រូវការធនធាន |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2008 | | | | 2009 | | | | 2010 | | | | | | 2008 | 2009 | 2010 | |
| | 1 | 2 | 3 | 4 | 1 | 2 | 3 | 4 | 1 | 2 | 3 | 4 | | | | | | |
| **គោលបំណងទី ២៤ ៖ កែលម្អដំណើរការ និងប្រតិបត្តិការអនុវត្តថវិកា** | | | | | | | | | | | | | | | | | | |
| ២៤.១.បន្តកាត់បន្ថយពេលវេលាសម្រាប់ការស្នើសុំធានាចំណាយ និងការទូទាត់ នៅក្នុងក្រសួង-ស្ថាប័ន ។<br><br>( ដោយសន្មតថាមានការកែលម្អទៅលើប្រព័ន្ធដែលកំពុងអនុវត្ត និងការចាប់ផ្ដើមអនុវត្តជាបណ្ដើរៗ FMIS នៅក្នុងឆ្នាំ ២០០៩ និង ២០១០ ) | X | X | X | X | | | | | | | | | ក្រុមអនុវត្តថវិកា/ហិរញ្ញកិច្ច, រតនាគារជាតិ, ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ការកែលម្អជាបណ្ដើរៗ នៃក្របខ័ណ្ឌ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាប្រព័ន្ធ ៖<br>- ភាពស័ក្តិសិទ្ធិនៃការត្រួតពិនិត្យធានាចំណាយ<br>- ប្រសិទ្ធភាព នៃដំណើរការប្រតិបត្តិការ និងការត្រួតពិនិត្យ | ការត្រួតពិនិត្យធានាចំណាយត្រូវបានបង្កើត និងមានភាពស័ក្តិសិទ្ធិ ជាបណ្ដើរៗ<br><br>ដំណើរការ | ការត្រួតពិនិត្យធានាចំណាយត្រូវបានបង្កើត ហើយនឹងមានភាពស័ក្តិសិទ្ធិក្នុងការកម្រិតការធានាចំណាយ ទៅតាមទំហំទឹកប្រាក់ដែលមាន និងឥណទានដែលបានអនុម័ត ដោយមានករណីលើក | ការត្រួតពិនិត្យធានាចំណាយត្រូវបានបង្កើត ហើយនឹងមានភាពស័ក្តិសិទ្ធិក្នុងការកម្រិតការធានាចំណាយទៅតាមទំហំទឹកប្រាក់ដែលមាន និង ឥណទានដែលបានអនុម័ត | MDTF/IDA |

| | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | | | | | ផ្ទៃក្នុង<br><br>(សូចនាករ PEFA ២០) | ប្រតិបត្តិការជាមូលដ្ឋាន និង ការត្រួតពិនិត្យផ្ទៃក្នុងត្រូវបានបង្កើត | លែងតិចតួចតែប៉ុណ្ណោះ<br><br>ការត្រួតពិនិត្យដំណើរការប្រតិបត្តិការ និង ការត្រួតពិនិត្យផ្ទៃក្នុងត្រូវបានអនុវត្តស្ទើរតែពេញលេញ | ការត្រួតពិនិត្យដំណើរការប្រតិបត្តិការ និងការត្រួតពិនិត្យផ្ទៃក្នុងត្រូវបានអនុវត្តពេញលេញ | |
| ២៤.២.កែលម្អដំណើរការនៃប្រតិបត្តិការនៅក្នុង កសហវ/ក្រសួង-ស្ថាប័ន ដើម្បីឱ្យស្របទៅនឹងការវិវឌ្ឍន៍នៃប្លង់គណនេយ្យ និងបទដ្ឋានគណនេយ្យ ព្រមទាំងធ្វើការផ្ទៀងផ្ទាត់គណនីធនាគារជាប្រចាំ | X | X | X | | | | | | | | | | រតនាគារជាតិ, វិនិយោគ, ហិរញ្ញកិច្ច, ក្រសួង-ស្ថាប័នពាក់ព័ន្ធ | - ប្រកាន់ខ្ជាប់ចំពោះការអនុវត្តតាមដំណើរការប្រតិបត្តិការ ( ចំណាយចរន្តចំណាយវិនិយោគ និងការផ្តល់ហិរញ្ញប្ប | ភាគច្រើននៃប្រតិបត្តិការបានគោរពតាមបទដ្ឋានគណនេយ្យ និងប្លង់គណនេយ្យ | ប្រតិបត្តិការបានគោរពតាមបទដ្ឋានគណនេយ្យ និងប្លង់គណនេយ្យដោយមានការលើកលែងមួយចំនួន | ប្រតិបត្តិការបានគោរពតាមបទដ្ឋានគណនេយ្យ និងប្លង់គណនេយ្យដោយមានការលើកលែងតិចតួច) | IMF/France/MDTF/IDA |

| | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | | | | | ទាន) ឱ្យស្របតាមប្លង់គណនី និង បទដ្ឋានគណនេយ្យ<br>-លុបបំបាត់ការផ្តល់ប្រាក់បុរេប្រទានមិនសមស្របសម្រាប់ចំណាយវិនិយោគ<br>- ផ្ទៀងផ្ទាត់ជាប្រចាំ (សូចនាករ **PEFA** ១៨ និង១៩) | ផ្ទៀងផ្ទាត់ និង ជម្រះបញ្ជីចំពោះធនាគារដែលគ្រប់គ្រងថវិការដ្ឋ និង ផ្នាកគណនីក្នុងរយៈពេល២ខែប្រចាំត្រីមាស | ផ្ទៀងផ្ទាត់ និង កែតម្រូវចំពោះធនាគារដែលគ្រប់គ្រងថវិការដ្ឋ និង ផ្នាកគណនីក្នុងរយៈពេល២ខែប្រចាំត្រីមាស | ផ្ទៀងផ្ទាត់និង កែតម្រូវចំពោះធនាគារដែលគ្រប់គ្រងថវិការដ្ឋ និង ផ្នាកគណនីក្នុងរយៈពេល ១ខែ ប្រចាំ ត្រីមាស | |
| ២៤.៣. បង្កើនកម្រិតយល់ដឹងភាពជាម្ចាស់ ការចូលរួម និង សមត្ថភាពផ្នែក FMIS ដល់ | X | X | X | X | X | X | X | X | X | X | X | X | ព័ត៌មានវិទ្យា, ក្រសួង-ស្ថាប័នពាក់ព័ន្ធ | គោលការណ៍ណែនាំ និង កម្មវិធីផ្តល់ការយល់ | កម្មវិធីផ្តល់ការយល់ដឹងពី FMIS ត្រូវបាន | | | MDTF/IDA |

| | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| កសហវ ក្រសួង-ស្ថាប័ន និង រដ្ឋបាលថ្នាក់ក្រោមជាតិ | | | | | | | | | | | | | | ដឹងត្រូវបាន បង្កើត | រៀបចំនិងអនុវត្ត | | | |
| ២៤.៤.កសាងសមត្ថភាពគ្រប់គ្រងគម្រោង FMIS ដោយរួមទាំងនៅ កសហវ ក្រសួង-ស្ថាប័ន និងអង្គភាពថ្នាក់ក្រោមជាតិ | X | X | X | X | X | X | | | X | X | | | ព័ត៌មានវិទ្យា, ក្រសួង-ស្ថាប័ន ពាក់ព័ន្ធ | | | | | |
| ២៤.៥. ពង្រឹងការរៀបចំ FMIS និងបញ្ចប់ដំណើរការលទ្ធកម្ម | X | X | X | X | X | X | X | X | X | X | | | ព័ត៌មានវិទ្យា, ក្រសួង-ស្ថាប័ន ពាក់ព័ន្ធ | លទ្ធកម្ម **FMIS** ត្រូវបានបញ្ចប់ និង សមត្ថភាព អ្នកប្រើប្រាស់ **FMIS** ត្រូវបាន កសាង | ផែនការអនុវត្ត សមត្ថភាពគ្រប់គ្រង និងអនុវត្ត គម្រោងនៅ កសហវ ក្រសួង-ស្ថាប័ន និងអង្គភាពថ្នាក់ក្រោម ជាតិ ដែលត្រូវសាកល្បង ត្រូវបាន | ធ្វើឱ្យកើតចេញ ជារូបរាងនូវ ប្រព័ន្ធ និង បណ្តុះបណ្តាល អ្នកប្រើប្រាស់ គ្រប់ម៉ូឌុលរបស់ **FMIS**<br>អនុវត្តម៉ូឌុលការ រៀបចំថវិកា ឆ្នាំ | | |
| ២៤.៦. រៀបចំផែនការអនុវត្តរួម (ការសាកល្បង និង ការពង្រីក) ដោយរួមបញ្ចូល កសហវ ក្រសួង-ស្ថាប័ន និង អង្គភាពថ្នាក់ក្រោមជាតិ | | | X | X | X | X | X | X | X | X | X | X | ព័ត៌មានវិទ្យា, ក្រសួង-ស្ថាប័ន ពាក់ព័ន្ធ | | | | | |
| ២៤.៧. រៀបចំផែនការ និងវគ្គបណ្តុះបណ្តាលព្រមទាំងឯកសារបណ្តុះបណ្តាលសម្រាប់ការបន្ត | X | X | X | X | X | X | X | X | X | X | X | X | ព័ត៌មានវិទ្យា, ក្រសួង-ស្ថាប័ន ពាក់ព័ន្ធ | | | | | |

| | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| បណ្តុះបណ្តាលដល់គ្រប់មន្ត្រីដែលពាក់ព័ន្ធនឹង FMIS នៅ កសហវ ក្រសួង-ស្ថាប័ន និង អង្គភាពថ្នាក់ក្រោមជាតិ | | | | | | | | | | | | | | | បញ្ចប់ | ២០១០ | | |
| ២៤.៨. ការអនុវត្តសាកល្បងជំហានដំបូង និងពង្រីកការអនុវត្ត FMIS ( ម៉ូឌុលស្នូល និង ម៉ូឌុលសម្រាប់ថវិកា ) | | | | | | | X | X | X | X | X | X | ព័ត៌មានវិទ្យា | ម៉ូឌុលស្នូលត្រូវបានអនុវត្តសាកល្បងនៅរតនាគារជាតិ នៅក្រសួង-ស្ថាប័នចំនួន៥ និងរតនាគារខេត្តចំនួន៥ | | | ម៉ូឌុលស្នូលត្រូវបានអនុវត្តសាកល្បងនៅរតនាគារជាតិ ក្រសួង-ស្ថាប័នចំនួន៥ និង រតនាគារខេត្តចំនួន៥ | |

| គោលបំណង/សកម្មភាព | ពេលវេលា (ត្រីមាស) | | | | | | | | | | | | ក្រសួង-ស្ថាប័ន/ អង្គភាព | សូចនាករគន្លឹះ | គោលដៅ | | | តម្រូវការធនធាន |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2008 | | | | 2009 | | | | 2010 | | | | | | 2008 | 2009 | 2010 | |
| | 1 | 2 | 3 | 4 | 1 | 2 | 3 | 4 | 1 | 2 | 3 | 4 | | | | | | |
| **២៥. កែលម្អប្រព័ន្ធគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុដើម្បីធានាតម្លាភាព** | | | | | | | | | | | | | | | | | | |
| ២៥.១.ពិនិត្យឡើងវិញនូវស្តង់ដារគណនេយ្យរដ្ឋបាលសាធារណៈ ដែលមានលក្ខណៈជាអន្តរជាតិ (IPSAS, GAAP) និង វាយតម្លៃភាពប្រាកដនិយម និងភាពសមស្របនៃលំដាប់លំដោយក្នុងការដាក់ឱ្យអនុវត្តស្តង់ដារគណនេយ្យនេះដោយផ្សារភ្ជាប់ទៅនឹងការពង្រីកការប្រើប្រាស់ FMIS | | | | | | | | | | | | | ក្រុមអនុវត្តថវិកា, ក្រុមគោលនយោបាយ/ រតនាគារជាតិ, គោលនយោបាយ, ក្រសួង-ស្ថាប័នពាក់ព័ន្ធ | របាយការណ៍ហិរញ្ញវត្ថុដែលមានគុណភាពភាពទៀងទាត់ និង តម្លាភាព<br>-ស្តង់ដារ<br>-របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ<br><br>(សូចនាករ *PEFA* ២៥ ) | មូលដ្ឋានស្តង់ដារ និង ទម្រង់របាយការណ៍គណនេយ្យ/ ថវិកាត្រូវបានកំណត់<br><br>របាយការណ៍ហិរញ្ញវត្ថុដែលមិនទាន់ពេញលេញត្រូវបានរៀបចំ (ចំណូលចំណាយក្រៅក្របខ័ណ្ឌថវិកា | របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំ (មិនគិតបញ្ចូលទ្រព្យមិនមែនហិរញ្ញវត្ថុ) ដោយឈរលើមូលដ្ឋាន , | របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំ ( មិនគិតបញ្ចូលទ្រព្យមិនមែនហិរញ្ញវត្ថុ ) ដោយឈរលើមូលដ្ឋាន, ពេល | MDTF/ IDA |

| | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | | | | | | មិនទាន់បាន បញ្ចូល) | ពេលវេលា និង លក្ខខណ្ឌ តម្រូវ ដែលបានឯកភាព<br><br>ស្តង់ដារ របាយការណ៍ គណនេយ្យហិរញ្ញ វត្ថុ ត្រូវបានផ្សព្វ ផ្សាយ និង របាយការណ៍ គណនេយ្យត្រូវ បានផ្តល់សម្រាប់ សវនកម្ម | វេលា និងលក្ខខណ្ឌ តម្រូវដែលបានឯក ភាព<br><br>ស្តង់ដាររបាយ- ការណ៍គណនេយ្យ ហិរញ្ញវត្ថុ ត្រូវបាន ផ្សព្វផ្សាយ និង របាយការណ៍ គណនេយ្យត្រូវ បានផ្តល់សម្រាប់ សវនកម្ម និង ផ្សព្វផ្សាយជា សាធារណៈ | |
| ២៥.២. ដាក់ឱ្យអនុវត្តនូវរបាយ- ការណ៍អនុវត្តថវិកាប្រចាំត្រីមាស ដែលបញ្ជាក់អំពីការងារដែលបាន បំពេញធៀបនឹងគោលដៅ | | X | X | X | X | | | | | | | | ក្រុមគោលន.បា ក្រុមរៀបចំ ថវិកា/ថវិកា, វិនិយោគ, | របាយការណ៍ អនុវត្តថវិកា ប្រចាំត្រីមាស និងប្រចាំឆ្នាំ ត្រូវ | របាយការណ៍ អនុវត្តថវិកា ប្រចាំឆមាស ត្រូវបានផ្សព្វ | របាយការណ៍ អនុវត្តថវិកា ប្រចាំឆមាស និង ប្រចាំឆ្នាំ ត្រូវ | របាយការណ៍ អនុវត្តថវិកា ប្រចាំត្រីមាស ឆមាសនិងប្រចាំ | |

| | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| លទ្ធផលទទួលបានការយឺតយ៉ាវ និងវិធានការដោះស្រាយ ៖ ពីក្រសួង-ស្ថាប័នមក កសហវ និងនៅផ្ទៃក្នុងក្រសួង-ស្ថាប័ន ពីអង្គភាពថវិការហូតដល់ថ្នាក់ដឹកនាំ | | | | | | | | | | | | | គោលនយោបាយក្រសួង-ស្ថាប័នពាក់ព័ន្ធ | បានបោះពុម្ពផ្សាយ<br><br>( សូចនាករ *PEFA* ២៣ និង ២៤ ) | ផ្សាយក្នុងរង្វង់ ០៨ សប្តាហ៍ ទៅតាមវិស័យ និងកម្មវិធីសំខាន់ៗ | បានផ្សព្វផ្សាយក្នុងរង្វង់ ០៦ សប្តាហ៍ ទៅតាមវិស័យ និងកម្មវិធីសំខាន់ៗ | ឆ្នាំដោយបញ្ចូលការធានាចំណាយ និងដំណាក់កាលនៃការទូទាត់ត្រូវបានផ្សព្វផ្សាយក្នុងរង្វង់ ០៤ សប្តាហ៍ | |
| ២៥.៣.កែលម្អទម្រង់របាយ-ការណ៍ អនុវត្តថវិកាដែលត្រូវផ្ញើទៅគណៈរដ្ឋមន្ត្រី និងស្ថាប័ននីតិបញ្ញត្តិ | | | X | X | | X | | | | X | | | ក្រុមរៀបចំថវិកា/ថវិកា, វិនិយោគ | | | | | |
| ២៥.៤. កែលម្អទម្រង់របាយ-ការណ៍ និងការផ្លាស់ប្តូរព័ត៌មានជាមួយសាធារណជន | X | X | X | X | X | X | X | X | X | X | X | X | ក្រុមគោលនយោបាយ/គោលនយោបាយ,ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ព័ត៌មានហិរញ្ញវត្ថុសំខាន់ៗ អាចរកបាន ៖<br>-ឯកសារថវិកា<br>-របាយការណ៍អនុវត្តថវិកាប្រចាំឆ្នាំ<br>-របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ | យ៉ាងហោចណាស់ត្រូវមានរបាយការណ៍ ០៣ ក្នុងចំណោមរបាយណ៍ទាំង៦ | យ៉ាងហោចណាស់ត្រូវមានរបាយការណ៍ ០៤ក្នុងចំណោមរបាយការណ៍ទាំង ៦ | យ៉ាងហោចណាស់ត្រូវមានរបាយការណ៍ ០៥ ក្នុងចំណោមរបាយការណ៍ទាំង៦ | |

| | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | | | | | -របាយការណ៍សវនកម្មផ្ទៃក្រៅ<br>-ការប្រគល់កិច្ចសន្យា<br>-ការផ្តល់ធនធានសម្រាប់អង្គភាពសេវាជាមូលដ្ឋាន<br>(សូចនាករ *PEFA* ១០) | | | | |
| ២៥.៥. ដាក់ឱ្យអនុវត្តយន្តការដើម្បីបញ្ចប់ការចុះបញ្ជីសារពើ-ភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ និងធ្វើបច្ចុប្បន្នភាពជាប្រចាំ | X | X | X | X | X | X | X | X | X | X | X | X | ក្រុមចំណូល/ទ្រព្យសម្បត្តិរដ្ឋ | បញ្ជីសារពើភ័ណ្ឌ ត្រូវធ្វើបច្ចុប្បន្នភាពជាប្រចាំទ្រព្យសម្បត្តិរដ្ឋ | យន្តការត្រូវបានរៀបចំ | យន្តការត្រូវបានចាប់ផ្តើមអនុវត្ត | យន្តការត្រូវបានអនុវត្តពេញលេញ | MDTF |

| គោលបំណង/សកម្មភាព | ពេលវេលា (ត្រីមាស) | | | | | | | | | | | | ក្រសួង-ស្ថាប័ន អង្គភាព | សូចនាករគន្លឹះ | គោលដៅ | | | តម្រូវការធនធាន |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2008 | | | | 2009 | | | | 2010 | | | | | | 2008 | 2009 | 2010 | |
| | 1 | 2 | 3 | 4 | 1 | 2 | 3 | 4 | 1 | 2 | 3 | 4 | | | | | | |
| **គោលបំណងទី ២៦ ៖ កែលម្អសវនកម្ម និងអធិការកិច្ច ព្រមទាំងឆ្លើយតបទៅ និងប្រើប្រាស់លទ្ធផលនៃរបាយការណ៍សវនកម្ម និងអធិការកិច្ច** | | | | | | | | | | | | | | | | | | |
| ២៦.១. បង្កើតឱ្យមានអង្គភាពសវនកម្មផ្ទៃក្នុងនៅគ្រប់ក្រសួង | X | X | X | X | X | X | X | X | | | | | ក្រុមគាំទ្រ/សវនកម្មផ្ទៃក្នុង, ក្រសួង-ស្ថាប័ន | សវនកម្មផ្ទៃក្នុងត្រូវចាប់ដំណើរការនៅក្នុងស្ថាប័នសំខាន់ៗរបស់រដ្ឋាភិបាល ហើយអនុវត្តប្រព័ន្ធត្រួតពិនិត្យ ។ ចេញផ្សាយជាទៀងទាត់ របាយ-ការណ៍ ប្រចាំត្រីមាស និង ចាត់វិធានការដោះស្រាយ | រៀបចំផែនការយុទ្ធសាស្ត្រសវនកម្មផ្ទៃក្នុង<br>-វិសាលភាព<br>-តួនាទី<br>-វិធីសាស្ត្រ<br>-FMIS<br>-របាយការណ៍ | អង្គភាពភាគច្រើន (៥0%) បានចេញរបាយការណ៍ជាប្រចាំ | អ្នកគ្រប់គ្រងភាគច្រើន (៥0%) បានឆ្លើយតបទៅនឹងលទ្ធផលសវនកម្ម និងបានចាត់វិធានការដោះស្រាយ | MDTF/ IDA |
| ២៦.២. កែលម្អយន្តការដើម្បីធានាការឆ្លើយតបប្រកបដោយប្រសិទ្ធភាពទៅនឹងលទ្ធផលសវនកម្ម និងអធិការកិច្ចនៅតាមបណ្តាអង្គភាពថវិកា | X | X | X | X | X | X | X | X | X | X | X | X | ក្រុមគាំទ្រ, ក្រុមគោលនយោបាយ/សវនកម្មផ្ទៃក្នុង, អគ្គាធិការដ្ឋាន, ក្រសួង-ស្ថាប័ន | | | | | |
| ២៦.៣.រៀបចំនិងកែលម្អផែនការសវនកម្ម/អធិការកិច្ចប្រចាំឆ្នាំរបស់ក្រសួង-ស្ថាប័នដោយផ្អែកលើលក្ខណ:វិនិច្ឆ័យវាយតម្លៃហានិភ័យដែលបានផ្តល់អនុសាសន៍ដោយកសហវ | X | X | X | X | X | X | X | X | X | X | X | X | ក្រុមគាំទ្រ, ក្រុមគោលនយោបាយ/សវនកម្មផ្ទៃក្នុង, អគ្គាធិការដ្ឋាន, ក្រសួង-ស្ថាប័ន | | រៀបចំកម្រងនីតិវិធី និង កម្មវិធីបណ្តុះ-បណ្តាល | អនុវត្តកម្មវិធីបណ្តុះបណ្តាល | | |

| | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២៦.៤. កសហវ ពិនិត្យមើលឡើងវិញ ពីភាពគ្រប់គ្រាន់នៃគំរូរបាយការណ៍សវនកម្ម/ អធិការកិច្ច | X | X | X | X | X | X | X | X | X | X | X | X | ក្រុមគាំទ្រ, ក្រុមគោលនយោបាយ/ សវនកម្មផ្ទៃក្នុង, អគ្គាធិការដ្ឋាន | បញ្ហាដែលកើតមាន (សូចនាករ *PEFA* ១០ ) | | | | |
| ២៦.៥. កែលម្អរបាយការណ៍សវនកម្ម/អធិការកិច្ច | X | X | X | X | X | X | X | X | X | X | X | X | ក្រុមគោលនយោបាយ/ អគ្គាធិការដ្ឋាន | | | | | |

| គោលបំណង/សកម្មភាព | ពេលវេលា (ត្រីមាស) | | | | | | | | | | | | ក្រសួង-ស្ថាប័ន អង្គភាព | សូចនាករគន្លឹះ | គោលដៅ | | | តម្រូវការធនធាន |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2008 | | | | 2009 | | | | 2010 | | | | | | 2008 | 2009 | 2010 | |
| | 1 | 2 | 3 | 4 | 1 | 2 | 3 | 4 | 1 | 2 | 3 | 4 | | | | | | |
| **គោលបំណងទី ២៧ ៖ ពង្រឹង និងរៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រវិមជ្ឈការហិរញ្ញវត្ថុ** | | | | | | | | | | | | | | | | | | |
| ២៧.១. សិក្សាពីការអនុវត្តនាពេលបច្ចុប្បន្ននិងបង្កើតជម្រើសសម្រាប់ពង្រឹងការរៀបចំ និង អនុវត្តថវិកាខេត្ត-ក្រុង | | X | X | X | X | X | | | | | | | ក្រុមរៀបចំថវិកាហិរញ្ញវត្ថុមូលដ្ឋាន | សមត្ថភាព និង ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ សាធារណៈនៅថ្នាក់ក្រោមជាតិត្រូវបានបង្កើត | យុទ្ធសាស្ត្រត្រូវបានរៀបចំ និង ចាប់ផ្តើមដាក់ឱ្យអនុវត្តដើម្បីពង្រឹងប្រព័ន្ធរៀបចំ និង អនុវត្តថវិកា | យុទ្ធសាស្ត្រត្រូវបានអនុវត្តពេញលេញ | | MDTF/ IDA |
| ២៧.២. កែលម្អចំណូលមិនមែនសារពើពន្ធរបស់ខេត្ត-ក្រុង | | X | X | X | X | X | X | X | X | X | X | X | ក្រុមរៀបចំថវិកា/ ហិរញ្ញវត្ថុ មូលដ្ឋាន | | | | | |
| ២៧.៣. កែលម្អការរៀបចំ និង ការអនុវត្តថវិកាព្រមទាំងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុខេត្ត ក្រុង ស្រុក និង ខណ្ឌ | | X | X | X | X | X | X | X | X | X | X | X | ក្រុមរៀបចំថវិកា/ ហិរញ្ញវត្ថុ មូលដ្ឋាន | | | | | |
| ២៧.៤. កែលម្អការរៀបចំ និង អនុវត្តថវិកាព្រមទាំងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ/សង្កាត់ | | X | X | X | X | X | X | X | X | X | X | X | ក្រុមរៀបចំថវិកា/ ហិរញ្ញវត្ថុ មូលដ្ឋាន | ការប្រមូលចំណូលមិនមែនសារពើពន្ធត្រូវបានកែលម្អ | ចំណូលមិនមែនសារពើពន្ធបាន ១០% | ចំណូលមិនមែនសារពើពន្ធបាន ១៥% | ចំណូលមិនមែនសារពើពន្ធកើនបាន ២០% | |
| ២៧.៥. ពង្រឹងសមត្ថភាពក្នុងការ | | X | X | X | X | X | X | X | X | X | X | X | ក្រសួង-ស្ថាប័ន | | | | | |

| | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| រៀបចំ និងអនុវត្តថវិកាព្រមទាំងការគ្រប់គ្រងហិរញ្ញវត្ថុក្នុងក្របខ័ណ្ឌវិមជ្ឈការ និងវិសហមជ្ឈការ | | | | | | | | | | | | | ក្រុមរៀបចំថវិកា/ហិរញ្ញវត្ថុមូលដ្ឋាន | | របាយការណ៍ប្រចាំឆ្នាំ ស្តីពីហិរញ្ញវត្ថុនៅថ្នាក់ក្រោមជាតិត្រូវបានរៀបចំទាន់ពេលវេលា និង អាចប្រើប្រាស់បាន | របាយការណ៍ក្នុងឆ្នាំ ស្តីពីហិរញ្ញវត្ថុនៅថ្នាក់ក្រោមជាតិត្រូវបានរៀបចំទាន់ពេលវេលា និង អាចប្រើប្រាស់បាន | របាយការណ៍ក្នុងឆ្នាំស្តីពីហិរញ្ញវត្ថុ គ្រប់ជ្រុងជ្រោយនៅថ្នាក់ក្រោមជាតិត្រូវបានរៀបចំទាន់ពេលវេលា និងអាចប្រើប្រាស់បាន | |
| ២៧.៦. ពិនិត្យឡើងវិញ និង ធ្វើវិសោធនកម្មច្បាប់ អនុក្រឹត្យ និងបទបញ្ញត្តិផ្សេងៗ ដើម្បីឱ្យមានសង្គតិភាពទៅនឹងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង និង ស្រុក ខណ្ឌ | | X | X | X | | | | | | | | | ក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការ, ក្រសួង-ស្ថាប័ន | | | | | |
| ២៧.៧. រៀបចំយុទ្ធសាស្ត្រ និងគោលនយោបាយវិមជ្ឈការហិរញ្ញវត្ថុ ដោយផ្អែកលើក្របខ័ណ្ឌយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនិងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | | X | X | X | | | | | | | | | ក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការ, ក្រសួង-ស្ថាប័ន | ផែនការអន្តរកាលស្តីពីវិមជ្ឈការ និងវិសហមជ្ឈការហិរញ្ញវត្ថុត្រូវបានរៀបចំ | យុទ្ធសាស្ត្រវិមជ្ឈការ និងវិសហមជ្ឈការហិរញ្ញវត្ថុ និងផែនការអន្តរកាល ត្រូវបានរៀបចំ | ផែនការអន្តរកាលត្រូវបានអនុវត្ត | | |

| | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២៧.៨.រៀបចំផែនការលម្អិត ដើម្បីគាំទ្រដល់ការអនុវត្តជាបឋម នូវទិដ្ឋភាពហិរញ្ញវត្ថុ និង សារពើពន្ធដែលមានចែងនៅក្នុងច្បាប់ស្តីពីការគ្រប់គ្រង រដ្ឋបាលរាជធានី ខេត្ត ក្រុង និង ស្រុក ខណ្ឌ | | X | X | X | | | | | | | | | ក្រុមការងារ វិមជ្ឈការ និង វិសហមជ្ឈការ, ក្រសួង-ស្ថាប័ន | ច្បាប់ និង បទប្បញ្ញត្តិត្រូវបានធ្វើវិសោធនកម្មនិងដាក់ឱ្យអនុវត្តជាបណ្តើរៗ<br><br>វិភាជន៍មូលនិធិសម្រាប់ថ្នាក់ក្រោមជាតិ និង ការរៀបចំរបាយការណ៍ត្រូវមានតម្លាភាព និងផ្អែកលើមូលដ្ឋានច្បាស់លាស់ (សូចនាករ *PEFA* ០៨ ) | ច្បាប់និងបទបញ្ញត្តិ ត្រូវបានធ្វើវិសោធនកម្ម<br><br>ដំណើរការវិភាជន៍និងផ្ទេរធនធានតាមរយៈខ្សែបណ្តាយ និង ខ្សែទទឹង ព្រមទាំងប្រព័ន្ធរបាយការណ៍ត្រូវបានរៀបចំ | ច្បាប់និងបទបញ្ញត្តិដែលបានធ្វើវិសោធនកម្មត្រូវបានអនុវត្ត<br><br>ដំណើរការវិភាជន៍និងផ្ទេរធនធានតាមរយៈខ្សែបណ្តោយនិងខ្សែទទឹងព្រមទាំងប្រព័ន្ធរបាយការណ៍ត្រូវបានដាក់ឱ្យអនុវត្តជាជំហានដំបូង | វិភាជន៍មូលនិធិសម្រាប់ថ្នាក់ក្រោមជាតិ និង ការរៀបចំរបាយការណ៍ត្រូវមាន តម្លាភាព និងផ្អែកលើមូលដ្ឋានច្បាស់លាស់ | |

| គោលបំណង/សកម្មភាព | ពេលវេលា (ត្រីមាស) | | | | | | | | | | | | ក្រសួង-ស្ថាប័ន អង្គភាព | សូចនាករគន្លឹះ | គោលដៅ | | | តម្រូវការ ធនធាន |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2008 | | | | 2009 | | | | 2010 | | | | | | 2008 | 2009 | 2010 | |
| | 1 | 2 | 3 | 4 | 1 | 2 | 3 | 4 | 1 | 2 | 3 | 4 | | | | | | |
| **គោលបំណងទី ២៨ ៖ ការកសាងសមត្ថភាពស្ថាប័ន និងវិធានការលើកទឹកចិត្ត** | | | | | | | | | | | | | | | | | | |
| ២៨.១. រៀបចំស្ថាប័នដើម្បីឆ្លើយតបនឹងដំណាក់កាលទី ២ ដោយរួមមាន ៖ ការបញ្ចប់ការវិភាគមុខងារនៅគ្រប់នាយកដ្ឋាននៃកសហវ និង នាយកដ្ឋានហិរញ្ញវត្ថុនៃក្រសួង-ស្ថាប័ន ។ រៀបចំ និងអនុវត្តផែនការយុទ្ធសាស្ត្ររបស់នាយកដ្ឋាននីមួយៗ ។ រៀបចំ និងផ្សព្វផ្សាយឯកសារណែនាំស្តីពីប្រព័ន្ធគ្រប់គ្រង។ រៀបចំគោលនយោបាយសម្រាប់យុទ្ធសាស្ត្រគ្រប់គ្រងព័ត៌មានវិទ្យានៅកសហវ ការកសាងសមត្ថភាពនាយកដ្ឋាន ការប្រើប្រាស់ជំនួយ | | X | X | X | X | X | X | X | X | X | X | X | ក្រុមគាំទ្រទូទៅ/បុគ្គលិក, ព័ត៌មានវិទ្យា, គ្រប់នាយកដ្ឋាន, ក្រសួង-ស្ថាប័ន | បញ្ចប់ការវិភាគមុខងារ<br><br>អនុវត្តផែនការយុទ្ធសាស្ត្ររបស់នាយកដ្ឋាន (នាយកដ្ឋានកសហវ និងនាយកដ្ឋានហិរញ្ញវត្ថុក្រសួង-ស្ថាប័ន ពាក់ព័ន្ធ ) | បញ្ចប់ការវិភាគមុខងារ នៅកសហវ<br><br>ផែនការយុទ្ធសាស្ត្រនាយកដ្ឋាននៃ កសហវ និង ក្រសួងស្ថាប័ន ពាក់ព័ន្ធត្រូវបានរៀបចំនឹងចាប់ផ្តើមអនុវត្ត ។ ការត្រួតពិនិត្យពី | អនុវត្តអនុសាសន៍ ដែលទទួលបានពីការវិភាគមុខងារ<br><br>ពិនិត្យតាមដានត្រួតពិនិត្យឡើងវិញ និងកែសម្រួលផែនការយុទ្ធសាស្ត្រនាយកដ្ឋាន ។ ការត្រួតពិនិត្យពីខាងក្រៅត្រូវបានអនុវត្ត ។ | ពិនិត្យ និងកែសម្រួលផែនការយុទ្ធសាស្ត្រនាយកដ្ឋាន ។ ការត្រួតពិនិត្យពីខាងក្រៅត្រូវបានអនុវត្ត ។ | MDTF/ IDA |

| | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| បច្ចេកទេសប្រកបដោយប្រសិទ្ធ-ភាព ។ កែលម្អការអនុវត្តការងារតាមរយៈការបង្កើនការប្រើប្រាស់បច្ចេកវិទ្យា។ | | | | | | | | | | | | | | រៀបចំនិងអនុវត្តដំណើរការសម្រាប់ការរៀបចំឯកសារណែនាំស្ដីពីប្រព័ន្ធគ្រប់គ្រង<br><br>គោលនយោ-បាយ ស្ដីអំពីការប្រើប្រាស់ជំនួយបច្ចេកទេសត្រូវបានរៀបចំ និងអនុវត្ត។<br>គាំទ្រដល់ វិទ្យា | ខាងក្រៅ ត្រូវបានអនុវត្ត ។<br><br>ដំណើរការ និងឯកសារណែនាំបឋមត្រូវបានរៀបចំ ។<br><br>គោលនយោ-បាយ ស្ដីអំពីការប្រើប្រាស់ជំនួយបច្ចេកទេសត្រូវបានរៀបចំ និងអនុវត្ត។<br>ក្របខ័ណ្ឌគាំទ្រ | ឯកសារណែនាំប្រព័ន្ធគ្រប់គ្រងត្រូវបានរៀបចំនិងផ្សព្វផ្សាយ<br><br>គោលនយោ-បាយស្ដីអំពីការប្រើប្រាស់ជំនួយបច្ចេកទេសត្រូវបានពិនិត្យឡើងវិញ និង កែសម្រួល ។<br>ក្របខ័ណ្ឌគាំទ្រ | ឯកសារណែនាំប្រព័ន្ធគ្រប់គ្រងត្រូវបានរៀបចំនិងផ្សព្វផ្សាយ<br><br>គោលនយោ-បាយស្ដីអំពីការប្រើប្រាស់ជំនួយបច្ចេកទេសត្រូវបានពិនិត្យឡើងវិញ និង កែសម្រួល ។<br>ក្របខ័ណ្ឌគាំទ្រ | |

| | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | | | | | ស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ បណ្តុះបណ្តាលគ្រូបង្គោល<br><br>ដំណើរការបណ្តាញទំនាក់ទំនងនៅក្នុងក្រសួងទាំងមូលសម្រាប់គាំទ្រទំនាក់ទំនង និងការចែករំលែកព័ត៌មាន និងទិន្នន័យរវាងនាយកដ្ឋាន | ដល់វិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបានរៀបចំ ។<br><br>គោលនយោ-បាយ និង ស្តង់ដារព័ត៌មានវិទ្យាត្រូវបានបង្កើត ។ | ដល់វិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវបានអនុវត្ត<br><br>រចនាសម្ព័ន្ធ LAN/ WAN ត្រូវបានប្រើប្រាស់ (ភ្ជាប់ទៅនិង FMIS) | ត្រូវបានពិនិត្យឡើងវិញ និង កែលម្អ<br><br>រចនាសម្ព័ន្ធ LAN/ WAN ត្រូវបានប្រើប្រាស់ (ភ្ជាប់ទៅនិង FMIS) | |
| ២៨.២. ការអភិវឌ្ឍធនធានមនុស្សសម្រាប់ដំណាក់កាលទី ២ ដោយរួមមាន ៖ ការបង្កើតក្រុម | | X | X | X | X | X | | | | | | | ក្រុមគាំទ្រទូទៅ, លេខាធិការដ្ឋាន, វិ.សេដ្ឋកិច្ច និង | អនុវត្តគោលនយោបាយធនធានមនុស្ស | ការត្រួតពិនិត្យឡើងវិញផលប៉ះពាល់នៃ | គោលនយោបាយធនធានមនុស្សត្រូវបាន | គោលនយោបាយធនធានមនុស្សត្រូវបាន | |

| | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| មន្ត្រីចលករ និងការជ្រើសរើសមន្ត្រីពីខាងក្រៅលើជំនាញដែលមិនមានគ្រប់គ្រាន់ ។ រៀបចំឱ្យមានគោលនយោបាយបង្វិលជុំនៃការងារ។ រៀបចំផែនការរក្សាទុកមន្ត្រីដែលមានជំនាញសមស្រប និងសមត្ថភាព | | | | | | | | | | | | | ហិរញ្ញវត្ថុ, បុគ្គលិក, ក្រសួង-ស្ថាប័ន | ដែលបានកែសម្រួលដោយផ្អែកលើការពិនិត្យឡើងវិញរចនាសម្ព័ន្ធស្ថាប័ននៅក្នុងកសហវ និងក្រសួង-ស្ថាប័ន និងផ្អែកលើផែនការយុទ្ធសាស្ត្រនាយកដ្ឋាន | គោលនយោបាយធនធានមនុស្សត្រូវបានបញ្ចប់ ។ បានផ្តល់អនុសាសន៍ជាយុទ្ធសាស្ត្រដល់ការគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្ស៖<br>-ចំនួនបុគ្គលិក<br>-ការជ្រើសរើស<br>-ការរក្សាទុក<br>-បង្វិលជុំការងារ<br>-សមិទ្ធកម្ម<br>-បណ្តុះបណ្តាល | កែសម្រួល និងឯកភាព ហើយចាប់ផ្តើមអនុវត្ត | កែសម្រួល និងអនុវត្ត | |
| ២៨.៣. ការកសាង និងបណ្តុះបណ្តាលជំនាញសម្រាប់ដំណាក់កាលទី២ ដែលមានដូចជា ៖ ការ | | X | X | X | X | X | | | | | | | ក្រុមគាំទ្រទូទៅ/ វិ.សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, | បណ្តុះបណ្តាលមន្ត្រីនៅ កសហវ និង ក្រសួង- | -វិភាគពីតម្រូវការបណ្តុះបណ្តាលជា | ពង្រីកការបណ្តុះបណ្តាល | ពង្រីកការបណ្តុះបណ្តាល | |

| | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ពង្រីកនូវការកសាងជំនាញ និង<br>រៀបចំវគ្គសិក្សាមូលដ្ឋាន ។<br>រៀបចំជាបឋមវគ្គសិក្សាថ្មី<br>សម្រាប់មុខជំនាញសំខាន់ៗ ។<br>ត្រូវចាប់ផ្តើមដំណើរការវគ្គសិក្សា<br>ដែល កសហវ បានរៀបចំ និង<br>រៀបចំ ផែនការកសាងសមត្ថភាព<br>នៅតាមក្រសួង-ស្ថាប័ន ដែលស្ថិត<br>នៅក្នុងក្របខ័ណ្ឌនៃផែនការរបស់<br>កសហវ ។ ស្របពេលគ្នានេះដែរ<br>ត្រូវបន្តរៀបចំផែនការបណ្តុះ<br>បណ្តាលនៅបរទេសជាពិសេស<br>សម្រាប់ក្រុមមន្ត្រីចលករ ព្រម<br>ទាំងរៀបចំ និងអនុវត្តផែនការ<br>ទស្សនកិច្ចសិក្សា | | | | | | | | | | | | | ក្រសួង-ស្ថាប័ន | ស្ថាប័ន<br>-គណនេយ្យ<br>(១.០០០ នាក់)<br>-កុំព្យូទ័រ<br>(១.៥០០ នាក់)<br>-លទ្ធកម្ម<br>(១.០០០ នាក់)<br>-អ្នកគ្រប់គ្រង<br>(៥០០ នាក់)<br><br>រៀបចំ និង<br>អនុវត្តយន្តការ<br>វាយតម្លៃ<br><br>រៀបចំផែនការ<br>បណ្តុះបណ្តាល<br>នៅបរទេស និង<br>ទស្សនកិច្ច | លម្អិត<br>-រៀបចំផែនការ<br>បណ្តុះបណ្តាល<br>តាមលំដាប់<br>លំដោយ<br>-កំណត់ស្ថាប័ន<br>សម្រាប់ផ្តល់<br>ការបណ្តុះ<br>បណ្តាល ( វិទ្យា<br>ស្ថាន សេដ្ឋកិច្ច<br>និង ហិរញ្ញវត្ថុ ឬ<br>នៅខាងក្រៅ )<br>-ចុះកិច្ចសន្យា<br>ជាមួយស្ថាប័ន<br>ដែលផ្តល់ការ<br>បណ្តុះបណ្តាល<br>-រៀបចំវគ្គ និង<br>ឯកសារសម្រាប់ | វាយតម្លៃលើ<br>ការបណ្តុះ<br>បណ្តាលហើយ<br>ធ្វើការកែ<br>សម្រួលក្នុង<br>ករណីចាំបាច់ | វាយតម្លៃលើ<br>ការបណ្តុះ<br>បណ្តាលហើយ<br>ធ្វើការកែ<br>សម្រួលក្នុង<br>ករណីចាំបាច់ | |

| | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | | | | | សិក្សា | បណ្តុះបណ្តាល<br>-សាកល្បង<br>ចាប់ផ្តើមបណ្តុះ<br>បណ្តាល | | | |
| ២៨.៤. រៀបចំឱ្យមានការលើកទឹកចិត្តសម្រាប់ដំណាក់កាលទី២ ដែលមានដូចជា ៖ ពិនិត្យ និងពង្រីកគម្រោងផ្តល់លាភការផ្អែកលើលទ្ធផលការងារ (MBPI) ដោយបន្ថែមចំនួនមន្ត្រី ។ រៀបចំវិធានការដើម្បីគាំទ្រដល់អ្នកដែលប៉ះពាល់ដោយសារការផ្លាស់ប្តូរដំណើរការ និង ស្ថាប័ន ។ រៀបចំវិធីសាស្ត្រសម្រាប់វាយតម្លៃដើម្បីទទួលបានការបណ្តុះបណ្តាលផ្អែកតាមតម្រូវការ ។ បង្កើនឱ្យមានការយល់ដឹង និងចូលរួមនៅក្នុងផែនការកសាងសមត្ថភាព ។ | | X | X | X | X | X | | | | | | | ក្រុមគាំទ្រទូទៅ/<br>បុគ្គលិក,<br>ក្រសួង-ស្ថាប័ន | ពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពគម្រោង MBPI ដើម្បីគាំទ្រផែនការសកម្មភាពដំណាក់កាល ទី ២<br>- ពង្រីកនៅផ្ទៃក្នុងកសហវ<br>- ពង្រីកទៅក្រសួង-ស្ថាប័នពាក់ព័ន្ធ | ការពង្រីកគម្រោង MBPI នៅកសហវ ត្រូវបានបញ្ចប់<br>បញ្ចប់ការរៀបចំការសាកល្បង MBPI នៅក្រសួង-ស្ថាប័ន ពាក់ព័ន្ធ<br>ពង្រីក MBPI ជាបឋមទៅក្រសួង-ស្ថាប័នសាកល្បង | ពង្រីក MBPI ដល់ ក្រសួង-ស្ថាប័នពាក់ព័ន្ធដែលចូលរួមក្នុងកម្មវិធីកំណែទម្រង់ | បន្តពង្រីក MBPI ដល់ក្រសួង-ស្ថាប័នពាក់ព័ន្ធដែលចូលរួមក្នុងកម្មវិធីកំណែទម្រង់ | |

| | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២៨.៥. រៀបចំ និង អនុវត្ត យុទ្ធសាស្ត្រទំនាក់ទំនង និង សម្រប-សម្រួលសម្រាប់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | X | X | X | X | | | | | | | | | គណៈកម្មាធិការកំណែទម្រង់/លេខាធិការដ្ឋានកែទម្រង់ | យុទ្ធសាស្ត្រទំនាក់ទំនង និង សម្រប សម្រួល ត្រូវបានរៀបចំ និង អនុវត្ត<br>-កិច្ចប្រជុំរបស់គណៈកម្មាធិការកែទម្រង់<br>-គេហទំព័ររបស់ PFMRP<br>- ព្រឹត្តិប័ត្ររបស់ PFMRP<br>- PFMRP សង្ខេប<br>- សិក្ខាសាលា/កិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំរបស់ PFMRP | រៀបចំ និង អនុវត្តយុទ្ធសាស្ត្រ ទំនាក់ទំនង និងសម្របសម្រួល<br>-ដំណើរការ គេហទំព័រ<br>-ព្រឹត្តិប័ត្រប្រចាំត្រីមាស<br>-សិក្ខាសាលា ស្តីពីផែនការសកម្មភាពរួម (CAP2)<br><br>-កិច្ចប្រជុំប្រចាំឆ្នាំ | បន្តអនុវត្ត យុទ្ធសាស្ត្រ<br><br>វាយតម្លៃ និង កែសម្រួល ក្នុងករណីចាំបាច់ | បន្តអនុវត្ត យុទ្ធសាស្ត្រ<br><br>វាយតម្លៃ និង កែសម្រួលក្នុងករណីចាំបាច់ | MDTF / IDA |

| | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២៨.៦.កំណត់ និងចងក្រងឯកសារ ស្តីអំពីការទទួលខុសត្រូវរបស់ស្ថាប័ននីមួយៗនិងអង្គភាពសម្របសម្រួលដែលត្រូវចូលរួមនៅក្នុងដំណាក់កាលទី២ | X | X | X | X | | | | | | | | | គណៈកម្មាធិការកំណែទម្រង់/<br>លេខាធិការដ្ឋាន | វិភាគរចនាសម្ព័ន្ធគ្រប់គ្រងកម្មវិធីកែទម្រង់ក្នុងក្របខ័ណ្ឌផែនការសកម្មភាពដំណាក់កាលទី២<br>-កំណត់តួនាទីនិងការទទួលខុសត្រូវ<br>-ផែនការសកម្មភាពរួម<br>-ផែនការសកម្មភាពនាយកដ្ឋាននិងក្រសួង<br>-រៀបចំយន្តការតាមដាន និងការរៀបចំរបាយការណ៍ | កំណត់តួនាទី និង ការទទួលខុសត្រូវ<br><br>រៀបចំផែនការសកម្មភាពរួម និងផែនការសកម្មភាពនាយកដ្ឋាន និងក្រសួង | | | MDTF/ IDA |

| | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២៨.៧. រៀបចំ និងអនុវត្ត យុទ្ធសាស្ត្រសម្រាប់ដាក់បញ្ចូលបញ្ហាប្រទាក់ក្រឡាគ្នាទៅក្នុងការរៀបចំស្ថាប័នសម្រាប់ដំណាក់កាលទី២ | X | X | X | X | X | | | | | | | | គណៈកម្មាធិការកំណែទម្រង់/លេខាធិការដ្ឋាន | រៀបចំយុទ្ធសាស្ត្រដើម្បីដោះស្រាយ<br>–ការងារដែលពាក់ព័ន្ធច្រើនអង្គភាព<br>-ការភ្ជាប់ទំនាក់ទំនងរវាងអង្គភាពពាក់ព័ន្ធ | កំណត់បញ្ហា និងរៀបចំយុទ្ធសាស្ត្រ ដោយរួមទាំងការរៀបចំយន្តការត្រួតពិនិត្យតាមដាន<br>យុទ្ធសាស្ត្រត្រូវបានអនុវត្ត | ពិនិត្យតាមដាន និង កែសម្រួលក្នុងករណីចាំបាច់ | ពិនិត្យតាមដាន និងកែសម្រួលក្នុងករណីចាំបាច់ | MDTF/ IDA |
| ២៨.៨. រៀបចំ និងអនុវត្តយុទ្ធ-សាស្ត្រដើម្បីបង្កើនទំនាក់ទំនងក្នុងកម្រិតបច្ចេកទេស រវាងគណៈកម្មាធិការប្រតិបត្តិ និងទីប្រឹក្សាផ្នែកគ្រប់គ្រងហិរញ្ញវត្ថុ | X | X | X | X | X | | | | | | | | | | | | | |
| ២៨.៩. កែលម្អអង្គភាពសម្របសម្រួល តួនាទី ការទទួលខុសត្រូវ នីតិវិធី និងឯកភាពទៅលើក្របខ័ណ្ឌធនធាន | X | X | X | X | X | | | | | | | | គណៈកម្មាធិការកំណែទម្រង់/លេខាធិការដ្ឋាន | ដំណើរការយន្តការសម្របសម្រួល<br>-តួនាទី/ការទទួលខុសត្រូវ<br>-សមត្ថភាព<br>-គោលដៅនៃសមិទ្ធកម្ម | ចងក្រងឯកសារស្តីពី ៖<br>-តួនាទី/ការទទួលខុសត្រូវ<br>-សមត្ថភាព<br>-គោលដៅនៃសមិទ្ធិកម្ម<br>-នីតិវិធី | ពិនិត្យតាមដាន និងកែសម្រួលក្នុងករណីចាំបាច់ | ពិនិត្យតាមដាន និងកែសម្រួលក្នុងករណីចាំបាច់ | MDTF/ IDA |

| | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | | | | | -នីតិវិធី<br>-ធនធាន<br>-យន្តការតាម-ដាន និង របាយការណ៍ | -ធនធាន<br>-យន្តការ តាមដាននិង របាយការណ៍<br><br>អនុវត្តតាមការរៀបចំខាងលើ | | | |
| ២៨.១០. ពិនិត្យតាមដាន និង វាយតម្លៃវឌ្ឍនភាពដើម្បីសម្រេចបានចក្ខុវិស័យដំណាក់កាលទី២ តាមរយៈការអនុវត្តផែនការ សកម្ម-ភាពរួមដំណាក់កាល ទី២ ។ ធ្វើបច្ចុប្បន្នភាពផែនការសកម្មភាពរួមដំណាក់កាលទី២ ក្នុងករណីចាំបាច់ | X | X | X | X | X | X | X | X | X | X | X | X | គណៈកម្មាធិការកំណែទម្រង់/ លេខាធិការដ្ឋាន | របាយការណ៍វឌ្ឍនភាពប្រចាំត្រីមាស និង ប្រចាំឆ្នាំ និង របាយការណ៍ហិរញ្ញវត្ថុ និង សវនកម្ម<br><br>ការវាយតម្លៃឯករាជ្យប្រចាំឆ្នាំ<br>-កិច្ចប្រជុំប្រចាំ | របាយការណ៍វឌ្ឍនភាពកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញ-វត្ថុសាធារណៈ<br><br>របាយការណ៍របស់ក្រុមវាយតម្លៃឯករាជ្យ | របាយការណ៍វឌ្ឍនភាពកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញ-វត្ថុសាធារណៈ<br><br>របាយការណ៍របស់ក្រុមវាយតម្លៃឯករាជ្យ | របាយការណ៍វឌ្ឍនភាពកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញ-វត្ថុសាធារណៈ<br><br>របាយការណ៍របស់ក្រុមវាយតម្លៃឯករាជ្យ | MDTF/ IDA |

| | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | | | | | ខែរបស់គណៈ<br>កម្មការកែ<br>ទម្រង់ និង<br>គណៈកម្មការ<br>ដៃគូអភិវឌ្ឍន៍<br>-កិច្ចប្រជុំប្រចាំ<br>ត្រីមាសរបស់<br>គណៈកម្មាធិ-<br>ការកែទម្រង់<br>និងក្រុមការងារ<br>បច្ចេកទេស<br>-កិច្ចប្រជុំត្រួត<br>ពិនិត្យប្រចាំឆ្នាំ | | | | |

# ផ្នែកទី ៣

# ផែនការសកម្មភាពសម្រាប់ជំហានបន្ទាប់ដែលត្រូវចាប់ផ្តើមជាបណ្តើរៗ

| គោលបំណង/សកម្មភាព | ពេលវេលា (ត្រីមាស) | | | | | | | | | | | | ក្រសួង-ស្ថាប័ន អង្គភាព | សូចនាករគន្លឹះ | គោលដៅ | | | តម្រូវការធនធាន |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2008 | | | | 2009 | | | | 2010 | | | | | | 2008 | 2009 | 2010 | |
| | 1 | 2 | 3 | 4 | 1 | 2 | 3 | 4 | 1 | 2 | 3 | 4 | | | | | | |
| **គោលបំណងទី ៣១ ៖ ការកែលម្អ និងការពង្រីកការអនុវត្តថវិកាតាមកម្មវិធី** | | | | | | | | | | | | | | | | | | |
| ៣១.១. ពិនិត្យឡើងវិញ និង កែលម្អការអនុវត្តថវិកាតាមកម្មវិធី | | X | X | X | X | X | X | X | X | X | X | X | ក្រុមរៀបចំថវិកា/ ថវិកា, ក្រសួង-ស្ថាប័ន | បង្កើនបទពិសោធន៍បន្ថែមទៀត ពីការអនុវត្តថវិកាតាមកម្មវិធីដើម្បីឆ្ពោះទៅពង្រីកវិសាលភាពពេញលេញនៅជំហានទី៣ និងទី៤ (សូចនាករ PEFA ៥) | បន្តការសាកល្បងឱ្យកាន់តែស៊ីជម្រៅចំពោះក្រសួងទាំង ៨ ហើយត្រូវពិនិត្យឡើងវិញលើក្របខ័ណ្ឌជាទស្សនៈ និងការអនុវត្តសាកល្បងថវិកាតាមកម្មវិធី | បន្តការសាកល្បងឱ្យកាន់តែស៊ីជម្រៅ | បន្តការសាកល្បងឱ្យកាន់តែស៊ីជម្រៅ | MDTF/ IDA |
| ៣១.២ រៀបចំយុទ្ធសាស្ត្រដើម្បីពង្រីកថវិកាតាមកម្មវិធី | | X | X | X | X | X | X | X | X | X | X | X | ក្រុមរៀបចំថវិកា/ ថវិកា, ក្រសួង-ស្ថាប័ន | | | | | |

| | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៣១.៣. អនុវត្តផែនការបណ្តុះបណ្តាលនិងការកសាងសមត្ថភាពសម្រាប់អនុវត្តថវិកាតាមកម្មវិធី | | X | X | X | X | X | X | X | X | X | X | X | ក្រុមរៀបចំថវិកា/ថវិកា, ក្រសួង-ស្ថាប័ន | រៀបចំផែនការបណ្តុះបណ្តាល និងផ្តល់ការបណ្តុះបណ្តាល | បញ្ចប់ការរៀបចំផែនការ និង ឯកសារបណ្តុះបណ្តាល និង បណ្តុះបណ្តាលគ្រូបង្គោល<br><br>សាកល្បងអនុវត្តការបណ្តុះបណ្តាលបឋម | បន្តពង្រីកការបណ្តុះបណ្តាល | បន្តពង្រីកការបណ្តុះបណ្តាល | |

| គោលបំណង/សកម្មភាព | ពេលវេលា (ត្រីមាស) | | | | | | | | | | | | ក្រសួង-ស្ថាប័ន អង្គភាព | សូចនាករគន្លឹះ | គោលដៅ | | | តម្រូវការ ធនធាន |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2008 | | | | 2009 | | | | 2010 | | | | | | 2008 | 2009 | 2010 | |
| | 1 | 2 | 3 | 4 | 1 | 2 | 3 | 4 | 1 | 2 | 3 | 4 | | | | | | |
| **គោលបំណងទី ៣២ ៖ បន្តកែលម្អភាពគ្រប់ជ្រុងជ្រោយ និង ការធ្វើសមាហរណកម្មថវិកា** | | | | | | | | | | | | | | | | | | |
| ៣២.១.រៀបចំគោលនយោបាយសម្រាប់ធ្វើសមាហរណកម្មថវិកា។ បន្តកែលម្អការធ្វើសមាហរណកម្មថវិកាចរន្ត និងមូលធនតាមរយៈការបន្តអនុវត្តក្របខ័ណ្ឌចំណាយរយៈពេលមធ្យម (MTEF) ផែនការយុទ្ធសាស្ត្រថវិកា (BSPs) និង ថវិកាតាមកម្មវិធី (BP) ។ ឆ្លុះបញ្ចាំងទិដ្ឋភាពការកាត់បន្ថយភាពក្រីក្រ និងយែនឌ័រទៅក្នុងគោលការណ៍ណែនាំស្ដីពីផែនការយុទ្ធសាស្ត្រថវិកា និងថវិកាតាមកម្មវិធី | | X | X | X | X | X | X | X | X | X | X | X | ក្រុមរៀបចំថវិកា, ក្រុមគោលនយោបាយ/ថវិកា, វិនិយោគ, គោលនយោបាយក្រសួង-ស្ថាប័ន | អនុវត្តជាបណ្ដើរៗ យុទ្ធសាស្ត្រសម្រាប់គណនាតម្រូវការចំណាយតាមវិស័យ<br><br>អនុវត្តជាបណ្ដើរៗ ក្របខ័ណ្ឌពហុឆ្នាំ<br><br>( សូចនាករ PEFA ៦និង៧ ) | គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធបានបញ្ជូន BSPs មក កសហវ<br><br>គ្រប់ចំណាយទាំងអស់ដែលធ្វើហិរញ្ញប្បទានដោយរដ្ឋាភិបាលត្រូវបញ្ចូលទៅក្នុង MTEF | វាយតម្លៃលើគុណភាពនៃការរៀបចំ BSP ទៅគ្រប់ក្រសួង-ស្ថាប័ន និងសាកល្បងនៅតាមខេត្ត-ក្រុង<br><br>គ្រប់ចំណាយទាំងអស់ដែលធ្វើហិរញ្ញប្បទានដោយរដ្ឋាភិបាល និង យ៉ាងហោច ៥0% នៃចំណាយហិរញ្ញ- | វាយតម្លៃលើគុណភាពនៃការរៀបចំ BSP ទៅគ្រប់ក្រសួង - ស្ថាប័ន និងសាកល្បងនៅតាមខេត្ត-ក្រុង<br><br>គ្រប់ចំណាយទាំងអស់ដែលធ្វើហិរញ្ញប្បទានដោយរដ្ឋាភិបាល និង យ៉ាងហោច ៧៥% នៃចំណាយហិរញ្ញ- | MDTF/ IDA |

| | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | | | | | | | ឬទានដោយដៃគូអភិវឌ្ឍន៍ ត្រូវបញ្ចូលទៅក្នុង MTEF | ឬទានដោយដៃគូអភិវឌ្ឍន៍ ត្រូវបញ្ចូលទៅក្នុង MTEF | |
| ៣២.២. បន្តបញ្ចូលចំណូល-ចំណាយដែលនៅក្រៅបរិបថថវិកាទៅក្នុងថវិកាប្រចាំឆ្នាំ រួមទាំងការបង្កើនជាបណ្តើរៗ នូវការបញ្ចូលមូលនិធិពីដៃគូអភិវឌ្ឍន៍ទៅក្នុងថវិកាប្រចាំឆ្នាំ | | X | X | X | X | X | X | X | X | X | X | X | ក្រុមរៀបចំថវិកា/ថវិកា, វិនិយោគ, ក្រសួង-ស្ថាប័ន | | សិក្សា និងវាយតម្លៃទំហំនៃចំណាយក្រៅបរិបថថវិការបស់រដ្ឋាភិបាល ហើយកំណត់បន្ទាត់គោល | កាត់បន្ថយចំណាយក្រៅបរិបថថវិការបស់រដ្ឋាភិបាល ៥% លើបន្ទាត់គោល និង យ៉ាងហោច ៥០% នៃដៃគូអភិវឌ្ឍន៍ផ្តល់របាយការណ៍ប៉ាន់ប្រមាណចំណាយវិនិយោគ ហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ | កាត់បន្ថយចំណាយក្រៅបរិបថថវិការបស់រដ្ឋាភិបាល ១០% លើបន្ទាត់គោល និង យ៉ាងហោច ៧៥% នៃដៃគូអភិវឌ្ឍន៍ផ្តល់របាយការណ៍ប៉ាន់ប្រមាណចំណាយវិនិយោគហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ | MDTF/ IDA |

# ឧបសម្ព័ន្ធទី ២

# យន្តការដឹកនាំ និងសម្របសម្រួល

# យន្តការដឹកនាំ និងសម្របសម្រួល

ជាទូទៅ យន្តការដឹកនាំ និងសម្របសម្រួលសម្រាប់ការអនុវត្តជំហានទី១/ដំណាក់កាលទី១ មានប្រសិទ្ធភាព ដែលរចនាសម្ព័ន្ធដឹកនាំ និងយន្តការសម្របសម្រួលនេះ មានដូចខាងក្រោម ៖

- ក្រុមការងារបច្ចេកទេសគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFMTWG) ដឹកនាំដោយរដ្ឋាភិបាលជាមួយអ្នកសម្របសម្រួលដៃគូអភិវឌ្ឍន៍ គឺជាវេទិកាប្រកបដោយប្រសិទ្ធភាពដើម្បីពិនិត្យតាមដាន និងធ្វើសេចក្តីសម្រេចកម្រិតខ្ពស់រវាងរដ្ឋាភិបាល និង ដៃគូអភិវឌ្ឍន៍ ។ សមាសភាពនៃក្រុមការងាររួមមានសមាជិកទាំងអស់របស់គណៈកម្មាធិការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដៃគូអភិវឌ្ឍន៍ទាំងអស់ និង តំណាងមកពីក្រសួងចំនួន ១១ ។ ក្រុមការងារបច្ចេកទេសធ្វើការប្រជុំតាមត្រីមាស និងអាចធ្វើការប្រជុំផ្អែកតាមភាពចាំបាច់ ។
- គណៈកម្មាធិការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដឹកនាំដោយរដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រួមជាមួយប្រធាននាយកដ្ឋានទាំងអស់ជាសមាជិក ។ គណៈកម្មាធិការនេះ គឺជាវេទិកាដ៏មានប្រសិទ្ធភាពមួយសម្រាប់ធ្វើការត្រួតពិនិត្យ និងធ្វើការសម្រេចចិត្តផ្នែកបច្ចេកទេសក្នុងកម្រិតខ្ពស់ក្នុងក្របខ័ណ្ឌរដ្ឋាភិបាល ។ គណៈកម្មាធិការធ្វើការប្រជុំប្រចាំខែ និងអាចធ្វើការប្រជុំផ្អែកតាមភាពចាំបាច់ ។
- គណៈកម្មាធិការដៃគូអភិវឌ្ឍន៍ គឺជាវេទិកាដ៏មានប្រសិទ្ធភាពសម្រាប់ការសម្របសម្រួល និងត្រួតពិនិត្យផ្នែកបច្ចេកទេសក្នុងកម្រិតខ្ពស់ក្នុងរង្វង់ដៃគូអភិវឌ្ឍន៍ ។ គណៈកម្មាធិការធ្វើការប្រជុំប្រចាំខែនិងអាចធ្វើការប្រជុំផ្អែកតាមភាពចាំបាច់ ។
- លេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់ទទួលបន្ទុកជួយដល់គណៈកម្មាធិការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈលើផ្នែកបច្ចេកទេស និងរដ្ឋបាលក៏ដូចជាសម្របសម្រួល និងជួយដល់គ្រប់នាយកដ្ឋាន និងដៃគូអភិវឌ្ឍន៍ ។

## គំនូសបំព្រួញទី១ ៖ យន្តការដឹកនាំ និងសម្របសម្រួលដំណាក់កាលទី១




ដូចបានបញ្ជាក់នៅក្នុងសេចក្តីផ្តើមនៃដំណាក់កាលទី២ ខាងលើ ការចូលរួមប្រកបដោយភាពស័ក្តិសិទ្ធិនៃអង្គភាពថវិការបស់ក្រសួង-ស្ថាប័ន គឺជាប្រការសំខាន់ណាស់សម្រាប់ការអនុវត្តដំណាក់កាលជាបន្តបន្ទាប់នៃកំណែទម្រង់ ។ កិច្ចខិតខំពង្រឹងសមត្ថភាពត្រូវរៀបចំឱ្យកាន់តែប្រសើរ និងកាន់តែខ្លាំងក្លា ព្រោះថាដំណាក់កាលបន្ទាប់នៃកម្មវិធីកំណែទម្រង់ មិនអាចអាស្រ័យតែលើក្រសួងសេដ្ឋកិច្ច និងហិរញ្ញ-វត្ថុប៉ុណ្ណោះទេ ប៉ុន្តែត្រូវពឹងផ្អែកលើក្រសួង-ស្ថាប័នទាំងអស់ ។ ការចូលរួមពីបណ្តាក្រសួង-ស្ថាប័នទាំងអស់ដូចក្នុងដំណាក់កាលទី១ មិនគ្រប់គ្រាន់ទេសម្រាប់ការអនុវត្តដំណាក់កាលបន្ទាប់នៃកំណែទម្រង់។ ក្រសួង-ស្ថាប័នត្រូវមានភាពជាម្ចាស់ មានការទទួលខុសត្រូវដោយផ្ទាល់ និងមានតួនាទីដឹកនាំ ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុថ្មី ។ ដូច្នេះ រចនាសម្ព័ន្ធដឹកនាំ និងយន្តការសម្របសម្រួលត្រូវបានកែលម្អ ដូចខាងក្រោម ៖

- ធ្វើការកែសម្រួលអនុក្រឹត្យស្តីពីគណៈកម្មាធិការគោលនយោបាយ និងសេដ្ឋកិច្ច ដែលដឹកនាំដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពង្រីកវិសាលភាពគ្រប់គ្រងលើកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ គណៈកម្មាធិការនេះជាវេទិកាកម្រិតខ្ពស់ដែលមានសមាសភាពរដ្ឋមន្ត្រីពីក្រសួង-ស្ថាប័ន សំខាន់មួយចំនួនជាសមាជិក ។
- បង្កើតគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដឹកនាំដោយរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលមានសមាសភាពចូលរួមពីថ្នាក់អគ្គនាយក ឬ អគ្គលេខាធិការទទួលបន្ទុកផ្នែកហិរញ្ញវត្ថុពីគ្រប់ក្រសួង-ស្ថាប័ន ។ គណៈ-កម្មាធិការនេះ ជាវេទិកាបច្ចេកទេសកម្រិតខ្ពស់ដើម្បីគ្រប់គ្រង តាមដាន និងសម្របសម្រួលការអនុវត្តកម្មវិធីកំណែទម្រង់ ។

- គណៈកម្មាធិការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅជំហានទី១ ប្រែក្លាយជាគណៈកម្មការកែទម្រង់ហិរញ្ញវត្ថុសាធារណៈនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដឹកនាំដោយរដ្ឋលេខាធិការ និងមានអគ្គនាយក ព្រមទាំងប្រធាននាយកដ្ឋានទាំងអស់នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសមាជិក។
- កែសម្រួលលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់ ដែលបំពេញកិច្ចការជួយដល់គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង គណៈកម្មការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ ផ្តល់ការគាំទ្រដល់គ្រប់នាយកដ្ឋាននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈនៅតាមបណ្តាក្រសួង-ស្ថាប័ន ។
- បង្កើតក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅតាមក្រសួង-ស្ថាប័ន ដែលដឹកនាំដោយអគ្គលេខាធិការ/អគ្គនាយក ទទួលបន្ទុកផ្នែកហិរញ្ញវត្ថុ និងជាសមាជិកនៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ សមាជិកនៃក្រុមការងារនេះ ត្រូវជាប្រធាននាយកដ្ឋានហិរញ្ញវត្ថុ ឬ គណនេយ្យ ប្រធាននាយកដ្ឋានផែនការ និងប្រធានអង្គភាពគ្រប់គ្រងគម្រោង ។

## គំនូសបំព្រួញទី២ ៖ យន្តការដឹកនាំ និងសម្របសម្រួលដំណាក់កាលទី២



# ឧបសម្ព័ន្ធទី ៣

# យន្តការសម្រាប់ការចូលរួមរបស់ក្រសួង-ស្ថាប័ន

# យន្តការសម្រាប់ការចូលរួមរបស់ក្រសួង-ស្ថាប័ន

ការចូលរួមយ៉ាងសកម្មរបស់ក្រសួង-ស្ថាប័ន និងអង្គភាពថវិកាគឺជាប្រការសំខាន់នៅក្នុងដំណើរការកំណែទម្រង់ជំហានទី២ ។ ឧបសម្ព័ន្ធនេះ បង្ហាញអំពីយន្តការដើម្បីសម្រេចបានការចូលរួមនេះ ។

ក្រសួង-ស្ថាប័នទាំងអស់នឹងតម្រូវឱ្យរៀបចំផែនការសកម្មភាពរបស់ខ្លួនដោយផ្អែកលើក្របខ័ណ្ឌដែលបានកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ សកម្មភាពការងារមួយចំនួនអាចត្រូវបានបង្កើតដោយក្រសួង-ស្ថាប័នផ្ទាល់ ប៉ុន្តែសកម្មភាពការងារភាគច្រើននឹងត្រូវបានចង្អុលបង្ហាញជាបឋមដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលក្រសួង-ស្ថាប័នត្រូវឆ្លើយតប ។ ក្រសួង-ស្ថាប័ននឹងត្រូវបានពន្យល់អំពីចរិតលក្ខណៈនៃការចូលរួមរបស់ខ្លួនទៅតាមផ្នែកជាក់ស្តែងនីមួយៗ ។ ក្រសួង-ស្ថាប័ននឹងត្រូវបានផ្តល់ជំនួយហិរញ្ញប្បទាន និងជំនួយបច្ចេកទេស ។ មន្ត្រីដែលធ្វើការក្នុងកំណែទម្រង់នឹងទទួលបានការផ្តល់លាភការតាមលទ្ធផលការងារ ។ ជាពិសេស ឧបសម្ព័ន្ធនេះបង្ហាញអំពី ៖

- ដំណើរការនៃការចូលរួម
- ការរៀបចំផែនការសកម្មភាពការងារ និងការកសាងសមត្ថភាព
- ធនធានដែលត្រូវផ្តល់ដល់ក្រសួង-ស្ថាប័ន
- ក្របខ័ណ្ឌត្រួតពិនិត្យតាមដានវឌ្ឍនភាព

ការរៀបចំរចនាសម្ព័ន្ធដើម្បីឱ្យក្រសួង-ស្ថាប័ន ចូលរួមក្នុងក្របខ័ណ្ឌដឹកនាំ និង ត្រួតពិនិត្យតាមដានត្រូវបានបង្ហាញនៅក្នុងឧបសម្ព័ន្ធទី ២ ខាងលើ ។

## *ដំណើរការនៃការចូលរួម*

ដើម្បីគាំទ្រដល់ការចូលរួមរបស់ក្រសួង-ស្ថាប័ន យន្តការនៃដំណើរការចូលរួមត្រូវបានបង្ហាញ ដូចខាងក្រោម ៖

| **ការបង្ហាញ និងការប្រឹក្សាជាបឋម** | |
|---|---|
| ១. ការប្រឹក្សាអំពីទម្រង់ និងខ្លឹមសារ ( គោលបំណង និងសកម្មភាព ) នៃផែនការជំហានទី២ | • រៀបចំសិក្ខាសាលាបឋម ស្តីពីសេចក្តីព្រាងផែនការសកម្មភាពរួម<br>• បន្តរៀបចំសិក្ខាសាលា ស្តីពីផែនការសកម្មភាពរួមសម្រេចចុងក្រោយ |

| | |
|---|---|
| **រៀបចំរចនាសម្ព័ន្ធស្ថាប័ន** | |
| ២. តម្រូវឱ្យមានការបង្កើតឡើងនូវក្រុមការងារកំណែទម្រង់នៅតាមក្រសួង-ស្ថាប័ន | • ការបង្កើតក្រុមការងារត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល<br>• ជូនដំណឹងដល់ កសហវ ស្តីពីរចនាសម្ព័ន្ធ និងសមាជិកភាពរបស់ក្រុមការងារដែលបានបង្កើត |
| ៣. រៀបចំក្រសួង-ស្ថាប័ន ជាក្រុមៗ ដើម្បីងាយស្រួលក្នុងការសម្របសម្រួល | • បង្កើតជាបួនក្រុមដើម្បីឱ្យស្របទៅតាមគោលបំណងនៃថវិកាដែលបានបែងចែកជាបួនវិស័យ |
| ៤. បង្កើតយន្តការសម្របសម្រួល | សូមពិនិត្យមើលនៅក្នុងឧបសម្ព័ន្ធទី២ |
| **កំណត់សកម្មភាពការងារដែលក្រសួង-ស្ថាប័នត្រូវចូលរួម** | |
| ៥. នាយកដ្ឋានទាំងអស់របស់ កសហវ ត្រូវកំណត់សកម្មភាពការងារដែលត្រូវឱ្យក្រសួង-ស្ថាប័ន នីមួយៗចូលរួម | • នាយកដ្ឋាននីមួយៗរបស់ កសហវ ត្រូវកំណត់ពីសកម្មភាពការងារដែលតម្រូវឱ្យមានការចូលរួមទាំងនៅក្នុងផែនការសកម្មភាពរួមទាំងនៅក្នុងផែនការសកម្មភាពលម្អិតរបស់នាយកដ្ឋាន<br>• នាយកដ្ឋានទាំងអស់ត្រូវរៀបចំតារាងសង្ខេបស្តីពីតម្រូវការនៃការចូលរួម |
| ៦. ផ្តល់តារាងសង្ខេបស្តីពីតម្រូវការនៃការចូលរួមដល់ក្រសួង-ស្ថាប័ន | • រៀបចំសិក្ខាសាលាដើម្បីណែនាំដល់ក្រសួង-ស្ថាប័ន និងជួយសម្របសម្រួលក្នុងការពិភាក្សា |
| **ការរៀបចំផែនការសកម្មភាពដោយក្រសួង-ស្ថាប័ន** | |
| ៧. ការរៀបចំផែនការសកម្មភាពការងារ | • ក្រសួង-ស្ថាប័ន រៀបចំផែនការសកម្មភាពការងាររបស់ខ្លួនទៅតាមទម្រង់ដែលបានកំណត់ដោយគណៈកម្មាធិការដឹកនាំការងារកែទម្រង់ |
| ៨. ការរៀបចំផែនការកសាងសមត្ថភាព | • ក្រសួង-ស្ថាប័ន រៀបចំផែនការកសាងសមត្ថភាពរបស់ខ្លួនទៅតាមទម្រង់ដែលបានកំណត់ដោយគណៈកម្មាធិការដឹកនាំការងារកែទម្រង់ |
| ៩. គណៈកម្មាធិការដឹកនាំការងារកែទម្រង់ អនុម័តលើផែនការសកម្មភាព | • បញ្ជូនផែនការដែលបានរៀបចំមកគណៈកម្មាធិការដឹកនាំការងារកែទម្រង់ |

| | |
|---|---|
| ការងារ និង ផែនការកសាងសមត្ថភាពរបស់ក្រសួង-ស្ថាប័ន | • ការពិនិត្យ និងពិភាក្សា<br>• គណៈកម្មាធិការដឹកនាំការងារកែទម្រង់ផ្តល់ការអនុម័ត |
| **ផ្តល់ការគាំទ្រ និងការប្រឹក្សា** | |
| ១០. ការគាំទ្រពីទីប្រឹក្សាស្នូល | • ទីប្រឹក្សាស្នូលរបស់គណៈកម្មាធិការដឹកនាំការងារកែទម្រង់នៅក្នុងផ្នែកគន្លឹះទាំង៨ ត្រូវបានជ្រើសរើស ហើយអាចជួយដល់ក្រសួង-ស្ថាប័នក្នុងការរៀបចំផែនការនៅពេលមានតម្រូវការ |
| ១១. ការគាំទ្រពីវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងលេខាធិការដ្ឋាន | • វិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងលេខាធិការដ្ឋានត្រៀមខ្លួនផ្តល់ការណែនាំដល់ក្រសួង-ស្ថាប័ន ក្នុងការរៀបចំផែនការសកម្មភាព |
| ១២. កំណត់ពីជំនួយបច្ចេកទេស ដែលក្រសួង-ស្ថាប័ន ត្រូវការ | • កំណត់ពេលវេលាដែលត្រូវការទីប្រឹក្សា និង ធនធានរបស់កម្មវិធីដែលមានស្រាប់នៅតាមផ្នែក<br>• កំណត់តម្រូវការគាំទ្របន្ថែមពីក្រុមទីប្រឹក្សាស្នូល |
| ១៣. បង្កើតកម្មវិធីទំនាក់ទំនង | • រៀបចំកម្មវិធី<br>• អនុវត្តកម្មវិធី |

## *ការរៀបចំផែនការសកម្មភាព និងផែនការកសាងសមត្ថភាពរបស់ក្រសួង-ស្ថាប័ន*

ក្រសួង-ស្ថាប័ន ត្រូវបង្កើតផែនការសកម្មភាព និងផែនការកសាងសមត្ថភាពរបស់ខ្លួនស្របតាមទម្រង់ផែនការសកម្មភាពរបស់ កសហវ ។ បទបង្ហាញអំពីទម្រង់នេះ នឹងត្រូវផ្តល់ជូនដល់ក្រសួង-ស្ថាប័ន ស្របតាមនីតិវិធីដែលបានបញ្ជាក់ដូចខាងលើ ។

បណ្តាផ្នែកទាំងឡាយកំណត់ដោយផែនការសកម្មភាពរួម ដែលតម្រូវឱ្យក្រសួង-ស្ថាប័នចូលរួម និងប្រភេទនៃសកម្មភាពចូលរួមមានបង្ហាញនៅក្នុងតារាង « ជំហានទី២/ ដំណាក់កាលទី២ ៖ សកម្មភាពដែលតម្រូវឱ្យមានការចូលរួមពីក្រសួង-ស្ថាប័ន » ។

*ជំហានទី២/ដំណាក់កាលទី២ ៖ សកម្មភាពដែលតម្រូវឱ្យមានការចូលរួមពីក្រសួង-ស្ថាប័ន*

| ចង្កោមសកម្មភាព | ប្រភេទនៃសកម្មភាពចូលរួមរបស់ក្រសួង-ស្ថាប័ន |
|---|---|
| **ក្រុមប្រមូលចំណូល** | |
| **គោលបំណងទី ១១ ៖ បន្តកែលម្អរដ្ឋបាល និងគោលនយោបាយចំណូល** | |
| ១១.១. កែសម្រួល និង អនុវត្តគោលនយោបាយចំណូលរយៈពេលមធ្យម | • ត្រូវមានការសហការពីសំណាក់ក្រសួង-ស្ថាប័ន ដើម្បីជំរុញឱ្យអនុវត្តនូវលក្ខខណ្ឌដែលមាននៅក្នុងកិច្ចសន្យាដើម្បីទូទាត់បំណុល ។<br>• ក្រសួង-ស្ថាប័ន និង អាជ្ញាធរដែនដីត្រូវផ្តល់ព័ត៌មានអំពីប្រភពចំណូលថ្មីៗ ។<br>• ពិភាក្សាជាមួយក្រសួង-ស្ថាប័នស្តីពីយន្តការប្រមូល គ្រប់គ្រង និងតាមដានចំណូលមិនមែនសារពើពន្ធ ។<br>• ផ្តល់ទិន្នន័យធាតុចូល ជាពិសេសក្រសួងមហាផ្ទៃ ក្រសួងទេសចរណ៍ និងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដើម្បីរៀបចំក្របខ័ណ្ឌច្បាប់ស្តីពីល្បែងស៊ីសង ។<br>• ត្រូវការធាតុចូលលើគោលនយោបាយសារពើពន្ធស្តីពីល្បែងស៊ីសងពីក្រសួង-ស្ថាប័ន ។<br>• ត្រូវការនូវគោលការណ៍ណែនាំច្បាស់លាស់ពីរដ្ឋាភិបាលដើម្បីសើរើ និងពន្លឿននូវការអនុម័តក្របខ័ណ្ឌច្បាប់ស្តីពីល្បែងស៊ីសង និងពីទីស្តីការគណៈរដ្ឋមន្ត្រីដើម្បីទទួលបាននូវធាតុចូលយ៉ាងសកម្មសម្រាប់ការប្រជុំ និងដំណើរការអនុម័ត ។<br>• ការចូលរួមយ៉ាងសកម្មរបស់ ក្រសួង-ស្ថាប័ន ( ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងសាធារណការ ក្រសួងទេសចរណ៍ ក្រសួងសុខាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងយុត្តិធម៌ ) ដើម្បីចូលរួមក្នុងការប្រជុំ និងក្នុងដំណើរការអនុម័តបទបញ្ញត្តិស្តីអំពីធានារ៉ាប់រង ។<br>• ធ្វើការសិក្សាស្ទាបស្ទង់ទូទាំងប្រទេសស្តីពីស្ថាប័នមីក្រូហិរញ្ញវត្ថុនៅក្រៅទីផ្សារមីក្រូហិរញ្ញវត្ថុផ្លូវការ ដើម្បីកំណត់នូវទីផ្សារមីក្រូហិរញ្ញវត្ថុក្រៅផ្លូវការ (ធានារ៉ាប់រង) ។<br>• ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ធនាគារជាតិ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ធនាគារអភិវឌ្ឍន៍អាស៊ី ក្រសួងមហាផ្ទៃ និងក្រសួងពាណិជ្ជកម្ម ត្រូវចូលរួមយ៉ាងសកម្ម |

| | |
|---|---|
| | នៅក្នុងកិច្ចប្រជុំ និងឆ្លើយតបទៅនឹងតម្រូវការឯកសារ និងជួយទប់ស្កាត់នូវសកម្មភាពជំនួញ អចលនទ្រព្យខុសច្បាប់របស់ក្រុមហ៊ុន ។ |
| ១១.៥. បន្តកែលម្អគោលនយោបាយ និងរដ្ឋបាលចំណូលមិនមែនសារពើពន្ធរួមទាំងទ្រព្យសម្បត្តិរដ្ឋ | • ត្រូវការធាតុចូលពីក្រសួង-ស្ថាប័ន ដើម្បីធ្វើសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ។<br>• បង្កើតក្រុមការងារ/គណៈកម្មការ ដែលរួមមានតំណាងពី ក្រសួង-ស្ថាប័ន ដើម្បីធ្វើសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ។ អនុគណៈកម្មការចំនួនពីរនឹងត្រូវបង្កើតឡើង ដើម្បីទទួលខុសត្រូវក្នុងការប្រមូលឯកសារបច្ចេកទេស និងធ្វើសេចក្តីព្រាងច្បាប់ ។<br>• កសហវ និង កអក ត្រូវដឹកនាំធ្វើសេចក្តីព្រាងអនុក្រឹត្យ ។<br>• ក្រសួង-ស្ថាប័ន ត្រូវមានវិធានការនិងនីតិវិធីដើម្បីគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋដែលមាននៅអង្គភាពស្វយ័តក្រោមការគ្រប់គ្រងរបស់ខ្លួន ។<br>• ក្រសួង-ស្ថាប័ន ត្រូវផ្តល់ព័ត៌មានពាក់ព័ន្ធសម្រាប់រៀបចំគោលនយោបាយចំណូល ។<br>• ក្រសួង-ស្ថាប័ន ត្រូវរៀបចំជាក្រុមការងារដើម្បីត្រៀមសហការជាមួយ កសហវ លើបញ្ហាផ្សេងៗ ។<br>• សើរើក្របខ័ណ្ឌច្បាប់ដែលមាន និងលើកសំណើដើម្បីធ្វើការកែសម្រួល ។<br>• ក្រសួង-ស្ថាប័ន ត្រូវផ្តល់មតិ និងព័ត៌មានត្រឡប់ស្តីពីសេចក្តីព្រាងបង្កាន់ដៃជាតិផ្តល់តួលេខ និងព័ត៌មានស្តីពីការប្រមូលចំណូល ការបង់ចំណូលទៅរតនាគារជាតិ បំណុល និង ចំណូល ។<br>• លើកសំណើស្តីពីប្រព័ន្ធលើកទឹកចិត្ត និងពិភាក្សាជាមួយ កសហវ ។<br>• សហការជាមួយមន្ត្រីដែលបានចាត់តាំងដើម្បីតាមដានការប្រមូលចំណូលនៅក្រសួង-ស្ថាប័ន ។ |
| **គោលបំណងទី២៥ ៖ កែលម្អប្រព័ន្ធគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុដើម្បីឆ្ពោះទៅតម្លាភាព** | |
| ២៥.៥. ដាក់ឱ្យអនុវត្តយន្តការដើម្បីបញ្ចប់ការចុះបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ និងធ្វើបច្ចុប្បន្នភាពជាប្រចាំ | • ក្រសួង-ស្ថាប័ន និងអាជ្ញាធរដែនដីត្រូវលើកឡើងអំពីបញ្ហាគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌទាក់ទិននឹងការអនុវត្តក្របខ័ណ្ឌច្បាប់ដែលមានជាធរមាន និងធ្វើសេចក្តីរាយការណ៍អំពីបញ្ហាទាំងនោះ។<br>• ក្រសួង-ស្ថាប័ន ត្រូវផ្តល់មតិយោបល់លើគោលការណ៍សៀវភៅណែនាំ និងនីតិវិធី ។ |

| | |
|---|---|
| | • ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវចេញនូវប័ណ្ណកម្មសិទ្ធិជូនគ្រប់ក្រសួង-ស្ថាប័ន និងអាជ្ញាធរដែនដី ។ កសហវ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវសហការជាមួយគ្នាលើបញ្ហានេះ ។<br>• ក្រសួង-ស្ថាប័ន ត្រូវផ្តល់ជាមតិយោបល់នៅពេលរៀបចំតាក់តែងគោលការណ៍ សៀវភៅណែនាំ និងនីតិវិធីផ្សេងៗ ។<br>• រៀបចំក្រុមការងារដើម្បីប្រមូលឯកសារនិងរៀបចំធ្វើសេចក្តីព្រាងច្បាប់ ។<br>• កសហវ ត្រូវការជំនួយពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីចេញនូវប័ណ្ណកម្មសិទ្ធិ ។<br>• កសហវ និង ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវពិភាក្សាគ្នាអំពីដំណើរការ ផែនការ និងហិរញ្ញប្បទានដើម្បីអនុវត្តគម្រោងនេះ ។ |
| **ក្រុមរៀបចំថវិកា** | |
| **គោលបំណងទី ២១ ៖ កែលម្អបន្ទាត់គណនេយ្យភាពដោយកំណត់ឱ្យបានច្បាស់ពីតួនាទី មុខងារ និង ការទទួលខុសត្រូវ របស់ក្រសួង-ស្ថាប័នគ្រប់កម្រិត និងរបស់អង្គភាពក្រោមឱវាទ** | |
| ២១.៣. កំណត់អង្គភាពថវិកា និងអ្នកគ្រប់គ្រងថវិកានៅរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | • កំណត់លក្ខណៈពេញលេញរបស់អង្គភាពថវិកា និងអ្នកគ្រប់គ្រងថវិកា និងរៀបចំគំនូសបំព្រួញអំពីលំហូរថវិកា និងគណនេយ្យភាពដែលកំពុងអនុវត្តរបស់ក្រសួង-ស្ថាប័ន ដោយផ្អែកលើគោលការណ៍ណែនាំរបស់ កសហវ ។<br>• ស្នើឡើងនូវអង្គភាព/អ្នកគ្រប់គ្រងថវិកាថ្មី និងលំហូរថវិកា និងគណនេយ្យភាពថ្មីដោយផ្អែកលើគោលការណ៍ណែនាំរបស់ កសហវ ។ |
| ២១.៤. កំណត់ពីការទទួលខុសត្រូវនៃការគ្រប់គ្រងនៅគ្រប់កម្រិត | • រៀបចំវាយតម្លៃអង្គភាព/អ្នកគ្រប់គ្រងថវិកាថ្មី និងលំហូរថវិកា/គណនេយ្យភាពថ្មី ដោយផ្អែកតាមគោលការណ៍ណែនាំរបស់ កសហវ ។<br>• រៀបចំវាយតម្លៃស្ថាប័នដោយរួមមានការវិភាគមុខងារ និងការត្រួតពិនិត្យលើដំណើរការការងារ នៅក្នុងក្របខ័ណ្ឌដែលរៀបចំឡើងដោយ កសហវ និងផ្តល់អនុសាសន៍កែលម្អ ។<br>• រៀបចំផែនការសកម្មភាពដើម្បីអនុវត្តអង្គភាព/អ្នកគ្រប់គ្រងថវិកាថ្មី និងលំហូរថវិកា/គណនេយ្យភាពថ្មី ។<br>• រៀបចំនីតិវិធីផ្ទៃក្នុងដើម្បីត្រួតពិនិត្យតាមដានការអនុវត្តអង្គភាព/អ្នកគ្រប់គ្រងថវិកាថ្មី និង លំហូរថវិកា/គណនេយ្យភាពថ្មី និងចាត់វិធានការសមស្របប្រសិនបើចាំបាច់ដើម្បីដោះស្រាយបញ្ហាដែលកើតមានឡើង ។ |

| | |
|---|---|
| ២១.៥. រៀបចំ និងចេញផ្សាយកម្រងនីតិវិធីណែនាំដែលពន្យល់ពីការផ្តល់សិទ្ធិអំណាច និងការទទួលខុសត្រូវដល់អង្គភាពថវិកា និងអ្នកគ្រប់គ្រងថវិកាហើយផ្សព្វផ្សាយតាមរយៈវគ្គបណ្តុះបណ្តាល និង សិក្ខា-សាលា | • ផ្តល់យោបល់កែលម្អទៅលើគោលការណ៍ណែនាំអំពីអង្គភាព/អ្នកគ្រប់គ្រងថវិកាថ្មី និងលំហូរថវិកា/គណនេយ្យភាពថ្មី ។<br>• ផ្សព្វផ្សាយកម្រងនីតិវិធីណែនាំនៅក្នុងក្រសួង-ស្ថាប័ននីមួយៗ ដោយសហការជាមួយនឹងនាយកដ្ឋានថវិកានៃ កសហវ ។<br>• រៀបចំបណ្តុះបណ្តាលគ្រូបង្គោលនៅក្នុងក្រសួង-ស្ថាប័ននីមួយៗ ដើម្បីបណ្តុះបណ្តាលបន្តដល់មន្ត្រីនៅក្នុងការអនុវត្តអង្គភាព/អ្នកគ្រប់គ្រងថវិកាថ្មី និងលំហូរថវិកា/គណនេយ្យភាពថ្មី ។ |
| **គោលបំណងទី២២ ៖ កែលម្អឧបករណ៍ដែលជំរុញឱ្យមានការទទួលខុសត្រូវចំពោះការគ្រប់គ្រងហិរញ្ញវត្ថុ និងការពង្រឹងគណនេយ្យភាព** | |
| ២២.២.រៀបចំឱ្យមានតារាងបញ្ជាក់អំពីសិទ្ធិអំណាច និងភាពទន់ភ្លន់ដែលនឹងផ្តល់ជូនអង្គភាពថវិកាដែលបានបំពេញលក្ខណៈវិនិច្ឆ័យដែលមានការឯកភាពសម្រាប់ប្រព័ន្ធគ្រប់គ្រងធនធានសាធារណៈដ៏ត្រឹមត្រូវ | • ចូលរួម និង ផ្តល់មតិយោបល់ជាធាតុចូលដល់នាយកដ្ឋានថវិកានៃ កសហវ ដើម្បីកំណត់ពីសិទ្ធិអំណាចដែលត្រូវផ្ទេរទៅក្រសួង-ស្ថាប័ន ។ |
| ២២.៣.ធ្វើការត្រួតពិនិត្យឡើងវិញជាប្រចាំលើ លទ្ធផលនៃការគ្រប់គ្រងធនធានដែលសម្រេចបានដោយអង្គភាពថវិកានីមួយៗដើម្បីធ្វើជាមូលដ្ឋានក្នុងការពង្រីកការផ្តល់សិទ្ធិអំណាច និង ភាពទន់ភ្លន់ | • ផ្តល់ធាតុចូលដល់នាយកដ្ឋានថវិកានៃ កសហវ នៅក្នុងការរៀបចំតារាងត្រួតពិនិត្យបទដ្ឋានគ្រប់គ្រងហិរញ្ញវត្ថុ ដើម្បីធ្វើឱ្យតារាងនោះអាចអនុវត្តបាន និងមានភាពប្រាកដនិយម ។<br>• ផ្អែកតាមគោលការណ៍ណែនាំរបស់នាយកដ្ឋានថវិកានៃ កសហវ ក្រសួង-ស្ថាប័ននីមួយៗត្រូវរៀបចំវាយតម្លៃខ្លួនឯងដើម្បីកំណត់បន្ទាត់មូលដ្ឋាននៃបទដ្ឋានគ្រប់គ្រងហិរញ្ញវត្ថុរបស់ខ្លួន ។<br>• រៀបចំផែនការការងារផ្ទាល់ខ្លួនដើម្បីសម្រេចបានគោលដៅនេះ ជាមួយនឹងការត្រួតពិនិត្យតាមដានផ្ទៃក្នុង និងការរៀបចំរបាយការណ៍ដើម្បីឆ្លើយតបនឹងតម្រូវការរបស់ កសហវ ។ |

| គោលបំណងទី ២៣ ៖ បន្តកែលម្អការអនុវត្តមាតិកាថវិកា ថ្មី និង ប្លង់គណនេយ្យថ្មី | |
|---|---|
| ២៣.១.ត្រួតពិនិត្យឡើងវិញ និងបន្តកែលម្អប្លង់គណនេយ្យថ្មី និងចំណាត់ថ្នាក់ថវិកាថ្មី ដើម្បីពង្រឹងនឹងអនុវត្តជាបណ្តើរៗ ចំណាត់ថ្នាក់សេដ្ឋកិច្ច មុខងារ និង រដ្ឋបាល | • រៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោលដើម្បីបណ្តុះបណ្តាលបន្តដល់មន្ត្រីពាក់ព័ន្ធអំពីការប្រើប្រាស់ចំណាត់ថ្នាក់សេដ្ឋកិច្ចថ្មី ។<br>• រាយការណ៍អំពីការលំបាកនៅក្នុងការអនុវត្តមកនាយកដ្ឋានថវិកានៃកសហវដើម្បីទទួលបានដំណោះស្រាយ ។<br>• ផ្តល់មតិយោបល់ដល់នាយកដ្ឋានថវិកាអំពីការអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចថ្មីទៅលើអ្វីដែលត្រូវកែលម្អ ។<br>• ផ្តល់របាយការណ៍បើកផ្តល់នៃគម្រោងវិនិយោគទៅតាមមាតិកាថវិកាមកនាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការនៃ កសហវ ។ |
| ២៣.២. សិក្សា និងផ្តល់ជម្រើសចំណាត់ថ្នាក់តាមកម្មវិធី | • ផ្តល់ធាតុចូលក្នុងការរៀបចំចំណាត់ថ្នាក់ថវិកាតាមកម្មវិធី និងមុខងារដល់នាយកដ្ឋានថវិកា នៃ កសហវ ។<br>• បញ្ជូនមន្ត្រីដើម្បីចូលរួមបណ្តុះបណ្តាលអំពីការប្រើប្រាស់ចំណាត់ថ្នាក់ថវិកាតាមកម្មវិធី និង មុខងារ ។<br>• រៀបចំវគ្គបណ្តុះបណ្តាល ផ្សព្វផ្សាយនៅក្នុងក្របខ័ណ្ឌក្រសួង-ស្ថាប័ននីមួយៗ ។ |
| គោលបំណងទី ២៥៖ កែលម្អរបាយការណ៍គណនេយ្យ របាយការណ៍ហិរញ្ញវត្ថុ និង តម្លាភាព | |
| ២៥.២. ដាក់ឱ្យអនុវត្តនូវរបាយការណ៍អនុវត្តថវិកាប្រចាំត្រីមាសដែលបញ្ជាក់អំពីការងារដែលបានបំពេញធៀបនឹងគោលដៅ លទ្ធផលទទួលបាន ការយឺតយ៉ាវនិងវិធានការដោះស្រាយ ៖ ពីក្រសួង-ស្ថាប័នមក កសហវ និង នៅផ្ទៃក្នុងក្រសួង-ស្ថាប័នពីអង្គភាពថវិការហូតដល់ថ្នាក់ដឹកនាំ | • ពិនិត្យឡើងវិញការរៀបចំរបាយការណ៍ផ្ទៃក្នុង និងគំរូរបាយការណ៍ដើម្បីឱ្យស្របជាមួយតម្រូវការរបាយការណ៍ថ្មីពី កសហវ ។<br>• រៀបចំ និងស្នើឡើងការរៀបចំរបាយការណ៍ផ្ទៃក្នុង និងគំរូរបាយការណ៍ថ្មីដើម្បីឆ្លើយតបនឹងតម្រូវការរបស់ កសហវ ។<br>• បណ្តុះបណ្តាលមន្ត្រីពាក់ព័ន្ធអំពីការរៀបចំរបាយការណ៍ និងគំរូរបាយការណ៍ថ្មី ។ |

| គោលបំណងទី ២៧ ៖ ពង្រឹង និង រៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រវិមជ្ឈការហិរញ្ញវត្ថុ | |
|---|---|
| ២៧.៦. ពិនិត្យឡើងវិញ និង ធ្វើវិសោធនកម្មច្បាប់ អនុក្រឹត្យ និងបទបញ្ញត្តិ ផ្សេងៗ ដើម្បីឱ្យមានសង្គតិភាពទៅនឹងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង និង ស្រុក ខណ្ឌ | • ផ្តល់មតិយោបល់ និង អនុសាសន៍ដល់សេចក្តីព្រាងច្បាប់ អនុក្រឹត្យ និងបទបញ្ញត្តិនានាដែលពាក់ព័ន្ធដោយផ្ទាល់ ឬ ប្រយោលទៅនឹងក្រសួង-ស្ថាប័ននីមួយៗ ( កសហវ នឹងបញ្ជូនសេចក្តីព្រាងទាំងនោះទៅឱ្យក្រសួង-ស្ថាប័ន ) |
| ២៧.៧. រៀបចំយុទ្ធសាស្ត្រ និងគោលនយោបាយ វិមជ្ឈការហិរញ្ញវត្ថុ ដោយផ្អែកលើក្របខ័ណ្ឌយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនិងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | • ចូលរួមនៅក្នុងការរៀបចំយុទ្ធសាស្ត្រវិមជ្ឈការហិរញ្ញវត្ថុរយៈពេលមធ្យម និងរយៈពេលវែង ។ ក្រសួង-ស្ថាប័នត្រូវពិនិត្យមើលពីមុខងារនិងការទទួលខុសត្រូវដែលនឹងត្រូវធ្វើប្រតិភូកម្មទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ។ |
| **គោលបំណងទី ៣១ ៖ ការកែលម្អ និង ការពង្រឹងការអនុវត្តថវិកាតាមកម្មវិធី** | |
| ៣១.១. ពិនិត្យឡើងវិញ និងកែលម្អការអនុវត្តថវិកាតាមកម្មវិធី | • ផ្តល់មតិយោបល់ដល់នាយកដ្ឋានថវិកានៃ កសហវ ដើម្បីកែលម្អការរៀបចំគោលការណ៍ណែនាំពីការរៀបចំថវិកាតាមកម្មវិធី ។<br>• ផ្តល់មតិយោបល់ដល់នាយកដ្ឋានថវិកានៃ កសហវ អំពីលក្ខណៈវិនិច្ឆ័យដ៏សំខាន់ដើម្បីរៀបចំថវិកាតាមកម្មវិធីឱ្យបានល្អប្រសើរ ។<br>• ផ្តល់មតិយោបល់ដល់នាយកដ្ឋានថវិកានៃ កសហវ ដើម្បីកែលម្អវិធីសាស្ត្រត្រួតពិនិត្យវាយតម្លៃ និងការដាក់ពិន្ទុលើការរៀបចំថវិកាតាមកម្មវិធី ។<br>• រាយការណ៍ពីការលំបាកក្នុងការអនុវត្តមកនាយកដ្ឋានថវិកាដើម្បីទទួលបាននូវការណែនាំ និង លើកឡើងនូវវិធានការកែលម្អការរៀបចំថវិកាតាមកម្មវិធី ដូចជាការរៀបចំរចនា- |

| | |
|---|---|
| | សម្ព័ន្ធស្ថាប័នឡើងវិញជាដើម ។<br>• ផ្តល់មតិយោបល់មកនាយកដ្ឋានថវិកាអំពីផ្នែកដែលត្រូវកែលម្អ ដែលទាក់ទងនឹងការរៀបចំ និងការអនុវត្តថវិកាតាមកម្មវិធី ។<br>• ត្រួតពិនិត្យប្រចាំឆ្នាំលើការរៀបចំកម្មវិធី អនុកម្មវិធី និងសកម្មភាព ដើម្បីធានាឱ្យការរៀបចំនោះឆ្លើយតប តាមទិសដៅគោលនយោបាយ ហើយធ្វើការកែសម្រួលប្រសិនបើចាំបាច់ ។<br>• រៀបចំនូវយន្តការផ្ទៃក្នុងដើម្បីរាយការណ៍អំពីការអនុវត្តថវិកាតាមកម្មវិធីឱ្យឆ្លើយតបទៅតាមតម្រូវការរបស់ កសហវ ។<br>• រៀបចំផែនការការងារដើម្បីសម្រេចបានគោលដៅនេះ ។ |
| ៣១.២ រៀបចំយុទ្ធសាស្ត្រដើម្បីពង្រីកថវិកាតាមកម្មវិធី | • ផ្តល់មតិយោបល់ដល់នាយកដ្ឋានថវិកានៃ កសហវ ទៅលើការរៀបចំយុទ្ធសាស្ត្រ និងលក្ខណៈវិនិច្ឆ័យដើម្បីកំណត់ពីភាពគ្រប់គ្រាន់ និងពេលវេលានៃការពង្រីកការសាកល្បងថវិកាតាមកម្មវិធី ។<br>• រៀបចំនីតិវិធីផ្ទៃក្នុងដើម្បីអនុវត្តសាកល្បងថវិកាតាមកម្មវិធី ។ |
| ៣១.៣. អនុវត្តផែនការបណ្តុះបណ្តាល និងអភិវឌ្ឍសមត្ថភាពសម្រាប់អនុវត្តថវិកាតាមកម្មវិធី | • ធ្វើការវាយតម្លៃខ្លួនឯងដើម្បីកំណត់តម្រូវការកសាងសមត្ថភាពដែលទាក់ទងនឹងការរៀបចំថវិកាតាមកម្មវិធី ហើយធ្វើសំណើមកនាយកដ្ឋានថវិកានៃ កសហវ ។<br>• ប្រើប្រាស់សេចក្តីណែនាំរបស់នាយកដ្ឋានថវិកាសម្រាប់រៀបចំវគ្គបណ្តុះបណ្តាលផ្ទៃក្នុងដើម្បីធានាថាសមត្ថភាពក្នុងការរៀបចំថវិកាតាមកម្មវិធីត្រូវបានកសាង និងមាននិរន្តរភាព ។ |
| **គោលបំណងទី ៣២ ៖ បន្តកែលម្អភាពគ្រប់ជ្រុងជ្រោយ និង សមាហរណកម្មថវិកា** | |
| ៣២.១.រៀបចំគោលនយោបាយសម្រាប់ធ្វើសមាហរណកម្មថវិកា ។ បន្តកែលម្អការធ្វើសមាហរណកម្មថវិកាចរន្ត និងមូលធនតាមរយៈការបន្តអនុវត្តក្របខ័ណ្ឌចំណាយរយៈពេល | • បង្កើត និងធ្វើឱ្យដំណើរការក្រុមការងារថវិកាដែលមានសមាសភាពមកពី នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុ និងអង្គភាពគ្រប់គ្រងគម្រោងដើម្បីរៀបចំផែនការយុទ្ធសាស្ត្រថវិកាក្រសួង ។<br>• ធ្វើការកំណត់ពីតម្រូវការកសាងសមត្ថភាពដែលទាក់ទងនឹងការវិភាគគោលនយោបាយតាម វិស័យ និងការរៀបចំផែនការយុទ្ធសាស្ត្រដោយលើកសំណើមកនាយកដ្ឋានថវិកានៃ កសហវ ។<br>• រៀបចំវគ្គបណ្តុះបណ្តាលផ្ទៃក្នុងដល់មន្ត្រីពាក់ព័ន្ធដទៃទៀតអំពីការវិភាគគោលនយោបាយ |

| | |
|---|---|
| មធ្យម (MTEF) ផែនការយុទ្ធសាស្ត្រថវិកា (BSPs) និង ថវិកាតាមកម្មវិធី (BP)។ ឆ្លុះបញ្ចាំងទិដ្ឋភាពនៃការកាត់បន្ថយភាពក្រីក្រ និង យែនឌ័រ ទៅក្នុងគោលការណ៍ណែនាំស្តីពីផែនការយុទ្ធសាស្ត្រថវិកា និងថវិកាតាមកម្មវិធី | តាមវិស័យ និងការរៀបចំផែនការយុទ្ធសាស្ត្រដោយប្រើប្រាស់មន្ត្រីដែលទទួលបានការបណ្តុះបណ្តាលពី កសហវ ។ |
| ៣២.២.បន្តបញ្ចូលចំណូល-ចំណាយ ដែលនៅក្រៅបរិបថថវិកាទៅក្នុងថវិកាប្រចាំឆ្នាំរួមទាំងការបង្កើនជាបណ្តើរៗនូវការបញ្ចូលមូលនិធិពីដៃគូអភិវឌ្ឍន៍ទៅក្នុង ថវិកាប្រចាំឆ្នាំ | • រៀបចំ និងចេញប្រកាសណែនាំដល់គ្រប់សហគ្រាសពាណិជ្ជកម្ម និងឧស្សាហកម្ម និងគ្រឹះស្ថានសាធារណៈរដ្ឋបាលដែលស្ថិតនៅក្រោមក្រសួង-ស្ថាប័ន ឱ្យរៀបចំថវិកាតាមការណែនាំរបស់ កសហវ ហើយធ្វើសមាហរណកម្មថវិកាទាំងនោះទៅក្នុងថវិកាប្រចាំឆ្នាំរបស់ក្រសួង-ស្ថាប័ន ។<br>• រៀបចំយន្តការតាមដានផ្ទៃក្នុង និងរៀបចំរបាយការណ៍ចំណូល-ចំណាយ ដែលអនុវត្តក្រៅបរិបថថវិកាមក កសហវ តាមគំរូដែលរៀបចំដោយនាយកដ្ឋានថវិកានៃ កសហវ ។<br>• សហការជាមួយនឹងនាយកដ្ឋានថវិកានៃ កសហវ ដើម្បីធ្វើសមាហរណកម្មចំណូល-ចំណាយក្រៅបរិបថថវិកាទៅក្នុងថវិកាប្រចាំឆ្នាំរបស់ក្រសួង-ស្ថាប័ន ។ |
| **ក្រុមអនុវត្តថវិកា និងគោលនយោបាយ** | |
| **គោលបំណងទី១៣ ៖ បន្តកែលម្អការគ្រប់គ្រងសាច់ប្រាក់ និងការគ្រប់គ្រងគណនីធនាគារ** | |
| ១៣.១.បន្តប្រមូលផ្តុំគណនីធនាគាររបស់រដ្ឋាភិបាល និងពង្រឹងគណនីទោលរបស់រតនាគារ ( TSA) | • រាយការណ៍ជូនរតនាគារជាតិនៅរាល់ដំណាច់ខែនីមួយៗស្តីពីការបើកគណនីសន្សំនៅធនាគារជាតិកម្ពុជា និងនៅតាមធនាគារពាណិជ្ជផ្សេងៗទៀត ។<br>• ធនាគារជាតិនៃកម្ពុជា និងសាខានៅតាមខេត្ត ក្រុង ត្រូវបំពេញតារាងគំរូ ( បញ្ជីនៃចំនួនគណនី ) ដែលរតនាគារជាតិបានផ្តល់ជូន ហើយត្រូវរាយការណ៍ជូនរតនាគារជាតិឱ្យបានទៀងទាត់ និងទាន់ពេលវេលា ។<br>• ក្រសួង-ស្ថាប័ន ទាំងអស់ត្រូវបំពេញតារាងគំរូដែលផ្តល់ដោយរតនាគារជាតិ ( បញ្ជីនៃចំនួនគណនី ) ហើយត្រូវរាយការណ៍ជូនរតនាគារជាតិឱ្យបានទៀងទាត់ និងទាន់ពេលវេលា ។ ក្រសួង-ស្ថាប័ន ត្រូវធ្វើការផ្ទៀងផ្ទាត់ជាមុនជាមួយធនាគារ ។ |

| | |
|---|---|
| | • ក្រសួង-ស្ថាប័នទាំងអស់ត្រូវសហការជាមួយរតនាគារជាតិ ដោយត្រូវរាយការណ៍ពីចំនួនគណនីដែលខ្លួនមាន និងត្រូវធ្វើការបិទគណនីទាំងនោះដោយស្ម័គ្រចិត្ត ។<br>• ក្រសួង-ស្ថាប័ន ទាំងអស់ត្រូវផ្តល់ព័ត៌មានត្រឹមត្រូវស្តីពីលំហូរសាច់ប្រាក់នៃគណនីរបស់ខ្លួន ។ |
| ១៣.២. បន្តពង្រីកការប្រើប្រាស់ប្រព័ន្ធធនាគារសម្រាប់ប្រតិបត្តិការចំណូល និងចំណាយសាធារណៈ | • មន្ត្រីរាជការនៅគ្រប់ក្រសួង-ស្ថាប័នដែលមានប្រាក់បៀវត្សចាប់ពី ៤០០.០០០ រៀលឡើងទៅត្រូវបើកគណនីប្រាក់បៀវត្សនៅធនាគារ ANZ Royal ។ គ្រប់ក្រសួង-ស្ថាប័នត្រូវធ្វើការតាមដាន និងត្រួតពិនិត្យចំពោះការអនុវត្តចំពោះការបើកគណនីប្រាក់បៀវត្សនេះ ។ |
| ១៣.៣.ប្រមូលផ្តុំនិងបន្ត កែលម្អផែនការសាច់ប្រាក់ (ចាប់ផ្តើមពីប្រចាំត្រីមាស/ ប្រចាំខែ និង ចាប់ផ្តើមជាបណ្តើរៗទៅប្រចាំសប្តាហ៍ និងប្រចាំថ្ងៃ) | • ផ្តល់តួលេខព្យាករណ៍ចំណូល-ចំណាយដែលមានបច្ចុប្បន្នភាពត្រឹមត្រូវ និងទៀងទាត់ពេលវេលា ។<br>• ធ្វើបច្ចុប្បន្នភាព ពិនិត្យឡើងវិញ និងកែសម្រួលផែនការចំណូល-ចំណាយ ។<br>• ផ្តល់តួលេខលើគ្រប់ការបញ្ជាទិញដែលមិនប្រក្រតី ។<br>• ផ្តល់ទិន្នន័យចំណូល-ចំណាយ ដោយធ្វើការប្រៀបធៀបជាមួយលទ្ធផលជាក់ស្តែង ។<br>• ផ្តល់ព័ត៌មានឱ្យបានត្រឹមត្រូវស្តីពីលំហូរសាច់ប្រាក់ និងសមតុល្យសាច់ប្រាក់នៃគណនីរដ្ឋាភិបាលដែលក្រសួង-ស្ថាប័ន កាន់កាប់ ។<br>• ផ្តល់ធាតុចូលដែលមានតម្លៃដល់អង្គភាពគ្រប់គ្រងសាច់ប្រាក់ស្តីពីការរំពឹងទុកនៃការប្រើប្រាស់ធនធានសាច់ប្រាក់ដោយក្រសួង-ស្ថាប័ន ។<br>• ផ្តល់ការប៉ាន់ប្រមាណចំណាយប្រចាំត្រីមាស ដើម្បីត្រួតពិនិត្យការបើកផ្តល់ថវិកា ។<br>• ផ្តល់ហេតុផលចំពោះការប្រៀបធៀបរវាងការប៉ាន់ប្រមាណ និងលទ្ធផលជាក់ស្តែង ។ |
| ១៣.៤. បន្តតាមដានបំណុលកកស្ទះ និង អាយុកាលរបស់វា | • រៀបចំ និងផ្តល់អាណត្តិឱ្យទាន់ពេលវេលា ។<br>• នាយកដ្ឋានថវិកា នាយកដ្ឋានហិរញ្ញកិច្ច នាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ និងក្រសួង-ស្ថាប័ន ត្រូវបង្កើតយន្តការរៀបចំផែនការធានាចំណាយឱ្យបានទៀងទាត់ពេលវេលា ។<br>• ក្រសួង-ស្ថាប័ន ត្រូវដាក់អាណត្តិឱ្យស្របតាមកម្មវិធីចំណាយដើម្បីបញ្ចៀសការគរអាណត្តិនៅចុងឆ្នាំ ។ |

| គោលបំណងទី ១៤ ៖ បន្តកែលម្អលទ្ធកម្មសាធារណៈ | |
|---|---|
| ១៤.១. កែលម្អក្របខ័ណ្ឌច្បាប់លទ្ធកម្មសាធារណៈ | • បង្កើតផែនការលទ្ធកម្មប្រចាំឆ្នាំ ។<br>• រៀបចំកាលវិភាគដើម្បីអនុវត្ត និងតាមដានដំណើរការលទ្ធកម្ម ។<br>• ផ្តល់មតិយោបល់ និងធាតុចូលដើម្បីជួយដល់នាយកដ្ឋានលទ្ធកម្មសាធារណៈ បញ្ចប់សេចក្តី ព្រាងច្បាប់លទ្ធកម្ម ។ |
| ១៤.២. អនុវត្តអនុក្រឹត្យថ្មី ស្តីពីលទ្ធកម្មសាធារណៈ និងវិធាន និងបទបញ្ញត្តិលទ្ធកម្មសាធារណៈដោយរួមទាំងឯកសារដេញថ្លៃជាស្តង់ដារ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | • បញ្ជូនមន្ត្រីដែលមានសមត្ថភាពដើម្បីចូលរួមវគ្គបណ្តុះបណ្តាល ។<br>• ធានាថាមន្ត្រីដែលទទួលការបណ្តុះបណ្តាលបំពេញការងារទៅតាមជំនាញ ។<br>• រាយការណ៍នូវរាល់សកម្មភាពលទ្ធកម្មទាំងអស់ ( វិធីសាស្រ្តលទ្ធកម្ម និងនិតិវិធីដែលបានកែលម្អ ) ។ |
| ១៤.៣. បន្តពង្រឹងសមត្ថភាពរបស់អង្គភាពលទ្ធកម្ម នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដើម្បីអនុវត្តអនុក្រឹត្យថ្មីស្តីពីលទ្ធកម្ម សាធារណៈ និងវិធាន និង បទបញ្ញត្តិលទ្ធកម្មសាធារណៈដោយរួមទាំងឯកសារដេញថ្លៃជាស្តង់ដារ ។ | |
| ១៤.៤. ពង្រឹងសមត្ថភាពនាយកដ្ឋានលទ្ធកម្មសាធារណៈ ដើម្បីត្រួតពិនិត្យតាមដាន និងវាយតម្លៃសមិទ្ធកម្មនៃប្រព័ន្ធលទ្ធកម្មសាធារណៈ | • ផ្តល់ទិន្នន័យនៃទិន្នផល និងលទ្ធផលស្តីពីសកម្មភាពលទ្ធកម្មដែលក្រសួងស្ថាប័នបានអនុវត្តក្នុងរយៈពេលកំណត់នីមួយៗ មកនាយកដ្ឋានលទ្ធកម្មសាធារណៈនៃ កសហវ ។<br>• ផ្តល់កិច្ចសហប្រតិបត្តិការ និងការជួយសម្រួលដល់នាយកដ្ឋានលទ្ធកម្មសាធារណៈនៃ កសហវ ដើម្បីអាចអនុវត្តការត្រួតពិនិត្យជាក្រោយឱ្យបានជោគជ័យ ។ |

| | |
|---|---|
| ១៤.៥. បង្កើនភាពប្រកួតប្រជែង និងតម្លាភាពក្នុងដំណើរការលទ្ធកម្មតាមរយៈការបង្កើនការផ្សព្វផ្សាយជាសាធារណៈ និងដោយចំហ | • ផ្តល់ឯកសារពាក់ព័ន្ធនានា និងទិន្នន័យស្តីពីសកម្មភាពលទ្ធកម្មដែលអនុវត្តដោយក្រសួង-ស្ថាប័ន ។ |
| ១៤.៦.កំណត់ឱ្យបានច្បាស់ពីបន្ទាត់គណនេយ្យភាពក្នុងដំណើរការលទ្ធកម្ម | • បញ្ជូនមន្ត្រីដែលមានសមត្ថភាពសមស្របដើម្បីចូលរួមនៅក្នុងសិក្ខាសាលា ។<br>• បញ្ជាក់នូវបន្ទាត់គណនេយ្យភាពនៃការគ្រប់គ្រងនៅក្នុងក្រសួង-ស្ថាប័ន ។ |
| **គោលបំណងទី២៣ ៖ បន្តកែលម្អការអនុវត្តមាតិកាថវិកាថ្មី និងប្លង់គណនេយ្យថ្មី** | |
| ២៣.១. ត្រួតពិនិត្យឡើងវិញ និងបន្តកែលម្អប្លង់គណនេយ្យថ្មី និងចំណាត់ថ្នាក់ថវិកាថ្មី ដើម្បីពង្រឹង និង អនុវត្តជាបណ្តើរៗ ចំណាត់ថ្នាក់សេដ្ឋកិច្ច មុខងារ និង រដ្ឋបាល | • សហការជាមួយនាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ នាយកដ្ឋានចំណូលមិនមែនពន្ធ នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ នាយកដ្ឋានឧស្សាហកម្ម និងហិរញ្ញវត្ថុ ដើម្បីធ្វើរបាយការណ៍ប្រចាំខែជូនរតនាគារជាតិ ។<br>• ផ្តល់ធាតុចូលដល់នាយកដ្ឋានគោលនយោបាយ សេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈនៃកសហវ ។<br>• បង្កើតទម្រង់ដើម្បីកត់ត្រាប្រតិបត្តិការដែលនៅខាងក្រៅរតនាគារជាតិឱ្យស្របទៅនឹងចំណាត់ថ្នាក់ថវិកា ជាពិសេសប្រតិបត្តិការរបស់ដៃគូអភិវឌ្ឍន៍ ។ |
| ២៣.៣. សិក្សា និងផ្តល់ជម្រើសសម្រាប់ឈានទៅប្រព័ន្ធគណនេយ្យបង្គរជាជំហានៗ | • ក្រសួង-ស្ថាប័ន ត្រូវសហការជាមួយនាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ នាយកដ្ឋានចំណូលមិនមែនពន្ធ នាយកដ្ឋានឧស្សាហកម្ម និងហិរញ្ញវត្ថុ និងនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ ដើម្បីផ្តល់បញ្ជីសារពើភ័ណ្ឌដល់រតនាគារជាតិ ។ |
| **គោលបំណងទី២៤ ៖ កែលម្អដំណើរការ និងប្រតិបត្តិការអនុវត្តថវិកា** | |
| ២៤.១.បន្តកាត់បន្ថយពេលវេលាសម្រាប់ការស្នើសុំធានាចំណាយ និងការទូទាត់នៅក្នុងក្រសួង-ស្ថាប័ន ។ | • ពិនិត្យឡើងវិញមុខងារដែលមានស្រាប់នៅតាមកម្រិតផ្សេងៗ និងធ្វើសេម៉ាដំណើរការនៃសំណើសុំឥណទានចំណាយ ( ធានាចំណាយ និងអាណត្តិបើកប្រាក់ ) នៅតាមក្រសួង-ស្ថាប័ន ។<br>• បង្កើតផែនការអនុវត្ត និងបង្កើតមធ្យោបាយដើម្បីតាមដានលំហូរមូលនិធិស្របទៅតាមដំណើរការថ្មី ។ |

| | |
|---|---|
| ( ដោយសន្មតថាមានការកែលម្អ ទៅលើប្រព័ន្ធដែលកំពុងអនុវត្ត និងការចាប់ផ្តើមអនុវត្តជាបណ្តើរៗ FMIS នៅក្នុងឆ្នាំ ២០០៩ និង ២០១០ ) | • កសហវ/ក្រសួង-ស្ថាប័ន ត្រូវកាត់បន្ថយពេលវេលាសម្រាប់ដំណើរការធានាចំណាយការបង់ចំណូល ការចំណាយនៅក្នុងក្រសួង-ស្ថាប័ន របស់ខ្លួន ។ |
| ២៤.២.កែលម្អដំណើរការនៃប្រតិបត្តិការនៅក្នុងកសហវ/ក្រសួង-ស្ថាប័នដើម្បីឱ្យស្រប ទៅនឹងការវិវឌ្ឍន៍នៃប្លង់គណនេយ្យ និងបទដ្ឋានគណនេយ្យ ព្រមទាំងធ្វើការផ្ទៀងផ្ទាត់គណនីធនាគារជាប្រចាំ | • កសហវ/ក្រសួង-ស្ថាប័ន ពិនិត្យឡើងវិញពីការកត់ត្រាអណត្តិ ឬ បុរេប្រទានដោយគោរពតាមវិធានគណនេយ្យ និងប្លង់គណនេយ្យថ្មីឱ្យស្របទៅតាមថវិកាតាមជំពូក ។ |
| **គោលបំណងទី២៥ ៖ កែលម្អប្រព័ន្ធគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុ ដើម្បីធានាតម្លាភាព** | |
| ២៥.១. ពិនិត្យឡើងវិញនូវស្តង់ដារគណនេយ្យរដ្ឋបាលសាធារណៈដែលមានលក្ខណៈជាអន្តរជាតិ (IPSAS, GAAP) និងវាយតម្លៃភាពប្រាកដនិយមនិងភាពសមស្របនៃលំដាប់លំដោយក្នុងការដាក់ឱ្យអនុវត្តស្តង់ដារគណនេយ្យដោយភ្ជាប់ទៅនឹងការពង្រីកការប្រើប្រាស់ FMIS ។ | • ក្រសួង-ស្ថាប័ន ត្រូវគោរពតាមពេលវេលាកំណត់ដោយត្រូវដាក់អាណត្តិយ៉ាងយូរត្រឹមថ្ងៃទី ២៥ ខែ ធ្នូ នៃឆ្នាំនីមួយៗ ។ |

| | |
|---|---|
| **គោលបំណងទី៣២ ៖ បន្តកែលម្អតាពគ្រប់ជ្រុងជ្រោយ និង សមាហរណកម្មថវិកា** | |
| ៣២.១.រៀបចំគោលនយោបាយសម្រាប់ធ្វើសមា-ហរណកម្មថវិកា ។ បន្តកែលម្អការធ្វើសមាហរណកម្មថវិកាចរន្ត និងមូលធនតាមរយៈការបន្តអនុវត្តក្របខ័ណ្ឌចំណាយរយៈពេលមធ្យម (MTEF) ផែនការយុទ្ធសាស្ត្រថវិកា (BSPs) និងថវិកាតាមកម្មវិធី (BP) ។ ឆ្លុះបញ្ចាំងទិដ្ឋភាពការកាត់បន្ថយភាពក្រីក្រ និងយែនឌ័រទៅក្នុងគោល-ការណ៍ណែនាំស្តីពីផែនការយុទ្ធសាស្ត្រថវិកា និងថវិកាតាមកម្មវិធី | • ផ្តល់ទិន្នន័យនៃទិន្នផល និងលទ្ធផលដើម្បីធ្វើបច្ចុប្បន្នភាពឯកសារក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ។<br>• រៀបចំជាមួយក្រសួង-ស្ថាប័ន ដើម្បីធ្វើការអង្កេតលើការអនុវត្ត MTEF ពីក្រោមឡើងលើ ។<br>• ពិនិត្យឡើងវិញនូវទំនាក់ទំនងពិតប្រាកដរវាងផែនការតាមវិស័យ និងផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ (NSDP) ។<br>• ធ្វើចំណាត់ថ្នាក់អាទិភាពនៃអនុកម្មវិធី និងសកម្មភាពនៃការរៀបចំថវិកាតាមកម្មវិធី ។<br>• កំណត់វិធានការជោគជ័យ និងសូចនាករជោគជ័យនៃការរៀបចំថវិកាតាមកម្មវិធីជាមួយបណ្តាក្រសួងអាទិភាព ដែលមានសង្គតិភាពជាមួយក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចរយៈពេលមធ្យម ។<br>• សហការជាមួយ កអក និងក្រសួង-ស្ថាប័នដើម្បីពិនិត្យឡើងវិញបណ្តាប្រភពហិរញ្ញប្ប-ទាន ផ្សេងៗ ។<br>• ធ្វើរបាយការណ៍ប្រចាំត្រីមាសអំពីការអនុវត្តគម្រោង/កម្មវិធី របស់ក្រសួង-ស្ថាប័ន ។ |
| **សវនកម្មនិងការពិនិត្យតាមដាន** | |
| **គោលបំណងទី២៦ ៖ កែលម្អសវនកម្ម និងអធិការកិច្ច ព្រមទាំងឆ្លើយតប និងប្រើប្រាស់លទ្ធផលនៃរបាយការណ៍សវនកម្ម និងអធិការកិច្ច** | |
| ២៦.១. បង្កើតឱ្យមានអង្គភាពសវនកម្មផ្ទៃក្នុងនៅគ្រប់ក្រសួង ។ | • នាយកដ្ឋានសវនកម្មផ្ទៃក្នុងរបស់ក្រសួងត្រូវតែងតាំងមន្ត្រីបង្គោលដែលនឹងត្រូវផ្តល់ជំនួយបច្ចេកទេសដល់នាយកដ្ឋានសវនកម្មផ្ទៃក្នុងរបស់ក្រសួង ។<br>• សហការជាមួយអាជ្ញាធរសវនកម្មជាតិដើម្បីរៀបចំបញ្ជីសំណួរដែលរួមបញ្ចូលទាំងលក្ខណៈវិនិច្ឆ័យចាំបាច់មួយចំនួនដូចជា ចំនួនបុគ្គលិក ទីកន្លែងធ្វើការសមស្រប សម្ភារៈបរិក្ខារ ការរៀបចំផែនការប្រចាំឆ្នាំ និងរបាយការណ៍ ។<br>• នាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃ កសហវ សហការជាមួយក្រសួងដើម្បីតាមដានវឌ្ឍន-ភាព ។<br>• រាយការណ៍ជូន កសហវ ស្តីពីការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុងរបស់ក្រសួង ។ |

| | |
|---|---|
| ២៦.២. កែលម្អយន្តការ ដើម្បីធានាការឆ្លើយតបប្រកបដោយប្រសិទ្ធភាពទៅនឹងលទ្ធផលសវនកម្ម និងអធិការកិច្ចនៅតាមបណ្តាអង្គភាពថវិកា ។ | • នាយកដ្ឋានសវនកម្មផ្ទៃក្នុងរបស់ក្រសួង ត្រូវបំពេញសវនកម្មដោយផ្អែកលើផែនការសវនកម្ម ប្រចាំឆ្នាំ ។<br>• ការត្រួតពិនិត្យពាក់កណ្តាលឆ្នាំអាចត្រូវអនុវត្ត ដើម្បីតាមដានវឌ្ឍនភាពនៃការអនុវត្តតាមអនុសាសន៍របស់សវនករ ។<br>• បណ្តុះបណ្តាលសវនករអំពីការវាយតម្លៃហានិភ័យ និងបច្ចេកទេសសវនកម្មផ្ទៃក្នុង ។<br>• បន្តអនុវត្តនីតិវិធីសវនកម្ម និងគោរពតាមស្តង់ដារសវនកម្ម និងក្រមសីលធម៌ ។ ការងារសវនកម្មលម្អិតត្រូវអនុវត្តតាមសៀវភៅណែនាំស្តីពីសវនកម្ម ។<br>• ចូលរួមក្នុងសិក្ខាសាលាស្តីពីបញ្ហានានាដែលបានរកឃើញនៅក្នុងការងារសវនកម្មប្រចាំឆ្នាំ ។<br>• បញ្ចូលស្ថិតិនានារបស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង និងលិខិតបទដ្ឋានផ្សេងៗរបស់នាយក-ដ្ឋាន សវនកម្មផ្ទៃក្នុងទៅក្នុងប្រព័ន្ធកុំព្យូទ័រព្រមទាំងរក្សាទុកជាឯកសាររឹងផងដែរ ។<br>• បង្កើតប្រព័ន្ធទិន្នន័យដើម្បីប្រើប្រាស់ជាប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងត្រូវធ្វើបច្ចុប្បន្នភាពជាប្រចាំ ។<br>• បង្កើតប្រអប់សវនកម្មនៅតាមខេត្ត-ក្រុងដើម្បីទប់ស្កាត់ការកេងបន្លំ និងជាជំនួយដើម្បីកំណត់ពីចំណុចខ្សោយនៅក្នុងប្រព័ន្ធត្រួតពិនិត្យ ។ |
| ២៦.៣. រៀបចំនិងកែលម្អផែនការសវនកម្ម/អធិការកិច្ចប្រចាំឆ្នាំរបស់ក្រសួង- ស្ថាប័នដោយផ្អែកលើលក្ខណៈវិនិច្ឆ័យវាយតម្លៃហានិភ័យដែលបានផ្តល់អនុសាសន៍ដោយ កសហវ ។ | • នាយកដ្ឋានសវនកម្មផ្ទៃក្នុងរបស់ក្រសួង ត្រូវបញ្ជូនផែនការសវនកម្មមកនាយកដ្ឋានសវនកម្ម ផ្ទៃក្នុងនៃ កសហវ ដើម្បីពិនិត្យមើលឡើងវិញ ។ រៀបចំជាសិក្ខាសាលាដើម្បីពង្រឹងការរៀបចំផែនការសវនកម្ម ។<br>• ក្រសួងត្រូវបញ្ជូនរបាយការណ៍សវនកម្មឆ្នាំ ២០០៨ មក កសហវ ដើម្បីធ្វើការពិនិត្យឡើងវិញ និងអាចផ្តល់ជាអនុសាសន៍ ។ |
| ២៦.៤. កសហវ ពិនិត្យមើលឡើងវិញពីភាពគ្រប់គ្រាន់នៃគំរូរបាយការណ៍សវនកម្ម/អធិការកិច្ច ។ | • នាយកដ្ឋានសវនកម្មផ្ទៃក្នុងរបស់ កសហវ កំណត់ពីស្តង់ដារសម្រាប់ការរៀបចំផែនការសវនកម្ម និងសហការជាមួយក្រសួងដើម្បីរៀបចំផែនការសវនកម្ម ។<br>• ក្រសួង ត្រូវរៀបចំរបាយការណ៍ទៅតាមគំរូដែលផ្តល់ឱ្យដោយនាយកដ្ឋានសវនកម្មផ្ទៃក្នុងរបស់ កសហវ ។ |

| ប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុ | |
|---|---|
| **គោលបំណងទី២៤ ៖ កែលម្អការអនុវត្តថវិកា និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ** | |
| ២៤.៣. បង្កើនកម្រិតយល់ដឹងភាពជាម្ចាស់ការចូលរួម និងសមត្ថភាព ផ្នែក FMIS ដល់ កសហវ ក្រសួង-ស្ថាប័ន និង រដ្ឋបាលថ្នាក់ក្រោមជាតិ ។ | • ចូលរួមក្នុងវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងកម្មវិធីបង្កើនសមត្ថភាពផ្សេងៗ ស្តីពី FMIS ដែលនឹងរៀបចំដោយ កសហវ ។<br>• ចែករំលែកនូវចំណេះដឹង ឬព័ត៌មានបន្ទាប់ពីបានចូលរួមសិក្ខាសាលាជូនដល់មន្ត្រីផ្សេងទៀត នៅតាមក្រសួង-ស្ថាប័ន ។<br>• កំណត់ឱ្យបានច្បាស់លាស់អំពីអ្នកដែលត្រូវប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុ ។ |
| ២៤.៤.កសាងសមត្ថភាពគ្រប់គ្រងគម្រោង FMIS ដោយរួមទាំងនៅ កសហវ ក្រសួង-ស្ថាប័ន និងអង្គភាពថ្នាក់ក្រោមជាតិ ។ | • បង្កើតក្រុមការងារ FMIS ចំនួន ០៣ នាក់ នៅតាមបណ្តាក្រសួង-ស្ថាប័ន ។<br>• ចាត់តាំងមន្ត្រីដែលមានគុណសម្បត្តិត្រឹមត្រូវដើម្បីចូលរួមក្នុងក្រុម FMIS ដែលស្នើដោយ កសហវ ។<br>• ត្រូវប្រាកដថាមន្ត្រីដែលចាត់តាំងឱ្យចូលក្នុងក្រុម FMIS នឹងចូលរួមគ្រប់វគ្គបណ្តុះបណ្តាល សិក្ខាសាលា និងកម្មវិធីបង្កើនសមត្ថភាពផ្សេងទៀតស្តីពី FMIS ។ |
| ២៤.៥. ពង្រឹងការរៀបចំ FMIS និងបញ្ចប់ដំណើរការលទ្ធកម្ម ។ | • រៀបចំដំណើរការការងារដែលមានស្រាប់ឱ្យទៅជាដំណើរការការងារសម្រាប់ការអនុវត្ត FMIS នាពេលអនាគត ។<br>• ជួយសម្រួលក្នុងការរៀបចំ FMIS គ្រប់ដំណាក់កាល ។<br>• កំណត់ឱ្យបានច្បាស់ថា តើប្រភេទរបាយការណ៍ពិសេសអ្វីខ្លះដែលត្រូវការពីប្រព័ន្ធ FMIS ។ |
| ២៤.៦. រៀបចំផែនការអនុវត្តរួម ( ការសាកល្បង និងការពង្រីក ) ដោយរួមបញ្ចូល កសហវ ក្រសួង-ស្ថាប័ន និង អង្គភាពថ្នាក់ក្រោមជាតិ ។ | • យល់ដឹងអំពីឯកសារគោលនយោបាយ FMIS និងយល់ដឹងអំពីយុទ្ធសាស្ត្រនៃការពង្រីកការអនុវត្ត ។<br>• ចូលរួមក្នុងកម្មវិធីគ្រប់គ្រងការផ្លាស់ប្តូរនៃដំណើរការការងារ ។<br>• ជួយសម្រួលដល់ការអនុវត្តយុទ្ធសាស្ត្រគ្រប់គ្រងការផ្លាស់ប្តូរនៅតាមក្រសួង-ស្ថាប័ន។ |
| ២៤.៧. រៀបចំផែនការ និងវគ្គបណ្តុះបណ្តាលព្រមទាំងឯកសារបណ្តុះបណ្តាល | • បញ្ជូនមន្ត្រីត្រូវជំនាញដែលនឹងក្លាយជាអ្នកប្រើប្រាស់ប្រព័ន្ធ FMIS ដើម្បីចូលរួមក្នុងកម្មវិធីកសាងសមត្ថភាព FMIS ។<br>• ចូលរួមយ៉ាងសកម្មក្នុងគ្រប់វគ្គបណ្តុះបណ្តាល សិក្ខសាលា និងក្នុងកម្មវិធីកសាងសមត្ថ- |

| | |
|---|---|
| សម្រាប់ការបន្តបណ្តុះ-បណ្តាល ដល់គ្រប់មន្ត្រីដែលពាក់ព័ន្ធនឹង FMIS នៅ កសហវ ក្រសួង-ស្ថាប័ន និង អង្គភាពថ្នាក់ក្រោមជាតិ ។ | ភាព FMIS ដទៃទៀត ។<br>• កំណត់នូវកម្មវិធីកសាងសមត្ថភាពអ្វីខ្លះ ដែលចាំបាច់របស់ក្រសួង-ស្ថាប័នមុនពេលដាក់ឱ្យអនុវត្តនូវប្រព័ន្ធ FMIS ។<br>• សហការជាមួយ កសហវ ក្នុងការបង្កើតកម្មវិធីកសាងសមត្ថភាពដទៃទៀត និងក្នុងការចែករំលែកចំណេះដឹង ។ |
| **ការកសាងសមត្ថភាព** | |
| **គោលបំណងទី២៨ ៖ ការកសាងសមត្ថភាពស្ថាប័ន និង វិធានការលើកទឹកចិត្ត** | |
| ២៨.១. រៀបចំស្ថាប័នដើម្បីឆ្លើយតបនឹងដំណាក់កាល ទី២ ដោយរួមមាន ៖ ការបញ្ចប់ការវិភាគមុខងារនៅគ្រប់នាយកដ្ឋាននៃ កសហវ និង នាយកដ្ឋានហិរញ្ញវត្ថុនៃក្រសួង-ស្ថាប័ន ។ រៀបចំ និង អនុវត្តផែនការយុទ្ធសាស្ត្ររបស់នាយកដ្ឋាននីមួយៗ ។ រៀបចំ និង ផ្សព្វផ្សាយឯកសារណែនាំស្តីពីប្រព័ន្ធគ្រប់គ្រង ។ រៀបចំគោលនយោបាយសម្រាប់យុទ្ធ-សាស្ត្រគ្រប់គ្រងព័ត៌មានវិទ្យានៅ កសហវ ការកសាងសមត្ថភាពនាយកដ្ឋាន ការប្រើប្រាស់ជំនួយបច្ចេកទេសប្រកបដោយប្រសិទ្ធភាព ។ កែលម្អការអនុវត្តការងារតាមរយៈការបង្កើនការប្រើប្រាស់បច្ចេកវិទ្យា ។ | • តាក់តែងគោលនយោបាយ និងយុទ្ធសាស្ត្រវិភាគមុខងាររបស់ក្រសួង-ស្ថាប័ន ហើយដាក់ជូន កសហវ ដើម្បីផ្តល់យោបល់ ។<br>• រៀបចំឯកសារណែនាំអំពីការវិភាគមុខងាររបស់ក្រសួង-ស្ថាប័ន និងដាក់ជូន កសហវ ដើម្បីផ្តល់យោបល់ ។<br>• ស្នើការរៀបចំបទបញ្ញត្តិច្បាប់ពាក់ព័ន្ធនឹងការវិភាគមុខងាររបស់ក្រសួង-ស្ថាប័ន និងដាក់ជូន កសហវ ដើម្បីផ្តល់យោបល់ ។<br>• ចាត់ចែងអនុវត្តការវិភាគមុខងាររបស់ក្រសួង-ស្ថាប័ន ។<br>• រៀបចំការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពគោលនយោបាយជំនួយបច្ចេកទេសរបស់ក្រសួង-ស្ថាប័ន និងដាក់ជូន កសហវ ដើម្បីផ្តល់យោបល់ ។<br>• ស្នើនូវនីតិវិធីសមស្របសម្រាប់ការប្រើប្រាស់ជំនួយបច្ចេកទេសប្រកបដោយប្រសិទ្ធភាពរបស់ ក្រសួង-ស្ថាប័ន និងដាក់ជូន កសហវ ដើម្បីផ្តល់យោបល់ ។<br>• រៀបចំផែនការសកម្មភាពអនុវត្តការអភិវឌ្ឍន៍ស្ថាប័នរបស់ក្រសួង-ស្ថាប័ន ដោយរួមបញ្ចូលទាំងការវិភាគមុខងារ ការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពជំនួយបច្ចេកទេស និង MBPI ។ |

| | |
|---|---|
| ២៨.២. ការអភិវឌ្ឍធនធានមនុស្សសម្រាប់ដំណាក់កាលទី២ ដោយរួមមាន ៖ ការបង្កើតក្រុមមន្ត្រីចលករ និងការជ្រើសរើសមន្ត្រីពីខាងក្រៅលើជំនាញដែលមិនមានគ្រប់-គ្រាន់ ។ រៀបចំឱ្យមានគោលនយោបាយបង្វិលជុំនៃការ-ងារ ។ រៀបចំផែនការរក្សាទុកមន្ត្រីដែលមានជំនាញសមស្រប និង សមត្ថភាព ។ | • រៀបចំគោលនយោបាយជ្រើសរើសរបស់ក្រសួង-ស្ថាប័ន និងដាក់ជូន កសហវ ដើម្បីផ្តល់យោបល់ ។<br>• រៀបចំផែនការផ្លាស់ប្តូរវេនការងារសម្រាប់មន្ត្រីចលកររបស់ក្រសួង-ស្ថាប័ន និងដាក់ជូន កសហវ ដើម្បីផ្តល់យោបល់ ។<br>• តាក់តែងផែនការនិងគោលនយោបាយរក្សាទុកមន្ត្រីរាជការរបស់ក្រសួង-ស្ថាប័ន និងដាក់ជូន កសហវ ដើម្បីផ្តល់យោបល់ ។ |
| ២៨.៣. ការកសាង និង បណ្តុះបណ្តាលជំនាញសម្រាប់ដំណាក់កាលទី២ ដែលមានដូចជា ៖ ការពង្រីកនូវការកសាងជំនាញ និង រៀបចំវគ្គសិក្សាមូលដ្ឋាន ។ រៀបចំជាបឋមវគ្គសិក្សាថ្មីសម្រាប់មុខជំនាញសំខាន់ៗ។ ត្រូវចាប់ផ្តើមដំណើរការវគ្គសិក្សាដែល កសហវ បាន រៀបចំ និងរៀបចំផែនការកសាងសមត្ថភាពនៅតាមក្រសួង-ស្ថាប័ន ដែលស្ថិតនៅក្នុងក្របខ័ណ្ឌនៃផែនការរបស់ កសហវ ។ ស្របពេល | • សហការជាមួយ កសហវ ដើម្បីកំណត់ការខ្វះខាតផ្នែកជំនាញ និងតម្រូវការបណ្តុះបណ្តាល ។<br>• ធ្វើរបាយការណ៍អំពីការលំបាកទាំងឡាយនៃការដាក់អនុវត្តការអភិវឌ្ឍជំនាញដោយទូលំ-ទូលាយ និងតម្រូវការបណ្តុះបណ្តាលមក កសហវ ដើម្បីផ្តល់យោបល់ ។<br>• សហការជាមួយ កសហវ ជ្រើសរើសមន្ត្រីមានសមត្ថភាពចូលរួមការបណ្តុះបណ្តាលរៀបចំដោយ កសហវ ។<br>• ប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពមន្ត្រីដែលបានទទួលការបណ្តុះបណ្តាលនៅ កសហវ។<br>• ធ្វើការផ្ទេរប្រកបដោយប្រសិទ្ធភាពនូវចំណេះដឹង និង បទពិសោធន៍មន្ត្រីដែលបានទទួលការបណ្តុះបណ្តាលដល់មន្ត្រីដទៃទៀតនៅក្នុងក្រសួង-ស្ថាប័ន ។<br>• ធ្វើការពិនិត្យវាយតម្លៃប្រសិទ្ធភាពនៃការបណ្តុះបណ្តាលរៀបចំដោយ កសហវ ។<br>• តាក់តែងផែនការអភិវឌ្ឍន៍សមត្ថភាពក្រសួង-ស្ថាប័ន ហើយដាក់ជូន កសហវ ដើម្បីផ្តល់យោបល់ ។<br>• រៀបចំកម្មវិធីបណ្តុះបណ្តាលនៅនឹងកន្លែងផ្ទាល់ដើម្បីបង្ហាញដល់មន្ត្រីទាំងឡាយដែលស្ថិតក្នុងការផ្លាស់ប្តូរថ្មីក្រោមកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ ។ |

| | |
|---|---|
| គ្នានេះដែរត្រូវបន្ត រៀបចំផែនការបណ្តុះបណ្តាលនៅបរទេសជា ពិសេសសម្រាប់ក្រុមមន្ត្រីចលករ ព្រមទាំងរៀបចំ និងអនុវត្តផែនការទស្សនកិច្ចសិក្សា ។ | |
| ២៨.៤. រៀបចំឱ្យមានការលើកទឹកចិត្តសម្រាប់ដំណាក់កាលទី២ ដែលមានដូចជា ៖ ពិនិត្យ និង ពង្រីកគម្រោងផ្តល់លាភការផ្អែកលើលទ្ធផលការងារ(MBPI) ដោយបន្ថែមចំនួនមន្ត្រី ។ រៀបចំវិធានការដើម្បីគាំទ្រដល់អ្នកដែលប៉ះពាល់ដោយសារការផ្លាស់ប្តូរដំណើរការ និងស្ថាប័ន ។ រៀបចំអភិក្រមសម្រាប់វាយតម្លៃដើម្បីទទួលបានការបណ្តុះបណ្តាលផ្អែកតាមតម្រូវការ ។ បង្កើនឱ្យមានការយល់ដឹង និង ចូលរួមនៅក្នុងផែនការកសាងសមត្ថ-ភាព ។ | • រៀបចំក្របខ័ណ្ឌ MBPI និងដាក់ជូន កសហវ ដើម្បីផ្តល់យោបល់ ។<br>• ផ្សព្វផ្សាយឯកសារណែនាំនៅក្នុងក្រសួង-ស្ថាប័ន ដោយសហការជាមួយ កសហវ ។ |

## *ប្រភពធនធានដែលត្រូវផ្តល់ដល់ក្រសួង-ស្ថាប័ន*

នៅក្នុងការរៀបចំ និងអនុវត្តផែនការសកម្មភាព និងផែនការកសាងសមត្ថភាព ក្រសួង-ស្ថាប័ន នឹងទទួលបាននូវជំនួយផ្នែកបច្ចេកទេស និងធនធានហិរញ្ញវត្ថុពី ៖

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** នឹងអាចផ្តល់ ៖

- ទីប្រឹក្សាស្នូលដែលមានបញ្ជាក់ជូនក្នុងឧបសម្ព័ន្ធទី៤ ខាងក្រោម ។
- ការគាំទ្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមរយៈមូលនិធិទំនុកចិត្តពហុដៃគូអភិវឌ្ឍន៍ដែលគ្រប់គ្រងដោយ កសហវ ។
- កម្មវិធីកសាងជំនាញ និងវគ្គបណ្តុះបណ្តាលដែលរៀបចំដោយ កសហវ ។

**ជំនួយគាំទ្រទ្វេភាគី** តាមរយៈ ៖

- កម្មវិធីជំនួយដែលមានស្រាប់ ដែលត្រូវបានផ្តល់ដោយផ្ទាល់ទៅក្រសួង-ស្ថាប័ន នៅពេលដែលមូលនិធិទាំងនោះអាចប្រើប្រាស់សម្រាប់សកម្មភាពដើម្បីគាំទ្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។
- កម្មវិធីជំនួយថ្មីដែលក្រសួង-ស្ថាប័ន អាចធ្វើការចរចាឱ្យមានផ្នែកមួយនៃកម្មវិធីនោះអាចប្រើប្រាស់សម្រាប់សកម្មភាពគាំទ្រកម្មវិធីកែទម្រង់ការគ្រប់គ្រង ហិរញ្ញវត្ថុសាធារណៈ ។

មូលនិធិនឹងត្រូវផ្តល់ផងដែរ ដើម្បីប្រើប្រាស់ជាលាភការផ្អែកលើសមិទ្ធកម្មសម្រាប់មន្ត្រីទាំងឡាយដែលបំពេញកិច្ចការដោយផ្ទាល់ក្នុងការងារកែទម្រង់របស់ក្រសួង-ស្ថាប័ន ។

ទំហំនៃប្រភពធនធានទាំងនេះនឹងអាស្រ័យលើកម្មវិធីដែលកំពុងដំណើរការរួចទៅហើយ និងអាចខុសប្លែកគ្នាពីក្រសួង-ស្ថាប័នមួយទៅក្រសួង-ស្ថាប័នមួយ ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័ន នឹងធ្វើការពិភាក្សាលើលក្ខខណ្ឌតម្រូវ និងការបំពេញលក្ខខណ្ឌតម្រូវទាំងនោះដោយផ្អែកលើការងារបឋមនិងផែនការកសាងសមត្ថភាពរបស់ ក្រសួង-ស្ថាប័ន ។

## *ក្របខ័ណ្ឌត្រួតពិនិត្យតាមដានវឌ្ឍនភាព*

ក្រសួង-ស្ថាប័ន នឹងទទួលបានឯកសារមួយចំនួន ដើម្បីជួយសម្រួលដល់ការត្រួតពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពផែនការសកម្មភាពរបស់ខ្លួន ៖

- របាយការណ៍វឌ្ឍនភាពនៃ PFMRP ទាំងមូល ។

- របាយការណ៍វឌ្ឍនភាពរបស់នាយកដ្ឋាននៃ កសហវ ដែលកំណត់ពីពេលវេលាសម្រាប់ក្រសួង-ស្ថាប័ន ត្រូវចូលរួមចំណែកនៅក្នុងសកម្មភាពណាមួយ ។
- ផែនការសកម្មភាព និងផែនការកសាងសមត្ថភាពដែលបានធ្វើបច្ចុប្បន្នភាព ។

*ក្រសួង-ស្ថាប័ន ត្រូវរៀបចំបង្កើត ៖*

- របាយការណ៍ផ្ទៃក្នុង ដើម្បីវាយតម្លៃពីវឌ្ឍនភាពការងារនៅក្នុងផែនការសកម្មភាពរបស់ខ្លួន ។
- របាយការណ៍វឌ្ឍនភាពប្រចាំត្រីមាស ស្របតាមទម្រង់នៃរបាយការណ៍ដែលនឹងត្រូវផ្តល់ជូនដោយ កសហវ ។

បញ្ហាប្រទាក់ក្រឡាគ្នាត្រូវបានគ្រប់គ្រង និងសម្របសម្រួលដោយក្រុមការងារដែលបង្កើតឡើងនៅក្នុង កសហវ ។ មន្ត្រីនៃក្រសួង-ស្ថាប័ន ត្រូវចូលរួមនៅក្នុងកិច្ចដំណើរការនេះតាមរយៈ ៖

- ការបញ្ចូលមន្ត្រីបង្គោលរបស់ ក្រសួង-ស្ថាប័ន ជាសមាជិកភាពនៅក្នុងក្រុមសម្របសម្រួលសមស្របណាមួយ ។
- ពិភាក្សារួមគ្នាជាមួយ កសហវ និងក្រសួង-ស្ថាប័ន លើរបាយការណ៍វឌ្ឍនភាព ។
- ចែករំលែកការប្រើប្រាស់ជំនួយបច្ចេកទេសរួមគ្នា និងធ្វើការណែនាំក្នុងករណីចាំបាច់ ។

# ឧបសម្ព័ន្ធទី ៤

# ការកែលម្អការប្រើប្រាស់ទីប្រឹក្សាបច្ចេកទេសនៅ
# ដំណាក់កាលទី ២

ការជ្រើសរើសជំនួយបច្ចេកទេសក្នុងអំឡុងពេលអនុវត្តដំណាក់កាលទី១ ជាញឹកញាប់ មានការយឺតយ៉ាវ លំបាកស្មុគស្មាញ និងផ្តល់លទ្ធផលមិនជាទីគាប់ចិត្ត ។ មូលហេតុមួយចំនួន ដែលបណ្តាលឱ្យមានបញ្ហានេះ មានដូចជា ៖

- កិច្ចលទ្ធកម្មជ្រើសរើសទីប្រឹក្សាបច្ចេកទេសជាញឹកញាប់ត្រូវបានធ្វើឡើងដោយផ្អែកលើមូលដ្ឋានការងារដោយឡែកៗពីគ្នា ដែលតាមពិតទៅ ការងារទាំងអស់នេះគួរត្រូវប្រមូលផ្តុំ ហើយមានមន្ត្រីមានសមត្ថភាពម្នាក់ទទួលបន្ទុកលើការងារនេះ ។
- នាយកដ្ឋាននានាតែងរង់ចាំរហូតដល់ពេលមានសេចក្តីត្រូវការទើបស្នើសុំជំនួយ ។ កិច្ចលទ្ធកម្មតែងអូសបន្លាយពេលវេលាយូរជាងការរំពឹងទុកក្នុងការទទួលជំនួយបច្ចេកទេស ។
- ការព្រាងលក្ខខណ្ឌយោង (TOR) សម្រាប់ជ្រើសរើសទីប្រឹក្សាបច្ចេកទេស (TA) របស់នាយកដ្ឋានត្រូវការពេលវេលាច្រើន ហើយជារឿយៗ នាយកដ្ឋានមិនសូវមានការយល់ដឹងពីវិធីសាស្ត្រក្នុងការសរសេរលក្ខខណ្ឌយោងឱ្យបានត្រឹមត្រូវ ស្របតាមលក្ខណៈទីផ្សារការងារផ្នែកពិគ្រោះយោបល់ ។ ហេតុនេះហើយលក្ខខណ្ឌយោងដែលបានរៀបចំ គឺសម្រាប់តែជួយដល់នាយកដ្ឋានណាមួយតែប៉ុណ្ណោះ ទោះបីជាការងារភាគច្រើនមានទំនាក់ទំនងគ្នាជាមួយបណ្តានាយកដ្ឋានជាច្រើនក៏ដោយ ។
- ដោយសារតែការចាប់ផ្តើមកិច្ចលទ្ធកម្មមានការយឺតយ៉ាវទើបនាំឱ្យទីប្រឹក្សាដែលមានជំនាញខ្ពស់ភាគច្រើនបានទទួលបំពេញកិច្ចការផ្សេង ហើយមិនអាចទទួលយកកិច្ចការ របស់ កសហវ ។
- លក្ខណៈលម្អិតនៃការងារ និងការពិនិត្យតាមដានសមិទ្ធកម្មនៅមានភាពទន់ខ្សោយ ។ ជួនកាល ការពិនិត្យតាមដាននេះត្រូវបានធ្វើឡើងចំពោះតែនាយកដ្ឋានពាក់ព័ន្ធប៉ុណ្ណោះ យើងមិនបានពិនិត្យមើលពីបច្ច័យនៃការងារដែលបានបំពេញទៅលើកម្មវិធីកែទម្រង់ទាំងមូលឡើយ ។

បញ្ហានេះនឹងអាចកាន់តែស្មុគស្មាញថែមទៀតនៅក្នុងដំណាក់កាលទី២ ដោយសារតែមានការចូលកាន់តែច្រើនពីក្រសួង-ស្ថាប័ននានា ។

ដើម្បីបង្កើនល្បឿនការងារ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គួរតែធ្វើលទ្ធកម្មក្នុងនាមឱ្យខ្លួនឯងផ្ទាល់ និងក្នុងនាមក្រសួង-ស្ថាប័ន ដើម្បីជ្រើសរើសទីប្រឹក្សា “ស្នូល” មួយចំនួនដែលនឹងត្រូវធ្វើកិច្ចសន្យាដោយផ្អែកលើមូលដ្ឋាន “តម្រូវការ” សម្រាប់ចំនួនថ្ងៃកំណត់ជាក់លាក់ក្នុងរយៈពេលមួយដែលនឹងត្រូវកំណត់ដោយ កសហវ នៅពេលសេចក្តីត្រូវការកើតមាន ។ កិច្ចសន្យានឹងមានលក្ខណៈដូចខាងក្រោម ៖

- ជាកិច្ចសន្យាទីប្រឹក្សាឯកត្តជន ឬ ទីប្រឹក្សាដែលត្រូវផ្តល់ដោយក្រុមហ៊ុន ។
- ជាដំបូង កិច្ចសន្យាត្រូវកំណត់ចំនួនថ្ងៃការងារសម្រាប់រយៈពេលមួយឆ្នាំ ។
- បន្ទាប់ពីរយៈពេល ១ ឆ្នាំ កសហវ អាចបន្តកិច្ចសន្យាសម្រាប់រយៈពេលរហូតដល់២ឆ្នាំ អាស្រ័យលើសមិទ្ធកម្មល្អរបស់ទីប្រឹក្សាបច្ចេកទេស ។
- ជាទូទៅ ទីប្រឹក្សាទាំងអស់ជាទីប្រឹក្សាមិនស្ថិតនៅជាអចិន្ត្រៃយ៍ ( ប៉ុន្តែមានទីប្រឹក្សាខ្លះអាចមកបំពេញកិច្ចការជាប្រចាំសម្រាប់រយៈពេលខ្លី ) ដែលប្រការនេះធ្វើឱ្យនាយកដ្ឋានមានភាពជាម្ចាស់លើការអនុវត្តសកម្មភាពការងាររបស់ខ្លួន ហើយនាយកដ្ឋានអាចទទួលបានយោបល់បច្ចេកទេសដោយងាយស្រួលនៅពេលមានតម្រូវការ។

លក្ខណៈលម្អិតនៃការងារសម្រាប់ទីប្រឹក្សាស្នូលត្រូវរៀបចំដូចខាងក្រោម ៖

- នាយកដ្ឋានទាំងអស់ ត្រូវកំណត់អំពីសកម្មភាពការងារលម្អិតនៅក្នុងផែនការសកម្មភាពរបស់ខ្លួនដែលត្រូវការជំនួយបច្ចេកទេស ។
- លេខាធិការដ្ឋាននឹងពិនិត្យសកម្មភាពទាំងនេះ ហើយចងក្រងសកម្មភាពទាំងនេះទៅជាបណ្តុំសកម្មភាព។
- ទីប្រឹក្សាស្នូលនឹងត្រូវជ្រើសរើសដើម្បីអនុវត្តកន្សោមសកម្មភាពនីមួយៗ ដោយផ្អែកលើប្រភេទ និងពេលវេលានៃបណ្តាសកម្មភាពទាំងនោះ ។ ប៉ុន្តែក្នុងករណីមានសកម្មភាពដាច់ដោយឡែក ដែលតម្រូវឱ្យមានជំនាញពិសេស អ្នកជំនាញក្នុងវិស័យនោះអាចនឹងត្រូវជ្រើសរើសដាច់ដោយឡែកពីទីប្រឹក្សាស្នូល ។
- លក្ខខណ្ឌយោងនឹងត្រូវរៀបចំសម្រាប់បណ្តុំសកម្មភាពនីមួយៗ ជាដំបូងដោយលេខាធិការដ្ឋានដោយមានជំនួយពីទីប្រឹក្សាបច្ចេកទេសគោល ហើយលក្ខខណ្ឌយោងនេះនឹងត្រូវដាក់ឱ្យនាយកដ្ឋានពាក់ព័ន្ធដើម្បីពិនិត្យ និងផ្តល់យោបល់ ។
- ការងារផ្សេងទៀតរបស់ទីប្រឹក្សាស្នូល គឺត្រូវផ្តល់កិច្ចគាំទ្រដល់ការរៀបចំលក្ខខណ្ឌយោងសម្រាប់ទីប្រឹក្សាឯកទេស ។ ទីប្រឹក្សាស្នូលក៏ត្រូវផ្តល់ការគាំទ្រដល់ក្រសួង-ស្ថាប័ន ផងដែរតាមជំនាញរបស់ខ្លួនក្នុងការពិនិត្យឡើងវិញ និងផ្តល់យោបល់លើផែនការសកម្មភាព និងផែនការកសាងសមត្ថភាពរបស់ក្រសួង-ស្ថាប័ន ព្រមទាំងការកំណត់ពីតម្រូវការបច្ចេកទេសរបស់ក្រសួង-ស្ថាប័ន ទាំងនោះ ។
- ទីប្រឹក្សាស្នូលក៏ត្រូវយល់ដឹងផងដែរ អំពីកាតព្វកិច្ចរបស់មន្ត្រីដែលទទួលលាភការផ្អែកលើលទ្ធផលការងារ ដែលជាសហសេវិកបំពេញការងាររួមជាមួយគ្នា ។ ប្រការសំខាន់គឺថា មន្ត្រីទាំងនោះនៅតែ

មានកាតព្វកិច្ចបំពេញការងាររបស់ខ្លួន ប៉ុន្តែ ទីប្រឹក្សាត្រូវផ្តល់យោបល់ណែនាំជួយដល់មន្ត្រីនោះនៅពេលដែលមានតម្រូវការ ។

- ទីប្រឹក្សាស្នូលនឹងត្រូវចូលរួមក្នុងការរៀបចំ និងបង្រៀននូវវគ្គជំនាញមួយចំនួនដែលបានកំណត់ក្នុងផែនការអភិវឌ្ឍសមត្ថភាព ។ ដូច្នេះ ត្រូវដាក់បញ្ចូលការងារនេះទៅក្នុងលក្ខខណ្ឌយោងរបស់ទីប្រឹក្សាទាំងនោះ ។
- នាយកដ្ឋានពាក់ព័ន្ធនានានឹងចូលរួមក្នុងការជ្រើសរើសទីប្រឹក្សា ។ បញ្ជីជ្រើសរើសសម្រាំង (shortlist) នឹងត្រូវបានបង្កើតឡើងដោយការប្រកួតប្រជែង ដែលក្នុងនោះមានទីប្រឹក្សាឯកត្តជនយ៉ាងហោចណាស់ពី ៣-៦ នាក់ដែរ ។
- គំរូសាមញ្ញសម្រាប់កំណត់តម្រូវការការងាររបស់ទីប្រឹក្សាស្នូល ត្រូវតែរៀបចំឱ្យមានសម្រាប់នាយក-ដ្ឋានពាក់ព័ន្ធ ដើម្បីកំណត់ពីភារកិច្ចជាក់ស្តែង និងច្បាស់លាស់ដែលទីប្រឹក្សា "ស្នូល" ត្រូវបំពេញ ។

ដោយផ្អែកលើផែនការសកម្មភាពការងារដែលត្រូវអនុវត្តសម្រាប់ដំណាក់កាលទី២ នៃកម្មវិធីកែទម្រង់ ទីប្រឹក្សាស្នូលមួយចំនួនដែលគួរចាប់ផ្តើមជ្រើសរើសឱ្យបានឆាប់រហ័ស សម្រាប់ផ្តល់ការប្រឹក្សាលើផ្នែកដូចខាងក្រោម ៖

- ប្រឹក្សាលើក្របខ័ណ្ឌម៉ាក្រូ និងហិរញ្ញវត្ថុសាធារណៈ (Macro-fiscal) ព្រមទាំងការគាំទ្រដល់ការអនុវត្ត ។
- ប្រឹក្សាលើគោលនយោបាយចំណូល និងការគាំទ្រដល់ការអនុវត្ត ។
- ប្រឹក្សាលើការរៀបចំថវិកា និងការគាំទ្រដល់ការអនុវត្ត ។
- ប្រឹក្សាលើការអនុវត្ត និងការគ្រប់គ្រងថវិកា ព្រមទាំងការគាំទ្រដល់ការអនុវត្ត ។
- ប្រឹក្សាលើប្រព័ន្ធគណនេយ្យ និងប្រព័ន្ធរបាយការណ៍ ព្រមទាំងការគាំទ្រដល់ការអនុវត្ត ( រួមទាំង FMIS ) ។
- ប្រឹក្សាលើការធ្វើសវនកម្ម និងការគាំទ្រដល់ការអនុវត្ត ។
- ប្រឹក្សាលើការបណ្តុះបណ្តាល និងការគាំទ្រដល់ការអនុវត្ត ។
- ប្រឹក្សាលើការអភិវឌ្ឍធនធានមនុស្ស និងការគាំទ្រដល់ការអនុវត្ត ( រួមមានការបង្កើត និងអនុវត្តយុទ្ធ-សាស្ត្រទំនាក់ទំនងទាក់ទិននឹងកម្មវិធីកែទម្រង់ ) ។

ក្របខ័ណ្ឌពិនិត្យតាមដានសមិទ្ធកម្ម ដែលបានកែសម្រួលតម្រូវឱ្យនាយកដ្ឋាននីមួយៗរាយការណ៍អំពីសមិទ្ធកម្មនៃសកម្មភាពការងារ ។ គោលបំណងគឺមិនត្រឹមតែបង្ហាញថា សកម្មភាពការងារដែលត្រូវបំពេញបានធ្វើរួចហើយប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងចង់បង្ហាញឱ្យឃើញពីអត្ថប្រយោជន៍នៃការរួមចំណែកនៃសកម្មភាពការងារទាំងនោះដល់ការជំរុញកំណែទម្រង់ឱ្យឆ្ពោះទៅមុខជាលំដាប់ ។ លេខាធិការដ្ឋាននឹងបំពេញតួនាទីជាគន្លឹះក្នុងការសម្របសម្រួលលើកិច្ចការនេះ ។ ក្របខ័ណ្ឌពិនិត្យតាមដានសមិទ្ធកម្មទាំងនេះត្រូវបានកំណត់យ៉ាងលម្អិតដូចមានក្នុងឯកសារភ្ជាប់ខាងក្រោម ។

ម្យ៉ាងទៀត ការប្រើប្រាស់ជំនួយបច្ចេកទេសគួរស្ថិតនៅក្រោមការគ្រប់គ្រងរបស់ កសហវ ។ ជាបឋម លេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់ត្រូវរៀបចំរបាយការណ៍សង្ខេបប្រចាំត្រីមាសស្តីអំពីជំនួយបច្ចេកទេសដែលបានទទួល សមិទ្ធកម្មរបស់ទីប្រឹក្សា និង លទ្ធផលសម្រេចបាន ។ របាយការណ៍នេះត្រូវផ្តល់ជូនដល់គណៈកម្មការ និងក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃក្រសួង-ស្ថាប័ន ដើម្បីធ្វើការវាយតម្លៃ និង ផ្តល់មតិយោបល់ជូនគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

ឯកសារភ្ជាប់ទៅនឹងឧបសម្ព័ន្ធទី៤

## ការពង្រឹងការពិនិត្យតាមដានលើសមិទ្ធកម្មរបស់ទីប្រឹក្សាបច្ចេកទេស

### *ការកែសម្រួលលក្ខខណ្ឌយោងសម្រាប់ទីប្រឹក្សាបច្ចេកទេស*

ចំពោះការរៀបចំលក្ខខណ្ឌយោង ត្រូវបញ្ចូលកថាខ័ណ្ឌខាងក្រោមនេះ ៖

**ទីមួយ** ត្រូវធ្វើឱ្យមានភាពច្បាស់លាស់ចំពោះក្របខ័ណ្ឌរាយការណ៍ ៖

"ទីប្រឹក្សាស្នូលតម្រូវឱ្យរាយការណ៍លើសកម្មភាពការងារនីមួយៗ ដែលត្រូវបានប្រគល់ឱ្យបំពេញ ។ របាយការណ៍ដែលតម្រូវឱ្យធ្វើជូនសមភាគីការងារ លេខាធិការដ្ឋានកែទម្រង់ និងទីប្រឹក្សាគោលរួមមាន ៖

- របាយការណ៍ការងារបឋម និងផែនការការងារ ។
- របាយការណ៍ការងារសម្រាប់បេសកកម្មនីមួយៗ ( នៅពេលមានបេសកកម្មច្រើន ) ។
- របាយការណ៍ចុងក្រោយ នៅពេលបញ្ចប់សកម្មភាពការងារទាំងស្រុង ។

**ទីពីរ** ធ្វើឱ្យមានភាពច្បាស់លាស់ដល់ទីប្រឹក្សា លើលក្ខខណ្ឌវិនិច្ឆ័យដែលត្រូវប្រើសម្រាប់វិនិច្ឆ័យសមិទ្ធកម្មរបស់ទីប្រឹក្សាគឺ ៖

"ការបំពេញបានតាមលក្ខខណ្ឌតម្រូវនៃលក្ខខណ្ឌយោង នឹងត្រូវវាយតម្លៃផ្អែកតាមគំរូដូចមានខាងក្រោម ។ ទីប្រឹក្សា និងសមភាគីការងារតម្រូវឱ្យធ្វើការត្រួតពិនិត្យលើវឌ្ឍនភាពជាប្រចាំទៅតាមពេលវេលាសមស្របដោយផ្អែកលើមូលដ្ឋាននៃឯកសារគំរូ" ។

ការវាយតម្លៃគឺសម្រាប់បម្រើគោលដៅផ្ទៃក្នុងរបស់ក្រសួង-ស្ថាប័ន ទោះជាលទ្ធផលនៃការវាយតម្លៃនេះ អាចនឹងត្រូវផ្តល់ជូនទីប្រឹក្សាឱ្យបានជ្រាបក៏ដោយ ។

**ទីបី** ការវាយតម្លៃត្រូវធានាថានេះជាការវាយតម្លៃទៅវិញទៅមករវាងទីប្រឹក្សា និង សមភាគីការងាររបស់ខ្លួន ៖

ទីប្រឹក្សាគួរដាក់បញ្ចូលនៅក្នុងរបាយការណ៍របស់ខ្លួន អំពីការវាយតម្លៃទំនាក់ទំនងជាមួយសមភាគីការងាររបស់ខ្លួន និងឧបសគ្គនានាចំពោះការអនុវត្តសកម្មភាពការងារដែលបានកំណត់នៅក្នុងលក្ខខណ្ឌយោង ។

ឯកសារគំរូដែលមានភ្ជាប់មកជាមួយខាងក្រោមនេះ នឹងត្រូវបំពេញដើម្បីវាយតម្លៃលទ្ធផលការងាររបស់ទីប្រឹក្សា ។ ការវាយតម្លៃនេះត្រូវផ្អែកលើផ្នែកគន្លឹះ៣ ដូចខាងក្រោម ៖

- សមិទ្ធកម្មនៃការទទួលខុសត្រូវដែលបានប្រគល់ និងការផ្ដល់ប្រឹក្សាលើគោលនយោបាយ និងបច្ចេកទេស ។
- ផ្ដល់លទ្ធផលដូចដែលបានកំណត់ក្នុងលក្ខខណ្ឌយោង ។
- សមត្ថភាពត្រូវបានកសាង និងចីរភាពនៃលទ្ធផលត្រូវបានសម្រេច ។

លើសពីនេះទៀត ប្រធាននាយកដ្ឋាន ឬ អង្គភាពទាំងអស់តម្រូវឱ្យយល់បានច្បាស់លាស់អំពីអ្វីដែលសម្រេចបាន ហើយនឹងត្រូវយកទៅប្រើប្រាស់របៀបណា ព្រមទាំងទទួលយកអនុសាសន៍ និងការផ្ដល់ប្រឹក្សាមកពិនិត្យដើម្បីអនុវត្ត ។

## គំរូសម្រាប់វាយតម្លៃសមិទ្ធកម្មរបស់ទីប្រឹក្សា

### ការវាយតម្លៃដោយសមភាគី

| ការទទួលខុសត្រូវ | សមិទ្ធកម្ម ( សូមអានសេចក្តីណែនាំអំពីការផ្តល់និទ្ទេស ) | | | | |
|---|---|---|---|---|---|
| | មិនពេញចិត្ត | ពេញចិត្តខ្លះ | ពេញចិត្ត | ល្អ | ល្អណាស់ |
| ( ដូចដែលកំណត់ក្នុងលក្ខខណ្ឌយោង ) | | | | | |

ហេតុផលសម្អាង/ភស្តុតាងសម្រាប់ការវាយតម្លៃ ................

| លទ្ធផល | សមិទ្ធកម្ម ( សូមអានសេចក្តីណែនាំអំពីការផ្តល់និទ្ទេស ) | | | | |
|---|---|---|---|---|---|
| | មិនពេញចិត្ត | ពេញចិត្តខ្លះ | ពេញចិត្ត | ល្អ | ល្អណាស់ |
| ( ដូចដែលកំណត់ក្នុងលក្ខខណ្ឌយោង ) | | | | | |

ហេតុផលសម្អាង/ភស្តុតាងសម្រាប់ការវាយតម្លៃ ...................

| ការអភិវឌ្ឍសមត្ថភាព និងចីរភាពដែលបានរួមចំណែក | សមិទ្ធកម្ម ( សូមអានសេចក្តីណែនាំអំពីការផ្តល់និទ្ទេស ) | | | | |
|---|---|---|---|---|---|
| | មិនពេញចិត្ត | ពេញចិត្តខ្លះ | ពេញចិត្ត | ល្អ | ល្អណាស់ |
| ( ដូចដែលកំណត់ក្នុងលក្ខខណ្ឌយោង ) | | | | | |

ហេតុផលសម្អាង/ភស្តុតាងសម្រាប់ការវាយតម្លៃ ................

មតិយោបល់ដោយប្រធាននាយកដ្ឋាន ឬ ប្រធានអង្គភាព

| | |
|---|---|
| សមិទ្ធកម្មរួម | |
| តើលទ្ធផលនឹងត្រូវយកទៅប្រើប្រាស់របៀបណា | |
| បទពិសោធន៍ដែលទទួលបានពីការជ្រើសរើស និង ប្រើប្រាស់ទីប្រឹក្សា | |
| ការប្រើប្រាស់ទីប្រឹក្សានៅពេលអនាគត | |

ហត្ថលេខា ............................ ប្រធាននាយកដ្ឋាន ឬ ប្រធានអង្គភាព

| |
|---|
| មតិយោបល់បន្ថែមដោយ ៖<br>១. លេខាធិការដ្ឋាន<br>២. ទីប្រឹក្សាបច្ចេកទេសស្នូល |

# ឧបសម្ព័ន្ធទី ៥

# យុទ្ធសាស្ត្រសម្រាប់ការអនុវត្ត

៥.១ ការអភិវឌ្ឍសមត្ថភាពដើម្បីគាំទ្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

៥.២ ផែនការកសាងសមត្ថភាពក្រសួង-ស្ថាប័ន

៥.៣ គោលនយោបាយប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ

ឧបសម្ព័ន្ធ ៥.១

# ការអភិវឌ្ឍសមត្ថភាពដើម្បីគាំទ្រដល់ កម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ

## ផែនការកសាងសមត្ថភាព

## ១.	សេចក្តីផ្តើម

វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៃ កសហវ បានដាក់ជូនអនុគណៈកម្មាធិការកសាងសមត្ថភាពនូវផែនការបណ្តុះបណ្តាលដើម្បីគាំទ្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅខែមិនា ឆ្នាំ២០០៧ ។ ផែនការនេះបានឆ្លុះបញ្ចាំងពីសេចក្តីត្រូវការក្នុងការបណ្តុះបណ្តាលដើម្បីគាំទ្រកម្មវិធីកែទម្រង់ដែលកំពុងដំណើរការ ហើយត្រូវបានអនុម័ត និងកំពុងអនុវត្ត ។

កម្មវិធីអភិវឌ្ឍសមត្ថភាពត្រូវបានទទួលស្គាល់ថាចាំបាច់ និងមានលក្ខណៈទូលំទូលាយ ដែលផែនការបណ្តុះបណ្តាលនេះគ្រាន់តែជាផ្នែកមួយតែប៉ុណ្ណោះ ។ ដើម្បីឱ្យអ្នកដែលបំពេញការងារផ្នែកគ្រប់គ្រងហិរញ្ញវត្ថុ ជាពិសេសស្ត្រីជាថ្នាក់ដឹកនាំនៅក្នុងស្ថាប័នរដ្ឋាភិបាល អាចកែលម្អនូវអ្វីដែលពួកគាត់បំពេញដើម្បីឱ្យស្របតាមទិសដៅរបស់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រការនេះគឺតម្រូវឱ្យមានការយកចិត្តទុកដាក់ មិនត្រឹមតែទៅលើការផ្តល់ជំនាញប៉ុណ្ណោះទេ តែថែមទាំងលើរបៀបដឹកនាំ ចាត់ចែងការងារ និងការលើកទឹកចិត្តរបស់ពួកគាត់ផងដែរ ។ គោលបំណងនៃយុទ្ធសាស្ត្រនេះ គឺដើម្បីដាក់ចេញនូវផែនការកសាងសមត្ថភាពដូចជា ការបង្កើនសមត្ថភាពមន្ត្រីរាជការជាស្ត្រី ដែលនឹងដើរតួយ៉ាងសំខាន់នៅក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈត្រូវបានយកចិត្តទុកដាក់ ។

### ១.១.	សាវតារបស់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ដើម្បីឱ្យមានភាពស័ក្តិសិទ្ធិ កម្មវិធីអភិវឌ្ឍសមត្ថភាពត្រូវតម្រង់ទិសឆ្ពោះទៅរកការគាំទ្រគោលបំណងនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

គោលបំណងនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺសំដៅបង្កើនកម្រិតស្តង់ដារឱ្យកាន់តែខ្ពស់លើការគ្រប់គ្រង និងគណនេយ្យភាពនៃការកៀរគរធនធានចរន្ត និងមូលធនទាំងអស់របស់រដ្ឋាភិបាល ព្រមទាំងភាពស័ក្តិសិទ្ធិ និងប្រសិទ្ធិភាពក្នុងការប្រើប្រាស់ធនធានក្នុងការអនុវត្តកម្មវិធីអាទិភាពរបស់រាជរដ្ឋាភិបាល ។ ទិសដៅរយៈពេលវែងគឺត្រូវកែប្រែប្រព័ន្ធការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលឱ្យក្លាយជាប្រព័ន្ធមួយដែលត្រូវបានទទួលស្គាល់ជាទូទៅ និងមានលក្ខណៈស្តង់ដារអន្តរជាតិ ។

នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា បានផ្តល់អនុសាសន៍នៅក្នុងអារម្ភកថានៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កាលពីថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ២០០៤ ថា ការពង្រឹងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈគឺជាការចាំបាច់ និងបន្ទាន់ ហើយនេះក៏ជាស្នូលនៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធិភាពនៅកម្ពុជា ហើយដែលកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញ-

វត្ថុសាធារណៈនេះមានសង្គតិភាពទៅនឹងផែនការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ( ឆ្នាំ២០០១-២០០៥ ) និងយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ( ឆ្នាំ២០០៣-២០០៥ ) ។ ការធ្វើឱ្យប្រសើរឡើងដល់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈគឺជាធាតុយ៉ាងសំខាន់មួយសម្រាប់ការពង្រឹងអភិបាលកិច្ចល្អ ដូច្នេះហើយរាជរដ្ឋាភិបាលកម្ពុជាបានកសាងនូវចក្ខុវិស័យនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រកបដោយភាពច្បាស់លាស់ និងបណ្តាជំហានចាំបាច់ឆ្ពោះទៅរកការសម្រេចចក្ខុវិស័យនេះ ។ រាជរដ្ឋាភិបាលទទួលស្គាល់ថា ការបង្កើតឱ្យមាននូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលល្អប្រសើរនឹងត្រូវការពេលវេលាច្រើនឆ្នាំ ព្រមទាំងកិច្ចខិតខំប្រឹងប្រែង ជាច្រើន ។

"ជំហាន" ទាំងបួន ត្រូវបានកំណត់ដោយឆ្លុះបញ្ចាំងវិធីសាស្ត្រជាដំណាក់កាលៗ ចាប់ផ្តើមពីការអភិវឌ្ឍជំហានទី១ ដែលជាជំហានធ្វើឱ្យថវិកាកាន់តែអាចជឿទុកចិត្តបានជាងមុន ។

## ១.២. តួនាទីនៃផែនការកសាងសមត្ថភាព

ផែនការកសាងសមត្ថភាពត្រូវបានបង្កើតឡើង ដើម្បីគាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងដើម្បីផ្តល់សមាសធាតុជាយុទ្ធសាស្ត្រស្របទៅនឹងតម្រូវការនៃជំហានទាំងបួនក្នុងការអនុវត្តកម្មវិធីកំណែទម្រង់ ។ ហេតុនេះផែនការនេះ ត្រូវបានរៀបចំជាដំណាក់កាលៗ ដើម្បីឆ្លើយតបទៅនឹងការវិវត្ត និងត្រូវស្ថិតក្នុងភាពសមស្របទៅនឹងដំណើរការនៃការអនុវត្តកម្មវិធីកំណែទម្រង់ ។ ជោគជ័យនៃការអនុវត្តកម្មវិធីកំណែទម្រង់នេះ មួយផ្នែកត្រូវពឹងផ្អែកទៅលើសមត្ថភាពរបស់មន្ត្រីរាជការនៃ កសហវ និងក្រសួង-ស្ថាប័នទាំងអស់ ក្នុងការកសាងចំណេះដឹង និង ជំនាញ ។ ការបំពេញទៅតាមតម្រូវការនេះ ត្រូវចាត់ទុកថាជាប្រការចាំបាច់ សម្រាប់គ្រប់នាយកដ្ឋាននៃ កសហវ និងក្រសួង-ស្ថាប័នទាំងអស់ ។

ប៉ុន្តែ ការបង្កើនការអភិវឌ្ឍសមត្ថភាពគឺមិនមានន័យត្រឹមតែអភិវឌ្ឍជំនាញតែម្យ៉ាងនោះទេ ។ ការអភិវឌ្ឍសមត្ថភាពក្នុងបរិបទនេះ គឺមិនគ្រាន់តែជាការអភិវឌ្ឍសមត្ថភាពរបស់បុគ្គលិកម្នាក់ៗរបស់នាយកដ្ឋានពាក់ព័ន្ធនៃ កសហវ ប៉ុណ្ណោះទេ តែត្រូវរួមទាំងការបង្កើតយន្តការដ៏សំខាន់ចាំបាច់ និងរឹងមាំសម្រាប់ក្រសួងដើម្បីសម្រេចគោលដៅនៃកម្មវិធីកែទម្រង់ ។ ការអភិវឌ្ឍសមត្ថភាពមានគោលបំណងធ្វើឱ្យមន្ត្រីរាជការអាចបំពេញតួនាទីរបស់ខ្លួនកាន់តែប្រសើរឡើងនៅក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ លើសពីនេះទៀត ការអភិវឌ្ឍសមត្ថភាពគួរក្លាយជាយានសំខាន់មួយ ដែលតាមរយៈយាននេះ យើងអាចកែប្រែនូវទិដ្ឋភាពអរូបីមួយចំនួនដូចជា អាកប្បកិរិយា ឆន្ទៈ ចរិតលក្ខណៈរបស់មន្ត្រីរាជការនៅក្នុងទំនាក់ទំនងការងារជាមួយសាធារណជន ។

ផែនការកសាងសមត្ថភាពត្រូវធានាថា សមាសធាតុផ្សេងៗនៃ កសហវ និងក្រសួង-ស្ថាប័ន អាចប្រតិបត្តិរួមគ្នាដើម្បីផ្តល់នូវកាលានុវត្តភាពសម្រាប់ការអភិវឌ្ឍធនធានមនុស្ស ។ ហេតុនេះហើយ គោលបំណងនៃផែនការកសាងសមត្ថភាពរបស់កម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈនេះធានាថារាល់យន្តការសមស្របត្រូវបានអនុវត្តជាបណ្តើរៗ ។

## ២. គោលបំណង និងទិសដៅនៃផែនការកសាងសមត្ថភាព

### ២.១ ទិសដៅរួម

ទិសដៅរួមនៃផែនការកសាងសមត្ថភាព គឺត្រូវគាំទ្រដល់ការសម្រេចឱ្យបាននូវចក្ខុវិស័យនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមរយៈការកសាងសមត្ថភាពជំនាញវិជ្ជាជីវៈ ការលើកទឹកចិត្ត និងបង្កើនឱ្យមានភាពចម្រុះនៃកម្លាំងពលកម្ម ដែលកម្លាំងពលកម្មនេះនឹងត្រូវដឹកនាំ គ្រប់គ្រង គាំទ្រ និងផ្តល់ការតបស្នងយ៉ាងត្រឹមត្រូវ។

### ២.២ គោលបំណងនៃការកសាងសមត្ថភាព

គោលបំណងជាគន្លឹះមួយចំនួននៃការកសាងសមត្ថភាពត្រូវបានកំណត់ដូចខាងក្រោម ៖

(១) កសាងសមត្ថភាពឱ្យស្របទៅនឹងដំណើរការថ្មីៗដែលមាននៅក្នុងដំណាក់កាលនីមួយៗ ។

(២) ធានាឱ្យបាននូវចីរភាពនៃសមត្ថភាពនៅក្នុងពេលអនាគតតាមរយៈការគ្រប់គ្រងស្ថាប័ន ធនធានមនុស្ស និងវិធានការលើកទឹកចិត្ត ។

(៣) កសាងសមត្ថភាពសម្រាប់រយៈពេលវែង ដែលស្របគ្នានឹងការបំពេញឱ្យបាននូវសេចក្តីត្រូវការរយៈពេលខ្លី ដើម្បីឱ្យស្ថាប័នទាំងមូលអាចរីកចម្រើនរហូតដល់អាចសម្រេចបាននូវគោលបំណងនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

(៤) លើកកម្ពស់ភាពជាអ្នកដឹកនាំរបស់ស្ត្រីនៅក្នុងរដ្ឋបាលសាធារណៈ តាមរយៈការបង្កើនចំណេះដឹងជំនាញ និងការកសាងជំនាញឱ្យកាន់តែទូលំទូលាយ ។

នៅក្នុងក្របខ័ណ្ឌនៃគោលបំណងគន្លឹះទាំងអស់នេះ សកម្មភាពការងារសំខាន់ៗមួយចំនួនត្រូវបានកំណត់ដូចខាងក្រោម ៖

(១) ជ្រើសរើសបុគ្គលិកមានសមត្ថភាពសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។
(២) ទាក់ទាញ រក្សាទុក និងផ្លាស់ប្តូរវេនការងារបុគ្គលិកឱ្យបានសមស្រប ។
(៣) បង្កើតឱ្យមានបរិស្ថានការងារល្អសម្រាប់មន្ត្រីរាជការដែលមានឆន្ទៈពិតប្រាកដក្នុងការអនុវត្តការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។
(៤) ធានាថា ការបណ្តុះបណ្តាលទាំងអស់ត្រូវបានផ្តល់អាទិភាពដើម្បី ៖
- ការសិក្សា និងការកសាងសមត្ថភាពគាំទ្រដល់ការងារជាអាទិភាព
- ហានិភ័យស្ថាប័នត្រូវកាត់បន្ថយជាអតិបរមា
- សកម្មភាពជាអាទិភាពត្រូវឆ្លើយតបទៅនឹងតម្រូវការថ្មីៗ ។
(៥) កសាងអ្នកដឹកនាំ និងអ្នកគ្រប់គ្រងរួមទាំងស្ត្រី សម្រាប់ពេលអនាគត ។
(៦) កាត់បន្ថយការបណ្តុះបណ្តាលដែលមានលក្ខណៈទ្រឹស្តីសុទ្ធសាធដោយប្រើប្រាស់វិធីសាស្ត្របណ្តុះ-បណ្តាលផ្សេងទៀត ។
(៧) ធានានូវសមភាពក្នុងការទទួលបានកាលានុវត្តភាពសម្រាប់ការសិក្សា និងកសាងសមត្ថភាពសមស្របចំពោះមន្ត្រីរាជការ ។

## ២.៣ លទ្ធផលគន្លឹះ

គោលបំណងទាំងនេះនឹងត្រូវវាយតម្លៃតាមរយៈការសម្រេចនូវលទ្ធផលនានាដូចខាងក្រោមនេះ ៖

(១) សមត្ថភាពរបស់ស្ថាប័ននៅក្នុងការអនុវត្តដំណើរការការងារថ្មី និងគ្រប់គ្រងដំណើរការការងារនេះនៅពេលបន្ទាប់ ។
(២) ការកើនឡើងនូវទំនុកចិត្តផ្នែកសមត្ថភាពរបស់មន្ត្រីរាជការនៃ កសហវ ក្នុងការអនុវត្ត និងគ្រប់គ្រងកំណែទម្រង់ ។
(៣) ការលេចឡើងនូវបេក្ខជនប្រកបដោយសមត្ថភាពជាអ្នកដឹកនាំ រួមទាំងស្ត្រីសម្រាប់ថ្ងៃអនាគត។
(៤) មន្ត្រីរាជការនឹងទទួលបានចំណេះដឹង ជំនាញ និងបទពិសោធន៍តាមតម្រូវការនៃការគ្រប់គ្រងហិរញ្ញ-វត្ថុសាធារណៈ ។
(៥) មន្ត្រីរាជការនឹងត្រូវបានលើកទឹកចិត្ត ព្រមទាំងយល់ដឹងពីការចូលរួមចំណែករបស់ខ្លួននៅក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

(៦) មន្ត្រីរាជការនឹងត្រូវបានដឹកនាំ និងគ្រប់គ្រងយ៉ាងត្រឹមត្រូវ ។

(៧) មន្ត្រីរាជការនឹងត្រូវបានគាំពារយ៉ាងសមរម្យ ហើយនឹងបំពេញការងារនៅក្នុងបរិស្ថានមួយដែលមានផាសុកភាពតាមដែលអាចអនុវត្តបាន ។

(៨) មន្ត្រីរាជការនឹងត្រូវបានទទួលនូវផលតបស្នងយ៉ាងសមរម្យ ។

(៩) ធនធានអាទិភាពនឹងត្រូវបែងចែកឱ្យបានសមស្រប និងចំទិសដៅដើម្បីបំពេញតម្រូវការការងារសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

(១០) ភាពជាម្ចាស់លើការគ្រប់គ្រងធនធានមនុស្សដែលកំពុងបំពេញការងារមានប្រសិទ្ធិភាព ។

(១១) មុខងារនៃធនធានមនុស្ស ជំរុញ និងគាំទ្រការផ្លាស់ប្តូរស្ថាប័នដើម្បីធ្វើឱ្យប្រសើរឡើងនូវសមិទ្ធកម្មក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

# ៣. ការកសាងសមត្ថភាពស្របជាមួយកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

## ៣.១. និដ្ឋភាពទូទៅ

ដូចបានបញ្ជាក់ខាងលើ ផ្នែកសំខាន់មួយនៃផែនការនេះគឺការកសាងសមត្ថភាពដែលត្រូវមានលក្ខណៈស៊ីសង្វាក់ជាមួយនឹងសកម្មភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងមូល ។ ប៉ុន្តែសកម្មភាពមួយចំនួន ត្រូវអនុវត្តបន្តរហូតនៅក្នុងកម្មវិធី ក្នុងន័យកសាងសមត្ថភាពដែលចាំបាច់ដើម្បីធានាចីរភាពនៃកម្មវិធី ។

គំនូសបំព្រួញខាងក្រោមកំណត់អំពីដំណាក់កាលនៃកំណែទម្រង់ ដែលនៅក្នុងដំណាក់កាលនីមួយៗបានកំណត់សកម្មភាពកសាងសមត្ថភាពជាក់លាក់ ជាផែនការចាំបាច់គាំទ្រដំណាក់កាលនីមួយៗនោះ ។ សកម្មភាពកសាងសមត្ថភាពទាំងនេះ ជាការរួមផ្សំគ្នារវាងការកសាងជំនាញពាក់ព័ន្ធនឹងដំណាក់កាលនីមួយៗ កម្មវិធីកសាងជំនាញទូទៅឱ្យកាន់តែទូលំទូលាយដែលត្រូវអនុវត្តបន្តរហូតក្នុងកម្មវិធីសកម្មភាពកសាងធន-ធានមនុស្ស ការកសាងសមត្ថភាពផ្អែកតាមជំនួយបច្ចេកទេស សកម្មភាពកសាងស្ថាប័ន និងការលើកទឹកចិត្ត ។ សកម្មភាពមួយចំនួនមានលក្ខណៈជាក់លាក់ចំពោះដំណាក់កាលនីមួយៗ សកម្មភាពខ្លះអនុវត្តសម្រាប់ច្រើនដំណាក់កាល ឬសម្រាប់កម្មវិធីទាំងមូល ។

# ការកសាងសមត្ថភាពស្របជាមួយកម្មវិធីកែទម្រង់

| ដំណាក់កាលទី ១ | ដំណាក់កាលទី ២ | ដំណាក់កាលទី ៣ | ដំណាក់កាលទី ៤ |
|---|---|---|---|
| ថវិកាដែលអាចជឿទុកចិត្តបានដោយសារតែផ្តល់ធនធាន ដែលអាចជឿទុកចិត្តនិងអាចព្យាករណ៍បានដល់អ្នកគ្រប់គ្រងថវិកា | ការកែលម្អជាបឋមប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងការធ្វើឱ្យអ្នកគ្រប់-គ្រងមានគណនេយ្យភាព | ការកែលម្អទំនាក់ទំនងរវាងអាទិភាព និងគោលដៅសេវាជាមួយនឹងការរៀបចំផែនការនិងការអនុវត្តថវិកា | សមាហរណកម្មនៃគណនេយ្យភាព និងដំណើរការត្រួតពិនិត្យឡើងវិញសម្រាប់ហិរញ្ញវត្ថុ និងសមិទ្ធកម្ម |

## ការកសាងជំនាញ

## ជំនាញបច្ចេកទេស

| | | | |
|---|---|---|---|
| • ការធ្វើផែនការលំហូរសាច់ប្រាក់ ( រតនាគារជាតិ, ន.ថវិកា)<br>• ការគ្រប់គ្រងលំហូរសាច់ប្រាក់ (រតនា-គារជាតិ អង្គភាពគ្រប់គ្រងសាច់ប្រាក់)<br>• ការរៀបចំប្លង់គណនេយ្យ (រតនា-គារជាតិ, ន.ថវិកា)<br>• យុទ្ធសាស្ត្របំណុល ( ន.វិនិយោគ និងសហប្រតិបត្តិការ, | • ប្រតិភូកម្មថវិកាប្រកបដោយភាពស័ក្តិសិទ្ធិ (ន.លទ្ធកម្មសាធារណៈ, ក្រសួង-ស្ថាប័ន)<br>• ការវិភាគរបាយ-ការណ៍ គណនេយ្យ ( គ្រប់អង្គភាពទាំងអស់ )<br>• ការប្រើប្រាស់ប្លង់គណនេយ្យ (ក្រសួង-ស្ថាប័ន, ន.ហិរញ្ញកិច្ច, ន.ថវិកា)<br>• ការវិភាគថវិកា (គ្រប់អង្គភាពទាំង | • ការរៀបចំថវិកាពហុឆ្នាំ<br>• ការវិភាគកម្មវិធី និងការធ្វើផែនការសេវាកម្ម<br>• កំណត់ជម្រើសសម្រាប់គោលបំណងថវិកា<br>• ការកំណត់លទ្ធផលគោលដៅ<br>• បទពិសោធន៍ទទួលបានពីការអនុវត្តថវិកា<br>• ការផ្សារភ្ជាប់ថវិកាចរន្ត និងថវិកាមូលធន | • សូចនាករនៃការអនុវត្តការងារ<br>• ការកំណត់អាទិភាព<br>• ការកំណត់ការប្រែប្រួលចំពោះលទ្ធផលសេវាកម្ម<br>• ការប្រឹក្សាប្រកបដោយប្រសិទ្ធភាពស្តីពីថវិកា<br>• ការរាយការណ៍ និងការទំនាក់ទំនង<br>• បទពិសោធន៍ទទួលបានពីការអនុវត្តថវិកា<br>• គណនេយ្យភាពប្រកបដោយប្រសិទ្ធ |

| | | | |
|---|---|---|---|
| រតនាគារជាតិ, ន.ថវិកា)<br>• ការគ្រប់គ្រងបំណុល (រតនាគារជាតិ, ន.វិនិយោគ និង សហប្រតិបត្តិការ)<br>• វិធីសាស្ត្រព្យាករណ៍ (ន.លទ្ធកម្មសាធារ-ណៈ, រតនាគារជាតិ, គយ និងរដ្ឋាករ, ន.ចំណូលមិនមែន សារពើពន្ធ)<br>• ការកសាងគោលនយោបាយចំណូល (ន.លទ្ធកម្ម សាធារណៈ,រតនាគារជាតិ, អគ្គ នាយកដ្ឋានគយ និងរដ្ឋាករ, អគ្គនាយកដ្ឋានពន្ធដារ)<br>• លទ្ធកម្មប្រព័ន្ធព័ត៌មានវិទ្យា (ន. លទ្ធកម្ម)<br>• ការកសាងនីតិវិធីការងារ (គ្រប់អង្គភាព ទាំងអស់) | អស់)<br>• ការឆ្លើយតបចំពោះថវិកា (គ្រប់អង្គភាពទាំងអស់ )<br>• ការកសាងផែនការសវនកម្ម (ន. សវនកម្មផ្ទៃក្នុង, អគ្គាធិការដ្ឋាន, ក្រសួង-ស្ថាប័ន)<br>• ការវិភាគហានិភ័យជាមូលដ្ឋានសម្រាប់សវនកម្ម (ន.សវនកម្មផ្ទៃក្នុង, អគ្គាធិការដ្ឋាន, ក្រសួង-ស្ថាប័ន)<br>• ការអនុវត្ត FMIS (ន. លទ្ធកម្មសាធារណៈ)<br>• ការប្រើប្រាស់ប្រព័ន្ធ FMIS ( គ្រប់អង្គ-ភាពទាំងអស់ )<br>• ការគ្រប់គ្រងការផ្លាស់ប្តូរទាក់ទិននឹងការដាក់ឱ្យប្រើប្រាស់ FMIS (គ្រប់អង្គភាពទាំងអស់, ក្រសួង-ស្ថាប័ន ) | • ស្វែងរកការសន្សំថវិកាប្រកបដោយប្រសិទ្ធភាព<br>• ការវិភាគចំណាយ | ភាពចំពោះ សាធារ-ណៈជន |

## ជំនាញមូលដ្ឋាន

| |
|---|
| ការយល់ដឹងអំពីកម្មវិធីកំណែទម្រង់<br>ការកសាងសមត្ថភាពគ្រប់គ្រង និងសមត្ថភាពវិភាគ<br>ការរៀបចំជំនាញវិជ្ជាជីវៈ<br>ជំនាញភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងការផ្លាស់ប្តូរ<br>ការបណ្តុះបណ្តាលនៅបរទេសសម្រាប់មន្ត្រីចលករ |

## វិធានការបណ្តុះបណ្តាលសមត្ថភាពឱ្យកាន់តែទូលំទូលាយ
## ការកសាងគោលនយោបាយធនធានមនុស្ស

| |
|---|
| ការកំណត់ក្របខ័ណ្ឌមន្ត្រីចលករ<br>ជ្រើសរើសបុគ្គលិកពីខាងក្រៅសម្រាប់ផ្នែកដែលមានជំនាញមិនគ្រប់គ្រាន់<br>កសាងផែនការផ្លាស់ប្តូរវេនការងារសម្រាប់មន្ត្រីចលករ<br>កសាងផែនការការរក្សាទុកមន្ត្រីចំពោះផ្នែកជំនាញគន្លឹះ |

## ការប្រើប្រាស់ជំនាញការពីខាងក្រៅ

| |
|---|
| គោលនយោបាយសម្រាប់ការប្រើប្រាស់ជំនួយបច្ចេកទេសប្រកបដោយភាពស័ក្តិសិទ្ធិ<br>ផែនការសិក្សា |

## ការរៀបចំស្ថាប័ន

| | | |
|---|---|---|
| ការដាក់ចេញនូវវិធានការនៅពេលចាប់ផ្តើមកម្មវិធីកែទម្រង់<br><br>ការវិភាគមុខងាររបស់រតនាគារ/នាយកដ្ឋានហិរញ្ញកិច្ច | • ការដាក់ឱ្យដំណើរការអង្គភាពសវនកម្ម<br>• ការពិនិត្យឡើងវិញនូវមុខងាររបស់នាយកដ្ឋានហិរញ្ញវត្ថុ នៅតាមក្រសួង-ស្ថាប័ន | ការពិនិត្យឡើងវិញនូវមុខងាររបស់នាយកដ្ឋានថវិកា |

| | | |
|---|---|---|
| | • ការពិនិត្យឡើងវិញនៃប្រតិភូកម្មថវិកានៅតាមក្រសួង-ស្ថាប័ន<br>• ការកសាងអភិក្រមជាប្រព័ន្ធសម្រាប់ការបង្កើតកម្រងប្រព័ន្ធនីតិវិធីណែនាំ | |

## ការរៀបចំការលើកទឹកចិត្ត

| | | |
|---|---|---|
| បង្កើតនិងអនុវត្តលាភការផ្អែកលើលទ្ធផលការងារ | • កំណត់ក្របខ័ណ្ឌមន្ត្រីចលករ<br>• ការដាក់ទណ្ឌកម្ម និងការលើកទឹកចិត្តសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុបានល្អ<br>• បង្កើតវិធានការគាំទ្រដល់មន្ត្រីរាជការដែលការងារទទួលរងផលប៉ះពាល់ពីការផ្លាស់ប្តូរស្ថាប័ន<br>• បង្កើតវិធីសាស្ត្រសម្រាប់ការបណ្តុះបណ្តាលដែលផ្អែកលើសេចក្តីត្រូវការ | • បញ្ចូលលាភការផ្អែកលើលទ្ធ-ផលការងារទៅក្នុងប្រព័ន្ធបៀវត្ស<br>• រៀបចំការផ្តល់រង្វាន់តាមរយៈវិភាជន៍ថវិកាសម្រាប់សំណើសុំថវិកាបានល្អ |

## ៣.២ តម្រូវការសម្រាប់ជំហានទី១ និង ទី២

ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជំហានទី ១ កំពុងជិតបញ្ចប់ប្រកបដោយភាពជោគជ័យ ហើយដំណាក់កាលអន្តរកាលទៅកាន់ដំណាក់កាលទី២ កំពុងត្រូវបានពិចារណាដោយថ្នាក់ដឹកនាំក្រសួង ។ ទោះជាយ៉ាងណាក៏ដោយ ប្រការគួរឱ្យកត់សម្គាល់គឺការកសាងសមត្ថភាពនៅក្នុងជំហានទី ១ មិនត្រូវបានអនុវត្តពេញលេញទេ ។ម្យ៉ាងទៀតទោះជាមានការផ្តល់នូវការបណ្តុះបណ្តាលទូទៅមួយចំនួនក៏ដោយ ក៏ការបណ្តុះបណ្តាលជំនាញជាក់លាក់នានាដែលបានកំណត់នៅក្នុងគំនូសបំព្រួញខាងលើនេះ គឺជាការចាំបាច់ដែលត្រូវតែអនុវត្តឱ្យបានស៊ីជម្រៅ ។ ជាងនេះទៀតការងារទាក់ទិននឹងការកសាងសមត្ថភាពឱ្យកាន់តែទូលំទូលាយមិនត្រូវបានអនុវត្តជាដុំកំភួននោះទេ គឺមានតែអនុវត្តការផ្តល់លាភការដោយផ្អែកលើលទ្ធផលការងារតែប៉ុណ្ណោះ ។ ដូច្នេះ កត្តាសំខាន់គឺត្រូវវិភាគពីសេចក្តីត្រូវការនានាសម្រាប់ជំហានទី ១ និងទី២ រួមគ្នា ដោយវិភាគពីសេចក្តីត្រូវការសម្រាប់គាំទ្រជំហានទី ១ និង ការរំពឹងទុកពីសេចក្តីត្រូវការសម្រាប់ជំហានទី ២ ។

សេចក្តីត្រូវការនៃការកសាងសមត្ថភាពនៅក្នុងជំហាទី១ និងទី២ ដូចមានបង្ហាញក្នុងគំនូសបំព្រួញខាងលើ រួមមានការកសាងសមត្ថភាពជំនាញ និងការកសាងសមត្ថភាពឱ្យកាន់តែទូលំទូលាយ ។ ទាក់ទិននឹង

ការកសាងសមត្ថភាពជំនាញវគ្គបណ្តុះបណ្តាលចាំបាច់មួយចំនួនត្រូវបានផ្តល់ជូនអគ្គនាយកដ្ឋាន និង នាយកដ្ឋាននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានដូចជា ៖ ការរៀបចំផែនការលំហូរសាច់ប្រាក់ ការគ្រប់គ្រងលំហូរសាច់ប្រាក់ ការរៀបចំប្លង់គណនេយ្យ យុទ្ធសាស្ត្រ និង ការគ្រប់គ្រងបំណុល ការព្យាករណ៍ និង ការរៀបចំគោលនយោបាយចំណូល ការធ្វើលទ្ធកម្មប្រព័ន្ធព័ត៌មានវិទ្យា (IT) ការរៀបចំដំណើរការ និង អភិក្រមការងារ ប្រតិភូកម្មថវិកាប្រកបដោយភាពស័ក្តិសិទ្ធិ ការបកស្រាយរបាយការណ៍គណនេយ្យ ការប្រើប្រាស់ប្លង់គណនេយ្យ ការវិភាគថវិកា ការឆ្លើយតបចំពោះថវិកា ការរៀបចំផែនការសវនកម្ម ការវិភាគហានិភ័យសម្រាប់ជាមូលដ្ឋានសវនកម្ម ការអនុវត្ត FMIS កាប្រើប្រាស់ប្រព័ន្ធ FMIS សម្រាប់ជំនាញបច្ចេកទេស និងការគ្រប់គ្រងការផ្លាស់ប្តូរទាក់ទិននឹងការដាក់ឱ្យប្រើប្រាស់ FMIS និងវគ្គសិក្សាមួយចំនួន ដូចជាការយល់ដឹងពីកម្មវិធីកំណែទម្រង់ ការកសាងសមត្ថភាពវិភាគ និងគ្រប់គ្រង និងជំនាញវិជ្ជាជីវៈ ជំនាញភាពជាអ្នកដឹកនាំ ជាដើម ។

វិធានការកសាងសមត្ថភាពឱ្យកាន់តែទូលំទូលាយ តម្រូវឱ្យអគ្គនាយកដ្ឋាន និង នាយកដ្ឋានទាំងអស់នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចាំបាច់ត្រូវរៀបចំគោលនយោបាយ ធនធានមនុស្ស ការប្រើប្រាស់ជំនាញការពីខាងក្រៅ និងការអនុវត្តការរៀបចំស្ថាប័ន និងការលើកទឹកចិត្ត ដើម្បីជំរុញដំណើរការនៃការអនុវត្តសមិទ្ធកម្ម ។

### ៣.៣. សេចក្តីត្រូវការសម្រាប់ជំហានទី ៣ និងទី ៤

គំនូសបំព្រួញខាងលើគឺឆ្លុះបញ្ចាំងពីសកម្មភាពទូលំទូលាយដែលត្រូវការសម្រាប់ជំហានទី ៣ និង ទី ៤ នេះគ្រាន់តែជាការទាញការចាប់អារម្មណ៍តែប៉ុណ្ណោះ គឺមិនតម្រូវឱ្យមានការរៀបចំជាសកម្មភាពលម្អិតនៅក្នុងដំណាក់កាលនេះទេ ។ បទពិសោធន៍ជាច្រើននឹងទទួលបានពីការអនុវត្តនៅក្នុងជំហានទី ១ និង ទី ២ ហើយបទពិសោធន៍ទាំងនេះ នឹងត្រូវបានប្រើប្រាស់ជាធាតុចូលនៅក្នុងការរៀបចំជំហានទី ៣ និង ទី ៤ នៅក្នុងពេលមួយដ៏សមស្រម ។

## ៤. សកម្មភាពគាំទ្រជំហានទី១ និងទី២ ដែលបានស្នើឡើង

### ៤.១ អភិក្រមកំណត់តម្រូវការជំនាញ

ការវិភាគតម្រូវការជំនាញ គឺត្រូវបានធ្វើឡើងដោយយកចិត្តទុកដាក់ទៅលើសេចក្តីត្រូវការទាំងមុខងារបច្ចុប្បន្ន និងទាំងការផ្លាស់ប្តូរដែលជាលទ្ធផលនៃការអនុវត្តកម្មវិធីកំណែទម្រង់ ។ ចំពោះការអនុវត្ត

ការវិភាគនេះ ជាដំបូង គឺមានការរៀបចំការសិក្សាអង្កេត ដោយប្រើប្រាស់បញ្ជីសំណួរ និងការសម្ភាសន៍ជាមួយអគ្គនាយកដ្ឋាន និង នាយកដ្ឋានពាក់ព័ន្ធ ដើម្បីប្រមូលទិន្នន័យ និងព័ត៌មានទាំងបរិមាណ និងគុណភាព ។

បន្ទាប់មកគឺធ្វើការវិភាគទៅលើទិន្នន័យបរិមាណ ដោយប្រើវិធីសាស្ត្រប្រៀបធៀប ដើម្បីកំណត់តម្រូវការជំនាញរវាងតម្រូវការរបស់ការងារថ្មី និងការងារបច្ចុប្បន្ន ។ ទន្ទឹមនឹងនេះ ទិន្នន័យគុណភាពត្រូវបានប្រើសម្រាប់គាំទ្រដល់ការកសាងជំនាញដើម្បីអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ការសិក្សានេះបានបង្ហាញឱ្យឃើញថា អគ្គនាយកដ្ឋាន និង នាយកដ្ឋានទាំងអស់ មិនអាចអនុវត្តការងារកំណែទម្រង់ប្រកបដោយប្រសិទ្ធិភាពបានទេ ដោយសារតែខ្វះខាតសមត្ថភាព និង ជំនាញជាក់លាក់ និង ចាំបាច់មួយចំនួន ។ ហេតុដូច្នេះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឬអគ្គនាយកដ្ឋាន និង នាយកដ្ឋានពាក់ព័ន្ធចាំបាច់ត្រូវបំពេញការខ្វះខាតនោះ តាមរយៈការបើកវគ្គបណ្តុះបណ្តាលនានាដូចមានរៀបរាប់ក្នុងគំនូសបំព្រួញខាងលើ រួមជាមួយនឹងការកសាងសមត្ថភាពទូលំទូលាយតាមរយៈការរៀបចំគោលនយោបាយធនធានមនុស្ស ការប្រើប្រាស់ជំនាញការពីខាងក្រៅ និង ការរៀបចំស្ថាប័ន និងការលើកទឹកចិត្ត ។

## ៤.២ ផ្នែកសំខាន់ៗនៃផែនការគោរពការកំណែទម្រង់នៅក្នុងជំហានទី១ និងទី២

ដោយផ្អែកលើការសិក្សាខាងលើនេះ តម្រូវការសម្រាប់វគ្គបណ្តុះបណ្តាលជំនាញ និង ការកសាងជំនាញទូលំទូលាយ គឺមានដូចខាងក្រោមនេះ ៖

### ៤.២.១. ការកសាងជំនាញ

### ជំនាញបច្ចេកទេស

| ជំហាន | មុខវិជ្ជា | អគ្គនាយកដ្ឋាន/នាយកដ្ឋាន |
|---|---|---|
| ១ | - ការរៀបចំផែនការលំហូរសាច់ប្រាក់<br>- ការគ្រប់គ្រងលំហូរសាច់ប្រាក់<br>- ការរៀបចំប្លង់គណនេយ្យ<br>- យុទ្ធសាស្ត្របំណុល<br>- ការគ្រប់គ្រងបំណុល<br>- ការព្យាករណ៍ | - រតនាគារជាតិ និងថវិកា<br>- រតនាគារជាតិ<br>- រតនាគារជាតិ និងថវិកា<br>- វិនិយោគ រតនាគារជាតិ និងថវិកា<br>- វិនិយោគ និង រតនាគារជាតិគោលនយោបាយ រតនាគារជាតិ គយ និង រដ្ឋាករ |

| | | |
|---|---|---|
| | - ការរៀបចំគោលនយោបាយចំណូល<br><br>- លទ្ធកម្មប្រព័ន្ធព័ត៌មានវិទ្យា (IT)<br>- ការរៀបចំដំណើរការការងារ (Business Process) | ពន្ធដារ ចំណូលមិនមែនពន្ធ ទ្រព្យសម្បត្តិរដ្ឋ និងឧស្សាហកម្មហិរញ្ញវត្ថុ<br>- ព័ត៌មានវិទ្យា និង លទ្ធកម្ម<br>- គ្រប់អគ្គនាយកដ្ឋាន និង នាយកដ្ឋានទាំងអស់ ។ |
| ២ | - ប្រតិភូកម្មថវិកាប្រកបដោយភាពស័ក្តិសិទ្ធ<br>- ការបកស្រាយរបាយការណ៍គណនេយ្យ<br>- ការប្រើប្រាស់ប្លង់គណនេយ្យ<br>- ការវិភាគថវិកា<br>- ការឆ្លើយតបចំពោះថវិកា<br>- ការរៀបចំផែនការសវនកម្ម<br>- ការវិភាគហានិភ័យសម្រាប់ជាមូលដ្ឋានសវនកម្ម<br>- ការអនុវត្ត FMIS<br>- ការប្រើប្រាស់ប្រព័ន្ធ FMIS<br>- ការគ្រប់គ្រងការផ្លាស់ប្តូរដែលទាក់ទិននឹងការដាក់ឱ្យអនុវត្ត FMIS | - ថវិកា និងក្រសួង-ស្ថាប័ន<br><br>- អគ្គនាយកដ្ឋាន និង នាយកដ្ឋានពាក់ព័ន្ធនៃ កសហវ<br>- ក្រសួង-ស្ថាប័ន និង អគ្គនាយកដ្ឋាន /នាយកដ្ឋានពាក់ព័ន្ធនៃកសហវ<br>- អគ្គនាយកដ្ឋាន/នាយកដ្ឋានពាក់ព័ន្ធនៃ កសហវ<br>- ក្រសួង-ស្ថាប័ន<br>- សវនកម្មផ្ទៃក្នុង អធិការកិច្ច និង ក្រសួង-ស្ថាប័ន<br>- សវនកម្មផ្ទៃក្នុង អធិការកិច្ច និង ក្រសួង-ស្ថាប័ន<br>- ព័ត៌មានវិទ្យា<br>- អគ្គនាយកដ្ឋាន/នាយកដ្ឋានពាក់ព័ន្ធនៃ កសហវ<br>- គ្រប់អគ្គនាយកដ្ឋាន/នាយកដ្ឋាននៃ កសហវ និង ក្រសួង-ស្ថាប័ន |

## ជំនាញមូលដ្ឋាន

| ជំហាន | មុខវិជ្ជា | អគ្គនាយកដ្ឋាន/នាយកដ្ឋាន |
|---|---|---|
| ១ និង ២ | - ការយល់ដឹងអំពីកម្មវិធីកំណែទម្រង់<br>- ការកសាងសមត្ថភាពវិភាគ និង សមត្ថភាពគ្រប់គ្រង<br>- ជំនាញវិជ្ជាជីវៈ<br>- ជំនាញភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងការផ្លាស់ប្តូរ<br>- អាហារូបករណ៍ទៅសិក្សានៅក្រៅប្រទេសសម្រាប់មន្ត្រីចលករ ដែលបានជ្រើសរើស | - គ្រប់អគ្គនាយកដ្ឋាន/នាយកដ្ឋាននៃ កសហវ និង ក្រសួង-ស្ថាប័ន |

## ៤.២.២. ការកសាងសមត្ថភាពឱ្យកាន់តែទូលំទូលាយ ការរៀបចំគោលនយោបាយធនធានមនុស្ស *

| ជំហាន | ជម្រើសគោលនយោបាយ | សកម្មភាពដែលស្នើឡើង | អ្នកអនុវត្ត/អ្នកគាំទ្រ |
|---|---|---|---|
| ២ | ការកំណត់ក្របខ័ណ្ឌមន្ត្រីចលករ | - បង្កើតលក្ខណៈវិនិច្ឆ័យសម្រាប់ការកំណត់<br>- រៀបចំយន្តការសម្រាប់ការជ្រើសរើស<br>- រៀបចំ និងបង្កើត លក្ខខណ្ឌដែលនឹងត្រូវអនុវត្តចំពោះមន្ត្រីចលករ | អគ្គនាយកដ្ឋាន/នាយកដ្ឋាននីមួយៗជាមួយនឹងការគាំទ្រដោយ EFI |
| | ការជ្រើសរើសបុគ្គលិកពីខាងក្រៅសម្រាប់ផ្នែកដែលមាន | - កំណត់នូវផ្នែកសំខាន់ៗដែលមានជំនាញមិនគ្រប់គ្រាន់ | អគ្គនាយកដ្ឋាន/នាយកដ្ឋាននីមួយៗជាមួយនឹងការគាំទ្រ |

| | | | |
|---|---|---|---|
| | ជំនាញមិនគ្រប់គ្រាន់ | - បង្កើតនិតិវិធីសម្រាប់ជ្រើសរើស<br>- រៀបចំដំណើរការផ្នែកបច្ចេកទេស<br>- រៀបចំគោលនយោបាយទាក់ទាញ | ដោយ EFI និងថ្នាក់ដឹកនាំកសហវ និង ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល |
| | កសាងផែនការផ្លាស់ប្តូរវេនការងារសម្រាប់មន្ត្រីចលករ | - រៀបចំផែនការប្តូរវេន ការងារ និង នីតិវិធីអនុវត្ត<br>- បង្កើតនូវបរិយាកាសការងារដែលអំណោយផលដល់ការប្តូរវេនការងារ | អគ្គនាយកដ្ឋាន/នាយកដ្ឋាននីមួយៗជាមួយនឹងការគាំទ្រដោយ EFI |
| | កសាងផែនការការរក្សាទុកមន្ត្រីចំពោះផ្នែកជំនាញគន្លឹះ | - រៀបចំគោលនយោបាយរក្សាទុកមន្ត្រី<br>- រៀបចំនីតិវិធីអនុវត្ត<br>- បង្កើតបរិយាកាសការងារអំណោយផល<br>- ផ្តល់កាលានុវត្តភាព ដល់ការកសាងវិជ្ជាជីវៈ<br>- រៀបចំគោលនយោបាយផ្តល់រង្វាន់ | អគ្គនាយកដ្ឋាន/នាយកដ្ឋាននីមួយៗជាមួយនឹងការគាំទ្រដោយ EFI |

*( * ) ៖ នឹងត្រូវអនុវត្តចាប់ពីជំហានទី២ ដល់ជំហានទី៤*

## ការប្រើប្រាស់ជំនាញការពីខាងក្រៅ

| ជំហាន | ជម្រើសគោលនយោបាយ | សកម្មភាពដែលស្នើឡើង | អ្នកអនុវត្ត/អ្នកគាំទ្រ |
|---|---|---|---|
| ១ និង២ | គោលនយោបាយសម្រាប់ការប្រើប្រាស់ជំនួយបច្ចេកទេស | - រៀបចំនីតិវិធីគ្រប់គ្រងច្បាស់លាស់សម្រាប់ប្រើប្រាស់ | SRCS និង វសហវ |

| | | | |
|---|---|---|---|
| | ប្រកបដោយភាពស័ក្តិសិទ្ធិ | ជំនួយបច្ចេកទេស<br>- រៀបចំយន្តការដើម្បីសួរនាំ អ្នកពិគ្រោះយោបល់ និង ចែករំលែកចំណេះដឹងនៅក្នុងកសហវ<br>- រៀបចំយន្តការប្រើប្រាស់អ្នកជំនាញការដើម្បីរួមចំណែកដល់កម្មវិធីបណ្តុះបណ្តាល | |
| | ការជ្រើសរើសអ្នកជំនាញការដើម្បីគាំទ្រដល់ផែនការកសាងសមត្ថភាព | - ជ្រើសរើសអ្នកជំនាញការពីររូប ៖<br>១) ជំនាញការបណ្តុះបណ្តាល<br>២) ជំនាញការផ្នែកធនធានមនុស្ស<br>- ជ្រើសរើសអ្នកជំនាញការបច្ចេកទេសផ្សេងៗទៀតតាមការចាំបាច់។ | |
| | ផែនការទស្សនកិច្ចសិក្សា | - កំណត់ផ្នែកដែលចាំបាច់ត្រូវការកែលម្អ<br>- រៀបចំកម្មវិធីទស្សនកិច្ចសិក្សា | វសហវ ដោយមានការគាំទ្រពីអគ្គនាយកដ្ឋាន/ នាយក-ដ្ឋាន និង ថ្នាក់ដឹកនាំកសហវ និង SRCS |

## ការរៀបចំស្ថាប័ន

| ជំហាន | ជម្រើសគោលនយោបាយ | សកម្មភាពដែលស្នើឡើង | អ្នកអនុវត្ត/អ្នកគាំទ្រ |
|---|---|---|---|
| ១ | ការដាក់ចេញនូវវិធានការនៅពេលចាប់ផ្តើមកម្មវិធីកែទម្រង់ | | អគ្គនាយកដ្ឋាន/នាយកដ្ឋាន និង ថ្នាក់ដឹកនាំកសហវ ដោយសហការជាមួយដៃគូអភិវឌ្ឍន៍ |

| | | | |
|---|---|---|---|
| | | | និងការគាំទ្រយ៉ាងខ្លាំងក្លាពី CAR |
| | ការវិភាគមុខងាររបស់រតនាគារជាតិ/នាយកដ្ឋានហិរញ្ញកិច្ច | សកម្មភាពដែលបានស្នើឡើងត្រូវបានរៀបចំដោយ TA នៅក្នុងខែមេសា ឆ្នាំ ២០០៧ | អ្នកពិគ្រោះយោបល់ផ្នែកបច្ចេកទេសត្រូវបានជ្រើសរើសដោយ SCS |
| ២ | ការដាក់ឱ្យដំណើរការនូវអង្គភាពសវនកម្ម | - រៀបចំគោលនយោបាយ<br>- រៀបចំលក្ខខណ្ឌការងាររបស់អង្គភាពសវនកម្ម និងណែនាំដល់ក្រសួង-ស្ថាប័នអំពីវិធីសាស្ត្រធ្វើការងារ<br>- គាំទ្រដល់ការអនុវត្តនៅតាមក្រសួង-ស្ថាប័ន | នាយកដ្ឋានសវនកម្មផ្ទៃក្នុងដោយមានការគាំទ្រពីអ្នកពិគ្រោះយោល់ផ្នែកបច្ចេកទេស |
| | ការពិនិត្យឡើងវិញនូវមុខងាររបស់នាយកដ្ឋានហិរញ្ញវត្ថុនៅតាមក្រសួង-ស្ថាប័ន | - ជ្រើសរើសក្រុមវិភាគមុខងារពីខាងក្រៅ<br>- រៀបចំកម្មវិធីវិភាគ មុខងារ<br>- អនុវត្តវិភាគមុខងារ<br>- រៀបចំសំណើដើម្បីធ្វើការផ្លាស់ប្តូរ | SCS ដោយមានការគាំទ្រពីជំនាញការបច្ចេកទេស |
| | ការពិនិត្យឡើងវិញនៃប្រតិភូកម្មថវិកានៅតាមក្រសួង-ស្ថាប័ន | - លើកសំណើជាមតិយោបល់ដែលទាក់ទិននឹងប្រតិភូកម្មប្រកបដោយភាពស័ក្តិសិទ្ធដល់អ្នកគ្រប់គ្រងគ្រប់លំដាប់ថ្នាក់<br>- រៀបចំយន្តការផ្តល់ការលើកទឹកចិត្ត និងការដាក់វិន័យដែលនឹងត្រូវអនុវត្តចំពោះអ្នកដែលបានទទួលការផ្តល់សិទ្ធិ | នាយកដ្ឋានថវិកាដោយមានការគាំទ្រពីថ្នាក់ដឹកនាំក្រសួង និងជំនាញការបច្ចេកទេស |

| | | | |
|---|---|---|---|
| | | អំណាច<br>- រៀបចំក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិចាំបាច់នានាសម្រាប់អនុវត្តសំណើនោះ | |
| | ការកសាងអភិក្រមជាប្រព័ន្ធសម្រាប់ការបង្កើតកម្រងប្រព័ន្ធនីតិវិធីណែនាំ | - រៀបចំនីតិវិធី<br>- រៀបចំយន្តការសម្រាប់អនុវត្តនីតិវិធីទាំងនោះ | នាយកដ្ឋានគោលនយោបាយដោយមានការជួយជ្រោម-ជ្រែងពី EFI |

## ការរៀបចំការលើកទឹកចិត្ត

| ជំហាន | ជម្រើសគោលនយោបាយ | សកម្មភាពដែលស្នើឡើង | អ្នកអនុវត្ត/អ្នកគាំទ្រ |
|---|---|---|---|
| ១ | បង្កើតនិងអនុវត្តលាភការផ្អែកលើលទ្ធផលការងារ | - ត្រួតពិនិត្យឡើងវិញលើយុទ្ធ-សាស្ត្រ និងវិធានការអនុវត្តលាភការផ្អែកលើលទ្ធផលការងារដែលកំពុងអនុវត្ត<br>- អនុវត្តការប្តូរវេន MBPI ឆ្ពោះទៅរកគោលដៅផលិតភាព<br>- លើកសំណើពង្រីក MBPI ទៅឱ្យក្រសួង-ស្ថាប័ន | SCS ដោយសហការជាមួយអគ្គនាយកដ្ឋាន/នាយកដ្ឋាន និងការគាំទ្រពីថ្នាក់ដឹកនាំកសហវ |
| ២ | កំណត់ក្របខ័ណ្ឌមន្ត្រីចលករ | - បង្កើតលក្ខណៈវិនិច្ឆ័យសម្រាប់ការកំណត់<br>- រៀបចំយន្តការសម្រាប់ការជ្រើសរើស<br>- រៀបចំ និងបង្កើតលក្ខខណ្ឌដែលនឹងត្រូវអនុវត្តចំពោះមន្ត្រីចលករ | អគ្គនាយកដ្ឋាន/នាយក ដ្ឋាននីមួយៗ ដោយមានការគាំទ្រពី EFI |

| | | | |
|---|---|---|---|
| | ការដាក់វិន័យ និងការលើកទឹកចិត្តសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុបានល្អ | - កំណត់អ្នកដែលនឹងត្រូវដាក់វិន័យ និងអ្នកដែលនឹងត្រូវ<br>- បានផ្តល់ការលើកទឹកចិត្ត<br>- រៀបចំនិតិវិធីក្នុងការដាក់វិន័យ និង ការលើកទឹកចិត្ត | នាយកដ្ឋានថវិកា ដោយមានការគាំទ្រពីថ្នាក់ដឹកនាំ និងជំនាញការបច្ចេកទេស |
| | បង្កើតវិធានការគាំទ្រដល់ មន្ត្រីរាជការដែលការងារ ទទួលរងផលប៉ះពាល់ពីការ ផ្លាស់ប្តូរស្ថាប័ន | - បង្កើតវិធានការសំណង និងយន្តការត្រួតពិនិត្យតាមដាន<br>- រៀបចំគោលនយោបាយក្នុងការជ្រើសរើសការងារថ្មី ការរក្សាទុក និងការប្តូរវេន | អគ្គនាយកដ្ឋាន/នាយក ដ្ឋានទីមួយៗ ដោយមាន ការគាំទ្រពី EFI និងថ្នាក់ ដឹកនាំកសហវ |
| | បង្កើតវិធីសាស្ត្រសម្រាប់ការបណ្តុះបណ្តាលដែលផ្អែកលើសេចក្តីត្រូវការ | - រៀបចំឱ្យមានការលើកឡើងនូវសំណើបណ្តុះបណ្តាល<br>- ផ្តល់នូវកម្មវិធីសិក្សាផ្សេងៗគ្នា<br>- សហប្រតិបត្តិការជាមួយស្ថាប័នបណ្តុះបណ្តាលជាតិ និង អន្តរជាតិ | EFI និងអគ្គនាយកដ្ឋាន/នាយកដ្ឋានដោយមានការគាំទ្រពីថ្នាក់ដឹកនាំកសហវ និងដៃគូអភិវឌ្ឍន៍ |
| | រៀបចំនូវកម្មវិធីផ្សារភ្ជាប់រវាងកម្មវិធីកំណែទម្រង់ទាំងមូល និងកម្មវិធីកសាងសមត្ថភាព | - រៀបចំផែនការផ្សារភ្ជាប់<br>- អនុញ្ញាតឱ្យមន្ត្រីដឹងអំពីផែនការនោះ និងអំពីតារាងពេលវេលា<br>- រៀបចំឯកសារសមស្រប<br>- អនុវត្តដោយឈរលើមូលដ្ឋានជាប្រចាំ | EFI និងអគ្គនាយកដ្ឋាន/នាយកដ្ឋានដោយមានការគាំទ្រពីថ្នាក់ដឹកនាំកសហវ និងដៃគូអភិវឌ្ឍន៍ |

ផែនការសកម្មភាពលំអិតដើម្បីអនុវត្តសកម្មភាពខាងលើនេះគឺមានបង្ហាញនៅក្នុងឧបសម្ព័ន្ធទី ១ ។

## ៥. ការរៀបចំការងារដើម្បីអនុវត្តផែនការនេះ

### ៥.១ តួនាទីរបស់វិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (វសហវ/EFI)

ដោយមើលឃើញយ៉ាងច្បាស់នូវសារៈសំខាន់នៃការកសាងសមត្ថភាពដើម្បីគាំទ្រដល់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចាត់តាំងឱ្យវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (វសហវ) រួមជាមួយអនុគណៈកម្មាធិការកសាងសមត្ថភាពរបស់ក្រសួង រៀបចំឡើងនូវផែនការកសាងសមត្ថភាព ។

វិទ្យាស្ថាននឹងដើរតួជាអ្នកសម្របសម្រួលលើការងារកសាងសមត្ថភាព ដែលរួមមានការងារ ០៥ យ៉ាង ៖

១. ការសម្របសម្រួលជាយុទ្ធសាស្ត្រ ចំពោះកិច្ចខិតខំប្រឹងប្រែងនៅក្នុងការកសាងសមត្ថភាព

២. កំណត់វិធីក្នុងការផ្តល់នូវសកម្មភាពបណ្តុះបណ្តាលដើម្បីឆ្លើយតបទៅនឹងសកម្មភាពដែលបានស្នើឡើងនៅក្នុងផែនការយុទ្ធសាស្ត្រ រួមទាំងសកម្មភាពកំណត់ដោយអគ្គនាយកដ្ឋាន នាយកដ្ឋាន និងអង្គភាពផ្សេងទៀត ដែលជាតួអង្គសំខាន់នៅក្នុងការអនុវត្តសកម្មភាពទាំងនោះ

៣. ផ្តល់ការបណ្តុះបណ្តាលដោយខ្លួនឯងប្រសិនបើអាចអនុវត្តបាន

៤. ជ្រើសរើស ឬជួលអ្នកដែលមានសមត្ថភាពផ្តល់ការបណ្តុះបណ្តាល ឬជំនាញបច្ចេកទេសផ្សេងទៀត ប្រសិនបើមិនមានជំនាញទាំងនោះ

៥. វាយតម្លៃលើផលប៉ះពាល់ និងយោបល់ឆ្លើយតប

ផែនការការងារដែលភ្ជាប់ជាមួយនេះ បានឆ្លុះបញ្ចាំងនូវការវាយតម្លៃទៅលើ វសហវ ថាតើផ្នែកណាខ្លះដែលវសហវ អាចឆ្លើយតបបាន និង ផ្នែកណាខ្លះទៀតចាំបាច់ត្រូវរកប្រភពពីខាងក្រៅ ។

វសហវ (EFI) មានគោលដៅកសាងសមត្ថភាពធនធានមនុស្ស និងពង្រឹងគុណភាពវិជ្ជាជីវៈរបស់មន្ត្រីរាជការនៅតាមក្រសួង-ស្ថាប័ន ដែលពាក់ព័ន្ធនឹងការងារគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង សេដ្ឋកិច្ច ។ ជាងនេះទៀត ដោយមើលឃើញថាការកសាងសមត្ថភាពគឺជាកត្តាសំខាន់ក្នុងការលើកកម្ពស់ប្រសិទ្ធភាព គុណភាព និង វិជ្ជាជីវៈការងារ ដើម្បីអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កសហវ មានគោលបំណងផ្តល់នូវវគ្គបណ្តុះបណ្តាលដោយផ្តោតលើសាវតាទូទៅនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ការអភិវឌ្ឍខ្លួន ការកសាងវិជ្ជាជីវៈ និង បច្ចេកទេស ការកសាងសមត្ថភាព សម្រាប់គ្រប់គ្រងដំណើរការការងារថ្មី និងភាពជំនាញជាអ្នកដឹកនាំសម្រាប់ទាំងមន្ត្រី កសហវ និងមន្ត្រីនៅតាមក្រសួង-ស្ថាប័នពាក់ព័ន្ធ ។

វសហវ នឹងបន្តសហការយ៉ាងជិតស្និទ្ធជាមួយអគ្គនាយកដ្ឋាន និង នាយកដ្ឋាននៃ កសហវ ដើម្បីធានាឱ្យមានជំនាញ និងចំណេះដឹងត្រឹមត្រូវ ហើយក៏មានវគ្គបណ្តុះបណ្តាលសំខាន់ៗដែលនឹងផ្តល់ឱ្យក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីធានានូវភាពជោគជ័យនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ វសហវ នឹងតម្រូវឱ្យក្រសួង-ស្ថាប័ន រៀបចំផែនការកសាងសមត្ថភាពនៅតាមក្រសួង-ស្ថាប័ននីមួយៗនៅក្នុងបរិការណ៍នៃក្របខ័ណ្ឌដែលបានកំណត់នៅក្នុងផែនការនេះ ហើយផែនការកសាងសមត្ថភាពដែលរៀបចំដោយក្រសួង-ស្ថាប័ននេះ នឹងត្រូវលើកយកមកពិនិត្យពិភាក្សារួមគ្នាដើម្បីផ្តល់យោបល់ រួមទាំងលទ្ធភាពទទួលបាននូវការបណ្តុះបណ្តាល និង ធនធានផ្សេងទៀត ។

## ៥.២ តម្រូវការគាំទ្ររបស់ វសហវ

ទោះជា វសហវ គឺជាវិទ្យាស្ថានបណ្តុះបណ្តាលមួយដែលមានបទពិសោធន៍ល្អក៏ដោយ ក៏ចាំបាច់តម្រូវឱ្យមានការចូលរួម និង ផ្តល់នូវធនធានបន្ថែមទៀត ជាពិសេស ៖

១. ថ្នាក់ដឹកនាំចាំបាច់ត្រូវផ្តល់នូវភាពជាអ្នកដឹកនាំ និងផ្តល់អានុសាសន៍លើការលំបាកទាំងឡាយដែលកើតមានឡើង ។

២. សហការយ៉ាងជិតស្និទ្ធជាមួយអគ្គនាយកដ្ឋាន និង នាយកដ្ឋាននៅក្នុងការចែករំលែកព័ត៌មានការជ្រើសរើសមន្ត្រីដែលមានគុណសម្បត្តិគ្រប់គ្រាន់ និង អនុញ្ញាតឱ្យចូលរួមក្នុងវគ្គបណ្តុះបណ្តាល ជាដើម ។

៣. ទទួលបាននូវជំនាញការបច្ចេកទេសដែលមានជំនាញ ចំណេះដឹង និង បទពិសោធន៍គ្រប់គ្រាន់ ដើម្បីជួយរៀបចំវគ្គបណ្តុះបណ្តាលសំខាន់ៗ និង ការកសាងជំនាញឱ្យកាន់តែទូលំទូលាយ ដោយរួមទាំងការចុះកិច្ចសន្យាពីខាងក្រៅ សម្រាប់ការងារកសាងសមត្ថភាពឱ្យស្របនឹងផែនការនេះ ប្រសិនបើចាំបាច់ ។

៤. ទទួលបាននូវជំនាញការបច្ចេកទេសដើម្បីគាំទ្រដល់ការអនុវត្តសកម្មភាពបណ្តុះបណ្តាល និងកម្មវិធីកសាងជំនាញឱ្យកាន់តែទូលំទូលាយ ។

## ៥.៣ ការគាំទ្រពីថ្នាក់ដឹកនាំក្រសួង ( តាមផ្លូវច្បាប់/ការពិភាក្សាជាមួយក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល CAR )

វសហវ មានការគ្រប់គ្រងល្អ និង មានបុគ្គលិកដែលមានភារកិច្ចផ្តល់នូវការកសាងសមត្ថភាពជូន កសហវ និង ក្រសួង-ស្ថាប័ន ។ ដើម្បីពង្រឹងតួនាទីរបស់ វសហវ នៅក្នុងការកសាងសមត្ថភាព វសហវ មានតម្រូវការដូចខាងក្រោម ៖

១. ទទួលបានការគាំទ្រយ៉ាងខ្លាំងពីថ្នាក់ដឹកនាំក្រសួង នៅក្នុងការរៀបចំគោលនយោបាយជ្រើសរើស ការរក្សាទុក និងការប្តូរវេនមន្ត្រី និង រៀបចំបទប្បញ្ញត្តិ ដែលទាក់ទិននឹងការផ្លាស់ប្តូរស្ថាប័ន ។

២. ប្រកាសឱ្យប្រើច្បាប់ និង បទប្បញ្ញត្តិដែលបានកែប្រែ ហើយដែលចាំបាច់ដល់ការអនុវត្តសកម្មភាពមួយចំនួននៅក្នុងផែនការនេះ ។

៣. ផ្តល់ការគាំទ្រនៅក្នុងការធ្វើការងារដែលទាក់ទិននឹងការអនុវត្តផែនការនេះ ជាមួយស្ថាប័នដទៃទៀត ដូចជា ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល (CAR) ។

៤. ផ្តល់ការគាំទ្រ និងធនធានបន្ថែមទៀតដល់គ្រប់សកម្មភាពរបស់ វសហវ ដែលទាក់ទងនឹងការបណ្តុះបណ្តាល និងការកសាងសមត្ថភាព ។

## ៥.៤ ការគាំទ្រពីថ្នាក់ដឹកនាំអគ្គនាយកដ្ឋាន និង នាយកដ្ឋាន

ប្រការសំខាន់គឺ ការបង្កើតឱ្យមានយន្តការធ្វើការងារជាមួយថ្នាក់ដឹកនាំអគ្គនាយកដ្ឋាន និងនាយកដ្ឋាន ដោយបង្កើតឱ្យមានការឯកភាពយល់គ្នាទៅលើអ្វីដែលជាតម្រូវការ និង ការវាយតម្លៃទៅលើអ្វីដែលកំពុងអនុវត្ត និងទៅលើអ្វីដែលនឹងកើតឡើង ។ ជាពិសេស សកម្មភាពដែលបានស្នើឡើងមួយចំនួន ទាមទារឱ្យមានការផ្តួចផ្តើមពីអគ្គនាយកដ្ឋាន និង នាយកដ្ឋានពាក់ព័ន្ធ ជាមួយនឹងការសហការយ៉ាងជិតស្និទ្ធពី វសហវ ។

## ៥.៥. ការទទួលបាននូវជំនាញការបច្ចេកទេស និង ការចុះកិច្ចសន្យាពីខាងក្រៅសម្រាប់ការងារកសាងសមត្ថភាព

ដើម្បីផ្តល់លទ្ធភាពដល់ វសហវ អគ្គនាយកដ្ឋាន និង នាយកដ្ឋាននៃកសហវ នៅក្នុងការអនុវត្តការទទួលខុសត្រូវចំពោះការកសាងសមត្ថភាព ប្រការសំខាន់ និង ចាំបាច់ គឺ ដៃគូអភិវឌ្ឍន៍ត្រូវផ្តល់ការគាំទ្រដល់ វសហវ អគ្គនាយកដ្ឋាន និង នាយកដ្ឋាននៃកសហវ លើចំណុចដូចខាងក្រោម ៖

១.	សហការយ៉ាងជិតស្និទ្ធទៅលើការកសាងសមត្ថភាពរបស់អគ្គនាយកដ្ឋាន និង នាយកដ្ឋាននៃ កសហវ
២.	ចែករំលែកនូវបទពិសោធន៍ និង ចំណេះដឹងដ៏ល្អលើការកសាងសមត្ថភាព
៣.	បន្តគាំទ្រទាំងផ្នែកធនធានជារូបវ័ន្ត ហិរញ្ញវត្ថុ និងបច្ចេកទេស

ក្នុងន័យបង្កើនប្រសិទ្ធិភាពនៃការប្រើប្រាស់ជំនួយបច្ចេកទេសលើការកសាងសមត្ថភាព វសហវ ស្នើឱ្យមានការរៀបចំយន្តការដូចខាងក្រោម ៖

១.	រៀបចំឱ្យមាននីតិវិធីគ្រប់គ្រងច្បាស់លាស់ចំពោះបេសកកម្មរបស់ជំនួយបច្ចេកទេសក្នុងផ្នែកនេះ
២.	ធានាថា មានការរៀបចំផែនការការងារដ៏ល្អសម្រាប់ការងារនីមួយៗរបស់ជំនួយបច្ចេកទេសនោះ
៣.	រៀបចំឱ្យមានដំណើរការលទ្ធកម្មដែលមានតម្លាភាព និង ឱ្យស្របទៅតាមនីតិវិធីរបស់ដៃគូអភិវឌ្ឍន៍
៤.	រៀបចំយន្តការត្រួតពិនិត្យដែលមានតម្លាភាព
៥.	ធ្វើសវនកម្មក្រោយចំណាយទៅលើការប្រើប្រាស់ជំនួយបច្ចេកទេសសម្រាប់ដំណាក់កាលនីមួយៗ ។

វសហវ អគ្គនាយកដ្ឋាន និង នាយកដ្ឋាននៃ កសហវ នឹងទាក់ទងជាមួយស្ថាប័នផ្សេងៗទៀត ដើម្បីនាំមកនូវការកសាងសមត្ថភាពប្រកបដោយប្រសិទ្ធិភាព ហើយការងារនោះមានដូចខាងក្រោម ៖

១.	សហការយ៉ាងជិតស្និទ្ធជាមួយស្ថាប័នបណ្តុះបណ្តាលជាតិ និងអន្តរជាតិ សម្រាប់ការកសាងសមត្ថភាពជាបុគ្គល ឬជាក្រុមហ៊ុនផ្តល់ការបណ្តុះបណ្តាល ។
២.	សហការយ៉ាងជិតស្និទ្ធជាមួយក្រុមហ៊ុនជ្រើសរើសជាតិ និង អន្តរជាតិ ដើម្បីជ្រើសរើសជំនាញការពីខាងក្រៅដែលចាំបាច់ ដូចជាអ្នកជំនាញការផ្នែកបច្ចេកទេសជាដើម ។
៣.	សហការយ៉ាងជិតស្និទ្ធជាមួយស្ថាប័នជាតិ និងអន្តរជាតិ សម្រាប់កម្មវិធីទស្សនកិច្ចសិក្សាដែលពាក់ព័ន្ធជាមួយនឹងការចែករំលែកជំនាញ បច្ចេកទេស ចំណេះដឹង និងបទពិសោធន៍ ។

## ៥.៦. ការពង្រីកទៅកាន់ក្រសួង-ស្ថាប័ន

ដើម្បីចែករំលែកបទពិសោធន៍ដែល កសហវ ទទួលបានពីការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទៅឱ្យកសួង-ស្ថាប័ន ការងារចំបងបួន ដូចខាងក្រោមត្រូវយកចិត្តទុកដាក់ ៖

១. ផ្តល់នូវចក្ខុវិស័យច្បាស់លាស់អំពីការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅក្នុង កសហវ តាមរយៈការរៀបចំសិក្ខាសាលា

២. ជ្រើសតាំងមន្ត្រី កសហវ ឱ្យធ្វើបទបង្ហាញអំពីបទពិសោធន៍ដែលទទួលបានពីការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងតួនាទីដ៏សំខាន់នៃការកសាងសមត្ថភាពទៅដល់ក្រសួង-ស្ថាប័ន

៣. ផ្តល់វគ្គបណ្តុះបណ្តាល រួមមានការកសាងជំនាញជាក់លាក់ និងការកសាងជំនាញឱ្យកាន់តែទូលំទូលាយទៅឱ្យក្រសួង-ស្ថាប័ន

៤. តម្រូវឱ្យក្រសួង-ស្ថាប័ន រៀបចំផែនការកសាងសមត្ថភាពនៅតាមក្រសួង-ស្ថាប័ននីមួយៗក្នុងក្របខ័ណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ហើយផែនការនេះនឹងត្រូវត្រួតពិនិត្យឡើងវិញជាមួយនឹងការផ្តល់នូវយោបល់កែលម្អផងដែរ ។

# ៦. ត្រួតពិនិត្យតាមដានលទ្ធផល និងផលប៉ះពាល់នៃការកសាងសមត្ថភាព

មានយន្តការមួយចំនួនដើម្បីត្រួតពិនិត្យតាមដានផែនការយុទ្ធសាស្រ្តកសាងសមត្ថភាព (CDSP) គឺនៅកម្រិតយុទ្ធសាស្រ្ត អនុគណៈកម្មាធិការកសាងសមត្ថភាព (Sub-Committee of Capacity Development) នឹងរៀបចំសិក្ខាសាលាជាមួយនឹងអគ្គនាយកដ្ឋាន និងនាយកដ្ឋាននៃ កសហវ ដើម្បីផ្តល់នូវកាលានុវត្តភាពក្នុងការពិនិត្យឡើងវិញ និងឆ្លុះបញ្ចាំងទៅលើយុទ្ធសាស្រ្តនោះ ហើយចុងក្រោយអនុគណៈកម្មាធិការនឹងតម្រូវឱ្យ វសហវ អគ្គនាយកដ្ឋាន និងនាយកដ្ឋានរៀបចំការត្រួតពិនិត្យប្រចាំឆ្នាំទៅលើយុទ្ធសាស្រ្ត និងសកម្មភាពដែលបានស្នើឡើង ។

វិធីសាស្រ្តប្រើប្រាស់សម្រាប់ត្រួតពិនិត្យតាមដានលទ្ធផល និងផលប៉ះពាល់នៃការកសាងសមត្ថភាពដូចជា ការរៀបចំតេស្តលើមុខវិជ្ជាដែលបានបណ្តុះបណ្តាល ការរៀបចំតេស្តទូលំទូលាយលើជំនាញដែលទទួលបាន និង ការអនុវត្តជំនាញនោះ ។

## ៦.១. ការត្រួតពិនិត្យលើមុខវិជ្ជាដែលបានបណ្តុះបណ្តាល

វសហាវ អគ្គនាយកដ្ឋាន និងនាយកដ្ឋាននៃកសហាវ ដែលចូលរួមអនុវត្តផែនការនេះនឹងត្រួតពិនិត្យតាមដានការអនុវត្តសកម្មភាព ដោយប្រើប្រាស់នូវបច្ចេកទេសវាយតម្លៃវគ្គសិក្សាជាបទដ្ឋានដែលមានភាពស័ក្តិសិទ្ធិ ។ ជាងនេះទៀត ដើម្បីធានាឱ្យមានការឆ្លើយតបជាសារវ័ន្ត ទម្រង់នៃការផ្តល់យោបល់ឆ្លើយតបនឹងត្រូវដាក់ឱ្យបំពេញដោយមានវត្តមានរបស់អ្នកបណ្តុះបណ្តាលផ្សេងទៀត និងតំណាងអគ្គនាយកដ្ឋាន និងនាយកដ្ឋាននីមួយៗ ចូលរួមចែក និងប្រមូលកម្រងសំណួរទាំងនោះ ។

យន្តការនេះត្រូវបានប្រើប្រាស់ ដើម្បីធ្វើការវាស់វែងនូវកម្រិតយល់ដឹងរបស់សិក្ខាកាម នៅមុន និងក្រោយវគ្គសិក្សា ហើយយន្តការនេះមានប្រយោជន៍ដល់អ្នកសម្របសម្រួលក្នុងការរៀបចំវិធីសាស្ត្រនៃការបណ្តុះបណ្តាលឱ្យស្របទៅតាមសមត្ថភាពរបស់សិក្ខាកាមដែលបានចូលរួម ។ លើសពីនេះទៀត យន្តការនេះជួយវាយតម្លៃចំណេះដឹង និងជំនាញរបស់សិក្ខាកាមដែលទទួលបានពីវគ្គសិក្សានេះ ។

ដំណើរការដូចគ្នានេះដែរ នឹងត្រូវបានអនុវត្តចំពោះការវាយតម្លៃលើការផ្តល់វគ្គបណ្តុះបណ្តាល តាមរយៈការប្រើប្រាស់ការត្រួតពិនិត្យជារចនាសម្ព័ន្ធលើការពេញចិត្តជាមួយការផ្តល់វគ្គបណ្តុះបណ្តាលនៅពេលចុងបញ្ចប់នៃវគ្គសិក្សានីមួយៗ ( រួមទាំងការពេញចិត្តជាមួយមាតិកានៃការបណ្តុះបណ្តាល អ្នកឧទ្ទេសនាម វិធីសាស្ត្រនៃការបណ្តុះបណ្តាល ឯកសារ កាលវិភាគ ទីកន្លែង បន្ទប់រៀន និងសិទ្ធិទទួលបាននូវការបណ្តុះបណ្តាល ) ។

## ៦.២ ការត្រួតពិនិត្យលើជំនាញដែលទទួលបាន

នេះជាយន្តការមួយដែលប្រើសម្រាប់វាស់វែងនូវកម្រិតយល់ដឹងរបស់សិក្ខាកាមនៅមុន និងក្រោយពេលផ្តល់វគ្គបណ្តុះបណ្តាល និងការអនុវត្តគោលនយោបាយធនធានមនុស្ស ។ ការត្រួតពិនិត្យនេះនឹងត្រូវបានអនុវត្តដោយការសម្ភាសន៍ជារចនាសម្ព័ន្ធ និងពាក់កណ្តាលរចនាសម្ព័ន្ធ ដោយផ្ទាល់ជាមួយមន្ត្រីដែលត្រូវបានបណ្តុះបណ្តាល និងមន្ត្រីដែលត្រូវប្តូរវេន ព្រមទាំងជាមួយអគ្គនាយកនៃអគ្គនាយកដ្ឋាន និងប្រធាននាយកដ្ឋាននីមួយៗ ដើម្បីបង្ហាញថា អគ្គនាយកដ្ឋាន និង នាយកដ្ឋានបានទទួលនូវការអភិវឌ្ឍន៍ប្រសើរជាងមុន ហើយមន្ត្រីមានការពេញចិត្តជាមួយនឹងសកម្មភាពកំណែទម្រង់ទាំងនោះ ។

## ៦.៣ ការត្រួតពិនិត្យលើការអនុវត្តជំនាញ

ការវាយតម្លៃលើផលប៉ះពាល់ និងការផ្តល់យោបល់ឆ្លើយតប អាចជាទម្រង់នៃការសម្ភាសន៍ជារចនាសម្ព័ន្ធ និងពាក់កណ្តាលរចនាសម្ព័ន្ធ ដោយផ្ទាល់ជាមួយអគ្គនាយកដ្ឋាន និង នាយកដ្ឋានពាក់ព័ន្ធ ( អគ្គ

នាយក ឬអគ្គនាយករង និង ប្រធាន ឬអនុប្រធាននាយកដ្ឋាននៃកសហវ ) និងជាមួយសិក្ខាកាមដោយផ្ទាល់ ។ ការត្រួតពិនិត្យនេះនឹងត្រូវបានអនុវត្តផងដែរ ដោយការវាស់វែងសមិទ្ធកម្មការងារ និងលទ្ធផលនៃការសាកល្បងការងារ ។ ការវាយតម្លៃលើផលប៉ះពាល់ និងការផ្តល់យោបល់ឆ្លើយតប នឹងផ្តោតទៅលើ ៖

១. ផលប៉ះពាល់ទៅលើលក្ខខណ្ឌ និង បរិយាកាសការងារសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង

២. សមិទ្ធកម្មរបស់សិក្ខាកាម នៅមុន និងក្រោយពេលផ្តល់ការបណ្តុះបណ្តាល ។

## ៦.៤ ការត្រួតពិនិត្យលើការកសាងសមត្ថភាព

ដើម្បីធ្វើការត្រួតពិនិត្យលើប្រសិទ្ធភាព នៃវិធានការកសាងសមត្ថភាពឱ្យកាន់តែទូលំទូលាយដែលបានកំណត់នៅក្នុងផែនការនេះ គឺមានការស្នើឡើងនូវលក្ខខណ្ឌវិនិច្ឆ័យ (Benchmarks) មួយចំនួនទៅលើការអនុវត្តរបស់ កសហវ ដែលជាស្ថាប័នមួយជំរុញការកសាងធនធានមនុស្ស ។ លក្ខខណ្ឌវិនិច្ឆ័យទាំងនេះ នឹងត្រូវប្រើប្រាស់ដើម្បីជួយចង្អុលទិសដៅដល់ផែនការកសាងសមត្ថភាព និងវាស់វែងវឌ្ឍនភាព ។

ឧបសម្ព័ន្ធទី ៥.២

# ទម្រង់សម្រាប់រៀបចំផែនការកសាងសមត្ថភាពនៅតាមក្រសួង-ស្ថាប័ន

មន្ត្រីបង្គោល (Focal points) នៅតាមក្រសួង-ស្ថាប័ន នឹងទទួលបាននូវការបកស្រាយដោយលម្អិតអំពីផែនការកសាងសមត្ថភាពដែលរៀបចំឡើងដោយ កសហវ ដែលផ្តោតនៅក្នុងជំហានទី ២ នេះ រួមទាំងការពន្យល់បកស្រាយអំពីសារវតារបស់ផែនការ ជំនាញ ការរៀបចំស្ថាប័ន ធនធានមនុស្ស និងការលើកទឹកចិត្ត ។

ផ្អែកលើការបកស្រាយនេះ ក្រសួង-ស្ថាប័ននឹងតម្រូវឱ្យបំពេញការងារបីយ៉ាងគឺ ៖

- ស្នើឡើងនូវវគ្គបណ្តុះបណ្តាលជំនាញ និង ជ្រើសរើសមន្ត្រីដើម្បីចូលរួម ។
- ក្រៅពីវគ្គបណ្តុះបណ្តាលដើម្បីចូលរួមចំណែកដល់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងមូលនោះ ក្រសួង-ស្ថាប័នអាចស្នើឡើងនូវវគ្គបណ្តុះបណ្តាលដោយឡែកផ្សេងទៀត ។
- ក្រៅពីលក្ខណៈទូទៅនៃវិធានការរៀបចំស្ថាប័ន គ្រប់គ្រងធនធានមនុស្ស និង លើកទឹកចិត្តដែលបានរៀបរាប់នៅក្នុងផែនការកសាងសមត្ថភាពរបស់ កសហវ ក្រសួង-ស្ថាប័ននីមួយៗអាចស្នើឡើងនូវវិធានការដោយឡែកផ្សេងទៀតដែលសមស្រប ។

រាល់សំណើដែលទាក់ទិននឹងបញ្ហាខាងលើនេះ ក្រសួង-ស្ថាប័ន ត្រូវលើកឡើងនៅក្នុងគំរូភ្ជាប់ជាមួយនេះ ។ នៅពេលចាប់ផ្តើមរៀបចំផែនការនេះ មិនចាំបាច់ឱ្យមានភាពគ្រប់ជ្រុងជ្រោយពេកទេ ព្រោះផែនការនេះនឹងត្រូវកែលម្អជាប្រចាំ ។

ផែនការនេះនឹងត្រូវត្រួតពិនិត្យឡើងវិញដោយ កសហវ និងត្រូវបានប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការពិភាក្សាបន្ថែមទៀតជាមួយក្រសួង-ស្ថាប័ននីមួយៗ ដែលទាក់ទងនឹងសំណើ និងតម្រូវការគាំទ្រដែលលើកឡើងដោយក្រសួង-ស្ថាប័ន ដើម្បីអនុវត្តផែនការនេះ ។

### ការកសាងជំនាញ

| មុខវិជ្ជាបណ្តុះបណ្តាល | មន្ត្រីចូលរួម |
|---|---|
| វគ្គបណ្តុះបណ្តាលដែលស្នើឡើងដោយ កសហវ | |
| • ប្រតិភូកម្មថវិកាប្រកបដោយភាពស័ក្តិសិទ្ធិ | |
| • ការបកស្រាយរបាយការណ៍គណនេយ្យ | |
| • ប្រសិទ្ធភាពនៃការប្រើប្រាស់ប្លង់គណនេយ្យ | |
| • ការវិភាគ/ការឆ្លើយតបចំពោះសំណើសុំថវិកា | |
| • ការរៀបចំផែនការសវនកម្ម | |
| • ការវិភាគហានីភ័យសម្រាប់ជាមូលដ្ឋានសវនកម្ម | |
| • ការអនុវត្ត និងការប្រើប្រាស់ FMIS | |
| • ការគ្រប់គ្រងការផ្លាស់ប្តូរដែលទាក់ទងនឹងប្រព័ន្ធ ព័ត៌មានវិទ្យា | |
| | |
| វគ្គបណ្តុះបណ្តាលផ្សេងទៀតដែលស្នើឡើងដោយក្រសួង-ស្ថាប័ន | |
| | |
| | |
| | |
| | |

ក្រៅពីលក្ខណៈទូទៅនៃវិធានការរៀបចំស្ថាប័ន គ្រប់គ្រងធនធានមនុស្ស និង លើកទឹកចិត្តដែលបានរៀបរាប់នៅក្នុងផែនការកសាងសមត្ថភាពរបស់ កសហវ ក្រសួង-ស្ថាប័ន នីមួយៗអាចស្នើឡើងនូវវិធានការដោយឡែកទៀត ដែលមានដូចខាងក្រោម ៖

### វិធានការរៀបចំស្ថាប័ន

| |
|---|
| |

### វិធានការកសាងធនធានមនុស្ស

| |
|---|
| |

### វិធានការលើកទឹកចិត្ត

| |
|---|
| |

# ឯកសារគោលនយោបាយ
# ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
( FMIS)



## ១. សេចក្តីផ្តើម

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានដាក់ឱ្យអនុវត្តជាផ្លូវការនៅខែ ធ្នូ ឆ្នាំ ២០០៤ ក្នុងគោលដៅកែលម្អស្តង់ដារនៃការគ្រប់គ្រង គណនេយ្យភាព និងភាពស័ក្តិសិទ្ធិ ក្នុងការកៀរគរធនធានថវិកាចរន្ត និងមូលធនរបស់រដ្ឋាភិបាល ។

ដើម្បីសម្រេចគោលដៅនេះ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងមូលត្រូវបានបែងចែកជា ៤ ដំណាក់កាល ។ គ្រប់នាយកដ្ឋានត្រូវមានភារកិច្ចក្នុងការរៀបចំផែនការសកម្មភាពរបស់ខ្លួនជាលម្អិត ។ សកម្មភាពចម្បងមួយរបស់កម្មវិធីកំណែទម្រង់ ត្រូវបានកំណត់យ៉ាងច្បាស់ថា ការអនុវត្តប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដោយប្រព័ន្ធព័ត៌មានវិទ្យានេះមានភារកិច្ចសំខាន់ក្នុងការជួយសម្រួល និង លើកកម្ពស់គណនេយ្យភាព និង តម្លាភាពក្នុងការពិនិត្យតាមដាន និង គ្រប់គ្រងចំណូល និង ចំណាយរបស់រដ្ឋ និង ធ្វើឱ្យប្រសើរឡើងព័ត៌មានអំពីសមិទ្ធកម្មផ្នែកហិរញ្ញវត្ថុ និង សេវាសាធារណៈ ។

ឯកសារគោលនយោបាយនេះ មានគោលបំណងចម្បងផ្តល់ជាយុទ្ធសាស្រ្តទូទៅក្នុងការអនុវត្តប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រកបដោយជោគជ័យ និង កំណត់ចក្ខុវិស័យទៅថ្ងៃមុខ ។

## ២. គោលបំណងនៃប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

គោលបំណងសំខាន់នៃការអនុវត្តគម្រោងប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យា និង ទូរគមនាគមន៍ទំនើបក្នុងការទ្រទ្រង់ និងធ្វើសមាហរណកម្មដំណើរការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឱ្យស្របតាមតម្រូវការនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

គោលបំណងសំខាន់ៗ មានចំនួន ៣ ដូចខាងក្រោម ៖

- **បង្កើនប្រសិទ្ធភាពនៃដំណើរការប្រតិបត្តិការហិរញ្ញវត្ថុ និង ការពិនិត្យតាមដាន**
    - ការបញ្ចូលទិន្នន័យតាមច្រកតែមួយ រក្សាទិន្នន័យរហូតដល់កម្រិតទាបបំផុត ការចែករំលែកទិន្នន័យ ការគ្រប់គ្រងផ្ទៃក្នុងប្រកបដោយបូរណភាព និង សុវត្ថិភាពពិតប្រាកដ ដំណើរការប្រតិបត្តិការហិរញ្ញវត្ថុជាក់ស្តែង/Online និងសវនកម្មផ្ទៃក្នុង ។
    - ជួយសម្រួលដល់ការគ្រប់គ្រង និង ពិនិត្យតាមដានប្រភពធនធាន ។
    - កំណត់តម្រូវការសម្រាប់ដំណើរការគ្រប់គ្រងប្រភពធនធានជាក់លាក់ ( ប្រាក់បៀវត្សទ្រព្យមិនមែនហិរញ្ញវត្ថុ និង អចលនទ្រព្យជាដើម ) ។
- **ការកែលម្អចំណាត់ថ្នាក់ថវិកា ការវាយតម្លៃ ការប្រមូលផ្តុំ និង ការផ្ទៀងផ្ទាត់**
    - បង្កើតឱ្យមានស្តង់ដារនៃចំណាត់ថ្នាក់ថវិកា ការវាយតម្លៃ និងវិធានផ្នែកគណនេយ្យ
    - ការពិនិត្យតាមដានលើចំណាយ
    - បង្កើតឱ្យមានរបាយការណ៍ទាន់ពេលវេលា ត្រឹមត្រូវ មានលក្ខណៈប្រមូលផ្តុំ និងមានភាពគ្រប់ជ្រុងជ្រោយ
    - បង្កើតឱ្យមានរបាយការណ៍ក្នុងទម្រង់ផ្សេងៗគ្នាចេញពីបណ្តុំទិន្នន័យតែមួយ
    - ការផ្ទៀងផ្ទាត់ថវិកាទៅតាមស្ថាប័ន អង្គភាពផ្សេងៗ
    - បង្កើតច្រកសម្រាប់សវនកម្ម
- **ការវិភាគសម្រាប់ផែនការ ការរៀបចំថវិកា ការធ្វើសេចក្តីសម្រេចចិត្ត ការពិនិត្យតាមដាន និង របាយ-ការណ៍**
    - ផលិតកម្មនៃព័ត៌មានសម្រាប់ការគ្រប់គ្រងប្រកបដោយវិសាលភាពទូលាយ និង ការវិភាគសម្រាប់ប្រើប្រាស់ក្នុងការរៀបចំផែនការគ្រប់គ្រង និង ការសម្រេចចិត្ត
    - ផលិតកម្មនៃចំណូលថវិកាជាបណ្តោះអាសន្ន និងចុងក្រោយ និង របាយការណ៍ហិរញ្ញ-វត្ថុ។

## ៣. វឌ្ឍនភាព

មកទល់បច្ចុប្បន្ននេះ គម្រោងប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) សម្រេចបានលទ្ធផលជាវិជ្ជមានដូចខាងក្រោម ៖

- បញ្ចប់កិច្ចលទ្ធកម្ម FMIS នៅដំណាក់កាលទី ១ ( នៅខែ ឧសភា ឆ្នាំ ២០០៨ ) ។
- បញ្ចប់ឯកសារសម្រាប់កិច្ចលទ្ធកម្ម FMIS នៅដំណាក់កាលទី ២ ដោយបញ្ចូលតម្រូវការផ្នែកហេដ្ឋារចនាសម្ព័ន្ធព័ត៌មានវិទ្យា និង ទូរគមនាគមន៍ និងការកែប្រែ ដែលកើតចេញពីដំណាក់កាលទី ១ ( នៅខែ ឧសភា ឆ្នាំ ២០០៨ ) ។
- បញ្ចប់ឯកសារលទ្ធកម្មបំពេញបន្ថែមផ្នែកហេដ្ឋារចនាសម្ព័ន្ធព័ត៌មានវិទ្យា និងទូរគមនាគមន៍ និងបានបញ្ជូនទៅធនាគារពិភពលោកដើម្បីផ្តល់សុពលភាពលើបច្ចេកទេស នៅខែ មិថុនា ឆ្នាំ ២០០៨ ។
- បង្កើតយន្តការ ( ក្រុមគ្រប់គ្រងការងារ FMIS ) ដើម្បីធានាដល់ការចូលរួមយ៉ាងសកម្មពីបណ្ដានាយកដ្ឋានពាក់ព័ន្ធនៅក្នុងការអនុវត្តគម្រោងនេះ ។ ជួយដល់នាយកដ្ឋាននីមួយៗ ក្នុងការចងក្រងអភិក្រមការងាររបស់នាយកដ្ឋាន និងកំណត់ឱ្យបាននូវអភិក្រមការងារដែលត្រូវតាមការគោលការណ៍ និងតាមស្តង់ដារកម្រិតខ្ពស់ ។
- បញ្ចប់ផែនការយុទ្ធសាស្ត្របណ្ដុះបណ្ដាលផ្នែកព័ត៌មានវិទ្យា និងទូរគមនាគមន៍រួម មាន ៣០ វគ្គបណ្តុះបណ្តាល ដែលក្នុងនោះមាន ២៣ វគ្គ ធ្វើនៅក្នុងស្រុក និង ៧ វគ្គនៅបរទេស និងការបណ្តុះបណ្តាលផ្នែកដំណើរការអនុវត្តការងារ មាន ៨ វគ្គ ដែលក្នុងនោះមាន ៧ វគ្គ ធ្វើនៅក្នុងស្រុក។
- បញ្ចប់ការជ្រើសរើសមន្ត្រីផ្នែកព័ត៌មានវិទ្យាចំនួន ១០ នាក់ ជាស្ថាពរនៅក្នុងខែ មេសាឆ្នាំ២០០៨ ដែលមន្ត្រីទាំងនេះបំពេញការងារក្នុងក្របខ័ណ្ឌជាមន្ត្រីនាយកដ្ឋានព័ត៌មានវិទ្យា លើផ្នែកបច្ចេក-ទេសជាមួយនឹងក្រុមហ៊ុនផ្គត់ផ្គង់កម្មវិធី FMIS ។
- កំពុងបញ្ចប់ដំណើរការជ្រើសរើស មន្ត្រីផ្នែកវិភាគអភិក្រមការងារតាមកិច្ចសន្យា ចំនួន ១០ នាក់មកបម្រើការផ្នែកអភិក្រមការងារ មាតិកាគណនេយ្យ ការធ្វើចំណាត់ថ្នាក់ថវិកា និង ការងារផ្សេងទៀត ដើម្បីជួយទ្រទ្រង់ដល់អភិក្រមការងារ ដែលជាធាតុចូលក្នុងការរៀបចំបង្កើតកម្មវិធី

កុំព្យូទ័រនៃប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង ការវិភាគបំពេញចន្លោះខ្វះខាតនានា ។

## ៤. បុរេលក្ខខណ្ឌនៃការអនុវត្តប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ក្នុងការធានាការអនុវត្តប្រកបដោយជោគជ័យនៃប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ទាមទារឱ្យមានបុរេលក្ខខណ្ឌមួយចំនួនដូចខាងក្រោម ៖

- ការប្តេជ្ញាចិត្តខ្ពស់ពីថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការទ្រទ្រង់គម្រោងប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមរយៈការគាំទ្រផ្នែកនយោបាយដើម្បីធានាឱ្យមានការសហការយ៉ាងជិតស្និទ្ធពីបណ្តានាយកដ្ឋាន និង ក្រសួង-ស្ថាប័ននានា ជាពិសេសក្នុងការផ្តល់នូវធាតុចូលសំខាន់ៗសម្រាប់គម្រោងនេះរួមមាន ៖ អភិក្រមការងារ ប្លង់គណនេយ្យ អនុសាសន៍លើតម្រូវការការងារ និង ជំនួយពីក្រុមការងាររបស់នាយកដ្ឋានពាក់ព័ន្ធនឹងការអនុវត្តគម្រោងនេះ ។
- សហប្រតិបត្តិការប្រកបដោយប្រសិទ្ធភាពពីគ្រប់ដៃគូពាក់ព័ន្ធទាំងអស់ ជាពិសេស លេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នាយកដ្ឋានថវិកា នាយកដ្ឋានវិនិយោគនិងសហប្រតិបត្តិការ រតនាគារជាតិ និងបណ្តាក្រសួងដែលត្រូវអនុវត្តគម្រោងក្នុងដំណាក់កាលសាកល្បង ។
- ការអភិវឌ្ឍការយល់ដឹងផ្នែកទស្សនទានពីគ្រប់ដៃគូពាក់ព័ន្ធ ។
- ការចូលរួមចំណែកយ៉ាងក្លៀវក្លាពីគ្រប់នាយកដ្ឋាន និង ក្រសួង-ស្ថាប័ន ។
- ជំនាញការផ្នែកកែទម្រង់ហិរញ្ញវត្ថុសាធារណៈ ផ្នែកព័ត៌មានវិទ្យា និង ទូរគមនាគមន៍ ផ្នែកគ្រប់គ្រងការផ្លាស់ប្តូរ ត្រូវជួយដល់ការកសាងសមត្ថភាព និង ការអនុវត្តគម្រោង ។
- កសាងសមត្ថភាពដល់អ្នកអនុវត្តគម្រោង និងអភិវឌ្ឍសមត្ថភាពចាំបាច់ក្នុងការធានាបាននូវចីរភាពគម្រោង ។
- ដំណើរការអនុវត្តជាជំហានៗ ដែលនឹងផ្តល់នូវពេលវេលាគ្រប់គ្រាន់ក្នុងការសិក្សា និងគ្រប់គ្រងការផ្លាស់ប្តូរគោលការណ៍ បទដ្ឋាន និង អភិក្រមការងារ ។ នេះជាការចាំបាច់ណាស់ក្នុងការ

ទទួលស្គាល់ថាដំណើរការទាំងនេះជាដំណើរការផ្លាស់ប្តូរ រចនាសម្ព័ន្ធស្ថាប័នសំខាន់ៗ និងមិនមែនជាការធ្វើស្វ័យប្រវត្តិកម្មធម្មតាសម្រាប់អភិក្រមការងារបច្ចុប្បន្ននោះឡើយ ។

- ការអនុវត្តគណនីទោលរតនាគារជាតិ គឺជាធាតុមួយដ៏ចាំបាច់ក្នុងការអនុវត្តគម្រោង ពោលគឺចំណូលទាំងអស់របស់រដ្ឋត្រូវតែហូរចូលទៅក្នុងគណនីទោលរតនាគារជាតិ ហើយការចំណាយក៏ត្រូវចេញពីគណនីនេះដែរ ដោយមានការវាយតម្លៃប្រៀបធៀបជាមួយការប្រើប្រាស់ធនាគារពាណិជ្ជ ។
- ការរៀបចំឱ្យមានបន្ទប់ដ៏សមស្របសម្រាប់ដំឡើងម៉ាស៊ីនកុំព្យូទ័រមេ និងការិយាល័យសម្រាប់មន្ត្រីថ្មីចំនួន ២០ នាក់ រួមទាំងក្រុមការងាររបស់ក្រុមហ៊ុនផ្គត់ផ្គង់កម្មវិធី ចំនួន ១០ នាក់ បន្ថែមទៀត ។
- យន្តការលើកទឹកចិត្តប្រកបដោយប្រសិទ្ធភាពក្នុងការទ្រទ្រង់ក្រុមការងារអនុវត្តគម្រោង ។

## ៥. និដ្ឋភាពទូទៅនៃកម្មវិធីកុំព្យូទ័រសម្រាប់ FMIS

កម្មវិធីកុំព្យូទ័រ FMIS មានមុខងារច្រើនក្នុងការទ្រទ្រង់ការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ។ នៅក្នុងការអនុវត្តគម្រោង FMIS នៅកម្ពុជាត្រូវការចាំបាច់នូវមុខងារដូចតទៅ ៖

### ៥.១. មុខងារសៀវភៅធំ

នេះជាមុខងារស្នូលរបស់ប្រព័ន្ធកម្មវិធី FMIS ដែលរក្សាទុកនូវរាល់ទិន្នន័យលម្អិតរបស់ប្រតិបត្តិការហិរញ្ញវត្ថុ និង ការផ្ទៀងផ្ទាត់ទិន្នន័យហិរញ្ញវត្ថុទាំងអស់ ។ មុខងារសៀវភៅធំក៏ផ្តល់ផងដែរនូវទំនាក់ទំនងរវាងមុខងារដទៃទៀតនៅក្នុងប្រព័ន្ធ និងមានព័ត៌មាននានាដូចជាការធ្វើចំណាត់ថ្នាក់ថវិកា ប្លង់គណនេយ្យ និងថវិកា និងការវិភាជន៍ រចនាសម្ព័ន្ធ របាយការណ៍តាមកាលបរិច្ឆេទនានា ( តាមខែ ត្រីមាស និង ឆ្នាំហិរញ្ញវត្ថុ ) វិធានគ្រប់គ្រងគណនេយ្យ គណនេយ្យបង្ករ គណនេយ្យសាច់ប្រាក់ ។ល។ ទិន្នន័យគណនេយ្យត្រូវបានកត់ត្រាទុក អនុញ្ញាតឱ្យពិនិត្យប្រតិបត្តិការថយក្រោយបាន ផ្តល់របាយការណ៍កម្រិតសង្ខេបបំផុតទៅតាមតម្រូវការរបស់អ្នកប្រើប្រាស់ ។ មុខងារនេះ អាចបង្កើតជារបាយការណ៍ហិរញ្ញវត្ថុក្នុងឆ្នាំ និងនៅដំណាច់ឆ្នាំបាន ។

នៅក្នុងគម្រោងស្នើឡើងសម្រាប់ FMIS នៅកម្ពុជា រចនាសម្ព័ន្ធពហុវិមាត្ររបស់ប្លង់គណនេយ្យ នឹងត្រូវយកមកប្រើប្រាស់ ហើយឱ្យមានសង្គតិភាពជាមួយនឹងការធ្វើចំណាត់ថ្នាក់ថវិកា និង ស្តង់ដារប្លង់គណនេយ្យអន្តរជាតិ ។ រចនាសម្ព័ន្ធទាំងអស់នឹងត្រូវកំណត់ឡើងទាំងស្រុងដោយអ្នកប្រើប្រាស់ ហើយត្រូវយកធ្វើជាទិន្នន័យគោល ។ មុខងារដែលត្រូវការឱ្យមានក្នុងប្លង់គណនេយ្យនោះ គឺប្រភពមូលនិធិ លេខគណនីជាតិ ស្ថាប័ន-អង្គភាព ចំណាយ គម្រោងកម្មវិធី ទីតាំង និង សកម្មភាព ។ គោលការណ៍គណនេយ្យ និងស្តង់ដារនានា នឹងត្រូវរៀបចំឡើងនៅក្នុងមុខងារសៀវភៅធំ ។ មុខងារសៀវភៅធំ នឹងជួយសម្រួលដល់ដំណើរការប្រកបដោយប្រសិទ្ធភាពនៃទិន្នន័យគណនេយ្យ ក៏ដូចជាការអនុវត្តជាបណ្តើរៗនៃគោលការណ៍ និងស្តង់ដារគណនេយ្យទំនើប ។

## ៥.២. មុខងាររៀបចំថវិកា

មុខងារនេះជួយដល់ការរៀបចំថវិកាប្រចាំឆ្នាំ និង ពហុឆ្នាំ ដោយអនុញ្ញាតឱ្យមានការរៀបចំថវិកា « ពីលើចុះមកក្រោម » រួមមានការព្យាករណ៍ច្រើនឆ្នាំ និង ការគ្រោងថវិកាសម្រាប់រៀបចំក្របខ័ណ្ឌចំណាយរយៈពេលមធ្យម និង ការរៀបចំថវិកា « ពីក្រោមឡើងលើ » រួមមានការរៀបចំកម្មវត្ថុចំណាយ ការកំណត់សកម្មភាព ប្រភពមូលនិធិ និងការគ្រោងចំណាយ ។ មុខងារនេះ នឹងមានរចនាសម្ព័ន្ធនៃការធ្វើចំណាត់ថ្នាក់ថវិកាដូចគ្នានឹងមុខងារសៀវភៅធំដែរ ហើយត្រូវអាស្រ័យលើប្រព័ន្ធសុវត្ថិភាពដែលអនុញ្ញាតឱ្យ ៖ ១- អ្នកប្រើប្រាស់ក្នុងការប្រើប្រាស់មុខងារគ្រោង និង រៀបចំថវិកាដើម្បីកសាងគម្រោងថវិកា ការស្នើសុំថវិកា ការធ្វើលទ្ធកម្មសម្រាប់ខ្លួនផ្ទាល់ ២- អនុញ្ញាតឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបំពេញមុខងារផ្គូផ្គងថវិកា ៣- សម្រួលដល់ការផ្ទៀងផ្ទាត់ថវិកាចរន្ត និង មូលធន និង ៤- ផ្តល់លទ្ធភាពឱ្យថវិកានៅក្នុងឆ្នាំដំណើរការ ( និយ័តភាព ការប៉ាន់ប្រមាណថវិកាបន្ថែម ។ល។ ) ។ ថវិកាដែលត្រូវបានអនុម័តចុងក្រោយនៅក្នុងសៀវភៅធំរបស់ប្រព័ន្ធ FMIS នឹងត្រូវទាញចេញពីទិន្នន័យដែលត្រូវបញ្ចូលផ្ទាល់ទៅក្នុងប្រព័ន្ធតែម្តងបន្ទាប់ពីរដ្ឋសភាបានអនុម័តលើច្បាប់ថវិកា ឬ អាចថតចម្លងមកពីមុខងារថវិកាដែលមានស្រាប់ក៏បាន ។

មុខងារថវិកានេះ អាចប្រើប្រាស់ជាគំរូសម្រាប់ជម្រើសថវិកានានានៅក្នុងដំណាក់កាលរៀបចំថវិកា អាចរៀបចំបញ្ជាតាមម៉ាក្រូក្នុងការបែងចែកថវិកានៅលើមូលដ្ឋានកំណត់ហើយជាស្រេច និង អាចចម្លងចូលពីថវិកានៅក្នុងឆ្នាំហិរញ្ញវត្ថុបច្ចុប្បន្ន ឬ ថវិកាដែលត្រូវចាយពិតប្រាកដ ( ជាសាច់ប្រាក់ ឬ ជាបង្គរ ) បន្ថែមលើថវិកាដែលនៅសល់ ដើម្បីជួយសម្រួលដល់ការរៀបចំថវិកានៅឆ្នាំបន្ទាប់ ។ ថវិកាប្រចាំឆ្នាំអាចត្រូវកំណត់ដោយក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ហើយទិន្នន័យអាចត្រូវចម្លងចូលពីប្រព័ន្ធខាងក្រៅ ( ពីគំរូ

ព្យាករណ៍សេដ្ឋកិច្ចនានា ការប៉ាន់ប្រមាណចំណូលថវិកាពីទីភ្នាក់ងារប្រមូលចំណូលនានា ) ។ នៅក្នុងឆ្នាំប្រតិបត្តិការ មុខងារថវិកា និង មុខងារសៀវភៅធំអាចកំណត់ទំហំថវិកាសម្រាប់ទីភ្នាក់ងារ ឬ អង្គភាពចំណាយនីមួយៗ ឬ ក៏ពុំមានកំណត់ និង អាចគ្រប់គ្រងលើសំណើធ្វើនិយ័តកម្ម និង ការអនុម័តឯកភាពតាមប្រព័ន្ធកម្មវិធីដោយផ្ទាល់តែម្តង ។

## ៥.៣. មុខងារលទ្ធកម្ម

ប្រព័ន្ធគ្រប់គ្រងលទ្ធកម្មនឹងអនុញ្ញាតឱ្យមានការពិនិត្យតាមដានលើកិច្ចលទ្ធកម្ម ( ការស្នើសុំបញ្ជាទិញ ប្រគល់-ទទួលទំនិញ ឬ សេវា ការភ្ជាប់ទៅនឹងការគ្រប់គ្រងសំណើសុំជាដើម ) នៃការប្រើប្រាស់មុខទំនិញជាប្រចាំតាមរយៈមូលដ្ឋានទិន្នន័យប្រមូលផ្តុំអ្នកផ្គត់ផ្គង់ ដែលភ្ជាប់ទៅនឹងការធានាចំណាយ និង ប្រព័ន្ធគណនីត្រូវសង ។ ប្រព័ន្ធនេះនឹងថែរក្សាមូលដ្ឋានទិន្នន័យពាក់ព័ន្ធនឹងកិច្ចសន្យាតាមមុខទំនិញ ដែលត្រូវបានបង្កើតឡើងតាមនីតិវិធីលទ្ធកម្ម ។ បណ្តាក្រសួង-ស្ថាប័ន និងស្ថាប័នស្វយ័ត អាចចូលប្រើប្រាស់ប្រព័ន្ធក្នុងការទិញទំនិញ ដោយប្រើមូលនិធិដែលមានការវិភាជន៍ស្រាប់នៅក្នុងដំណើរការថវិកាទូទៅ ។ មុខងារនេះអាចអនុញ្ញាតឱ្យអ្នកផ្គត់ផ្គង់ ឬ ផលិតករអាចប្រើប្រាស់អ៊ីនធឺណេតមើលព័ត៌មានស្តីពីកិច្ចសន្យា និង កំណត់ត្រាស្តីពីការបញ្ជាទិញរបស់ពួកគេបាន ។

## ៥.៤. មុខងារគណនីត្រូវសង

មុខងារគណនីត្រូវសងបង្កើតឡើងសម្រាប់គ្រប់គ្រងការចំណាយ និង ភ្ជាប់ទំនាក់ទំនងទៅនឹងមុខងារគ្រប់គ្រងទ្រព្យសម្បត្តិ ( ជាសាច់ប្រាក់ ឬជាបង្គរ ) និង គ្រប់គ្រងឥណទាយកនានាជាមួយនឹងព័ត៌មានស្តីពីការទូទាត់របស់ពួកគេ ។ ចំនួនភាគច្រើននៃការទូទាត់របស់រដ្ឋនឹងត្រូវកត់ត្រាតាមរយៈមុខងារនេះ លើកលែងតែប្រាក់បៀវត្សដែលត្រូវបានកត់ត្រាទុកក្នុងប្រព័ន្ធនេះដែរ ប៉ុន្តែនឹងត្រូវទូទាត់តាមរយៈប្រព័ន្ធគ្រប់គ្រងបៀវត្ស ហើយត្រូវផ្ទេរចូលទៅក្នុងមុខងារសៀវភៅធំ ។ ការទូទាត់ទាំងឡាយដូចជា ការបញ្ជាទិញ ចំណាយធ្វើដំណើរ ឬ ដឹកជញ្ជូន ការទិញអាជ្ញាប័ណ្ណកម្មវិធី ឬ សម្ភារៈកុំព្យូទ័រ និង ការជួសជុលថែរក្សា ការទូទាត់សម្រាប់ជួលទីប្រឹក្សាឬជំនាញការ ការទូទាត់សងប្រាក់កម្ចីមូលនិធិវិនិយោគ ការទូទាត់ការប្រាក់ និង ការទូទាត់សងកម្ចីនានា ។ រាល់ព័ត៌មានទាំងនេះ ឬ ច្រើនជាងនេះនឹងត្រូវបានរក្សាទុកទៅតាមកំណត់ត្រានៃការទូទាត់ ហើយគេអាចស្វែងរកព័ត៌មានទៅតាមមុខទិន្នន័យនីមួយៗ ឬ តាមមុខទិន្នន័យទាំងអស់រួមបញ្ចូលគ្នាក៏បាន ។

## ៥.៥. មុខងារគណនីត្រូវទារ

ការគ្រប់គ្រងចំណូលនឹងត្រូវសម្រួលឱ្យមានការស្រង់យកគ្រប់ប្រភពចំណូល ហើយធានាថាប្រភពទាំងនោះនឹងត្រូវធ្វើចំណាត់ថ្នាក់ និង បរិយាយយ៉ាងត្រឹមត្រូវជាមួយនឹងការផ្តល់ជាធាតុចូលនៅក្នុងការផ្ទៀងផ្ទាត់ទិន្នន័យហិរញ្ញវត្ថុរបស់រដ្ឋាភិបាល និង ធានាថាចំណូលដែលប្រមូលបានមក ត្រូវបានចែករំលែកស្របទៅតាមច្បាប់ថវិកាដែលមានសុពលភាព ឬ តាមគោលបំណងពិសេសដោយឡែកផ្សេងៗ ។ មុខងារនេះ នឹងបង្កលក្ខណៈងាយស្រួល ក្នុងការវាយតម្លៃលទ្ធផលចំណូលទៅតាមការប៉ាន់ប្រមាណចំណូលពីមុនមក និង ផ្តល់ជារបាយការណ៍នានាអំពីចំណូលយ៉ាងពេញលេញទាំងចំណូលពិត និង គ្រោងទុក ។ មុខងារនេះនឹងធ្វើសន្ធានកម្មទៅនឹងមុខងារសៀវភៅធំ ដើម្បី ៖

- ធ្វើបច្ចុប្បន្នភាពគណនីសៀវភៅធំ និង
- ផ្តល់ទិន្នន័យជាធាតុចូលសម្រាប់មុខងារគ្រប់គ្រងសាច់ប្រាក់ក្នុងការកំណត់ទំហំសាច់ប្រាក់ដែលមានរបស់រដ្ឋ និង ការរៀបចំព្យាករណ៍លំហូរសាច់ប្រាក់ ដើម្បីសម្រួលដល់ការបែងចែកសាច់ប្រាក់របស់រដ្ឋាភិបាល ។

ក្នុងទិដ្ឋភាពនៃការគ្រប់គ្រងចំណូល មុខងារគណនីត្រូវទារនឹងតាមដានរាល់ការទូទាត់ទាំងអស់ដែលទូទាត់ជូនមករដ្ឋាភិបាល ហើយកត់ត្រាព័ត៌មានទាំងនេះទៅក្នុងមុខងារសៀវភៅធំទៅតាមគណនីជំពាក់រដ្ឋរបស់អតិថិជន ដែលក្នុងន័យនេះរួមបញ្ចូលទាំងការទូទាត់ជាសាច់ប្រាក់ មូលប្បទានប័ត្រ ការផ្ទេរតាមអេឡិកត្រូនិក ពាណិជ្ជកម្មអេឡិកត្រូនិកសម្រាប់ការដោះស្រាយទូទាត់សងសរុប ឬ ទូទាត់សងជាភាគ ។ មុខងារនេះត្រូវតាមដាន ពិនិត្យមើល និង កត់ត្រារាល់ការទទួលប្រាក់ទូទាត់សងទាំងអស់ ។

មុខងារគណនីត្រូវទារ អាចកត់ត្រាចំណូល ( ជាសាច់ប្រាក់ ឬ ជាបង្គរ ) និង គ្រប់គ្រងឥណទាយិកនានា និង ការទូទាត់សងរដ្ឋរបស់ពួកគេ ទាំងការទូទាត់សងសរុប ឬ ជាភាគ និង កាត់កងទៅតាមការទូទាត់ដែលរដ្ឋជំពាក់ពួកគេបាន ។ ការទទួលប្រាក់ ទូទាត់សងភាគច្រើនរបស់រដ្ឋហូរចូលមកពីប្រភពសន្ធានកម្មពីប្រព័ន្ធពន្ធដារ និង គយ ហើយក៏កត់ត្រាប្រាក់ទូទាត់សងទាំងនេះពីប្រភពផ្សេងទៀត ដូចជា ប្រាក់ឈ្នួល ប្រាក់ពិន័យ ពន្ធក្នុងស្រុក អាជ្ញាប័ណ្ណ មូលនិធិជំនួយ ជំនួយឥតសំណង ការលក់ទ្រព្យសម្បត្តិរដ្ឋ កម្ចី និង ចំណូលមកពីការវិនិយោគ ។

## ៥.៦. មុខងារគ្រប់គ្រងទ្រព្យសម្បត្តិ និង បំណុល

ប្រព័ន្ធកម្មវិធី FMIS មានមុខងារគ្រប់គ្រងទ្រព្យសម្បត្តិ ដែលនឹងត្រូវប្រើសម្រាប់ចុះបញ្ជីទ្រព្យសម្បត្តិរដ្ឋទាំងអស់ទៅតាមតម្លៃបានឯកភាព ។ របាយការណ៍កំណត់ត្រាសន្និធិ ការជម្រះបញ្ជីសន្និធិ និងការផ្ទៀងផ្ទាត់ទ្រព្យសម្បត្តិជារូបវន្តនានាជាមួយនឹងតម្លៃ នឹងត្រូវប្រើជាជំនួយដល់ក្រសួង-ស្ថាប័ន និងអង្គភាពស្វយ័តទាំងអស់ក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ខ្លួនដើម្បីប្រសិទ្ធភាពនៃចំណាយទឹកប្រាក់សាធារណៈទៅលើទ្រព្យជាមូលធនទាំងនោះ ។ មុខងារនេះ រួមបញ្ចូលជាមួយគណនេយ្យធានាចំណាយ និង មុខងារគណនីត្រូវសង ត្រូវសម្រួលដល់ក្រសួង-ស្ថាប័ន និងអង្គភាពស្វយ័ត ដើម្បីកត់ត្រាទ្រព្យសម្បត្តិដែលទើបនឹងទិញបានថ្មីៗ និងព័ត៌មានលម្អិតផ្សេងៗ ។ មុខងារនេះត្រូវមានលទ្ធភាពក្នុងការលុបចោល រាល់ទ្រព្យសម្បត្តិទាំងឡាយណា ដែលបានរាយការណ៍មកថាបានបាត់បង់ ឬ ខូចខាត ហើយនិងកត់ត្រាទ្រព្យសម្បត្តិណាដែលបោះបង់ចោល ឬ ឈប់ប្រើការទៀត ។

ប្រព័ន្ធកម្មវិធី FMIS នឹងបង្កលក្ខណៈងាយស្រួលដល់ការស្រង់ទិន្នន័យពីប្រព័ន្ធគ្រប់គ្រងបំណុល និងវិនិយោគទៅក្នុងមុខងារសៀវភៅធំ ។

## ៥.៧. មុខងារគ្រប់គ្រងសាច់ប្រាក់

ការគ្រប់គ្រងសាច់ប្រាក់គឺជាមុខងារមួយរបស់ប្រព័ន្ធកម្មវិធី FMIS ដែលគ្រប់គ្រងលើការព្យាករណ៍លំហូរសាច់ប្រាក់ ការគ្រប់គ្រងសាច់ប្រាក់ធនាគារ និង ព័ត៌មានលម្អិតរបស់គណនីធនាគារ ។ ការធ្វើសមតុល្យគណនីធនាគារត្រូវបានធ្វើឡើង ហើយសមតុល្យរបស់គណនីនេះ និងដំណើរការពាក់ព័ន្ធ ត្រូវបានដំណើរការនៅក្នុងប្រតិបត្តិការសន្ធានកម្ម ។

កម្មវត្ថុនៃមុខងារគ្រប់គ្រងសាច់ប្រាក់ គឺព្យាករណ៍សាច់ប្រាក់ដែលមានសម្រាប់ធ្វើការទូទាត់ចំណាយដើម្បីធានាបាននូវការអនុវត្តថវិកា និង សម្រួលការធ្វើហិរញ្ញប្បទានលើចំណាយប្រកបដោយប្រសិទ្ធភាពនៅពេលមានតម្រូវការ កំណត់កំឡុងពេល និង ទំហំនៃកង្វះសាច់ប្រាក់ ធានាការទូទាត់បំណុលឱ្យបានទាន់ពេលវេលា និង អនុញ្ញាតឱ្យកែតម្រូវរបាយការណ៍ប្រាក់ទូទាត់សងទាំងអស់ និង ការប្រើប្រាស់កម្ចីរបស់រដ្ឋ ។

មុខងារនេះផ្តល់ទាំងទិន្នន័យ និង សមតុល្យសាច់ប្រាក់ ប្រាក់ទូទាត់សងរដ្ឋ និង ចំណាយ គណនីត្រូវទារ គណនីត្រូវសង ការធានាចំណាយ ការវិភាជន៍ថវិកាជាដើម ក្នុងគោលដៅផ្តល់ព័ត៌មានលំហូរសាច់ប្រាក់ចេញ និង ចូលនៅក្នុងកាលបរិច្ឆេទនៃរបាយការណ៍ណាមួយដែលអ្នកប្រើប្រាស់ប្រព័ន្ធត្រូវការចង់បាន ។

ព័ត៌មានគណនីធនាគារលម្អិត ក៏ផ្ដល់ផងដែរនូវគណនីធនាគារជារូបិយប័ណ្ណបរទេស និង អនុញ្ញាតឱ្យគណនីធនាគារណាមួយអាចតភ្ជាប់តែមួយខ្សែទៅកាន់ ឧទាហរណ៍ លេខកូដរបស់គម្រោង ( នៅក្នុងមុខងារសៀវភៅធំ ) ដែលបង្ហាញពីគណនីរបស់ដៃគូអភិវឌ្ឍន៍ប្រើប្រាស់ក្នុងការបង្វែសាច់ប្រាក់ពីមូលនិធិអភិវឌ្ឍន៍ណាមួយ ( ជាជំនួយមិនមែនថវិកា ) ។ ក្នុងដំណើរការនេះ គណនីត្រូវបានការពារសុវត្ថិភាពយ៉ាងមានប្រសិទ្ធភាពពីការចំណាយដោយផ្នែកផ្សេងទៀតរបស់រដ្ឋាភិបាល ហើយក៏ផ្ដល់នូវគំហើញមានប្រយោជន៍ និង ឆាប់រហ័សលើមូលនិធិដែលមាននៅក្នុងគណនីធនាគារទាំងនេះ ការប្រើប្រាស់មូលនិធិ និង ប្រវត្តិនៃការធ្វើសមតុល្យគណនីទាំងនេះ ។

## ៥.៨. មុខងារសន្ធានកម្ម

ប្រព័ន្ធកម្មវិធី FMIS នឹងភ្ជាប់ទៅកាន់ប្រព័ន្ធខាងក្នុង និង ខាងក្រៅផ្សេងទៀតដូចជា ៖

- ប្រព័ន្ធធនាគារ-ធនាគារជាតិនៃកម្ពុជា
- អគ្គនាយកដ្ឋានទីចាត់ការគយ និង រដ្ឋាករ
- អគ្គនាយកដ្ឋានពន្ធដារ
- ប្រព័ន្ធបៀវត្សរបស់ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល
- ប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងបំណុល
- កម្មវិធីកុំព្យូទ័រដទៃទៀត ( កម្មវិធីផលិតជាក្រដាសស្នាម ឬ លិខិតផ្សេងៗ កម្មវិធីគណនាជាតារាង ...)

## ៥.៩. មុខងាររបាយការណ៍

ជាឧបករណ៍មួយក្នុងការបង្កើតជារបាយការណ៍ហិរញ្ញវត្ថុទាំងជាទម្រង់ស្តង់ដារ ( តាមរបាយ-ការណ៍ស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល អង្គការរូបិយវត្ថុអន្តរជាតិ តារាងប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋ ...) និង តាមទម្រង់ផ្សេងៗទៀត ដែលអ្នកប្រើប្រាស់ត្រូវការតាមរយៈការស្រង់ទិន្នន័យពីរចនាសម្ព័ន្ធរបស់មាតិកាគណនី តាមកំឡុងកាលណាមួយ ឬ បង្កើតជារបាយការណ៍បង្ហាញនៅលើកញ្ចក់កុំព្យូទ័រដោយផ្ទាល់ ឬ បោះពុម្ពចេញជាឯកសារ ឬថតចម្លងទៅប្រើក្នុងកម្មវិធីអិចសែល ដើម្បីបង្កើតជាក្រាហ្វិកផ្សេងៗដោយផ្តល់របាយការណ៍ជាសាច់ប្រាក់ ឬ ជាបង្គុរ ។

ជម្រើសនៃរបាយការណ៍មាននៅគ្រប់មុខងារផ្សេងៗទៀតរបស់ប្រព័ន្ធកម្មវិធី FMIS ទាំងមុខងារសៀវភៅធំ គ្រប់គ្រងទ្រព្យសម្បត្តិ គណនីត្រូវសង ឬ ត្រូវទារ និង មុខងារ គ្រប់គ្រងសាច់ប្រាក់ ហើយរបាយការណ៍ អាចត្រូវបានកែប្រែដោយអ្នកប្រើប្រាស់ដែលមានបុព្វសិទ្ធិ ឬ អ្នកគ្រប់គ្រងប្រព័ន្ធនេះ ។ អ្នកប្រើប្រាស់ក៏អាចបោះពុម្ពរបាយការណ៍ប្រចាំថ្ងៃ ខែ ត្រីមាស និងឆ្នាំ នៅចុងបញ្ចប់នៃការិយបរិច្ឆេទ ឬ ពេលកំណត់ផ្សេងទៀត ។

## ៦. គោលដៅសំខាន់ៗសម្រាប់ការអនុវត្ត FMIS

ដើម្បីបន្ទឹរដំណើរការអនុវត្ត FMIS ដ៏ស្មុគស្មាញ ផែនការយុទ្ធសាស្ត្រត្រូវបានបង្កើតឡើង ( ដោយមានដំណើរការការងារបច្ចេកទេស ការគ្រប់គ្រងការផ្លាស់ប្តូរ ការកសាងសមត្ថភាព ជាដើម ) ហើយត្រូវបានកែសម្រួលជាបន្តបន្ទាប់ទៅតាមសេចក្តីត្រូវការជាក់ស្តែង តម្រូវតាមបរិស្ថាន កំហិតនៃពេលវេលា និងកត្តាផ្សេងៗទៀតដែលអាចជះឥទ្ធិពលលើវឌ្ឍនភាពរបស់គម្រោង ។ ផែនការនេះ ផ្តល់នូវលំដាប់ដ៏សមស្របនៃការអនុវត្តសកម្មភាព និង ការចែករំលែកការទទួលខុសត្រូវចំពោះសកម្មភាពនីមួយៗ ។ ផែនការនឹងធានាឱ្យបាននូវសហប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព និងជួយធ្វើឱ្យជៀសផុតពីការអនុវត្តហួសព្រំដែន ដោយផែនការរបស់គម្រោងត្រូវមានមូលដ្ឋានឈរលើការសម្រេចបាននូវកម្មវត្ថុ គោលដៅ និងសកម្មភាពនានាស្របទៅតាមពេលវេលាទាំងមូល ។ ផែនការក៏ជួយសម្រាលសកម្មភាពទាំងឡាយដើម្បីទប់ទល់នឹងហានិភ័យដែលអាចកើតមានឡើងនៅក្នុងការអនុវត្ត ។




## ៧. ផែនការកិច្ចលទ្ធកម្មប្រព័ន្ធ FMIS

កិច្ចលទ្ធកម្មសម្រាប់គម្រោងអនុវត្ត FMIS នេះមានលក្ខណៈស្មុគស្មាញណាស់ ។ ដើម្បីសម្រួលដល់ការងារនេះ កិច្ចលទ្ធកម្មនឹងត្រូវធ្វើក្នុងដំណាក់កាលពីរផ្សេងគ្នា និងទាមទារធានាឱ្យបាននូវ ៖

- ការប្រើកញ្ចប់កម្មវិធីកុំព្យូទ័រ ដែលមានការទទួលស្គាល់ជាលក្ខណៈអន្តរជាតិ និង ធ្វើរួចស្រាប់អាចប្រើបាន ជាហេតុនាំឱ្យមានការកាត់បន្ថយហានិភ័យដែលអាចពើបប្រទះឡើងពីការប្រើប្រាស់អ្នកផ្គត់ផ្គង់ច្រើន
- ការប្រើជំនាញការឯករាជ្យ និង មានបទពិសោធន៍ខ្ពស់ដើម្បីជួយកំណត់តម្រូវការការវាយតម្លៃការចរចា និង ពិនិត្យលើគុណភាព
- ការអនុវត្តកិច្ចសន្យាប្រកបដោយគណនេយ្យភាព និងមានលទ្ធផលជាក់ស្តែង ដែលអាចទទួលយកមកប្រើប្រាស់បាន
- កិច្ចសន្យាដែលមានការផ្ទេរចំណេះដឹងដ៏ច្រើនសមស្របដើម្បីធានាចីរភាពនៃ FMIS
- ការគាំទ្ររយៈពេលវែងក្នុងការអនុវត្តក្រោយបញ្ចប់កិច្ចសន្យា និងការបង្កើតក្រុមជំនួយគាំទ្រនៅក្នុងប្រទេសកម្ពុជា ក្នុងការផ្តល់ជំនួយលើការងារនេះ ។

កន្លងមក ឯកសារដេញថ្លៃនៅដំណាក់កាលទី ១ សម្រាប់កម្មវិធីកុំព្យូទ័រ FMIS ត្រូវបានបញ្ចប់ ។ ដើម្បីធានាឱ្យបានត្រូវតាមពេលវេលាអនុវត្ត ការដេញថ្លៃលើសម្ភារៈព័ត៌មានវិទ្យានឹងត្រូវបញ្ចូលជាមួយឯកសារដេញថ្លៃនៅដំណាក់កាលទី ២ សម្រាប់កម្មវិធី កុំព្យូទ័រ FMIS តែមួយ ។

បន្ទាប់ពីបញ្ចប់បញ្ជីសម្រាំងជ្រើសរើសក្រុមហ៊ុនផលិតកម្មវិធី និង ដើម្បីបង្កើនការយល់ដឹងច្បាស់ពីកញ្ចប់កម្មវិធីកុំព្យូទ័រនានា ការពន្យល់បង្ហាញអំពីប្រព័ន្ធត្រូវបានធ្វើឡើងសម្រាប់អ្នកពាក់ព័ន្ធទាំងអស់ ។ ក្រុមហ៊ុនមានឈ្មោះក្នុងបញ្ជីសម្រាំងជ្រើសរើសនីមួយៗដែលជាប់ក្នុងដំណាក់កាលទី ១ ត្រូវបានអញ្ជើញមកធ្វើការពន្យល់បង្ហាញពីផលិតផលរបស់ខ្លួន ស្របតាមតម្រូវការរបស់កម្ពុជា និងដើម្បីឆ្លើយបំភ្លឺចំពោះរាល់ចម្ងល់ទាំងឡាយដែលមាននៅក្នុងឯកសារដែលបានដាក់នៅដំណាក់កាលនោះ ។

តម្រូវការមុខងាររបស់ឯកសារដេញថ្លៃនៅដំណាក់កាលទី ២ ត្រូវបានព្រាងឡើង និង ត្រូវការពិនិត្យឡើងវិញជាបន្ទាន់ដោយនាយកដ្ឋានពាក់ព័ន្ធ ។ នាយកដ្ឋានពាក់ព័ន្ធត្រូវមានកាតព្វកិច្ចពិនិត្យលើតម្រូវការមុខងារនេះឡើងវិញ និងផ្តល់អនុសាសន៍លើតម្រូវការណាមួយដែលពុំទាន់បំពេញឱ្យបានគ្រប់គ្រាន់ ។ នាយកដ្ឋានពាក់ព័ន្ធត្រូវរៀបចំកិច្ចប្រជុំផ្ទៃក្នុងដោយមានការចូលរួមពីបណ្តាថ្នាក់ដឹកនាំការិយាល័យ និង មន្ត្រីជំនាញរបស់ខ្លួនទាំងអស់ដែលដឹងច្បាស់ពីលំហូរការងារ ដើម្បីពិនិត្យ និង ពិភាក្សាលើសេចក្តីព្រាងនៃតម្រូវការមុខងារ ព្រមទាំងផ្តល់មតិឆ្លើយតបមកនាយកដ្ឋានព័ត៌មានវិទ្យាវិញ ។ នាយកដ្ឋានទាំងឡាយណាដែលមិនផ្តល់មតិឆ្លើយតបទេនោះ មិនអាចទាមទារ ឬ តវ៉ាថាកម្មវិធីកុំព្យូទ័រ FMIS ពុំបានបំពេញទៅតាមតម្រូវការការងាររបស់នាយកដ្ឋានខ្លួនបានឡើយ ។

ឯកសារដេញថ្លៃកម្មវិធី FMIS ត្រូវបានប្រគល់ឱ្យក្រុមហ៊ុនផ្គត់ផ្គង់ដែលមានសុពលភាព នៅដើមខែកក្កដា ឆ្នាំ ២០០៨ ។ ក្រុមហ៊ុនផ្គត់ផ្គង់ មានពេល ៦ សប្តាហ៍ក្នុងការប្រគល់គម្រោងស្នើឡើងតាមឯកសារដេញថ្លៃរបស់ពួកគេមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុវិញ ហើយដំណើរការវាយតម្លៃឯកសារដេញថ្លៃបានប្រព្រឹត្តទៅនៅខែ សីហា ឆ្នាំ ២០០៨ ។




# ៨. ការរៀបចំអង្គការចាត់តាំងគ្រប់គ្រងគម្រោង និង ការកសាងសមត្ថភាព

## *៨.១. ការរៀបចំអង្គការចាត់តាំងគ្រប់គ្រងគម្រោង*

ការគ្រប់គ្រងគម្រោងប្រកបដោយប្រសិទ្ធភាព អង្គការចាត់តាំង និង ការកសាងសមត្ថភាព គឺជាទិដ្ឋភាពគន្លឹះសម្រាប់ការអនុវត្តគម្រោង FMIS ប្រកបដោយជោគជ័យ ។ ដោយយល់ច្បាស់ពីទិដ្ឋភាពខាងលើនេះ នាយកដ្ឋានព័ត៌មានវិទ្យាបានបង្កើតឡើងនូវការរៀបចំអភិបាលកិច្ចសម្រាប់គម្រោង FMIS ដែលមានសមាសភាពដូចជា ថ្នាក់ដឹកនាំកំពូលរបស់ក្រសួង អនុគណៈកម្មាធិការទ្រទ្រង់គម្រោង ក្រុមគ្រប់គ្រងគម្រោង និង អនុក្រុមការងារផ្សេងៗទៀតទទួលខុសត្រូវលើការអនុវត្តកម្មវិធីកុំព្យូទ័រ ការបណ្តុះបណ្តាលព័ត៌មានវិទ្យា និង ទូរគមនាគមន៍ សុវត្ថិភាព និង ការពិនិត្យតាមដាន ។ល។




មកដល់ពេលនេះ រចនាសម្ព័ន្ធគ្រប់គ្រងគម្រោងស្ទើរតែត្រូវបានរៀបចំចប់សព្វគ្រប់ទៅហើយ ។ រចនាសម្ព័ន្ធគ្រប់គ្រងថ្នាក់ដឹកនាំកំពូលត្រូវបានកំណត់រួច ហើយអនុគណៈកម្មាធិការទ្រទ្រង់គម្រោងក៏ត្រូវបានបង្កើតផងដែរ ដោយមានការចូលរួមពីថ្នាក់ដឹកនាំនាយកដ្ឋានទាំងអស់ ។ គម្រោងនេះ ត្រូវការការប្តេជ្ញាចិត្តខ្ពស់ពីថ្នាក់ដឹកនាំកំពូល និង អនុគណៈកម្មាធិការក្នុងការគាំទ្រដំណើរការអនុវត្តគម្រោង FMIS ។ ជាពិសេស អ្នកទាំងនេះមានតួនាទីជំរុញកិច្ចសហប្រតិបត្តិការ និង ការចូលរួមពីគ្រប់នាយកដ្ឋាន និង ក្រសួង-ស្ថាប័ននានា ។

សមាជិកនៅក្នុងអនុក្រុមការងារនឹងត្រូវកំណត់ចាត់តាំងដោយនាយកដ្ឋានទាំងអស់នៅក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងដោយក្រសួង-ស្ថាប័នពាក់ព័ន្ធ ។ ក្នុងការធានាឱ្យមាននូវកិច្ចសហការយ៉ាងជិតស្និទ្ធបំផុតពីដៃគូពាក់ព័ន្ធទាំងអស់ នាយកដ្ឋាននីមួយៗនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវរៀបចំក្រុមការងារ FMIS ដែលមានសមាសភាពយ៉ាងតិចមន្ត្រីដែលមានសមត្ថភាពចំនួន ៣ រូប ដែលត្រូវបានចាត់តាំងឱ្យធ្វើការនៅក្នុងអនុក្រុមការងារផ្សេងៗគ្នា ។ សមាជិកទាំងអស់នៅក្នុងអនុក្រុមការងារនឹងត្រូវទទួលបានការបណ្តុះបណ្តាល ហើយពួកគេនឹងក្លាយជាអ្នកប្រើប្រាស់ប្រព័ន្ធដ៏ចំណាន និងអាចបង្រៀនអ្នកដទៃបាន ។

គោលបំណងចម្បងរបស់សកម្មភាពទាំងនេះគឺ ៖ ១- ផ្តល់ធាតុចូលសម្រាប់លទ្ធកម្ម FMIS និង ហេដ្ឋារចនាសម្ព័ន្ធព័ត៌មានវិទ្យា និង ទូរគមនាគមន៍ ដូចជាតម្រូវការបច្ចេកទេស ឬ មុខងារ ២- កំណត់ និង រៀបចំឡើងវិញនូវអភិក្រមការងារបច្ចុប្បន្នសម្រាប់អង្គភាពចំណាយ និង ចំណូលនានា ក្នុងការទ្រទ្រង់ដល់ ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងរដ្ឋាភិបាល ៣- ពង្រីកឱ្យបានទូលំទូលាយលើការយល់ដឹង និង កាត់បន្ថយការភ័យខ្លាចអំពីប្រព័ន្ធ FMIS របស់បណ្តា នាយកដ្ឋាន និង ក្រសួង-ស្ថាប័នទាំងអស់ ៤- កសាងវប្បធម៌នៃកិច្ចសហការជិតស្និទ្ធរវាងដៃគូពាក់ព័ន្ធទាំង- អស់ ៥- ពង្រឹងឡើងវិញកម្មវិធីកសាងសមត្ថភាពសម្រាប់ក្រុមអនុវត្តគម្រោង អ្នកប្រើប្រាស់ប្រព័ន្ធសំខាន់ៗ និង អ្នកប្រើប្រាស់ចុងក្រោយ និង ៦- ក្លាយជាអ្នកគ្រប់គ្រងសំខាន់សម្រាប់ប្រព័ន្ធ ។

ក្រៅពីអនុក្រុមការងារទាំងឡាយ ក៏នៅមានតម្រូវការក្នុងការកសាងសមត្ថភាពមន្ត្រីឱ្យបានគ្រប់គ្រាន់ សម្រាប់ការគ្រប់គ្រងគម្រោង ។ ដើម្បីមានធនធានមនុស្សគ្រប់គ្រាន់ក្នុងការធ្វើការជាមួយក្រុមហ៊ុនម៉ៅការ នៅថ្ងៃអនាគត ចាំបាច់ត្រូវមានមន្ត្រីព័ត៌មានវិទ្យាចំនួន១០រូប និង អ្នកវិភាគការងារយ៉ាងតិចចំនួន ១០រូប ទៀត ។ មន្ត្រីគ្រប់គ្រងគម្រោងត្រូវធ្វើការយ៉ាងជិតស្និទ្ធជាមួយមន្ត្រីនៅក្នុងអនុក្រុមការងារនានា ។

ក្រៅពីរចនាសម្ព័ន្ធគ្រប់គ្រងគម្រោង ការទទួលបានទីប្រឹក្សាអន្តរជាតិដែលមានសមត្ថភាព និង បទ ពិសោធន៍ គឺជាកត្តាសំខាន់បំផុតសម្រាប់គម្រោង ។ ទីប្រឹក្សាផ្សេងៗ ដូចជាទីប្រឹក្សាផ្នែកព័ត៌មានវិទ្យា និង ទូរគមនាគមន៍ ទីប្រឹក្សាគម្រោងការ FMIS ទីប្រឹក្សាផ្នែកវិភាគមុខងារ ទីប្រឹក្សាគ្រប់គ្រងការផ្លាស់ប្តូរ និង អ្នកជំនាញការផ្នែកច្បាប់ គឺត្រូវការជាចាំបាច់ និងកំពុងត្រូវជ្រើសរើស ។

### *៨.២. ការកសាងសមត្ថភាព*

នាយកដ្ឋានព័ត៌មានវិទ្យាបានបង្កើតផែនការកសាងសមត្ថភាពយ៉ាងទូលំទូលាយមួយសម្រាប់ គម្រោង ។ ការបណ្តុះបណ្តាលត្រូវបានរៀបចំឡើងជាពិសេសសម្រាប់ក្រុមជាក់លាក់នានា ។

ចំពោះមន្ត្រីនៅក្នុងក្រុមការងាររបស់គម្រោងនៅតាមនាយកដ្ឋាន និង ក្រសួង-ស្ថាប័ននានា និង មន្ត្រី ផ្នែកវិភាគការងារ នឹងត្រូវទទួលការបណ្តុះបណ្តាលវគ្គផ្សេងៗ ដូចជាវគ្គកុំព្យូទ័រមូលដ្ឋាន គណនេយ្យរដ្ឋា- ភិបាល ប្លង់គណនេយ្យ ការរៀបចំថវិកា ការប្រើប្រាស់កម្មវិធីកុំព្យូទ័រ FMIS ការពិនិត្យមើលឡើងវិញលើ អភិក្រមការងារ ការគ្រប់គ្រងគម្រោង និង ការគ្រប់គ្រងការផ្លាស់ប្តូរ ។ គោលបំណងចម្បង គឺប្រែក្លាយ ក្រុមការងារនេះជាអ្នកប្រើប្រាស់ដ៏ចំណាន ។

អ្នកប្រើប្រាស់ចុងក្រោយលើកម្មវិធីកុំព្យូទ័រ FMIS នឹងត្រូវចែកជាក្រុមដូចខាងក្រោម ៖

១. **កម្រិតថ្នាក់ដឹកនាំជាន់ខ្ពស់** ៖ ( ពីថ្នាក់ដឹកនាយកដ្ឋានឡើងទៅដល់ថ្នាក់ដឹកនាំកំពូលរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ) មន្ត្រីទាំងនេះនឹងប្រើប្រាស់ប្រព័ន្ធនេះ តែលើកម្មវិធីការងារផ្តល់ការឯកភាពធ្វើសេចក្តីសម្រេច និងរបាយការណ៍តែប៉ុណ្ណោះ ។ ថ្នាក់ដឹកនាំនឹងត្រូវទទួលបានការបណ្តុះបណ្តាលបន្ថែមផងដែរលើចំណេះដឹងលើការអនុវត្តកម្មវិធីកុំព្យូទ័រ ទស្សនាទានមូលដ្ឋានទិន្នន័យ និង អ៊ីនធឺណេត និង សារអេឡិកត្រូនិក ។

២. **កម្រិតបច្ចេកទេស ឬ ប្រតិបត្តិ** ៖ មន្ត្រីទាំងនេះនឹងក្លាយជាអ្នកប្រើប្រាស់ និងអនុវត្តកម្មវិធីកុំព្យូទ័រ FMIS យ៉ាងពេញលេញ ហើយនឹងត្រូវទទួលបានការបណ្តុះបណ្តាលផ្នែកកុំព្យូទ័រមូលដ្ឋាន និង អនុវត្តដំណើរការប្រតិបត្តិការហិរញ្ញវត្ថុផ្សេងៗ ដែលមានកំណត់នៅក្នុង FMIS ។

៣. ការបណ្តុះបណ្តាលសម្រាប់អ្នកជំនាញបច្ចេកទេស នឹងត្រូវផ្តល់ការបណ្តុះបណ្តាលទៅតាមតម្រូវការ ( ដូចជា សវនកម្មផ្ទៃក្នុង និង ខាងក្រៅប្រព័ន្ធ ការគ្រប់គ្រងសន្ធានកម្ម ) ។

ចំពោះមន្ត្រីព័ត៌មានវិទ្យា និង វិភាគការងារនៅក្នុងនាយកដ្ឋានព័ត៌មានវិទ្យា និង សមាជិកថ្មីនៅក្នុងអនុក្រុមការងារ ក៏នឹងត្រូវទទួលបានការបណ្តុះបណ្តាលកុំព្យូទ័រមូលដ្ឋាន និង វគ្គជំនាញកម្រិតខ្ពស់ផ្សេងៗទៀតទៅតាមតម្រូវការ និង មុខងាររបស់ពួកគេនៅក្នុងការអនុវត្តគម្រោង ។

### *៨.៣. វគ្គបណ្តុះបណ្តាលកម្រិតមូលដ្ឋាន*

ដំណាក់កាលបណ្តុះបណ្តាលស្នូល គឺការប្រើប្រាស់កម្មវិធីកុំព្យូទ័រ FMIS និង វគ្គបណ្តុះបណ្តាលបច្ចេកទេសដែលនឹងត្រូវផ្តល់ដោយក្រុមហ៊ុនផ្គត់ផ្គង់ឱ្យគម្រោង ក្រោមការសហការជាមួយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ ដើម្បីស្ពានបនាគ្រឹះឱ្យបានឈានដល់ការបណ្តុះបណ្តាលទាំងនេះ អ្នកប្រើប្រាស់ប្រព័ន្ធត្រូវតែមានសមត្ថភាពយល់ច្បាស់ពីការប្រើប្រាស់កុំព្យូទ័រជាមូលដ្ឋាន ដំណើការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណ: និង ការគ្រប់គ្រងគម្រោង FMIS ជាមុនសិន ដើម្បីធានាថាពួកគេមានចំណេះដឹងជាមូលដ្ឋានក្នុង ការស្រូបយកនូវចំណេះដឹងនៅដំណាក់កាលបណ្តុះបណ្តាលស្នូល ។

ការបណ្តុះបណ្តាលជាមូលដ្ឋាននឹងបញ្ចូលនូវប្រធានបទគន្លឹះដូចតទៅ ៖ ១- ផ្នែកកម្មវិធីកុំព្យូទ័រ ៖ ការអនុវត្តកម្មវិធីកុំព្យូទ័ររួមមានកញ្ចប់កម្មវិធីកុំព្យូទ័របម្រើឱ្យការងារការិយាល័យ ការប្រើប្រាស់ទម្រង់អក្សរ

ខ្មែរយូនីកូដ ទស្សនាទានមូលដ្ឋានទិន្នន័យ អ៊ីនធឺណេត និង សារអេឡិកត្រូនិក ២- ផ្នែកសម្ភារៈកុំព្យូទ័រ ៖ លំនាំដើមអំពីកុំព្យូទ័រ ការជួសជុល និង ថែរក្សាកុំព្យូទ័រ និង ទស្សនាទានខ្លះៗលើបណ្ដាញតភ្ជាប់ និង ៣- ដំណើរការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

## *៨.៤. ការបណ្តុះបណ្តាលកម្មវិធីកុំព្យូទ័រដើម្បីអនុវត្ត FMIS*

ការបណ្តុះបណ្តាលនេះ នឹងត្រូវធ្វើឡើងដោយក្រុមហ៊ុនផ្គត់ផ្គង់គម្រោងក្រោមកិច្ចសហការជាមួយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ( នាយកដ្ឋានព័ត៌មានវិទ្យា និង វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឬ ដៃគូពាក់ព័ន្ធដទៃទៀត ) ។ ការផ្តល់វគ្គបណ្តុះបណ្តាលស្នូលនេះនឹងត្រូវផ្តួចផ្តើមធ្វើឡើងដោយក្រុមហ៊ុនផ្គត់ផ្គង់គម្រោង។ ទស្សនៈនៃការបណ្តុះបណ្តាល អ្នកបណ្តុះបណ្តាល នឹងត្រូវអនុវត្តដោយមានវគ្គបណ្តុះបណ្តាលគ្រប់គ្រាន់បន្ថែមលើមន្ត្រីព័ត៌មានវិទ្យា វិភាគការងារ និង អ្នកប្រើប្រាស់ដ៏ចំណាន ហើយវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាអ្នកធានាដល់មន្ត្រីទាំងនេះឱ្យបានបង្រៀនដល់មន្ត្រីជាច្រើនទៀតនៅក្នុងដំណាក់កាលដាក់ឱ្យប្រើប្រាស់ប្រព័ន្ធខណៈពេលដែលចំនួនអ្នកប្រើប្រាស់បានកើនឡើង ។ ក្រុមហ៊ុនផ្គត់ផ្គង់គម្រោងត្រូវធានាថាមន្ត្រីស្នូលទ្រទ្រង់ការអនុវត្តគម្រោងយល់ដឹងពីរបៀបប្រើប្រាស់កម្មវិធីកុំព្យូទ័រ FMIS និងបានជ្រួតជ្រាបបន្តិចម្តងៗពីបរិស្ថានរបស់ប្រព័ន្ធ និង មានលទ្ធភាពទាញយកផលប្រយោជន៍ពីប្រព័ន្ធដើម្បីបំពេញសេចក្តីត្រូវការការងាររបស់ពួកគេ ។

ក្រុមអនុវត្តគម្រោង FMIS និង អនុក្រុមការងារនឹងត្រូវការធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រុមការងាររបស់ក្រុមហ៊ុនផ្គត់ផ្គង់គម្រោងនៅគ្រប់ដំណាក់កាលអភិវឌ្ឍន៍កម្មវិធីកុំព្យូទ័រ FMIS និង ការតម្លើងបណ្តាញតភ្ជាប់ និង សម្ភារៈកុំព្យូទ័រ ដូចជាការរៀបចំឯកសារសម្រាប់កសាងកម្មវិធីកុំព្យូទ័រ ដំណើរការវិភាគសរសេរកូដ ការសាកល្បងស្វែងរកកំហុស ការកែប្រែឱ្យត្រូវតាមតម្រូវការ ការបង្កើតរបាយការណ៍ ការតបណ្តាញ ។ល។

## *៨.៥. ការរក្សាទុកមន្ត្រីដែលបានទទួលការបណ្តុះបណ្តាល*

តាមកម្រិតនៃការលើកទឹកចិត្តនាពេលបច្ចុប្បន្ននេះ មានការទទួលស្គាល់ថាប្រហែលជាពិបាកក្នុងការរក្សាទុកមន្ត្រីដើម្បីអនុវត្តគម្រោងប្រកបដោយចីរភាព ជាពិសេសគឺមន្ត្រីផ្នែកព័ត៌មានវិទ្យា ។ នៅពេលដែលមន្ត្រីទាំងនេះទទួលបានការបណ្តុះបណ្តាលចប់ហើយមានបទពិសោធន៍លើការអនុវត្តគម្រោងដ៏ធំ និង សំខាន់ដូចគម្រោង FMIS ថែមទៀតនោះ ពួកគេនឹងអាចក្លាយជាអ្នកមានជំនាញព័ត៌មានវិទ្យាដ៏ពូកែនៅកម្ពុជា ។

ដូច្នេះ ជាការចាំបាច់បំផុតក្នុងការផ្ដល់ការលើកទឹកចិត្តឱ្យបានគ្រប់គ្រាន់ដល់ពួកគេដើម្បីរក្សាទុកពួកគេឱ្យធ្វើការនៅក្នុងគម្រោង ។ ក្របខ័ណ្ឌផ្ដល់លាភការតាមលទ្ធផលការងារនឹងអាចប្រើជាការលើកទឹកចិត្តសម្រាប់មន្ត្រីជាប់ពាក់ព័ន្ធនឹងការអនុវត្តគម្រោងនេះ ។

## ៩. *គោលនយោបាយដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ FMIS*

ផែនការដាក់ឱ្យប្រើប្រាស់ដំបូងមានគោលដៅកំណត់ឱ្យចាប់ផ្ដើមប្រតិបត្តិការនៅថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១០ លើមុខងារស្នូលទាំងអស់សម្រាប់រតនាគារជាតិ បណ្ដាក្រសួង ត្រូវសាកល្បងចំនួន ៤ ( ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល ក្រសួងសាធារណៈការ និងដឹកជញ្ជូន និង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ) និង បណ្ដារតនាគារខេត្ត ចំនួន ៥ ទៀត ( កណ្ដាល បាត់ដំបង សៀមរាប បន្ទាយមានជ័យ និង ក្រុងព្រះសីហនុ ) ។ ក្នុងការត្រៀមរៀបចំសម្រាប់ដំណើរការទាំងនេះតាមផែនការមុខងារ រៀបចំថវិកានឹងត្រូវចាប់ផ្ដើមប្រតិបត្តិការនៅពាក់កណ្ដាលឆ្នាំ ២០០៩ ដោយសារតែមុខងារនេះជាមុខងារដើមដំបូងបំផុតដែលត្រូវអនុវត្តមុនការអនុវត្តថវិកា។ ក្ដីសង្ឃឹមនាពេលអនាគតក្នុងការចាប់ផ្ដើមប្រតិបត្តិការសម្រាប់ប្រព័ន្ធទាំងមូលនៅទូទាំងប្រទេសគឺអាស្រ័យលើសមត្ថភាពដែលមានស្រាប់ និងការដាក់ឱ្យប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធព័ត៌មានវិទ្យា និងទូរគមនាគមន៍ ។ ទោះជាយ៉ាងណាក្ដី ក៏មានក្ដីសង្ឃឹមនឹងផ្ដល់ការដាក់ឱ្យប្រើប្រាស់នៅថ្នាក់ក្រសួង និង នៅរតនាគារខេត្តផ្សេងបន្ថែមទៀត នៅថ្ងៃទី ១ មករា ឆ្នាំ ២០១១ ។




កម្មវិធីជាក់ស្តែងអាស្រ័យលើការកំណត់ពេលវេលានៅក្នុងកិច្ចសន្យា ការផ្គត់ផ្គង់សម្ភារៈ បរិក្ខារ និងការជ្រើសរើសដំណោះស្រាយ FMIS ចុងក្រោយ ប្រសិនបើលទ្ធផលមានការលំបាកស្មុគស្មាញ នោះនឹងត្រូវការពេលវេលាយូរក្នុងការរៀបចំកសាងឱ្យចេញជារូបរាងឡើង ដើម្បីឈានទៅដល់ដំណាក់កាលដែលអាចអនុវត្តបាន ។

នៅពេលដែលកំណត់បាននូវផលិតផល ជំហានដែលត្រូវធ្វើ និង ការកំណត់ពេលវេលានីមួយៗ ត្រូវបានជ្រើសយកដូចតារាងខាងក្រោម ហើយការងារទាំងនេះមិនចាំបាច់ត្រូវតែធ្វើតាមលំដាប់នេះទេ ព្រោះថាការងារខ្លះត្រូវបានបញ្ចប់រួចទៅហើយ ។ កាលវិភាគនេះគ្រាន់តែជាការចង្អុលបង្ហាញចំពោះមុខងារមួយៗប៉ុណ្ណោះ ទោះបីជាមានមុខងារខ្លះត្រូវការពឹងផ្អែកលើការងារមួយទៀតក៏ដោយហើយកត្តានេះមានសារៈសំខាន់ក្នុងការយល់ឱ្យបានច្បាស់អំពីផ្លូវជ្រើសរើស ។

| | | |
|---|---|---|
| ១ | ការសិក្សាពីការបំពេញគំលាត | ៤ សប្តាហ៍ |
| ២ | វគ្គបណ្តុះបណ្តាលមន្ត្រីស.ហ.វ ដែលអនុវត្តគម្រោង | ៦ សប្តាហ៍ |
| ៣ | រៀបចំកសាងឱ្យចេញជារូបរាងកម្មវិធីកុំព្យូទ័រ FMIS | ២ សប្តាហ៍ |

| | | |
|---|---|---|
| ៤ | ការឯកភាពពីអ្នកគ្រប់គ្រងការងារក្នុង កសហវ | ៤ សប្តាហ៍ |
| ៥ | រៀបចំឱ្យមានការកសាងឱ្យចេញជារូបរាង និង សាកល្បង | ៣-៨ សប្តាហ៍ |
| ៦ | ការសាកល្បងសមាហរណកម្មប្រព័ន្ធ និង កែកំហុស | ៤ សប្តាហ៍ |
| ៧ | សាកល្បងទទួលស្គាល់ពីអ្នកប្រើប្រាស់ និង កែកំហុស | ៦ សប្តាហ៍ |
| ៨ | រៀបចំជាឯកសារ និង បណ្តុះបណ្តាលអ្នកប្រើប្រាស់ | កំពុងដំណើរការ |
| ៩ | ការចាប់ផ្តើមដាក់ឱ្យប្រើប្រាស់កម្មវិធីកុំព្យូទ័រ FMIS | |

កាលវិភាគបែងចែកតាមសប្តាហ៍នីមួយៗមិនត្រូតជាន់គ្នាទេ ឧទាហរណ៍ ៖ នៅពេលដែលមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុអនុវត្តគម្រោងកំពុងទទួលការហ្វឹកហាត់ ពេលនោះក្រុមហ៊ុនជាប់កិច្ចសន្យានឹងរៀបចំដំឡើងប្រព័ន្ធ ហើយនៅពេលដែលប្រព័ន្ធកំពុងតែដំឡើង កម្មវិធីនឹងត្រូវផ្តោតទៅលើ SIT និង UAT ហើយនិងត្រូវអនុម័តដោយក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ រយៈពេលសាកល្បងដំឡើងប្រព័ន្ធ និងផ្នែកនីមួយៗនៃប្រព័ន្ធ គួរបង្ហាញអំពីការប៉ះពាល់លើកាលវិភាគ ឬ ទំហំនៃភាពស្មុគ្រស្មាញដែលអាចប៉ះពាល់ទៅលើគម្រោង ជាមួយនឹងការរៀបចំការគ្រប់គ្រងហិរញ្ញវត្ថុតាមប្រព័ន្ធព័ត៌មានវិទ្យាទាំងមូលរួមមានទាំងការគ្រប់គ្រងហិរញ្ញវត្ថុតាមប្រព័ន្ធព័ត៌មានវិទ្យា និង បណ្តាញគ្រឿងកុំព្យូទ័រ កម្មវិធីកុំព្យូទ័រ នឹងត្រូវអនុវត្តទន្ទឹមគ្នា ។

គម្រោងផែនការមូលដ្ឋានសម្រាប់ការដាក់ឱ្យអនុវត្ត គឺផ្តល់ឱ្យមានមុខងាររៀបចំ និងធ្វើផែនការថវិកាឱ្យប្រើប្រាស់បានតាមប្រព័ន្ធកុំព្យូទ័រជាមុនសិន ។ ហើយនេះក៏ប្រហែលជាកម្មវិធីដែលងាយជាងគេក្នុងការរៀបចំ ទោះបីជាត្រូវពឹងផ្អែកទៅលើប្លង់គណនេយ្យដែលកំពុងត្រូវបញ្ចប់ក៏ដោយ ដោយសារតែពេលវេលា និង ស្ថានភាពនៃការរៀបចំថវិកាមានមុខងារ ដែលមានផលប្រយោជន៍នៅមានកម្រិតនៅឡើយសម្រាប់ឆ្នាំដំបូង ។ នៅពេលដែលថវិកាប្រចាំឆ្នាំត្រូវបានរៀបចំហើយនៅខែ កញ្ញា ការបញ្ចូលប្រព័ន្ធថវិកាតាម FMIS ក្នុងនាយកដ្ឋានថវិកា រឹតតែធ្វើឱ្យមានការយឺតយ៉ាវចំពោះការអនុវត្តថវិកា ដោយសារតម្រូវការរៀបចំវគ្គបណ្តុះបណ្តាល ដូច្នេះការអនុវត្តមុខងាររៀបចំថវិកាគឺអាស្រ័យទៅតាមពេលវេលា ។

គម្រោងអនុវត្តជាជំហានទី ២ នោះគឺមុខងារសៀវភៅធំ មុខងារថវិកា និង ផ្នែកខ្លះនៃគណនីត្រូវទារ និង គណនីត្រូវសង ព្រមទាំងមុខងារធនាគារ ដើម្បីឱ្យរតនាគារអាចចាប់ផ្តើមកត់ត្រាប្រតិបត្តិការហិរញ្ញវត្ថុនៅក្នុងសៀវភៅធំកាន់តែឆាប់តាមលទ្ធភាពអាចធ្វើទៅបាន ។ ផ្នែកគណនីត្រូវទារ និង គណនីត្រូវសង គឺ

អាចកត់ត្រាព័ត៌មានអ្នកផ្គត់ផ្គង់តាមរយៈរតនាគារបាន ដើម្បីរៀបចំបង្កើតការអនុវត្តការកត់ត្រាមូលដ្ឋាន និង របាយការណ៍ ផ្អែកទៅលើទិន្នន័យដែលបានមកពីប្រព័ន្ធ FMIS ។ រតនាគារ[1]ត្រូវកត់ត្រាប្រតិបត្តិការដែលបានទទួលទាំងអស់ដោយការកត់ត្រាមូលដ្ឋាន និង បញ្ចូលទិន្នន័យទាំងនោះទៅក្នុងប្រព័ន្ធ FMIS ។ តាមមធ្យោបាយនេះប្រតិបត្តិការចេញចូលទាំងអស់ នឹងត្រូវកត់ត្រាជាសាច់ប្រាក់នៅពេលទូទាត់តាមប្រព័ន្ធធានាគារ ។

ការសាកល្បងត្រូវបើកឱ្យប្រើប្រាស់នាដើមឆ្នាំ ក៏ប៉ុន្តែមិនមែនគ្រប់កន្លែងសាកល្បងនឹងត្រូវចាប់ផ្តើមថ្ងៃទី ១ ខែ មករា នោះទេ ប្រហែលជាមានតែក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រតនាគារជាតិ និងក្រសួងផ្សេងមួយទៀតតែប៉ុណ្ណោះ ដែលត្រូវចាប់ផ្តើមសាកល្បងមុនគេ ព្រោះថាបើចាប់ផ្តើមច្រើនជាងនេះនឹងបណ្តាលឱ្យមានបញ្ហាដល់ធនធានដែលទ្រទ្រង់គម្រោងនេះ ។ នៅពេលដែលការសាកល្បងចប់ជាស្ថាពរ ហើយដំណើរការបានទទួលជោគជ័យ នោះទើបអាចចាប់ផ្តើមពង្រីកទៅក្រសួងពីរ ឬ បីទៀត រហូតដល់គ្រប់ក្រសួងសាកល្បងត្រូវបានតភ្ជាប់ឱ្យប្រើប្រាស់ប្រកបដោយដំណើរការល្អប្រសើរនាដំណាច់ឆ្នាំ ។ នៅពេលដែលក្រសួងសាកល្បងត្រូវបានតភ្ជាប់ ដូច្នេះរតនាគារត្រូវបានកាត់បន្ថយកិច្ចការសម្រាប់កន្លែងទាំងនោះដល់កម្រិតមួយដែលជាមូលដ្ឋានកិច្ចការរបស់រតនាគារជាតិ ( ឧទាហរណ៍ ការយល់ព្រមលើការទូទាត់ និងដំណើរការទូទាត់ និងទូទាត់តាមប្រព័ន្ធធនាគារ ។ល។ ) ។

កម្មវិធីដែលត្រូវបញ្ចូលឱ្យប្រើប្រាស់សម្រាប់កន្លែងសាកល្បង គឺអាស្រ័យទៅលើភាពរួចរាល់របស់កម្មវិធី FMIS និងភាពស្មុគ្រស្មាញនៃគម្រោងប្រព័ន្ធចុងក្រោយ ។ មុខងារដ៏សាមញ្ញបំផុតសម្រាប់កន្លែងសាកល្បងគឺ កម្មវិធីដែលត្រូវបញ្ចូលឱ្យប្រើប្រាស់មុខងារជាមូលដ្ឋាននៃគណនីត្រូវទារ និងគណនីត្រូវសងសម្រាប់នាយកដ្ឋាននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដូចជានាយកដ្ឋានថវិកា និងរតនាគារជាតិសម្រាប់សៀវភៅកត់ត្រា ប្រតិបត្តិការធនាគារ និងថវិកា ។ល។ ក្នុងខណៈដែលមុខងារនីមួយៗត្រូវបានដាក់ចេញឱ្យប្រើប្រាស់ គឺតម្រូវឱ្យមានការចុះត្រួតពិនិត្យលើកន្លែងសាកល្បង ដើម្បីបង្កើនការអនុវត្ត និង សមត្ថភាពអ្នកប្រើប្រាស់ប្រព័ន្ធថ្មី ។ យុទ្ធសាស្ត្រនេះបន្ថែមការងារច្រើនសម្រាប់ក្រុមអនុវត្តព័ត៌មានវិទ្យា និង អ្នកផ្គត់ផ្គង់គម្រោង FMIS ប៉ុន្តែផ្តល់ភាពងាយស្រួលដល់អ្នកប្រើប្រាស់ ហើយដំណោះស្រាយមួយទៀត គឺត្រូវការរង់ចាំ

1-អាចថាប្រតិបត្តិការទាំងនេះនឹងត្រូវបញ្ចូលភ្លាមៗនៅពេលដែលប្រតិបត្តិការនេះត្រូវបានអនុវត្តនៅក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អាចដោយនាយកដ្ឋានហិរញ្ញកិច្ច នាយកដ្ឋានលទ្ធកម្មជាដើម អាស្រ័យទៅលើភាពជាក់ស្តែង ដែលអភិក្រមការងារ នឹងត្រូវអនុវត្តត្រូវបានទទួលយល់ស្របឱ្យអនុវត្តមុនពេលដាក់ឱ្យកម្មវិធី FMIS ។

រហូតដល់តម្រូវការរបស់ទីកន្លែងសាកល្បងទាំងអស់បានបញ្ចប់ និង បញ្ចេញឱ្យប្រើប្រាស់ហើយ ទើបអាចអនុវត្តគម្រោង FMIS នេះធ្វើឱ្យមានភាពងាយស្រួលដល់ក្រុមការងារអនុវត្ត ប៉ុន្តែផ្តល់ផលលំបាកដល់អ្នកប្រើប្រាស់ ដូច្នេះគេមិនអាចធ្វើសេចក្តីសម្រេចបានទេរហូតទាល់តែមានការយល់ច្បាស់អំពីផលិតផល និងកាលវិភាគអ្នកផ្គត់ផ្គង់គម្រោងក្នុងការធ្វើផែនការ និងដាក់ប្រព័ន្ធឱ្យប្រើប្រាស់ ។

ថ្ងៃបើកដាក់ឱ្យប្រើប្រាស់ទីតាំងសាកល្បង គួរតែចាប់ផ្តើមក្នុង ខែ មករា ក្នុងឆ្នាំថវិកា ទោះបីជាមិនអាចឱ្យទីតាំងសាកល្បងទាំងអស់ចាប់ផ្តើមពេលជាមួយគ្នាក៏ដោយ ។ ប្រតិបត្តិការសាកល្បងទាំងអស់ នឹងត្រូវបញ្ចូលទៅក្នុងប្រព័ន្ធ FMIS ( ឧទាហរណ៍ ដោយរតនាគារ ឬ នាយកដ្ឋានហិរញ្ញកិច្ច ) ។ ដូច្នេះ គ្រប់ប្រតិបត្តិការសាកល្បងត្រូវបានកត់ត្រាទុកក្នុង FMIS ហើយនៅពេលដែលក្រុមអនុវត្តរៀបចំទីតាំងរួចហើយ ពេលនោះ នឹងមានការផ្អាកប្រតិបត្តិការសិនក្នុងពេលដែលទីតាំងប្រតិបត្តិការទាំងអស់ត្រូវបានអនុវត្តក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយប្រតិបត្តិការផ្សេងៗទៀត និងត្រូវបញ្ចូលដោយមន្ត្រីសាកល្បង ។ បើសិនជា ប្រតិបត្តិការទាំងអស់មិនបានកត់ត្រាបញ្ចូលក្នុងទីតាំងសាកល្បងក្នុងថ្ងៃទី ០១ ខែ មករា ការផ្លាស់ប្តូរពីដំណើការបច្ចុប្បន្នទៅជាដំណើការសាកល្បង នឹងក្លាយទៅជារឿងស្មុគ្រស្មាញ ហើយតម្រូវបង្កើតឱ្យមានការរៀបចំបើកសមតុល្យ និង ដំណើរប្រតិបត្តិការបញ្ចូលគ្នាលម្អិតសម្រាប់រយៈពេលក្រៅ FMIS និងប្រតិបត្តិការក្នុង FMIS ។ ការចាប់ផ្តើមក្នុងកំឡុងឆ្នាំថវិកា គឺតម្រូវឱ្យមានពលកម្មច្រើន ហើយភ្ជាប់មកជាមួយភាពប្រថុយប្រថាន និង កំហុសក៏ច្រើន ប៉ុន្តែផលប្រយោជន៍នៃការបញ្ចូលប្រតិបត្តិការទាំងអស់ទៅក្នុង FMIS ពីដើមទីនៃឆ្នាំថវិកា គឺថា FMIS អាចជាប្រភពតែមួយគត់នៃរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ប្រតិបត្តិការ ។

អនុវត្តសន្ទានកម្មរវាងបញ្ជីប្រាក់បៀវត្ស ប្រព័ន្ធប្រមូលពន្ធ ប្រព័ន្ធប្រមូលពន្ធគយ ប្រព័ន្ធគ្រប់គ្រងបំណុលត្រូវរង់ចាំការអនុវត្តប្រព័ន្ធសន្ទានកម្មសម្រាប់ FMIS និងប្រព័ន្ធប្រភពដើមក៏ដូចជានៅពេលដែលបង្កើតទូរគមនាគមន៍តភ្ជាប់ និង ផ្ទេរទិន្នន័យរួចរាល់សម្រាប់ចាប់ផ្តើមអនុវត្តទន្ទឹមគ្នានេះដែរ នៅពេលដែលមានការយឺតយ៉ាវ គឺតម្រូវឱ្យមានការបញ្ចូលទិន្នន័យទិន្នានុប្បវត្តិដោយដៃទៅក្នុងប្រព័ន្ធ FMIS ហើយបន្ទាប់មកការធ្វើសមតុល្យរវាងប្រព័ន្ធប្រភពដើម FMIS និង នៅពេលដែលសន្ទានកម្មកំពុងតភ្ជាប់ ។

ការបណ្តុះបណ្តាលអ្នកប្រើប្រាស់ គឺរំពឹងទៅលើភាពស្មុគ្រស្មាញគម្រោងរៀបចំប្រព័ន្ធ និង ប្រព័ន្ធកម្មវិធីជាពិសេសតម្រូវការអ្នកប្រើប្រាស់ ហើយសម្រាប់ដំណើរប្រតិបត្តិការគោល ត្រូវការពេលវេលាយ៉ាងតិចគឺមួយថ្ងៃសម្រាប់ពិនិត្យលើប្រព័ន្ធ FMIS ណែនាំឱ្យស្គាល់ពីប្រព័ន្ធថ្មី ការរៀបចំផ្ទៃកម្មវិធី ការរុករកបញ្ជីមុខ

ងារបញ្ហា និង ការប្រើចង្កឹះក្តារបញ្ជាងាយៗ ។ បន្តពីនេះទៀត ត្រូវការពេលវេលា ៣ ទៅ ៥ ថ្ងៃ សម្រាប់វគ្គបណ្តុះបណ្តាលមុខងារជាមួយការសាកល្បងកម្រិតយល់ដឹងមុន ពេលអនុញ្ញាតឱ្យប្រើប្រព័ន្ធហើយក៏ផ្តល់ឱ្យមានការរំឭកជារឿយៗ នៅទីស្នាក់ការអ្នកប្រើប្រាស់បើអាចធ្វើទៅរួចបន្ទាប់ពីពួកគេបានតភ្ជាប់ទៅនឹងប្រព័ន្ធដើម្បីជួយជំរុញការយល់ដឹងលើប្រព័ន្ធ FMIS ។ ផ្តោតទៅលើអ្នកប្រើប្រាស់ នៅជុំវិញកន្លែងមុខងារថវិកាអ្នកហ្វឹកហាត់ម្នាក់នឹងត្រូវធ្វើបទបង្ហាញទៅលើការប្រើប្រាស់ប្រព័ន្ធ ហើយបើមានមុខងារផ្សេងទៀត វគ្គបណ្តុះបណ្តាលនឹងត្រូវបន្តទៅ៥ថ្ងៃទៀត ដើម្បីបន្ថែមការយល់ដឹងអំពីមុខងារប្រព័ន្ធជាមួយគ្នានេះដែរ ។ វគ្គបណ្តុះបណ្តាលត្រូវតែធ្វើដោយផ្ទាល់នៅទីកន្លែង ដូច្នេះហើយអ្នកប្រើប្រាស់ត្រូវមានកុំព្យូទ័រ និង បរិស្ថានសាកល្បងដូចជា បរិស្ថានផលិតផលជាក់ស្តែង សម្រាប់ឱ្យអ្នកប្រើប្រាស់ធ្វើការសាកល្បងដំណើរប្រតិបត្តិការ ជាមួយវគ្គបណ្តុះបណ្តាលតែម្តង ។ នៅពេលដែលប្រព័ន្ធ FMIS បានចាប់ផ្តើមដាក់ឱ្យប្រើប្រាស់គ្រប់ទីកន្លែង នោះតម្រូវឱ្យមានក្រុមអ្នកជំនួយធ្វើការនៅពេលដែលមានបញ្ហាកើតឡើង ភាពមិនច្បាស់លាស់ ឬប្រព័ន្ធខូច ហើយវាជាការសំខាន់ដែលតម្រូវឱ្យកន្លែងសាកល្បងនីមួយៗមានគម្រោងអនុវត្តរបស់ខ្លួន និង ឯកសារនៃលទ្ធផលដំណើរការដើម្បីឱ្យដឹងច្បាស់អំពីចំនួនអ្នកបានចូលរួមវគ្គបណ្តុះបណ្តាលទទួលសិទ្ធិប្រើប្រាស់ប្រព័ន្ធ ឬ បញ្ចូលទិន្នន័យ ។ល។ ជាការជាក់ស្តែងបណ្តាញតភ្ជាប់កុំព្យូទ័រត្រូវតែមាននៅគ្រប់កន្លែង ហើយត្រូវសាកល្បងបណ្តាញនោះមុននឹងអាចដាក់ឱ្យប្រព័ន្ធដំណើរការ ។

ដូចគ្នានេះដែរ សំណើសម្រាប់ដំណើរការត្រូវបានលើកមកបង្ហាញ និង បុគ្គលិកទទួលការបណ្តុះបណ្តាលក្នុងដំណើរការថ្មីមុននឹងធ្វើការបណ្តុះបណ្តាលពីប្រព័ន្ធ FMIS ទន្ទឹមនេះដែរ អ្នកប្រើប្រាស់ទាំងអស់គួរតែបានទទួលការបណ្តុះបណ្តាលលើប្លង់គណនេយ្យ និង វគ្គសិក្សាចាំបាច់ផ្សេងទៀត ដើម្បីអាចគ្របដណ្តប់លើវគ្គបណ្តុះបណ្តាលផង និងប្រតិបត្តិការផង។

ក្នុងកំឡុងពេលសាកល្បង គម្រោងដំណើរការប្រតិបត្តិការទាំងមូលត្រូវមានការត្រួតពិនិត្យ និង កែសម្រួលយោងទៅតាមបទពិសោធន៍ ហើយនៅពេលដែលកន្លែងសាកល្បង ត្រូវបានប្រតិបត្តិ និងមានស្ថិរភាពនោះ មិនមានចំណោទក្នុងការបើកឱ្យប្រើប្រាស់ប្រព័ន្ធជាមួយក្រសួងពាក់ព័ន្ធ និង ខេត្តក្រុងនោះទេ ។

## ១០. អភិក្រមការងារ និង ប្លង់គណនេយ្យ

### ១០.១. អភិក្រមការងារ

ការរៀបចំភ្ជាប់ប្លង់អភិក្រមការងារគឺជាលក្ខណៈស្នូល និង ជាសារវ័ន្តសម្រាប់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅខណៈដែលអភិក្រមនានាត្រូវបានបង្កើនប្រសិទ្ធភាព ហើយអាចបង្កើតជាផលប្រយោជន៍សំខាន់ៗ សម្រាប់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង រាជរដ្ឋាភិបាល ។ ផលប្រយោជន៍ទាំងនេះរួមមាន ៖

- ដំណើរការប្រតិបត្តិការហិរញ្ញវត្ថុកាន់តែឆាប់រហ័ស
- ការទូទាត់ឱ្យអ្នកផ្គត់ផ្គង់ និង ការប្រមូលចំណូលកាន់តែឆាប់រហ័ស
- ធ្វើបច្ចុប្បន្នភាព និងធ្វើឱ្យមានព័ត៌មានគ្រប់ជ្រុងជ្រោយសម្រាប់រដ្ឋាភិបាលទាំងមូល
- កំណត់អត្តសញ្ញាណនៃហានិភ័យដែលមាននៅក្នុងអភិក្រមនានា និង កាត់បន្ថយហានិភ័យ កំណត់ការទទួលខុសត្រូវរបស់មន្ត្រីឱ្យបានកាន់តែច្បាស់ និង បង្កើនមូលដ្ឋានព័ត៌មានសម្រាប់ការធ្វើសវនកម្មឱ្យកាន់តែច្រើនថែមទៀត
- បង្កកប្រភពធនធានដែលកម្រ ( គាំទ្រដោយផ្តោតលើការកសាងសមត្ថភាព ) និង បែងចែកធនធានទាំងនោះឡើងវិញទៅដល់សកម្មភាពទាំងឡាយណាដែលមានផលិតភាពជាង ។

គោលបំណងរបស់អភិក្រមការងារ គឺការទទួលបាននូវកម្មវិធីកុំព្យូទ័រដែលអាចតាមដាន និងធ្វើឱ្យដំណើរការប្រតិបត្តិការហិរញ្ញវត្ថុតាំងពីការចាប់ផ្តើមកិច្ចលទ្ធកម្ម ឬការធានាចំណាយដំបូងរហូតដល់ការបញ្ចេញសាច់ប្រាក់នៅក្នុងវដ្តនៃប្រតិបត្តិការហិរញ្ញវត្ថុទាំងមូល ។

ខណៈពេលនៃការណែនាំឱ្យប្រើប្រាស់ប្រព័ន្ធ FMIS ប្រព័ន្ធហិរញ្ញវត្ថុដោយប្រើប្រាស់កុំព្យូទ័រមានភាពទន់ភ្លន់នៅក្នុងលទ្ធភាពកសាងឱ្យលេចជារូបរាងឡើងនៃដំណើរការផ្លាស់ប្តូរ ដែលនឹងមានសារៈសំខាន់ក្នុងការនាំឱ្យមានប្រព័ន្ធនេះដំណើរការនៅក្នុងប្រទេសកម្ពុជា ។

ប្រព័ន្ធនេះ ត្រូវបានរៀបចំបង្កើតឡើងទៅតាមវិធីសាស្ត្រដែលល្អប្រសើរបំផុត និង ជំរុញឱ្យមានការពិនិត្យសារឡើងវិញលើអភិក្រមការងារ ។ ការផ្លាស់ប្តូរអភិក្រមទាំងឡាយនឹងត្រូវការការផ្លាស់ប្តូរនៅក្នុងទិដ្ឋភាពច្បាប់ដែលគ្រប់គ្រង និង មានឥទ្ធិពលលើដំណើរការប្រតិបត្តិការហិរញ្ញវត្ថុ និង សមត្ថកិច្ចក្នុងការសម្រេច ។

ប្រតិបត្តិការហិរញ្ញវត្ថុ នឹងគ្របដណ្តប់រាល់ទិដ្ឋភាពទាំងអស់របស់ហិរញ្ញវត្ថុតាំងពីការចាប់ផ្តើមកិច្ចលទ្ធកម្មរហូតដល់ការទូទាត់ដល់អ្នកផ្គត់ផ្គង់ ការកសាងថវិកា និង កិច្ចលទ្ធកម្មទំនិញ និង សេវាកម្ម ក៏ដូចជាការធ្វើរបាយការណ៍លើព័ត៌មានហិរញ្ញវត្ថុ ។

គោលបំណងនៃការពិនិត្យឡើងវិញ គឺផ្តោតលើការកសាងអភិក្រមនាពេលបច្ចុប្បន្ននេះ ដោយពិនិត្យមើលថាតើដំណើរការទាំងនោះមានភាពស្មុគ្រស្មាញដែលមិនចាំបាច់ត្រួតគ្នា និង គ្មានប្រសិទ្ធភាព និង ដែលសកម្មភាពទាំងនេះពុំមានផ្តល់ផលប្រយោជន៍អ្វីបន្ថែមទៀត ឬ មិនអាចជៀសផុតពីហានិភ័យ ខណៈដែលទំហំនៃប្រតិបត្តិការហិរញ្ញវត្ថុ និង តម្លៃនៃប្រតិបត្តិការទាំងនោះនៅមានកម្រិតទាប ជារួមមានប្រយោជន៍ស្តួចស្តើងក្នុងការផ្លាស់ប្តូរ ប៉ុន្តែនៅពេលទំហំនៃប្រតិបត្តិការរីកធំឡើង និង/ឬ ក៏តម្លៃនៃប្រតិបត្តិការទាំងនេះកើនឡើង ហើយហានិភ័យ និង ការខ្វះខ្នាយឥតប្រយោជន៍កម្រិតខ្ពស់ នាំឱ្យការរៀបចំប្លង់ និង ការវិភាគលើអភិក្រមនេះ ត្រូវអនុវត្ត និងកែលម្អឱ្យប្រសើរឡើង ។

ដូច្នេះគោលនយោបាយសម្រាប់រៀបចំប្លង់ និង ពិនិត្យឡើងវិញលើអភិក្រមការងារនឹងត្រូវអនុវត្តដូចតទៅ ៖

- រៀបចំប្លង់អភិក្រមហិរញ្ញវត្ថុចំនួន ១០ ធំជាងគេបំផុតតាមទំហំនៃប្រតិបត្តិការហិរញ្ញវត្ថុ និង ការពិនិត្យឡើងវិញដើម្បីទទួលបានប្រសិទ្ធភាពជាងមុន បញ្ហាគ្រប់គ្រងហានិភ័យ និង គំនាបផ្នែកច្បាប់ និង នយោបាយ
- រៀបចំប្លង់អភិក្រមហិរញ្ញវត្ថុចំនួន ១០ ធំជាងគេបំផុតតាមតម្លៃនៃប្រតិបត្តិការហិរញ្ញវត្ថុ និង ការពិនិត្យឡើងវិញដើម្បីទទួលបានប្រសិទ្ធភាពជាងមុន បញ្ហាគ្រប់គ្រងហានិភ័យ និង គំនាបផ្នែកច្បាប់ និង នយោបាយ
- បង្កើតអភិក្រមត្រូវធ្វើសម្រាប់អភិក្រមហិរញ្ញវត្ថុខាងលើនេះប្រមាណជា ២០ អភិក្រម និង បរិយាយពីផលប៉ះពាល់នៃការផ្លាស់ប្តូរលើការរៀបចំមន្ត្រី និង អ្នកជំនាញជាដើម

- បរិយាយពីយុទ្ធសាស្ត្រក្នុងដំណាក់កាលត្រូវការការផ្លាស់ប្តូរ ដោយភ្ជាប់ជាមួយកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង ដំណើរការអនុវត្តគម្រោង FMIS
- ពិនិត្យឡើងវិញលើមុខងាររបស់អង្គភាព និង ការទទួលខុសត្រូវដែលទទួលឥទ្ធិពលពីដំណើរការផ្លាស់ប្តូរតាមដំណាក់កាលៗ ឬ តែមួយលើក
- កំណត់អត្តសញ្ញាណនៃគំនាបទាំងឡាយដែលនាំឱ្យមានភាពខុសគ្នារវាងការផ្លាស់ប្តូរអភិក្រមដោយការកម្មវិធីកែទម្រង់ និង ការផ្លាស់ប្តូរអភិក្រមដោយកម្មវិធី FMIS និង អំពីវិធីសាស្ត្រក្នុងការដោះស្រាយភាពខុសគ្នានេះ

ជំហានទាំងនេះនឹងកំណត់អត្តសញ្ញាណនៃប្រតិបត្តិការហិរញ្ញវត្ថុសំខាន់ជាងគេ និង អនុញ្ញាតឱ្យមានការវិភាគអភិក្រមបច្ចុប្បន្ន និងការកំណត់អត្តសញ្ញាណអប្រសិទ្ធភាពហានិភ័យ និង គំលាតនៅក្នុងដំណើរការពិនិត្យតាមដាន និង ការរៀបចំរបាយការណ៍ និង ការអភិវឌ្ឍគោលការណ៍ ជម្រើសនៃការសម្រេចឱ្យបានគោលបំណងរបស់ប្រតិបត្តិការហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព មានកម្រិតហានិភ័យទាប ចំណាយធនធានតិច និង បង្កើនលទ្ធផល និង ព័ត៌មានមានភាពលម្អិត និង គ្រប់គ្រាន់ ។

នៅពេលជ្រើសរើសកម្មវិធីកុំព្យូទ័រ FMIS នៅចុងបញ្ចប់អភិក្រមដែលមានស្រាប់ ឬ ដែលត្រូវបានកែប្រែរួច អាចត្រូវប្រើប្រាស់ដោយអ្នកផ្គត់ផ្គង់ទុកជាមូលដ្ឋានក្នុងការវាយតម្លៃអំពីរបៀបក្នុងការរៀបចំកសាង និង អនុវត្តកម្មវិធីកុំព្យូទ័រ FMIS ។

ការពិនិត្យឡើងវិញលើអភិក្រមការងារគឺជាសកម្មភាពត្រូវអនុវត្តជាបន្តបន្ទាប់ ប៉ុន្តែនៅពេលដែលការពិនិត្យឡើងវិញជាចម្បង ត្រូវបានបញ្ចប់ ការផ្លាស់ប្តូរជាបន្តបន្ទាប់គួរតែមានឥទ្ធិពល និង ពង្រីកបន្ថែម ។

ដំណើរការក្នុងការរៀបចំពិនិត្យតាមដាន នឹងត្រូវធ្វើឡើងនៅតាមនាយកដ្ឋាននីមួយៗ រៀងៗខ្លួន ស្របទៅតាមគំរូដែលបានប្រគល់ជូនដោយនាយកដ្ឋានព័ត៌មានវិទ្យា ។ ការរៀបចំប្លង់អភិក្រមការងារនេះ នឹងបង្ហាញអំពីការភ្ជាប់ទំនាក់ទំនងទៅនឹងបណ្តានាយកដ្ឋាន ឬ ស្ថាប័នខាងក្រៅនានា ហើយសកម្មភាព ឬ ចំណុចនៃការសម្រេចចិត្តនីមួយៗនឹងត្រូវជួយសម្រួលដោយការបរិយាយដោយសង្ខេបពីសកម្មភាពនោះ និង ហេតុផលនៃតម្រូវការសកម្មភាពនោះ ( ឧទាហរណ៍ ស្របតាមលក្ខខណ្ឌច្បាប់ ។ល។ ) និងលក្ខខណ្ឌត្រូវបំពេញផ្សេងៗ ទៀត ( ការលើសតម្លៃដែលបានកម្រិតជាដើម ) ។

បន្ទាប់មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងសហការជាមួយជំនាញការក្នុងការវិភាគ និង ពិនិត្យមើលឡើងវិញលើប្លង់អភិក្រមការងារទាំងអស់ និង វាយតម្លៃលើចំណុចដែលអាចត្រូវកែលម្អដែលអាចមានហានិភ័យកើតឡើង និង ការកែតម្រូវ ឬ ការកែលម្អអាចសម្រេចបានជាមួយគ្នា ជាមួយនឹងការកំណត់អត្តសញ្ញាណលើការផ្លាស់ប្តូរតាមលក្ខខណ្ឌច្បាប់ ឬ រចនាសម្ព័ន្ធដែលអាចត្រូវការក្នុងការសម្រេចឱ្យបានការផ្លាស់ប្តូរដែលបានស្នើ ។

បន្ទាប់មកទៀតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នឹងកំណត់ការឯកភាពលើការកែតម្រូវ និងការជំទាស់លើការផ្លាស់ប្តូរដែលបានស្នើ និង អាចចាប់ផ្តើមការអនុវត្តការផ្លាស់ប្តូរទាំងនោះរួមទាំងការរៀបចំតាមរយៈការបណ្តុះបណ្តាល ការកែសម្រួលលក្ខខណ្ឌច្បាប់ ឯកសារការអនុវត្ត និង ការធ្វើសវនកម្មពិនិត្យមើលលើលទ្ធផលការងារ និង ការបំពេញទៅតាមតម្រូវការការងារ ។

រៀបចំចងក្រងឯកសារអភិក្រមការងារថ្មី ដែលនឹងត្រូវផ្តល់ដោយអ្នកផ្គត់ផ្គង់នៅក្នុងដំណាក់កាលចាប់ផ្តើមធ្វើការបំពេញគំលាតនៃការអនុវត្ត ដើម្បីរៀបចំអភិក្រមនេះឱ្យបន្សីុដាក់ក្នុងការរៀបចំកសាងកម្មវិធីកុំព្យូទ័រ FMIS ។ ការទទួលខុសត្រូវជាបន្តសម្រាប់ការពិនិត្យមើលឡើងវិញលើអភិក្រមការងារនឹងត្រូវប្រគល់ជូននាយកដ្ឋានសវនកម្ម ដោយនេះជាផ្នែកមួយនៃតួនាទីរបស់នាយកដ្ឋាននេះ ក្នុងការអនុវត្តមុខងារសវនកម្មជាពិសេស នៅពេលដែលកម្មវិធី កុំព្យូទ័រ FMIS ត្រូវបានដាក់ឱ្យអនុវត្ត ។

### *១០.២. ការត្រួតពិនិត្យឡើងវិញនៃប្លង់គណនេយ្យ*

ការបង្កើតគណនេយ្យគ្រប់គ្រង ការត្រួតពិនិត្យ និង ដំណើរការរៀបចំរបាយការណ៍ ត្រូវបានបង្កើតជាជំហានដ៏សមស្រប ជំហានដំបូងគឺជាសាច់ប្រាក់ បន្ទាប់មកសាច់ប្រាក់ដែលបានកែសម្រួល ឬ គណនេយ្យបង្គរដែលបានកែសម្រួល និង ជាបញ្ចប់គឺគណនេយ្យបង្គរដ៏ពេញលេញ ។ លក្ខណៈពិសេសផ្សេងទៀតរបស់គណនេយ្យគឺការកត់ត្រាដ៏ត្រឹមត្រូវ ហើយការកត់ត្រានេះ គួរយកទៅពិចារណាឱ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបានក្នុងការបង្កើតគណនេយ្យ ព្រោះថាជាសសរគោលដ៏សំខាន់ក្នុងការត្រួតពិនិត្យប្រតិបត្តិការគម្រោងថវិកា។

ប្រទេសកម្ពុជា អនុវត្តគណនេយ្យរដ្ឋាភិបាលដោយផ្អែកលើមូលដ្ឋានសាច់ប្រាក់ទោះបីជាសព្វថ្ងៃនេះប្លង់គណនេយ្យត្រូវបានរៀបចំចាត់ថែងជាគណនេយ្យបង្គរក៏ដោយ ។ ប៉ុន្តែ គណនេយ្យនៅក្នុងរដ្ឋាភិបាលគួរចាប់ផ្តើមដោយផ្អែកលើគណនេយ្យសាច់ប្រាក់ ឱ្យស្របទៅនឹងប្រព័ន្ធគណនេយ្យដែលយកសាច់ប្រាក់ជា

មូលដ្ឋាន ដោយផ្តោតទៅលើការអនុវត្តតាមស្តង់ដារគណនេយ្យសាច់ប្រាក់ក្នុងគណនេយ្យរដ្ឋបាលសាធារណៈជាអន្តរជាតិ និង ស្របគ្នាជាមួយក្បួនច្បាប់ស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល ឆ្នាំ ២០០១ របស់អង្គការរូបិយវត្ថុអន្តរជាតិ ។

ការណែនាំអំពី FMIS នឹងត្រូវបង្ហាញពីលទ្ធភាពអនុវត្តការកត់ត្រា និងរបាយការណ៍ ដែលនឹងបង្កើតចំណែកនៃគោលបំណងដាក់ឱ្យប្រើប្រាស់ FMIS ។ ប្រព័ន្ធ FMIS គួរលេចចេញជារូបរាងសម្រាប់ផ្តល់ទាំងគណនេយ្យសាច់ប្រាក់ និង បង្គរ ប៉ុន្តែត្រូវផ្អែកទៅលើគណនេយ្យសាច់ប្រាក់រហូតដល់គណនេយ្យបង្គរត្រូវបានយល់ច្បាស់ ហើយសមត្ថភាពរបស់បុគ្គលិកត្រូវបានបង្កើនតាមរយៈរដ្ឋាភិបាលបង្កើតឡើងនូវគណនេយ្យសាច់ប្រាក់ និង បង្គរ ដែលត្រូវកែសម្រួលនោះ ។

ក្នុងទ្រង់ទ្រាយខ្លះនៃគណនេយ្យបង្គរ អាចផ្តល់តាមការកំណត់ជាមុនពី FMIS យកធ្វើទៅលើមូលដ្ឋានគណនេយ្យសាច់ប្រាក់ ប៉ុន្តែមិនគួរភ័ន្តច្រឡំជាមួយគណនេយ្យបង្គរទេ ។ ចំពោះគណនេយ្យបង្គរដើម្បីកំណត់មុខងារទម្រង់របស់វាឱ្យបានសមស្រប ប្រតិបត្តិការត្រូវចាប់យកពីប្រភពដំបូងមិនមែនចុងក្រោយ នៅពេលដែលទៅដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនោះទេ ។ នេះតម្រូវឱ្យមានការព្រមព្រៀងលើផែនការគ្រប់គ្រងទ្រព្យសម្បត្តិ ការគ្រប់គ្រងកូនបំណុល និង ម្ចាស់បំណុល ពីចំណុចមួយដែលបំណុលទាំង-ឡាយកើតឡើងមិនមែននៅពេលប្រតិបត្តិការត្រូវធ្វើបង្វើយដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនោះទេ ។

ភាពខុសគ្នានៃពេលវេលាសម្រាប់កត់ត្រាប្រតិបត្តិការ គឺជាភាពខុសគ្នាដ៏សំខាន់រវាងការបង្ហាញឱ្យឃើញពីគណនេយ្យបង្គរ និង ភាពជាក់ស្តែងរបស់វា ។

ទំនាក់ទំនងដោយផ្ទាល់ជាមួយនឹងមូលដ្ឋានគណនេយ្យគឺរចនាសម្ព័ន្ធនៃប្លង់គណនេយ្យ។ រចនា-សម្ព័ន្ធដែលបានប្រើនៅក្នុងរដ្ឋាភិបាល ( រតនាគារជាតិ ) ជាការកែប្រែដែលបានបង្កើតដោយទីប្រឹក្សាររបស់បារាំង និង សមស្របសម្រាប់បច្ចុប្បន្ន និងគោលបំណងប្រតិបត្តិការដោយដៃដ៏ធំធេង ។ យ៉ាងណាមិញវាមិនសមស្របក្នុងទម្រង់បច្ចុប្បន្នសម្រាប់ប្រើប្រាស់នៅក្នុងទ្រង់ទ្រាយដ៏ទំនើបនៃ FMIS ដែលផ្តល់នូវមុខងារជាច្រើន។ ជាផលវិបាក ក្នុងពេលស្របគ្នាជាមួយដំណើរការអភិវឌ្ឍគណនេយ្យ ប្លង់គណនេយ្យបច្ចុប្បន្ន ត្រូវធ្វើការកែប្រែជាថ្មី និង កែទម្រង់ឡើងវិញ ឬ ពង្រីកបន្ថែម ដើម្បីទទួលផលប្រយោជន៍ពីសមត្ថភាពរបស់កម្មវិធីកុំព្យូទ័រ FMIS ។

ហេតុនេះហើយចំពោះគណនេយ្យ ទិសដៅគោលនយោបាយនឹងរៀបចំបង្កើតប្លង់គណនេយ្យមួយឱ្យត្រូវនឹង FMIS ហើយដែលមានរចនាសម្ព័ន្ធ និង ទម្រង់ផ្តោតលើគោលបំណងពីរ ៖

១. ផ្តល់មូលដ្ឋានសម្រាប់កត់ត្រាប្រតិបត្តិការក្នុងទម្រង់ដ៏សមស្របក្នុងដែនកំណត់របស់ FMIS ដោយបានផ្អែកទាំងស្រុងលើប្លង់គណនេយ្យបច្ចុប្បន្ន ប៉ុន្តែដែលបានកែទម្រង់ និង ពង្រីកបន្ថែមហើយ ។

២. ផ្អែកដំបូងលើការអនុវត្តតាមក្បួនច្បាប់គណនេយ្យសាច់ប្រាក់នៃគណនេយ្យរដ្ឋបាលសាធារណៈជា អន្តរជាតិ និង ការរៀបចំរបាយការណ៍តាមឯកសារណែនាំអំពីស្ថិតិហិរញ្ញវត្ថុរបស់រដ្ឋាភិបាល ឆ្នាំ ២០០១ ។

ពឹងផ្អែកលើរចនាសម្ព័ន្ធគម្រោងចុងក្រោយសម្រាប់ការអនុវត្ត FMIS ( អាចអនុវត្តបានលុះត្រាតែផលិតផល និង ដៃគូប្រតិបត្តិត្រូវបានជ្រើសរើស ) ធ្វើការដាក់បង្ហាញគណនេយ្យសាច់ប្រាក់ និង បង្គរដែលកែសម្រួល មុនពេលបង្កើតគណនេយ្យបង្គរពេញលេញ ។

ដើម្បីសម្រេចក្របខ័ណ្ឌគោលនយោបាយ ដំណាក់កាលអភិវឌ្ឍន៍ឱ្យស្របជាមួយគម្រោង FMIS ទាមទារឱ្យរាជរដ្ឋាភិបាល ៖

- កំណត់ដំណើរការគណនេយ្យ និង របាយការណ៍បច្ចុប្បន្ន សម្រាប់ការផ្តល់របាយការណ៍ខាងក្នុង និងទៅក្រៅក្នុងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋសភា និង ក្រសួង-ស្ថាប័ន និង ខេត្ត-ក្រុង ព្រមទាំងអ្នកប្រើប្រាស់ដទៃទៀត ។
- កំណត់បញ្ហាប្លង់គណនេយ្យ ( ច្បាប់ នយោបាយ និងហិរញ្ញវត្ថុ ) ដែលអាចកើតឡើងពីដំណើរការកំណែទម្រង់ និង FMIS ។
- បរិយាយពីដំណើរដែលមានការផ្លាស់ប្តូរតាមដំណាក់កាលនីមួយៗ រហូតដល់គណនីបង្គរនិងការរៀបចំរបាយការណ៍ដែលអាចសម្រេចបាន និង តាមពេលវេលាកំណត់ ។
- កំណត់ផែនការកសាងសមត្ថភាព និង ការរៀបចំមន្ត្រីពាក់ព័ន្ធសម្រាប់ការផ្លាស់ប្តូរទៅរបបគណនេយ្យដែលកាន់តែស្មុគស្មាញ ។

- កំណត់អត្តសញ្ញាណនៃការផ្លាស់ប្តូរ និង ភាពទន់ខ្សោយនៅក្នុងការទទួលខុសត្រូវនៃការគ្រប់គ្រងហិរញ្ញវត្ថុនាពេលបច្ចុប្បន្នដែលនឹងត្រូវលើកយកមកដោះស្រាយនៅក្នុងដំណាក់កាលអន្តរកាល ។
- ខណៈដែលគម្រោង FMIS កំពុងអនុវត្ត និង ដាក់ឱ្យប្រើប្រាស់ការអនុវត្តគណនីធានាចំណាយ

ការកត់ត្រាសាច់ប្រាក់ធានាចំណាយមានលក្ខណៈឯករាជ្យ ទោះជារដ្ឋាភិបាលសម្រេចប្រើជាសាច់ប្រាក់ ឬ តាមគណនេយ្យបង្គរកែសម្រួល ឬ ពេញលេញក៏ដោយចុះ ។ ការកត់ត្រាសាច់ប្រាក់ធានាចំណាយទ្រទ្រង់ជាពិសេសដោយប្រព័ន្ធ FMIS ដែលក្នុងនោះទិន្នន័យនៃប្រតិបត្តិការត្រូវបានកត់ត្រាធានាចំណាយទុកភ្លាមៗតាមដែលអាចអនុវត្តនៅដើមដំបូងនៃវដ្តប្រតិបត្តិការ ដូចជា លទ្ធកម្មគួរកត់ត្រាទុកសាច់ប្រាក់ធានាចំណាយនៅខណៈពេលប្រគល់កិច្ចសន្យា ដើម្បីប្រយោជន៍ថា ថវិកាដែលត្រូវការត្រូវបានពិនិត្យមើលរួចរាល់ និង បម្រុងទុក ។ ការអភិវឌ្ឍទៅកាន់ប្រព័ន្ធ FMIS នឹងត្រូវផ្តល់ចំណុចចាប់ផ្តើមប្រតិបត្តិការដំបូងបំផុតដែលជាផលប្រយោជន៍ដ៏ធំធេង សម្រាប់រដ្ឋាភិបាលនៅក្នុងការគ្រប់គ្រងថវិកា ពិនិត្យតាមដាន និងធ្វើរបាយ-ការណ៍ថវិកា ។

## ១១. ហានិភ័យ និង ការកាត់បន្ថយ

ប្រព័ន្ធ FMIS នឹងជួបប្រទះហានិភ័យខ្លះ ។ ប៉ុន្តែ ហានិភ័យចម្បងទាំងឡាយអាចត្រូវបានបង្រួញឱ្យនៅតែពីរប្រភេទគឺអ្នកប្រើប្រាស់ និង អ្នកផ្គត់ផ្គង់ ។ ចំពោះអ្នកប្រើប្រាស់ ហានិភ័យគឺកង្វះខាតនូវកិច្ចសហប្រតិបត្តិការរបស់នាយកដ្ឋាន និង ក្រសួង-ស្ថាប័ន កង្វះខាតធនធានមនុស្ស បុគ្គលិក និង អ្នកប្រើប្រាស់មានសមត្ថភាពទាប ។ ហានិភ័យទាំងនេះត្រូវបានពិចារណា និង កាត់បន្ថយយ៉ាងម៉ឺងមាត់ ដោយការបង្កើតក្រុមការងារ FMIS ក្នុងនាយកដ្ឋានពាក់ព័ន្ធក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្នុងក្រសួង-ស្ថាប័នដទៃទៀត ។ បុគ្គលិកនៅក្នុងនាយកដ្ឋានព័ត៌មានវិទ្យា និង បុគ្គលិកនៅក្នុងក្រុម FMIS នឹងត្រូវបានបណ្តុះបណ្តាលតាមរយៈគម្រោងបង្កើនសមត្ថភាពផ្សេងៗជាច្រើន ។

ចំពោះផ្នែកអ្នកផ្គត់ផ្គង់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអាចប្រឈមនឹងហានិភ័យច្រើននៅក្នុងពេលអនាគត។ ដើម្បីកាត់បន្ថយហានិភ័យនេះ ឯកសារដេញថ្លៃត្រូវបានរៀបចំដោយបញ្ចូលរាល់តម្រូវការដើម្បីធ្វើឱ្យមានភាពប្រាកដថា អ្នកផ្គត់ផ្គង់នឹងគោរពតាមវិធានកំណត់ និងការរំពឹងទុក ។

## ១២. ផែនការសហប្រតិបត្តិការផ្ទៃក្នុង និង ផ្ទៃក្រៅ

ក្នុងបរិការនៃការអនុវត្តគម្រោង FMIS ការភ័ន្តច្រឡំយ៉ាងធ្ងន់ធ្ងរកើតមាន ដោយយល់ថាការងារនេះជាការងាររបស់នាយកដ្ឋានព័ត៌មានវិទ្យា ហើយនាយកដ្ឋានព័ត៌មានវិទ្យាត្រូវបំពេញកិច្ចការគ្រប់បែបយ៉ាងដើម្បីបង្កើតប្រព័ន្ធ FMIS ដ៏ល្អបំផុតមួយដល់រដ្ឋាភិបាល ។

តាមពិតទៅ FMIS ជាការងាររបស់នាយកដ្ឋានទាំងអស់ ។ នាយកដ្ឋានព័ត៌មានវិទ្យា គ្រាន់តែជាអ្នកជួយគាំទ្រក្នុងផ្នែកព័ត៌មានវិទ្យាតែប៉ុណ្ណោះ ។ តួអង្គសំខាន់គឺនាយកដ្ឋាន ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងរតនាគារខេត្ត ដែលជាម្ចាស់នៃប្រព័ន្ធ FMIS និង បរិយាកាសជុំវិញប្រព័ន្ធ ។ មានតែតួអង្គសំខាន់ទាំងនោះទេ ដែលដឹងច្បាស់ពីអ្វីដែលពួកគេរំពឹងចង់បានពីប្រព័ន្ធ របៀបប្រើប្រាស់ប្រព័ន្ធ ដើម្បីលុបបំបាត់ការលំបាកក្នុងការងារដែលធ្វើដោយដៃជាប្រចាំ អ្វីដែលប្រព័ន្ធគួរមាន និង បន្តមាន ដើម្បីជួយដល់ពួកគេក្នុងការបំពេញរាល់ប្រតិបត្តិការហិរញ្ញវត្ថុតាមមធ្យោបាយដែលមានតម្លាភាព និង ប្រសិទ្ធភាពបំផុត ។

## ១៣. ការផ្សព្វផ្សាយព័ត៌មាន

ព័ត៌មាននឹងត្រូវបោះផ្សាយតាមរយៈព្រឹត្តិបត្រព័ត៌មានជាប្រចាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយនិងគេហទំព័ររបស់ក្រសួង ( www.mef.gov.kh ) ។ ព័ត៌មាននឹងត្រូវធ្វើបច្ចុប្បន្នភាពជាប្រចាំជាពិសេសផ្នែកគម្រោង FMIS (http://fmis.mef.gov.kh ឬ www.mef.gov.kh/fmis) ។ អ្នកចូលទៅកាន់គេហទំព័រអាចរកបានព័ត៌មានជាច្រើនដែលទាក់ទងនឹង FMIS ព័ត៌មានបច្ចេកវិទ្យាព័ត៌មានវិទ្យា និង ព័ត៌មានសេដ្ឋកិច្ច ។

# ឧបសម្ព័ន្ធទី ៦

# តម្រូវការធនធានដើម្បីគាំទ្រកម្មវិធីកំណែទម្រង់ដំណាក់កាលទី២

ខាងក្រោមនេះ គឺការប៉ាន់ប្រមាណចំណាយរួម និង ប្រភេទចំណាយនីមួយៗ ដោយផ្អែកលើតម្រូវការនានាតាមនាយកដ្ឋាន អង្គភាព ស្ថាប័ ។ ថវិកានឹងត្រូវផ្សារភ្ជាប់ ជាមួយនឹងសកម្មភាពលម្អិតកំណត់នៅក្នុងផែនការសកម្មភាពនាយកដ្ឋាន ។

ធនធានសម្រាប់គាំទ្រកម្មវិធីកំណែទម្រង់ដំណាក់កាលទី២

| ធនធានសម្រាប់ដំណាក់កាលទី២ ( ឯកតាចំណាយគិតជាដុល្លារសហរដ្ឋអាមេរិក ) | សរុប | គោលដៅ | | | កំណត់សំគាល់ |
|---|---|---|---|---|---|
| | | ២០០៨ | ២០០៩ | ២០១០ | |
| ១-ការពង្រឹងលេខាធិការដ្ឋាន និងការសម្របសម្រួល | ៨០៦.៤០០ | ២៤៦.៤០០ | ២៨០.០០០ | ២៨០.០០០ | ដើម្បីពង្រឹងការងារស្នូលរបស់ខ្លួន រចនាសម្ព័ន្ធ លេខាធិការដ្ឋាន ត្រូវបានពង្រីក និងធ្វើការកែសម្រួល |

២-ជំនួយបច្ចេកទេស

| វិស័យបច្ចេកទេស | ធនធានសម្រាប់ដំណាក់កាលទី២ | | | | | ឆ្នាំ | | | |
|---|---|---|---|---|---|---|---|---|---|
| | | ទីប្រឹក្សាស្នូល | ជំនាញការបច្ចេកទេស | ជំនួយការបច្ចេកទេសរួម | សរុប | **២០០៨** | **២០០៩** | **២០១០** | |
| ទីប្រឹក្សាម៉ាក្រូហិរញ្ញវត្ថុនិងគាំទ្រការអនុវត្ត | ថ្ងៃ | ៨០ | ៣០ | | | | | | ផ្តោតការយកចិត្តទុកដាក់ទៅលើការកែលម្អនូវក្របខ័ណ្ឌហិរញ្ញវត្ថុនិងការព្យាករណ៍ដែលពាក់ព័ន្ធ ។ អាចមានតម្រូវការអ្នក |
| | ថ្លៃឯកតា | ១.២០០ | ១.២០០ | | | | | | |
| | ថវិកា | ៩៦.០០០ | ៣៦.០០០ | | ១៣២.០០០ | ៦០.០០០ | ៣៦.០០០ | ៣៦.០០០ | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | ជំនាញបច្ចេកទេស<br>បន្ថែមទៀតដើម្បីធ្វើឱ្យ<br>ល្អប្រសើរឡើងនូវ<br>ប្រព័ន្ធព្យាករណ៍ ។ |
| ទីប្រឹក្សាគោលនយោបាយចំណូល និង គាំទ្រការអនុវត្ត | ថ្ងៃ | ៨០ | ២០០ | | | | | | កែលម្អផ្នែកវិភាគ<br>បន្ថែមទៀតដើម្បីធ្វើឱ្យ<br>គោលនយោបាយ<br>ចំណូល និងការវិភាគ<br>ជម្រើសគោល<br>នយោបាយកាន់តែមាន<br>ភាពស៊ីជម្រៅ |
| | ថ្ងៃឯកតា | ១.២០០ | ១.២០០ | | | | | | |
| | ថវិកា | ៩៦.០០០ | ២៤០.០០០ | | ៣៣៦.០០០ | ១៣២.០០០ | ១៣២.០០០ | ៧២.០០០ | |
| ទីប្រឹក្សាសម្រាប់រៀបចំថវិកា និងគាំទ្រការអនុវត្ត | ថ្ងៃ | ១៥០ | ៨០ | ២០០ | | | | | ការងារទីប្រឹក្សាស្នូល<br>នឹងត្រូវបំពេញឱ្យស្មើរ<br>តែទាំងអស់សម្រាប់<br>នាយកដ្ឋានថវិកា<br>ផ្ទាល់។ ទន្ទឹមនឹងនេះក៏<br>ត្រូវគាំទ្រក្រសួងស្ថាប័ន<br>ដើម្បីឆ្លើយតបឱ្យកាន់ |
| | ថ្ងៃឯកតា | ១.២០០ | ១.២០០ | ១.២០០ | | | | | |
| | ថវិកា | ១៨០.០០០ | ៩៦.០០០ | ២៤០.០០០ | ៥១៦.០០០ | ១៦០.០០០ | ២៥០.០០០ | ១០៦.០០០ | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | តែស៊ីជម្រៅនៅក្នុងការអនុវត្តសាកល្បងថវិកាតាមកម្មវិធី ។ ទាមទារជំនាញការបច្ចេកទេសមួយចំនួនទាក់ទងទៅនឹងការរៀបចំអង្គភាពថវិកា ការបែងចែកមុខងារ និងកម្មវិធី និងការរៀបចំការងារនីតិកម្មទាក់ទងទៅនឹងសមាហារណកម្ម នៃសកម្មភាពដែលអស់ថវិកា។ |
| ទីប្រឹក្សាការប្រតិបត្តិ និងគ្រប់គ្រងថវិកា និងគាំទ្រការអនុវត្ត | ថ្ងៃ | ១៨០ | ៨០ | ៣០០ | | | | | |
| | ថ្លៃឯកតា | ១.២០០ | ១.២០០ | ១.២០០ | | | | | |
| | ថវិកា | ២១៦.០០០ | ៩៦.០០០ | ៣៦០.០០០ | ៦៧២.០០០ | ២៣០.០០០ | ២៦០.០០០ | ១៨២.០០០ | |
| ទីប្រឹក្សាផ្នែកគណនេយ្យ និងការធ្វើ | ថ្ងៃ | ២៥០ | ២៨០ | ១០០ | | | | | សេវាបច្ចេកទេសរបស់ជំនាញការ រួមមាន ៖ |
| | ថ្លៃឯកតា | ១.២០០ | ១.២០០ | ១.២០០ | | | | | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| របាយការណ៍ និងគាំទ្រការអនុវត្ត (រួមទាំង FMIS និង ICT) | ថវិកា | ៣០០.០០០ | ៣៣៦.០០០ | ១២០.០០០ | ៧៥៦.០០០ | ២៥០.០០០ | ៣៥០.០០០ | ១៥៦.០០០ | • ដំណើរការបំពេញមុខងារ/ ការងារ<br>• ផ្លាស់ប្ដូរការគ្រប់គ្រង<br>• ការគ្រប់គ្រង ICT |
| ទីប្រឹក្សាសវនកម្ម និងគាំទ្រការអនុវត្ត | ថ្ងៃ | ៣០០ | ៣០ | ១០០ | | | | | តម្រូវការទីប្រឹក្សាស្នូលម្នាក់បំពេញការងារពេញម៉ោងក្នុងរយៈពេលមួយ ឆ្នាំ និងបន្ទាប់មកត្រូវបំពេញការងារតាមរយៈពេលមួយកំណត់។ ទីប្រឹក្សាស្នូលក៏ជួយគាំទ្រការអនុវត្តរបស់ក្រសួង-ស្ថាប័នដើម្បីបង្កើនសមត្ថភាពតាមក្រសួងស្ថាប័ន។ |
| | ថ្លៃឯកតា | ១.២០០ | ១.២០០ | ១.២០០ | | | | | |
| | ថវិកា | ៣២០.០០០ | ៣៦.០០០ | ១២០.០០០ | ៤៧៦.០០០ | ១១០.០០០ | ២០០.០០០ | ១៦៦.០០០ | |
| ប្រឹក្សាផ្នែកការបណ្ដុះបណ្ដាល និងគាំទ្រការ | ថ្ងៃ | ១៨០ | ៦០ | ៣០០ | | | | | ទាមទារទីប្រឹក្សាស្នូលដែលផ្ដល់ដោយវិទ្យា |
| | ថ្លៃឯកតា | ១.២០០ | ១.២០០ | ១.២០០ | | | | | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| អនុវត្ត | ថវិកា | ២១៦.០០០ | ៧២.០០០ | ៣៦០.០០០ | ៦៤៨.០០០ | ១២០.០០០ | ៣០០.០០០ | ២២៨.០០០ | ស្ថានបណ្តុះបណ្តាលដែលទទួលស្គាល់អន្តរជាតិ ( បច្ចុប្បន្នកំពុងស្ថិតក្រោមការពិភាក្សា)។ ទីប្រឹក្សារូបនេះក៏ត្រូវជួយការងារ បណ្តុះបណ្តាលដល់ ក្រសួង-ស្ថាប័នផងដែរ ។ |
| ការអភិវឌ្ឍធនធានមនុស្ស | ថ្ងៃ | ១៨០ | ២០ | ២០០ | | | | | រួមមានការអភិវឌ្ឍនិងការអនុវត្តនូវយុទ្ធ-សាស្ត្រទំនាក់ទំនង |
| | ថ្លៃឯកតា | ១.២០០ | ១.២០០ | ១.២០០ | | | | | |
| | ថវិកា | ២១៦.០០០ | ២៤.០០០ | ២៤០.០០០ | ៤៨០.០០០ | ១៦០.០០០ | ២២០.០០០ | ១០០.០០០ | |
| បុគ្គលិកគាំទ្រគម្រោង FMIS | ខែ | | ៣៦០ | | | | | | បុគ្គលិកក្នុងស្រុកពី ១០ ទៅ ១៥ នាក់ ត្រូវបានបណ្តុះបណ្តាលដើម្បីអនុវត្តកម្មវិធី FMIS នៅ ក្រសួង |
| | ថ្លៃឯកតា | | ៥០០ | | | | | | |
| | ថវិកា | | ១៨០.០០០ | | ១៨០.០០០ | ៣០.០០០ | ៩០.០០០ | ៦០.០០០ | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រតនាគារជាតិ និងខេត្ត ក្រុង និង តាមក្រសួង-ស្ថាប័ន ។ |
| សរុប | | | | | ៤.១៩៦.០០០ | ១.២៥២.០០០ | ១.៨៣៨.០០០ | ១.១០៦.០០០ | |
| **៣-ការបណ្តុះបណ្តាល** | | | | | | | | | |
| ការបណ្តុះបណ្តាលក្នុងស្រុក | | | | | | | | | |
| ចំនួនវគ្គបណ្តុះបណ្តាល | | | | ៨០ | | | | | មានចំនួន ៣០ វគ្គក្នុង មួយឆ្នាំ ស្របតាម CDP |
| ថ្លៃឯកតា | | | | ៥.០០០ | | | | | |
| ថវិកា | | | | | ៤៥០.០០០ | ១៥០.០០០ | ១៥០.០០០ | ១៥០.០០០ | |
| | | | | | | | | | |
| ការបណ្តុះបណ្តាលក្រៅស្រុក | | | | | | | | | |
| ចំនួនវគ្គបណ្តុះបណ្តាល | | | | ៦០ | | | | | មានចំនួន ២០ វគ្គ ក្នុង មួយឆ្នាំ ស្របតាម CDP |
| ថ្លៃឯកតា | | | | ១២.០០០ | | | | | |
| ថវិកា | | | | | ៧២០.០០០ | ២៤០.០០០ | ២៤០.០០០ | ២៤០.០០០ | |
| | | | | | | | | | |
| ការបណ្តុះបណ្តាលរយៈពេលវែងនៅក្រៅប្រទេស | | | | | | | | | |
| ចំនួនបេក្ខជន | | | | ២០ | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ថ្លៃឯកតា | ១០០.០០០ | | | | | |
| ថវិកា | | ២.០០០.០០០ | ៦០០.០០០ | ៨០០.០០០ | ៦០០.០០០ | |
| សរុប | | ៣.១៧០.០០០ | ៩៩០.០០០ | ១.១៩០.០០ | ៩៩០.០០០ | |
| **៤-ការគ្រប់គ្រងហិរញ្ញវត្ថុតាមប្រព័ន្ធពត៏មានវិទ្យា** | | | | | | |
| ការរៀបចំ និងការអនុវត្តគម្រោង FMIS និងសម្ភារៈកុំព្យូទ័រ | | ១០.៤០០.០០០ | | | | ព័ត៏មានលម្អិតអំពី ការចំណាយ FMIS មានដូចខាងក្រោម |
| ដំណើរការចាប់ផ្តើមអនុវត្តគម្រោង | ១.១៣០.០០០ | | ១១៣.០០០ | ១.០១៧.០០០ | | |
| ដំណើរការលទ្ធកម្ម | ២២០.០០០ | | ១១០.០០០ | ១១០.០០០ | | |
| ការអនុវត្តនៅក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងសម្ភារៈកុំព្យូទ័រ | ៣.៤៥០.០០០ | | ៣៤៥.០០០ | ៣.១០៥.០០០ | | |
| ការសាកល្បងជំហានដំបូង និងសម្ភារៈកុំព្យូទ័រ | ១.៦៥០.០០០ | | | ៩៩០.០០០ | ៦៦០.០០០ | |
| ការសាកល្បងជំហានបន្ទាប់ និងសម្ភារៈកុំព្យូទ័រ | ៣.០៥០.០០០ | | | | ៣.០៥០.០០០ | |
| ការគ្រប់គ្រងគម្រោង | ១២០.០០០ | | ៤០.០០០ | ៤០.០០០ | ៤០.០០០ | |
| ចំណាយត្រៀមបំរុង | ៧៨០.០០០ | | ២៦០.០០០ | ២៦០.០០០ | ២៦០.០០០ | |
| ការរៀបចំផ្នែកផ្សេងៗទៀតក្នុងការគ្រប់គ្រងហិរញ្ញវត្ថុតាមប្រព័ន្ធកំព្យូទ័រ នៅក្នុងរយៈ-ពេលមួយ | | ១៥០.០០០ | ១៥.០០០ | ១៣៥.០០០ | | |
| សរុប | | ១០.៥៥០.០០ | ៨៨៣.០០០ | ៥.៦៥៧.០០០ | ៤.០១០.០០០ | |

| | | | | | | |
|---|---|---|---|---|---|---|
| **៥-សិក្ខាសាលា** | | | | | | |
| ចំនួនសិក្ខាសាលា | ៣០ | | | | | |
| ថ្លៃមធ្យម | ៥.០០០ | | | | | |
| សរុប | | ១៥០.០០០ | ៥០.០០០ | ៥០.០០០ | ៥០.០០០ | |
| | | | | | | |
| **៦- ការប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ** | | | | | | |
| ចំនួនសិក្ខាសាលា | ៣ | | | | | |
| ថ្លៃមធ្យម | ៣៥.០០០ | | | | | |
| សរុប | | ១០៥.០០០ | ៣៥.០០០ | ៣៥.០០០ | ៣៥.០០០ | |
| **៧- ឧបករណ៍ និងសម្ភារៈកុំព្យូទ័រ** | | | | | | |
| សម្ភារៈកុំព្យូទ័រសម្រាប់ការអនុវត្តគម្រោង FMIS | | | | | | ត្រូវបានបញ្ចូលនៅក្នុងការគណនាចំណាយគម្រោង FMISខាងលើ |
| សម្ភារៈកុំព្យូទ័រសម្រាប់ការិយាល័យអង្គភាពថវិការបស់ក្រសួង-ស្ថាប័ន | | ១០០.០០០ | | ៨០.០០០ | ២០.០០០ | |
| សម្ភារៈកុំព្យូទ័របន្ថែមសម្រាប់លេខាធិការដ្ឋាន | | ១៥.០០០ | | ១២.០០០ | ៣.០០០ | កន្លែងធ្វើការចំនួន ៥ មួយការិយាល័យត្រូវការថវិកា $ ៣.០០០ |
| សម្ភារៈ និងឧបករណ៍កំព្យូទ័រសម្រាប់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | | ១.៥០០.០០០ | ៩០០.០០០ | ៥០០.០០០ | ១០០.០០០ | |

| | | | | | | |
|---|---|---|---|---|---|---|
| យានយន្តបន្ថែម (ទំនាក់ទំនងតាមខេត្ត......) | | ១៨០.០០០ | ៧២.០០០ | ១០៨.០០០ | | តម្រូវការយានយន្ត ចំនួន ៥ គ្រឿង ( យានយន្ត ចំនួន ៣ គ្រឿង ប្រើប្រាស់រួមនៅលេខាធិការដ្ឋានដឹកនាំការងារកែទម្រង់ ) |
| សរុប | | ១.៧៩៥.០០០ | ៩៧២.០០០ | ៧០០.០០០ | ១២៣.០០០ | |
| **៨- ទំនាក់ទំនង និងផ្សព្វផ្សាយ** | | | | | | |
| ដំណើរការរៀបចំមុនពេលបោះពុម្ព | | ៥.០០០ | ១.០០០ | ២.០០០ | ២.០០០ | បោះពុម្ពផ្សព្វផ្សាយនូវព័ត៌មានជាប្រចាំ រួមទាំង ពង្រីកការផ្សព្វ-ផ្សាយ តាមគេហទំព័រ ឬ តាមរយៈ មធ្យោ-បាយផ្សេងៗ។ |
| ដំណើរការបោះពុម្ពផ្សាយ | | ៣០.០០០ | ៨.០០០ | ១១.០០០ | ១១.០០០ | |
| សរុប | | ៣៥.០០០ | ៩.០០០ | ១៣.០០០ | ១៣.០០០ | |
| **៩- ទស្សនកិច្ចសិក្សា** | | | | | | |
| ចំនួនទស្សនកិច្ចសិក្សា | ១២ | | | | | តាមរយៈបទពិសោធន៍អនុវត្តនៅដំណាក់កាលទី១បង្ហាញថាទស្សន |
| ថ្លៃឯកតា | ៣០.០០០ | | | | | |
| សរុប | | ៣៦០.០០០ | ១២០.០០០ | ១២០.០០០ | ១២០.០០០ | |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | | | កិច្ចសិក្សាគួរកម្រិតអ្នកចូលរួម ប៉ុន្តែតែត្រូវពង្រីកវិសាលភាពធំជាងមុន។ |
| **១០-ការផ្តល់ប្រាក់លាភការលើកទឹកចិត្តផ្អែកលើលទ្ធផលការងារ *(MBPI)*** | | | | | | |
| ការបន្តផ្តល់ប្រាក់លាភការលើកទឹកចិត្តផ្អែកលើលទ្ធផលការងារ *(MBPI)* សម្រាប់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | | | | | | |
| ចំនួនមន្ត្រី | ៥០០ | | | | | គោលដៅនឹងបង្កើនដល់ ៥០០ នាក់ ( បច្ចុប្បន្នមានចំនួនទាបជាងនេះ ) |
| ថ្លៃឯកតា (ខែ) | ២៧៥ | | | | | |
| ចំនួនខែ | ៣៦ | | | | | |
| | | ៤.៩៥០.០០០ | ១.៦៥០.០០០ | ១.៦៥០.០០០ | ១.៦៥០.០០០ | |
| ការផ្តល់ប្រាក់លាភការលើកទឹកចិត្តផ្អែកលើលទ្ធផលការងារដល់ក្រសួង-ស្ថាប័ន | | | | | | មន្ត្រីដែលនឹងទទួលបាន MBPI មានចំនួន ៥ ទៅ ១០នាក់ សម្រាប់ក្រសួង-ស្ថាប័ន ដែលពាក់ព័ន្ធ។ |
| ចំនួនមន្ត្រី | ១០០ | | | | | |
| ថ្លៃឯកតា (ខែ) | ២៧៥ | | | | | |
| ចំនួនខែ | ៣០ | | | | | |
| | | ៨២៥.០០០ | ១៦៥.០០០ | ៣៣០.០០០ | ៣៣០.០០០ | |
| សរុប | | ៥.៧៧៥.០០០ | ១.៨១៥.០០០ | ១.៩៨០.០០០ | ១.៩៨០.០០០ | |

| | | | | | | |
|---|---|---|---|---|---|---|
| ដកចេញថវិកាបដិភាគរបស់រាជរដ្ឋាភិបាល | | (៨៦៦.០០០) | (២៧២.០០០) | (២៩៧.០០០) | (២៩៧.០០០) | បច្ចុប្បន្នថវិកាបដិភាគរបស់រាជរដ្ឋាភិបាលមានអត្រា ១០%។ អត្រានេះកើនឡើង ៥% ក្នុងមួយឆ្នាំ។ |
| សរុប | | ៤.៩០៩.០០០ | ១.៥៤៣.០០០ | ១.៦៨៣.០០០ | ១.៦៨៣.០០០ | |
| សរុបថវិកាសម្រាប់ជំហានទី២ | | **២៦.០៧៦.៤០០** | **៦.១០០.៤០០** | **១១.៥៦៦.០០០** | **៨.៤១០.០០០** | |

| តារាងសង្ខេប | **សរុប** | **២០០៨** | **២០០៩** | **២០១០** | |
|---|---|---|---|---|---|
| ១- ឧបករណ៍ និងសម្ភារៈកុំព្យូទ័រ | ១២.២៦០.០០០ | ១.៨២៤.០០០ | ៦.៣៣០.០០០ | ៤.១០៦.០០០ | |
| ២- សេវាកម្មទីប្រឹក្សា | ៤.៤២១.៦០០ | ១.៣០៤.៨០០ | ១.៩២៤.៤០០ | ១.១៩២.៤០០ | |
| ៣- បណ្តុះបណ្តាល/សិក្ខាសាលា/ទស្សនកិច្ចសិក្សាក្រៅប្រទេស | ៣.៧៨៥.០០០ | ១.១៩៥.០០០ | ១.៣៩៥.០០០ | ១.១៩៥.០០០ | |
| ៤- ចំណាយប្រតិបត្តការ | ២៤០.០០០ | ៨០.០០០ | ៨០.០០០ | ៨០.០០០ | |
| ៥- ការផ្តល់ប្រាក់លាភការលើកទឹកចិត្តផ្អែកលើលទ្ធផលការងារ | ៥.៣៦៩.៨០០ | ១.៦៩៦.៦០០ | ១.៨៣៦.៦០០ | ១.៨៣៦.៦០០ | |
| | **២៦.០៧៦.៤០០** | **៦.១០០.៤០០** | **១១.៥៦៦.០០០** | **៨.៤១០.០០០** | |

# ឧបសម្ព័ន្ធទី ៧

# យន្តការត្រួតពិនិត្យតាមដាន

ក្នុងការអនុវត្តកម្មវិធីកែទម្រង់ជំហានទី២/ដំណាក់កាលទី២ នេះ រាជរដ្ឋាភិបាលកម្ពុជានឹងបន្តធ្វើការត្រួតពិនិត្យតាមដានជាប្រចាំនូវវឌ្ឍនភាព ដោយធ្វើការផ្ទៀងផ្ទាត់ទៅនឹងបណ្តាសូចនាករដែលបានកំណត់ ។ ប៉ុន្តែសកម្មភាពការងារនៅក្នុងជំហានទី ២ នេះ មានលក្ខណៈខុសប្លែកគ្នាពីជំហានទី ១ ដោយសារថាវឌ្ឍនភាពនៃផ្នែកគន្លឹះៗ នៅក្នុងជំហានទី ១ អាចគណនាជាបរិមាណបានដោយផ្ទាល់ និងមានភាពងាយស្រួលក្នុងការវាស់វែង ។ ចំណែកនៅក្នុងជំហានទី២ នេះ ការវាស់វែងវឌ្ឍនភាពតម្រូវឱ្យមានវិធីសាស្ត្រខុសពីជំហានទី ១ ។

ការត្រួតពិនិត្យតាមដានត្រូវបានចែកចេញជា ៣ កម្រិត ៖

កម្រិតទី១ ៖

គ្រប់នាយកដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ និង គ្រប់ក្រសួង-ស្ថាប័នទាំងអស់ ត្រូវមានផែនការសកម្មភាពលម្អិតរបស់ខ្លួន ដើម្បីសម្រេចបានលទ្ធផល និង គោលដៅ ដូចដែលបានកំណត់នៅក្នុងផែនការសកម្មភាពរួមនៅក្នុងឧបសម្ព័ន្ធទី ១ ទៅតាមឆ្នាំនីមួយៗ ។ លទ្ធផល និង គោលដៅដែលបង្ហាញនៅក្នុងផែនការសកម្មភាពរួម ( ឧបសម្ព័ន្ធទី១ ) បានកំណត់ពីនាយកដ្ឋាន អង្គភាព និង ក្រសួង-ស្ថាប័នដែលត្រូវដឹកនាំ និងចូលរួមអនុវត្ត ដើម្បីសម្រេចបាននូវលទ្ធផលដែលបានគ្រោងទុក ។ នាយកដ្ឋាន អង្គភាព និងក្រសួង-ស្ថាប័ន ត្រូវធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និង ប្រចាំឆ្នាំ ស្តីពីវឌ្ឍនភាព និងហានិភ័យដែលអាចកើតមានក្នុងការអនុវត្តផែនការសកម្មភាពរបស់ខ្លួន ហើយផ្ញើជូនគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមរយៈលេខាធិការដ្ឋាន ។ របាយការណ៍នោះ ត្រូវបញ្ជាក់ថាតើលទ្ធផល និងគោលដៅដែលបានកំណត់ អាចសម្រេចបានដែរឬទេ ? តើមានបញ្ហាអ្វី ដែលកើតឡើងចំពោះការសម្រេចលទ្ធផលនិងគោលដៅនោះដែរឬទេ ? ហើយថាតើមានវិធីណាដែលអាចជំនះចំពោះបញ្ហាទាំងនោះបានដែរឬទេ ? បណ្តាសូចនាករដែលត្រូវប្រើប្រាស់ដើម្បីធ្វើការវាស់វែងវឌ្ឍនភាពខាងលើ មានចែងនៅក្នុងផែនការសកម្មភាពរួម ( ឧបសម្ព័ន្ធទី១ ) ។ នៅដំណាច់ឆ្នាំនីមួយៗ យើងនឹងរៀបចំឱ្យមានការត្រួតពិនិត្យប្រចាំឆ្នាំ ដើម្បីត្រួតពិនិត្យលើសមិទ្ធផលធៀបទៅនឹងគោលដៅប្រចាំឆ្នាំ បញ្ហាប្រឈម និងដកស្រង់បទពិសោធន៍ ដើម្បីកែលម្អការអនុវត្តឱ្យកាន់តែមានប្រសិទ្ធភាព ។

កម្រិតទី២ ៖

ទន្ទឹមនឹងនេះ យើងក៏ត្រូវបន្តពិនិត្យតាមដានប្រចាំត្រីមាសផងដែរ លើគោលដៅគន្លឹះៗ ដែលទាក់ទងទៅនឹងសកម្មភាពការងារជំហានទី ១ ដើម្បីធានាថាសមិទ្ធផលនៃភាពជឿទុកចិត្តបាននៃថវិកាដែលបានកសាងនៅក្នុងដំណាក់កាលទី ១ កាន់តែមានភាពរឹងមាំ និង ត្រូវបានបន្តកែលម្អ ។ បណ្តា

សូចនាករដែលត្រូវប្រើប្រាស់ដើម្បីធ្វើការវាស់វែងវឌ្ឍនភាពនេះមានចែងនៅក្នុងឯកសារភ្ជាប់ទី១ នៃឧបសម្ព័ន្ធនេះ ។

កម្រិតទី៣ ៖

លើសពីនេះទៅទៀត យើងនឹងរៀបចំឱ្យមានផងដែរនូវការត្រួតពិនិត្យពាក់កណ្ដាលឆ្នាំ ដើម្បីពិនិត្យមើលពីវឌ្ឍនភាព ដោយធ្វើការផ្ទៀងផ្ទាត់ទៅនឹងបណ្ដុំនៃសូចនាករគន្លឹះមួយចំនួននៃជំហានទី២ (Sub-set of Platform 2 indicators) ដែលត្រូវបានចាត់ទុកថាជាសូចនាករសម្រាប់វាស់វែងការសម្រេចបានគោលដៅរួមនៃជំហានទី២ ។ មូលដ្ឋានគ្រឹះ (Milestones) សំខាន់ៗ ត្រូវបានកំណត់ដើម្បីតាមដានលទ្ធផលដែលសម្រេចបាន ហើយប្រព័ន្ធភ្លើងសញ្ញា (Traffic Light) នឹងត្រូវប្រើប្រាស់ក្នុងការត្រួតពិនិត្យតាមដាននេះ ។ ភ្លើងសញ្ញា **ពណ៌បៃតង** មានន័យថា សម្រេចបានតាមគោលដៅ ភ្លើងសញ្ញា **ពណ៌លឿង** មានន័យថា កំពុងមានវឌ្ឍនភាព និង ភ្លើងសញ្ញា **ពណ៌ក្រហម** មានន័យថា គ្មានវឌ្ឍនភាព ( ជាកិច្ចចាប់ផ្ដើម ភ្លើងសញ្ញាត្រូវមានពណ៌ក្រហមទាំងអស់ ) ។

គោលបំណងនៃការពិនិត្យតាមដាននេះ គឺដើម្បីពិនិត្យមើលជារួម និងក្នុងកម្រិតនយោបាយ ទៅលើវឌ្ឍនភាពដែលសម្រេចឱ្យបានធៀបនឹងគោលដៅជំហានទី ២ ។ បណ្ដាសូចនាករ ដែលត្រូវប្រើប្រាស់ដើម្បីវាស់វែងវឌ្ឍនភាពនេះ មានចែងនៅក្នុងឯកសារភ្ជាប់ទី ២ នៃឧបសម្ព័ន្ធនេះ ។

ឧបសម្ព័ន្ធទី៩ នឹងគូសបញ្ជាក់អំពីក្របខ័ណ្ឌនៃការចូលរួម និងទំនាក់ទំនងការងាររវាងគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍ ។

ទោះជារាជរដ្ឋាភិបាលកម្ពុជាមិនទាន់បានធ្វើការវាយតម្លៃយ៉ាងពេញលេញទៅលើប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ខ្លួនក៏ដោយ តែកម្ពុជាបាន និងកំពុងត្រួតពិនិត្យតាមដានវឌ្ឍនភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ខ្លួន ដោយផ្ទៀងផ្ទាត់ទៅនឹងក្របខ័ណ្ឌសូចនាករនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលទទួលស្គាល់ជាអន្តរជាតិ ដែលដកស្រង់ចេញពីគណនេយ្យភាពហិរញ្ញវត្ថុ និងចំណាយសាធារណៈ (PEFA) ។ PEFA គឺជាកម្មវិធីភាពជាដៃគូនៃពហុភាគី ដែលមានការឧបត្ថម្ភពីទ្វេភាគី និងពហុភាគីរបស់ដៃគូអភិវឌ្ឍន៍ ។ PEFA បានកំណត់ក្របខ័ណ្ឌការគ្រប់គ្រងសមិទ្ធកម្មនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅក្នុងខែមិថុនា ឆ្នាំ ២០០៥ ។ ឯកសារភ្ជាប់ទី៣នៃឧបសម្ព័ន្ធនេះ នឹងបង្ហាញពីសកម្មភាពការងារដែលបានអនុវត្តកន្លងមកនៅក្នុងជំហានទី១ និងដែលគ្រោងអនុវត្តនៅក្នុងជំហានទី២ មានគោលដៅរួមចំណែក កែលម្អឆ្ពោះទៅរកបណ្ដាសូចនាកររបស់ PEFA ។

<u>ឯកសារភ្ជាប់ទី១</u>

## បណ្ដាសូចនាករដែលអាចវាស់វែងជាបរិមាណបាននៃដំណាក់ទី១ ដែលត្រូវបន្តត្រួតពិនិត្យតាមដាននៅក្នុងដំណាក់ទី២

| សូចនាករ | គោលដៅ |
|---|---|
| ១. លទ្ធផលចំណូលក្នុងស្រុកសរុបជាបណ្ដើៗកាន់តែខិតទៅរកគោលដៅដែលបានអនុម័តនៅក្នុងច្បាប់ហិរញ្ញវត្ថុ | ចំណូលក្នុងស្រុកសរុបសម្រេចបាន + ឬ - ៥% ធៀបនឹងគោលដៅដែលបានអនុម័តនៅក្នុងច្បាប់ |
| ២. គ្មានការបង្កើតឡើងនូវបំណុលកកស្ទះថ្មី | បំណុលកកស្ទះត្រូវកម្រិតមិនឱ្យលើសពី ២% នៃចំណាយសរុប |
| ៣. អាណាប័កជាបណ្ដើៗ អាចបញ្ជាចំណាយទៅតាមកម្មវិធីចំណាយ និង ផែនការសាច់ប្រាក់ | ស្ថានភាពចំណាយមិនត្រូវតិចជាង ៖<br>- ត្រីមាសទី១ [១៥]%<br>- ត្រីមាសទី២ [៤៥]%<br>- ត្រីមាសទី៣ [៦៧]%<br>- ត្រីមាសទី៤ [៩៦]%<br>ភាគរយនៃការទូទាត់ជូនអ្នកផ្គត់ផ្គង់ និងបុគ្គលិកតាមប្រព័ន្ធធនាគារមិនត្រូវតិចជាង ៨0% នៃចំណាយសរុប<br>ភាគរយនៃការបង់ចំណូលតាមរយៈប្រព័ន្ធធនាគារមិនត្រូវតិចជាង ៦0% នៃចំណូលសរុប |
| ៤. ចំណាយតាមប្រភេទ ( សម្រាប់បុគ្គលិក និង មិនមែនបុគ្គលិក ) កាន់តែខិតទៅរកថវិកាដែលបានអនុម័ត | លទ្ធផលចំណាយ ធៀបនឹងថវិកាអនុម័តមិនត្រូវតិចជាង ៖<br>ប្រាក់បៀវត្ស [៩៨]%<br>ទំនិញ/សេវាកម្ម [៩៥]%<br>មូលធន [៨៥]% |
| ៥. ទិន្នផលចំណូលលើមូលដ្ឋានពន្ធកាន់តែប្រសើរជាងមុន តាមរយៈការកែលម្អប្រសិទ្ធភាពនៃការប្រមូល និងផែនការប្រើប្រាស់ប្រភពចំណូលមិនមែនសារពើពន្ធ | ការរួមចំណែកទៅក្នុង ផសស នៃចំណូលសរុប មានការកែលម្អដោយបង្កើនប្រមាណ 0.៥% ក្នុងមួយឆ្នាំ |

<u>ឯកសារភ្ជាប់ទី២</u>

## ការវាស់វែងសមិទ្ធកម្មកម្រិតខ្ពស់សម្រាប់ជំហានទី២

<u>គោលបំណងជំហានទី២</u> ៖ បង្កើនគណនេយ្យភាពដើម្បីសម្រេចបានការគ្រប់គ្រងហិរញ្ញវត្ថុប្រកបដោយភាពស័ក្តិសិទ្ធិ តាមរយៈការធ្វើឱ្យមន្ត្រីសាធារណៈគ្រប់លំដាប់ថ្នាក់អាចទទួលយកការខុសត្រូវចំពោះការត្រួតពិនិត្យ និងការគ្រប់គ្រងថវិកាសាធារណៈ ដោយផ្តល់សិទ្ធិអំណាចសមស្របសម្រាប់ការបំពេញការទទួលខុសត្រូវប្រកបដោយភាពស័ក្តិសិទ្ធិនិងបង្កើតនិងប្រើប្រាស់ប្រកបដោយភាពស័ក្តិសិទ្ធិ នូវឧបករណ៍សម្រាប់ជំរុញឱ្យមានគណនេយ្យភាព ។

| **គោលដៅ** | **ចំណុចគោលដែលសម្រេចបាន** | | | |
|---|---|---|---|---|
| | **ចំណុចគោលទី ១** | **ចំណុចគោលទី ២** | **ចំណុចគោលទី ៣** | **ចំណុចគោលទី ៤** |
| ១. បង្កើត និង អនុវត្តវិធានច្បាស់លាស់ចំពោះការទទួលខុសត្រូវ និង សិទ្ធិអំណាចរបស់អ្នកគ្រប់គ្រងថវិកា | ពិនិត្យឡើងវិញលើវិធានដែលមានស្រាប់ | បង្កើតវិធានថ្មីដោយឈរលើមូលដ្ឋាននៃការប្រមូលផ្តុំ | ដាក់ចេញនូវវិធានថ្មីដែលស្ថិតក្រោមក្របខ័ណ្ឌគតិយុត្តសមស្រប | ដាក់ចេញការណែនាំ និងផ្តល់ការបណ្តុះបណ្តាលសមស្រប |
| ភ្លើងសញ្ញា- | | | | |

| ២. ប្រព័ន្ធ FMIS ជាមូលដ្ឋានចាប់ដំណើរការ ហើយផ្តល់នូវទិន្នន័យគណនេយ្យ សម្រាប់តម្រូវការគ្រប់គ្រង និងការធ្វើរបាយការណ៍ ។ រៀបចំ ឋានានុក្រមនៃរបាយការណ៍គណនេយ្យ ដើម្បីបង្កើតទិន្នន័យដែលមានសង្គតិភាព និងបានផ្ទៀងផ្ទាត់ច្បាស់លាស់ សម្រាប់ក្រសួងស្ថាប័ន/ អង្គភាពថវិកា កសហវ គណៈរដ្ឋមន្ត្រី និងស្ថាប័ននីតិបញ្ញត្តិ | **ចំណុចគោលដែលសម្រេចបាន** | | | |
|---|---|---|---|---|
| | **ចំណុចគោលទី ១** | **ចំណុចគោលទី ២** | **ចំណុចគោលទី ៣** | **ចំណុចគោលទី ៤** |
| | កសាងរចនាសម្ព័ន្ធ និង សមត្ថភាព នៅក្នុង កសហវ ដើម្បីគ្រប់គ្រងការអនុវត្ត FMIS | កិច្ចលទ្ធកម្ម និងកិច្ចសន្យាសម្រាប់ប្រព័ន្ធត្រូវបានអនុវត្ត | ប្រព័ន្ធ FMIS ជាមូលដ្ឋានត្រូវបានអនុវត្ត | ប្រព័ន្ធ FMIS បង្កើតរបាយការណ៍បានត្រឹមត្រូវ មាន សង្គតិភាព និង អាចទទួលយកបាន |
| ភ្លើងសញ្ញា- | | | | |

| ៣. ការអនុវត្តប្តូរគណនេយ្យថ្មីដោយជោគជ័យ និងមានសង្គតិភាពរវាងចំណាត់ថ្នាក់គណនេយ្យ និង ចំណាត់ថ្នាក់ថវិកា នៅក្នុងឯកសារថវិកាជាផ្លូវការ | **ចំណុចគោលដែលសម្រេចបាន** | | | |
|---|---|---|---|---|
| | **ចំណុចគោលទី ១** | **ចំណុចគោលទី ២** | **ចំណុចគោលទី ៣** | **ចំណុចគោលទី ៤** |
| | កិច្ចប្រតិបត្តិការត្រូវស្របទៅតាមចំណាត់ថ្នាក់សេដ្ឋកិច្ចថ្មី | ស្រាវជ្រាវ និងសម្រេចជ្រើសរើសយកទម្រង់នៃចំណាត់ថ្នាក់តាមកម្មវិធី និងមុខងារ | អនុវត្តប្រព័ន្ធ FMISជាមូលដ្ឋានដោយគិតបញ្ចូលទាំងទម្រង់នៃចំណាត់ថ្នាក់មុខងារ និង កម្មវិធី | ចាប់ផ្តើមអនុវត្តចំណាត់ថ្នាក់មុខងារ និងកម្មវិធី |
| ភ្លើងសញ្ញា- | | | | |

| | | | | |
|---|---|---|---|---|
| ៤. សម្រេចបាននូវតម្លាភាពពេញលេញចំពោះកាតព្វកិច្ច និងបំណុលពន្ធនៃអ្នកជាប់ពន្ធ | **ចំណុចគោលដែលសម្រេចបាន** | | | |
| | **ចំណុចគោលទី ១** | **ចំណុចគោលទី ២** | **ចំណុចគោលទី ៣** | **ចំណុចគោលទី ៤** |
| | កំណត់ និង ពិភាក្សាលើវិធាន-ការជាក់លាក់ ដែលត្រូវដាក់ឱ្យអនុវត្ត | អ្នកជាប់ពន្ធអាចទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយច្បាស់លាស់ និង ងាយស្រួលស្តីពីបំណុលពន្ធ និង នីតិវិធីរដ្ឋបាល សម្រាប់ពន្ធធំៗទាំងអស់ | បើកយុទ្ធនាការយ៉ាងសកម្មដើម្បីអប់រំដល់អ្នកជាប់ពន្ធ | អនុវត្តប្រព័ន្ធប្រកាសពន្ធដែលមាននីតិវិធីរដ្ឋបាលប្រកបដោយតម្លា-ភាព និងមានប្រព័ន្ធត្រួតពិនិត្យទ្វេទិសសមស្រប (checks and balances System) |
| ភ្លើងសញ្ញា- | | | | |
| ៥.បង្កើនតម្លាភាពនៃរបាយការណ៍សម្រាប់សភា និងសាធារណជន | **ចំណុចគោលដែលសម្រេចបាន** | | | |
| | **ចំណុចគោលទី ១** | **ចំណុចគោលទី ២** | **ចំណុចគោលទី ៣** | **ចំណុចគោលទី ៤** |
| | កែលម្អទម្រង់របាយការណ៍ | ធ្វើការពិគ្រោះយោបល់ជាមួយអ្នកដែលប្រើប្រាស់ព័ត៌មានលើទម្រង់ដែលបានកែលម្អ | រៀបចំឱ្យមានការប្រមូលទិន្នន័យគ្រប់គ្រាន់ដើម្បីធ្វើរបាយការណ៍តាមទម្រង់ថ្មី | អនុវត្តទម្រង់របាយការណ៍ថ្មី និង ធ្វើការចែកចាយ |
| ភ្លើងសញ្ញា- | | | | |

| | | | | |
|---|---|---|---|---|
| ៦. បង្កើនភាពច្បាស់លាស់ និងតម្លាភាពចំពោះក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ រវាងស្ថាប័នសាធារណៈថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ<br><br>ភ្លើងសញ្ញា- | ចំណុចគោលដែលសម្រេចបាន | | | |
| | ចំណុចគោលទី ១ | ចំណុចគោលទី ២ | ចំណុចគោលទី ៣ | ចំណុចគោលទី ៤ |
| | ពិនិត្យឡើងវិញលើក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ រវាងស្ថាប័នសាធារណៈ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | រៀបចំក្របខ័ណ្ឌថ្មីដែលឆ្លើយតបទៅនឹងការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ | ធ្វើការពិគ្រោះយោបល់ជាមួយគ្រប់ក្រសួងស្ថាប័នមានសមត្ថកិច្ច និង ពាក់ព័ន្ធលើក្របខ័ណ្ឌថ្មី | អនុវត្តក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈថ្មី |
| | | | | |
| ៧. ដាក់ឱ្យអនុវត្តនូវវិធានការដាក់ទណ្ឌកម្ម ច្បាស់លាស់ចំពោះសកម្មភាព និង លទ្ធផលនៃការគ្រប់គ្រងធនធានមិនសមស្រប<br><br>ភ្លើងសញ្ញា- | ចំណុចគោលដែលសម្រេចបាន | | | |
| | ចំណុចគោលទី ១ | ចំណុចគោលទី ២ | ចំណុចគោលទី ៣ | ចំណុចគោលទី ៤ |
| | ពិនិត្យឡើងវិញលើរចនាសម្ព័ន្ធនៃការដាក់ទណ្ឌកម្ម ដែលមាន និងរៀបចំក្របខ័ណ្ឌថ្មី ដែលត្រូវធ្វើសមាហរណកម្ម | រៀបចំកែសម្រួលច្បាប់ ដើម្បីរំលេចឱ្យឃើញពីរចនាសម្ព័ន្ធថ្មី | ប្រកាសឱ្យប្រើច្បាប់ និង ផ្តល់ការបណ្តុះបណ្តាល | អនុវត្តការដាក់ទណ្ឌកម្មតាមរចនាសម្ព័ន្ធថ្មី និង ត្រួតពិនិត្យការអនុវត្តប្រកបដោយប្រសិទ្ធភាព |
| | | | | |
| ៨. បង្កើតប្រព័ន្ធផ្តល់ការលើកទឹកចិត្តច្បាស់លាស់ ចំពោះអ្នកគ្រប់គ្រងថវិកាដែលបានអនុវត្តបានសមស្រប ទៅនឹងស្តង់ដារនៃការ | ចំណុចគោលដែលសម្រេចបាន | | | |
| | ចំណុចគោលទី ១ | ចំណុចគោលទី ២ | ចំណុចគោលទី ៣ | ចំណុចគោលទី ៤ |
| | កំណត់ពីសិទ្ធិសេរីភាពនិង ភាពទន់ភ្លន់សម្រាប់ផ្តល់ជូនអ្នក | រៀបចំកែសម្រួលច្បាប់ ដើម្បីរំលេចឱ្យឃើញពីក្របខ័ណ្ឌថ្មី | ប្រកាសឱ្យប្រើច្បាប់ និង ផ្តល់ការបណ្តុះបណ្តាល | វាយតម្លៃ ដើម្បីជាមូលដ្ឋាននៃការផ្តល់សិទ្ធិសេរីភាព និង |

| | | | | |
|---|---|---|---|---|
| គ្រប់គ្រងហិរញ្ញវត្ថុ<br><br>ភ្លើងសញ្ញា- | គ្រប់គ្រងថវិកា ហើយរៀបចំជាក្របខ័ណ្ឌ | | | ភាពទន់ភ្លន់ឱ្យបានសមស្រប |
| ៩. រៀបចំការធ្វើសវនកម្មពេលក្រោយ (Post Audit) ដោយផ្អែកលើសវនកម្មផ្ទៃក្នុង ដើម្បីផ្តល់នូវសនកម្មដែលមានលក្ខណៈជាប្រព័ន្ធ និង មានការវាយតម្លៃហានិភ័យ<br><br>ភ្លើងសញ្ញា- | **ចំណុចគោលដែលសម្រេចបាន** | | | |
| | **ចំណុចគោលទី ១** | **ចំណុចគោលទី ២** | **ចំណុចគោលទី ៣** | **ចំណុចគោលទី ៤** |
| | រៀបចំផែនការយុទ្ធសាស្ត្រ នៃសវនកម្មផ្ទៃក្នុង<br><br>រៀបចំឯកសារណែនាំ និងកម្មវិធីបណ្តុះបណ្តាល | ចាប់ដំណើរការសវនកម្មផ្ទៃក្នុងនៅក្នុងក្រសួង-ស្ថាប័ន សំខាន់ៗរបស់រាជរដ្ឋាភិបាល និងធ្វើការត្រួតពិនិត្យជាលក្ខណៈប្រព័ន្ធ | ការរៀបចំរបាយការណ៍ជាប្រចាំរបស់ក្រសួងស្ថាប័នភាគច្រើន អនុវត្តកម្មវិធីបណ្តុះ-បណ្តាល | អ្នកគ្រប់គ្រងភាគច្រើនឆ្លើយតប និងចាត់វិធានការតាមរបាយការណ៍ដែលបានលើកឡើង |

| ១០.បង្កើនសមត្ថភាពជំនាញជាអប្បបរមាសម្រាប់ក្រសួង-ស្ថាប័នសំខាន់ៗ ដែលពាក់ព័ន្ធនឹងការអនុវត្តគណនេយ្យភាពប្រកបដោយភាពស័ក្តិសិទ្ធិ | **ចំណុចគោលដែលសម្រេចបាន** | | | |
|---|---|---|---|---|
| | **ចំណុចគោលទី ១** | **ចំណុចគោលទី ២** | **ចំណុចគោលទី ៣** | **ចំណុចគោលទី ៤** |
| | ការគាំទ្ររបស់វិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងនាយកដ្ឋានបុគ្គលិក ត្រូវបានបង្កើតវិធានការ ដើម្បីកសាងជំនាញដូចដែលមានចែងនៅក្នុងផែនការកសាងសមត្ថភាពត្រូវបានអនុវត្ត | ត្រូតពិនិត្យឡើងវិញលើផែនការកសាងសមត្ថភាព និង វាយតម្លៃលើប្រសិទ្ធភាពនៃលទ្ធផល | ត្រូតពិនិត្យឡើងវិញលើផែនការកសាងសមត្ថភាព និង វាយតម្លៃលើប្រសិទ្ធភាពនៃលទ្ធផល | ត្រូតពិនិត្យឡើងវិញលើផែនការកសាងសមត្ថភាព និងវាយតម្លៃលើប្រសិទ្ធភាពនៃលទ្ធផល |
| ភ្លើងសញ្ញា- | | | | |

ឯកសារភ្ជាប់ទី៣

## PEFA ÷ សក្ដានុពលភាពនៃការរួមចំណែករបស់ជំហាននីមួយៗ

| សូចនាករសមិទ្ធកម្ម (PI) | | ការរួមចំណែករបស់ជំហាននីមួយៗ | | | | សូចនាករសមិទ្ធកម្មជំហានទី ២ ដែលរួមចំណែកដល់ជំហាននីមួយៗ |
|---|---|---|---|---|---|---|
| | | ជំហានទី១ | ជំហានទី២ | ជំហានទី៣ | ជំហានទី៤ | |
| **PI-1** | ការអនុវត្តចំណាយធៀបនឹងថវិកាដែលបានអនុម័ត | X | | | | |
| **PI-2** | ការអនុវត្តចំណាយតាមប្រភេទធៀបទៅនឹងថវិកាដែលបានអនុម័ត | X | | | | |
| **PI-3** | ការអនុវត្តចំណូលធៀបទៅនឹងថវិកាដែលបានអនុម័ត | X | | | | |
| **PI-4** | ការតាមដានបំណុលកកស្ទះ | X | | | | |
| **PI-5** | ចំណាត់ថ្នាក់ថវិកា | | X | | | ២,៣ |
| **PI-6** | ភាពគ្រប់ជ្រុងជ្រោយនៃព័ត៌មាននៅក្នុងឯកសារថវិកា | | X | | X | ៥ |
| **PI-7** | កម្រិតនៃប្រតិបត្តិការរបស់រដ្ឋាភិបាលដែលមិនស្ថិតក្នុងប្រព័ន្ធរបាយការណ៍ | X | | | | |
| **PI-8** | តម្លាភាពនៃទំនាក់ទំនងហិរញ្ញវត្ថុសាធារណៈរវាងអន្តររដ្ឋបាល/ស្ថាប័ន | | X | | | ៦ |
| **PI-9** | ការពិនិត្យលើហានិភ័យផ្នែកហិរញ្ញវត្ថុសាធារណៈពីបណ្ដាស្ថាប័នសាធារណៈដទៃទៀត | X | | | | |
| **PI-10** | ការទទួលបានជាសាធារណៈនូវព័ត៌មានស្ដីពីហិរញ្ញវត្ថុសាធារណៈ | | X | | X | ២, ៥ |

| | | | | | | |
|---|---|---|---|---|---|---|
| **C. វដ្តនៃថវិកា** | | | | | | |
| **C (i) ថវិកាផ្អែកលើគោលនយោបាយ** | | | | | | |
| **PI-11** | ការចូលរួមនៅក្នុងដំណើរការរៀបចំថវិកាប្រចាំឆ្នាំ | X | | X | | |
| **PI-12** | ទស្សនទានពហុឆ្នាំចំពោះការរៀបចំផែនការហិរញ្ញវត្ថុសាធារណៈ គោលនយោបាយចំណាយ និង ថវិកា | | | X | X | |
| **C (ii) ការព្យាករណ៍ និងការត្រួតពិនិត្យការអនុវត្តថវិកា** | | | | | | |
| **PI-13** | តម្លាភាពចំពោះកាតព្វកិច្ច និងបំណុលពន្ធ សម្រាប់អ្នកជាប់ពន្ធ | | X | | | ៤ |
| **PI-14** | ភាពស័ក្តិសិទ្ធិនៃវិធានការចុះបញ្ជីអ្នកជាប់ពន្ធ និង ការវាយតម្លៃពន្ធ | X | | | | |
| **PI-15** | ភាពស័ក្តិសិទ្ធិក្នុងការប្រមូលចំណូលពន្ធ | X | | | | |
| **PI-16** | ការព្យាករណ៍បានអំពីថវិកាដែលមានសម្រាប់ការធ្វើធានាចំណាយ | X | | | | |
| **PI-17** | ការកត់ត្រានិងគ្រប់គ្រងសមតុល្យសាច់ប្រាក់ បំណុល និងការធានាចំណាយ | X | | | | |
| **PI-18** | ភាពស័ក្តិសិទ្ធិនៃការត្រួតពិនិត្យប្រាក់បៀវត្ស | | X | | | ២, ៨, ១០ |
| **PI-19** | ការប្រកួតប្រជែង តម្លៃនៃប្រាក់ និងការត្រួតពិនិត្យកិច្ចលទ្ធកម្ម | X | | | | |
| **PI-20** | ភាពស័ក្តិសិទ្ធិនៃការត្រួតពិនិត្យផ្ទៃក្នុងសម្រាប់ចំណាយដែលមិនមែនជាប្រាក់បៀវត្ស | | X | | | ២, ៧, ៨, ១០ |
| **PI-21** | ភាពស័ក្តិសិទ្ធិនៃសវនកម្មផ្ទៃក្នុង | X | X | | | ៩, ១០ |

| | | | | | | |
|---|---|---|---|---|---|---|
| **C (iii) គណនេយ្យ ការកត់ត្រា និង របាយការណ៍** | | | | | | |
| **PI-22** | ការផ្ទៀងផ្ទាត់កិច្ចបញ្ជីការគណនេយ្យទាន់ពេលវេលា និង ទៀងទាត់ | | X | | | ២, ៧ |
| **PI-23** | មានព័ត៌មានស្តីពីថវិកាដែលទទួលបានដោយអង្គភាពផ្តល់សេវា | | X | | | ១,២ |
| **PI-24** | របាយការណ៍នៃការអនុវត្តថវិកាក្នុងឆ្នាំប្រកបដោយគុណភាព និង ទៀងទាត់ | | X | | | ១,២ |
| **PI-25** | របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំដែលមានគុណភាព និង ទៀងទាត់ | | X | | | ២, ៥ |
| **C (iv) ការត្រួតពិនិត្យផ្ទៃក្រៅ និងសវនកម្ម** | | | | | | |
| **PI-26** | វិសាលភាព លក្ខណៈ និង ការតាមដានលើសវនកម្មផ្ទៃក្រៅ | | | X | X | |
| **PI-27** | ការត្រួតពិនិត្យរបស់ស្ថាប័ននីតិបញ្ញត្តិទៅលើច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ | | | | | |
| **PI-28** | ការត្រួតពិនិត្យរបស់ស្ថាប័ននីតិបញ្ញត្តិទៅលើរបាយការណ៍សវនកម្មផ្ទៃក្រៅ | | | X | X | |

# ឧបសម្ព័ន្ធទី ៨

## ការផ្សារភ្ជាប់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាមួយនឹងកម្មវិធីកំណែទម្រង់ដទៃទៀត

ស្របពេលដែលការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកាន់តែមានការរីកចម្រើនទៅមុខ ទំនាក់ទំនង និងការផ្សារភ្ជាប់រវាងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ទៅនឹងកម្មវិធីកំណែទម្រង់ដទៃទៀតក៏កាន់តែមានការកើនឡើងផងដែរ ដើម្បីកែលម្អប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ។

ការផ្សារភ្ជាប់ជាមួយកម្មវិធីកំណែទម្រង់ដទៃទៀត គឺដើម្បីធានាថាការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមិនត្រឹមតែមានប្រសិទ្ធភាពប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងចូលរួមជាវិភាគទានដល់ការអនុវត្តកម្មវិធីកំណែទម្រង់ផ្សេងៗទៀតដែលចាំបាច់ផងដែរ ។

តារាងខាងក្រោមនេះ នឹងបង្ហាញអំពីទំនាក់ទំនងសំខាន់ៗនៃកម្មវិធីកំណែទម្រង់ ៖

| **កម្មវិធីកំណែទម្រង់ដែលពាក់ព័ន្ធ** | **ទំនាក់ទំនងរវាងកម្មវិធីកំណែទម្រង់** | **យន្តការផ្សារភ្ជាប់** |
|---|---|---|
| វិមជ្ឈការ និង វិសហមជ្ឈការ | ការគ្រប់គ្រងធនធានគឺជាទិដ្ឋភាពដ៏សំខាន់មួយនៃការប្រគល់សិទ្ធិអំណាច ។<br>បង្កើនសមត្ថភាពក្នុងការគ្រប់គ្រងធនធានប្រកបដោយប្រសិទ្ធភាព ។<br>ផលប៉ះពាល់ទៅលើការគ្រប់គ្រងម៉ាក្រូហិរញ្ញវត្ថុ។ | សមាជិកភាពរបស់ក្រសួងមហាផ្ទៃនៅក្នុងគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។<br>ចែករំលែកព័ត៌មានអំពីផែនការសកម្មភាព ។<br>រៀបចំកម្មវិធីកែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការឱ្យមានសង្គតិភាពជាមួយនឹងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ<br>បញ្ចូលផែនការសកម្មភាពកែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ ទៅក្នុងផែនការសកម្មភាពកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ ។ |
| ការកែទម្រង់មន្ត្រីរាជការស៊ីវិល | យន្តការផ្តល់អំណាច និង គណនេយ្យភាព ។ ការគ្រប់គ្រងសមិទ្ធកម្ម ។ ការកែទម្រង់ស្ថាប័នដោយភ្ជាប់ជាមួយនឹងការទទួលខុសត្រូវលើថវិកា ។ | សមាជិកភាពរបស់ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលនៅក្នុងគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ ចែករំលែក |

| | | |
|---|---|---|
| | | ព័ត៌មានអំពីផែនការសកម្មភាព ។ កំណត់ពីផលប៉ះពាល់ដល់ស្ថាប័ន នៅក្នុងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ |
| ការកែទម្រង់ប្រាក់បំណាច់របស់មន្ត្រីរាជការ | ការផ្សារភ្ជាប់ប្រាក់បៀវត្សទៅនឹងសមិទ្ធកម្ម ។ ការទទួលបានប្រាក់បំណាច់ក្នុងកម្រិតសមស្របសម្រាប់ជីវភាព រស់នៅ ដែលជាមូលដ្ឋាននៃសមិទ្ធកម្ម និងក្រមសីលធម៌ ។ សមិទ្ធកម្មបន្ថែមក្នុងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលជាការសាកល្បង ក្នុងការកែទម្រង់ប្រាក់បំណាច់មន្ត្រីរាជការ ។ | សមាជិកភាពរបស់ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលនៅក្នុងគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ ការចែករំលែកបទពិសោធន៍ការអនុវត្តប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារ ។ ពង្រីកការអនុវត្តប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារទៅក្រសួង-ស្ថាប័នផ្សេងៗទៀត ។ |
| កម្មវិធីកំណែទម្រង់តាមវិស័យ | វិស័យមួយចំនួនមានកម្មវិធីកែទម្រង់ដែលស្ថិតនៅក្នុងផ្នែកមួយនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ការកែទម្រង់របៀបនេះនឹងផ្តល់ឱកាសសម្រាប់ការផ្សារភ្ជាប់ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារ-ណៈដែលមានលក្ខណៈទូលំទូលាយទៅនឹងការកែទម្រង់ការផ្តល់សេវា ។ | សមាជិកភាពរបស់ក្រសួង-ស្ថាប័នសំខាន់ៗនៅក្នុងគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ ការចែករំលែកព័ត៌មានអំពីផែនការសកម្មភាព និងធនធានដែលមាន ។ ការផ្សារភ្ជាប់ផែនការការងារ |

# ឧបសម្ព័ន្ធទី ៩

# កិច្ចព្រមព្រៀងគ្របដណ្ដប់លើគ្រប់វិស័យ

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានចាត់ទុកថាជាកិច្ចព្រមព្រៀងគ្របដណ្តប់លើគ្រប់វិស័យដើម្បីភាពជាដៃគូ (Sector Wide Agreement for Partnership - SWAP) រវាងរាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍ ។ កិច្ចព្រមព្រៀងគ្របដណ្តប់លើគ្រប់វិស័យដើម្បីភាពជាដៃគូ មានលក្ខណៈសំខាន់ៗមួយចំនួនដូចជា ៖

***គោលបំណងកែទម្រង់រួមគ្នា***

- ដោយមានការយល់ព្រមពីដៃគូអភិវឌ្ឍន៍ ទស្សនៈវិស័យនិងយុទ្ធសាស្ត្រកែទម្រង់រួមត្រូវបានបង្កើត និងជាកម្មសិទ្ធិរបស់រាជរដ្ឋាភិបាលកម្ពុជា ។
- សម្របសម្រួលការផ្តល់មូលនិធិ និង ការរៀបចំគាំទ្ររវាងគូអភិវឌ្ឍន៍ផ្សេងៗគ្នា ដើម្បីគាំទ្រការអនុវត្តការកែទម្រង់ ។ ទំនាក់ទំនងនេះនឹងត្រូវអនុវត្តតាមរយៈគោលការណ៍ភាពជាដៃគូដែលមានការឯកភាពគ្នា ។
- បន្តកិច្ចពិភាក្សាជាប្រចាំក្នុងក្រុមការងារបច្ចេកទេស[២] សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ ដើម្បីពិនិត្យលើយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ផែនការ និងកម្មវិធីរវាងគណៈកម្មាធិការដឹកនាំការងារកែទម្រង់និងដៃគូអភិវឌ្ឍន៍ ។ តំណាងអង្គការក្រៅរដ្ឋាភិបាលក៏ត្រូវបានអញ្ជើញឱ្យចូលរួមក្នុងកិច្ចប្រជុំក្នុងក្រុមការងារបច្ចេកទេសផងដែរ ។

***ការរៀបចំរបស់ដៃគូអភិវឌ្ឍន៍ដើម្បីផ្តល់ការគាំទ្រ***

- គណៈកម្មាធិការដៃគូអភិវឌ្ឍន៍ (DPC) ដែលជួយគាំទ្រដល់ការងារសម្របសម្រួលរវាងរាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍ រួមមានការបង្កើតយុទ្ធសាស្ត្រពហុឆ្នាំ និងផែនការជាដំណាក់ៗ ផែនការសកម្មភាពប្រចាំឆ្នាំ ការត្រួតពិនិត្យជាប្រចាំ និងការវាយតម្លៃតាមពេលកំណត់ច្បាស់លាស់ ។ រហូតមកដល់ពេលនេះ មានដៃគូអភិវឌ្ឍន៍ ១៣[៣] ដែលបានចូលរួមយ៉ាងសកម្មនៅក្នុងគណៈកម្មាធិការដៃគូអភិវឌ្ឍន៍នេះ ។
- លេខាធិការដ្ឋានដៃគូអភិវឌ្ឍន៍ មានមូលដ្ឋាននៅក្នុងការិយាល័យតំណាងធនាគារពិភពលោកប្រចាំនៅកម្ពុជាសម្រាប់គាំទ្រដល់គណៈកម្មាធិការដៃគូអភិវឌ្ឍន៍ ក្នុងការផ្តល់ការណែនាំផ្នែកបច្ចេកទេស និងគ្រប់គ្រងយ៉ាងសកម្ម ការបើកផ្តល់មូលនិធិដែលបានមកពីប្រាក់ជំនួយឥតសំណងរបស់ធានាគារពិភពលោក និង មកពីមូលនិធិទំនុកចិត្តរបស់ពហុអ្នកផ្តល់ជំនួយ។

---

២.ក្រុមការងារបច្ចេកទេស *PFM (TWG)* គឺជាក្រុមការងារដែលត្រូវបានបង្កើតឡើងក្រោមការរៀបចំពិគ្រោះយោបល់ជារួមដែលបានបង្កើតឡើងរវាងរាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍ ។

៣. *ADB, AusAid, CIDA, Dfid, EC,* បារាំង*,* អាឡឺម៉ង់*, IMF,* ជប៉ុន*, DANIDA, Sida, UNDP,* ធនាគារពិភពលោក

## គំនូសតាងទី ១ ៖ រចនាសម្ព័ន្ធនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ - ក្របខ័ណ្ឌគ្រប់គ្រង



*កិច្ចព្រមព្រៀងតាមផ្លូវច្បាប់សំខាន់ៗនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ*

កិច្ចព្រមព្រៀងតាមផ្លូវច្បាប់សំខាន់ៗ ដែលបានគ្របដណ្តប់លើកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រួមមាន ៖

- កិច្ចព្រមព្រៀងផ្នែករដ្ឋបាលសម្រាប់មូលនិធិទំនុកចិត្តរបស់ពហុអ្នកផ្តល់ជំនួយ (MDTF) រវាងធនាគារពិភពលោក និងដៃគូអភិវឌ្ឍន៍ទាំង១៣ ។ មូលនិធិទំនុកចិត្តរបស់ពហុអ្នកផ្តល់ជំនួយនេះទទួលបានជំនួយឥតសំណងពីការធ្វើសហហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ដើម្បីប្រើប្រាស់ជាមូលនិធិរួមគ្នា ។ នៅពេលបច្ចុប្បន្ននេះ មានដៃគូអភិវឌ្ឍន៍ ៤ ដែលបាននិងកំពុងប្រើប្រាស់យន្តការនេះ ។ ដៃគូអភិវឌ្ឍន៍មួយចំនួនផ្សេងទៀតក៏បានផ្តល់មូលនិធិដោយឡែកសម្រាប់គាំទ្រដល់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនេះផងដែរ ។
- ជំនួយឥតសំណងពីគម្រោងគណនេយ្យភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFMAP) ក៏បានធ្វើសហហិរញ្ញប្បទានដល់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នេះដែរ ។
- កិច្ចព្រមព្រៀងផ្តល់មូលនិធិ MDTE/PFMAP រវាងរាជរដ្ឋាភិបាលកម្ពុជា និង ធនាគារពិភពលោកសម្រាប់បើកផ្តល់មូលនិធិពី MDTF និង PFMAP ។ កិច្ចព្រមព្រៀងនេះកំណត់ពីសិទ្ធិចំណាយ និងរួមបញ្ចូលការរៀបចំផែនការសម្រាប់កម្មវិធី ការគ្រប់គ្រងថវិកា ការបើកផ្តល់ លទ្ធកម្ម ការអនុវត្តការគ្រប់គ្រងហិរញ្ញវត្ថុ ការធ្វើរបាយការណ៍ និងសវនកម្ម ។
- គោលការណ៍ភាពជាដៃគូសម្រាប់ដៃគូអភិវឌ្ឍន៍ ។
- អនុស្សារណៈនៃការយោគយល់គ្នាជាក់លាក់មួយសម្រាប់ការគ្រប់គ្រងការអនុវត្តប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារ ។

*ការរៀបចំផែនការ, ការតាមដាន, ការវាយតម្លៃ និង ការធ្វើរបាយការណ៍សម្រាប់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ*

ការរៀបចំផែនការប្រចាំឆ្នាំ និងពហុឆ្នាំ ការរៀបចំថវិកា ការធ្វើរបាយការណ៍ និង ការវាយតម្លៃសម្រាប់អនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានប្រព្រឹត្តទៅ ៖

- ដោយផ្អែកលើការរៀបចំរបស់រដ្ឋាភិបាល បេសកកម្មរួមគ្នាមួយត្រូវបានធ្វើឡើងសម្រាប់ដំណាក់កាលនីមួយៗនៃកម្មវិធីកែទម្រង់ ដើម្បីអនុម័តរួមគ្នារវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ទៅលើយុទ្ធសាស្ត្រពហុឆ្នាំ និង ផែនការសកម្មភាពរួមសម្រាប់កម្មវិធីកែទម្រង់ការ

គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ សូចនាករគន្លឹះ និងទិសដៅនៃកម្មវិធីកែទម្រង់ត្រូវបាន កំណត់ដើម្បីតាមដានសមិទ្ធកម្ម ។ ការរៀបចំសូចនាករ និងទិសដៅនេះត្រូវផ្អែកទៅលើ សូចនាករ PEFA ដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ ប៉ុន្តែត្រូវបានកែសម្រួលឱ្យស្រប ទៅនឹងបរិការណ៍នៃរាជរដ្ឋាភិបាលកម្ពុជា ។

- ជារៀងរាល់ឆ្នាំ ដោយមានការពិគ្រោះយោបល់ជាមួយដៃគូអភិវឌ្ឍន៍ ផែនការសកម្មភាព លម្អិតក៏ត្រូវបានរៀបចំដោយស្ថិតក្នុងក្របខ័ណ្ឌនៃផែនការសកម្មភាពរួមទាំងមូល ដើម្បី អនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ ការរៀបចំដូច្នេះគឺដើម្បីផ្តល់ជា មូលដ្ឋានសម្រាប់រៀបចំថវិកាប្រចាំឆ្នាំ និង លទ្ធកម្ម ។
- របាយការណ៍វឌ្ឍនភាពប្រចាំត្រីមាស និងប្រចាំឆ្នាំ និងរបាយការណ៍ហិរញ្ញវត្ថុជាប្រចាំ ត្រូវ បានរៀបចំ ។
- កិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំត្រូវបានរៀបចំ ដោយមានការចូលរួមពីភាគីពាក់ព័ន្ធទាំងអស់ ព្រមទាំងដៃគូអភិវឌ្ឍន៍ផងដែរ ។
- ការវាយតម្លៃឯករាជ្យត្រូវបានអនុវត្តដោយក្រុមវាយតម្លៃឯករាជ្យពីខាងក្រៅ (EAP) ដើម្បី វាយតម្លៃវឌ្ឍនភាពនៃកម្មវិធីកំណែទម្រង់ ។
- របាយកាណ៍ហិរញ្ញវត្ថុ និងរបាយការណ៍ត្រួតពិនិត្យប្រចាំឆ្នាំ ក៏ត្រូវបានធ្វើឡើង និងផ្ញើជូន គ្រប់ដៃគូអភិវឌ្ឍន៍ ។

### *ការផ្តល់មូលនិធិនាពេលបច្ចុប្បន្ន*

ប្រភពមូលនិធិសំខាន់ៗ ដែលគាំទ្រដល់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រួម មាន MDTF (Ausaid, Dfid, EC, & Sida) និង PFMAP ( ធនាគារពិភពលោក ) ។ ដៃគូអភិវឌ្ឍន៍ ផ្សេងទៀតផ្តល់ការគាំទ្រជាលក្ខណៈទ្វេភាគី ដោយផ្អែកលើជំនួយបច្ចេកទេសដោយឡែក ។ មូលនិធិ សរុបមានប្រហែល ៣២ លាន ដុល្លារអាមេរិក ។ រាជរដ្ឋាភិបាលត្រូវប្រើប្រាស់ប្រមាណ ៣០ លាន ដុល្លារអាមេរិក សម្រាប់រយៈពេល៥ឆ្នាំ ពីឆ្នាំ២០០៥-២០១០ ។ មូលនិធិដែលគាំទ្រទាំងអស់នេះ សំដៅ សម្រេចឱ្យបានគោលបំណងរួមគ្នានៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ ធនាគារ អភិវឌ្ឍន៍អាស៊ីកំពុងតែរៀបចំបង្កើតកម្មវិធីដោយឡែក ដើម្បីគាំទ្រដល់ក្រសួងអាទិភាពចំនួន ៣ ក្នុងការ អនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ គំនូសតាងទី ២ ខាងក្រោម បង្ហាញពីការ រៀបចំការផ្តល់មូលនិធិនៅពេលបច្ចុប្បន្ន ។

## គំនូសតាងទី២ ៖ ការផ្តល់មូលនិធិនៅពេលបច្ចុប្បន្ន




*ជាសរុប*

រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ខិតខំពុះពារដើម្បីធានាថា កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមាន ៖

- យុទ្ធសាស្ត្រច្បាស់លាស់ និងផែនការសកម្មភាព ដើម្បីសម្រួលដល់ការវិភាជន៍ធនធាន ការអនុវត្តរបស់រដ្ឋាភិបាល និងការត្រួតពិនិត្យសមិទ្ធកម្មរួមគ្នា
- ធនធានសមស្រប
- ទំនាក់ទំនងមានប្រសិទ្ធភាព និងការយោគយល់គ្នារវាងរាជរដ្ឋាភិបាលកម្ពុជា និង ដៃគូអភិវឌ្ឍន៍
- ការយកចិត្តទុកដាក់កម្រិតខ្ពស់ចំពោះការផ្លាស់ប្តូរព័ត៌មានរវាងអ្នកពាក់ព័ន្ធទាំងអស់
- ភាពជាអ្នកដឹកនាំមានប្រសិទ្ធភាពទាំងរាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍
- ការសម្របសម្រួល ទំនាក់ទំនង ជំនាញរដ្ឋបាល និងបច្ចេកទេសមានកម្រិតខ្ពស់សម្រាប់ភាគីទាំងសងខាងនៃកិច្ចព្រមព្រៀងគ្រប់ដណ្តប់លើគ្រប់វិស័យដើម្បីភាពជាដៃគូ
- សហប្រតិបត្តិការល្អរវាងលេខាធិការដ្ឋានទាំងពីរ ( លេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ និងគណៈកម្មាធិការដៃគូអភិវឌ្ឍន៍ )

- និរន្តរភាពនៃក្របខ័ណ្ឌច្បាប់ ហិរញ្ញប្បទាន ស្ថាប័ន សមិទ្ធកម្ម ការគ្រប់គ្រង និង ក្របខ័ណ្ឌតាមដាន ។

នៅដំណាក់កាលទី ២ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការចូលរួមរបស់ក្រសួង-ស្ថាប័នទាំងអស់របស់រដ្ឋាភិបាលជាប្រការមិនអាចខ្វះបាន ដែលត្រូវយកចិត្តទុកដាក់ ។

# ឧបសម្ព័ន្ធទី ១០

# ក្របខ័ណ្ឌសម្រាប់គ្រប់គ្រងហានិភ័យក្នុងដំណាក់កាល ទី ២

គ្រប់កម្មវិធីកំណែទម្រង់ តែងតែមាននូវហានិភ័យដែលទាក់ទិនទៅនឹងបរិយាកាសខាងក្រៅ និងខាងក្នុងនៃស្ថាប័ន ។ នៅក្នុងបរិការណ៍នេះ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក៏មិនខុសពីកម្មវិធីកែទម្រង់វិស័យសាធារណៈនៅតាមបណ្តាប្រទេសនានាដែរ គឺមានហានិភ័យមួយចំនួនដែលត្រូវយកចិត្តទុកដាក់ ។ ហេតុដូច្នេះហើយ ប្រការសំខាន់ត្រូវកំណត់ពីការលំបាក ភាពមិនប្រាកដនិយម និងហានិភ័យដែលអាចជះឥទ្ធិពលអវិជ្ជមានទៅលើកម្មវិធីកំណែទម្រង់ ហើយត្រូវចាត់វិធានការជាមុនដើម្បីកាត់បន្ថយហានិភ័យទាំងនោះ ។

វិធីសាស្ត្រដើម្បីកាត់បន្ថយហានិភ័យគឺ ជាបឋមត្រូវកំណត់ពីបណ្តាវិស័យដែលហានិភ័យអាចកើតមាន បន្ទាប់មកត្រូវកំណត់ពីកម្រិតនៃហានិភ័យ ហើយបន្ទាប់មកទៀត ទើបចាត់វិធានការចាំបាច់ដើម្បីកាត់បន្ថយ ឬ លុបបំបាត់ហានិភ័យទាំងនោះ ។ កម្រិតនៃហានិភ័យទាក់ទិនទៅនឹងការវាយតម្លៃលើការជះឥទ្ធិពលជាវិជ្ជមានដែលអាចកើតមាននៅពេលអនុវត្តសកម្មភាពណាមួយ ។ ហានិភ័យអាចមានកម្រិតទាប មធ្យម ឬ ខ្ពស់ ហើយកិច្ចខិតខំប្រឹងប្រែង និងវិធានការដែលត្រូវប្រកាន់យក ដើម្បីកាត់បន្ថយ ឬ លុបបំបាត់ ក៏ត្រូវសមស្របទៅតាមកម្រិតនៃហានិភ័យនោះដែរ ។

ខាងក្រោមនេះ ត្រូវបានចាត់ទុកថាជាហានិភ័យសំខាន់ៗ និងអនុសាសន៍សម្រាប់កាត់បន្ថយហានិភ័យដែលអាចកើតមាន នៅក្នុងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

| **ហានិភ័យសំខាន់ៗ** | **កម្រិតហានិភ័យ** | **សកម្មភាពកាត់បន្ថយហានិភ័យ** |
|---|---|---|
| ការគាំទ្រផ្នែកនយោបាយ និងការគ្រប់គ្រង មានការថយចុះ ( ការយកចិត្តទុកដាក់និងភាពជាអ្នកដឹកនាំ ) | ទាប- ការគាំទ្រផ្នែកនយោបាយ និងគ្រប់គ្រងមានភាពល្អប្រសើរ ។ អាចមានហានិ-ភ័យនៅតាមក្រសួង-ស្ថាប័ន | កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈត្រូវបន្តនិរន្តរភាពនៃការគាំទ្រផ្នែក នយោបាយនិងការគ្រប់គ្រងតាមរយៈគណៈកម្មាធិការដឹកនាំការងារកែទម្រង់ និងក្រុមការងារបច្ចេកទេស ហើយត្រូវធានាឱ្យមានការចូលរួមនៅក្នុងក្រុមសម្របសម្រួលនានានៃកម្ម-វិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ ផ្តល់ការណែនាំនៅកម្រិតនយោបាយដល់គ្រប់ក្រសួងស្ថាប័នដើម្បីចូលរួមនៅក្នុងកម្មវិធីកែទម្រង់នៅដំណាក់កាលទី២ |
| វឌ្ឍនភាពមានការថយចុះ ធ្វើឱ្យប៉ះពាល់ដល់បរិយាកាសការងារ និងធ្វើឱ្យការអនុវត្តការងារកែ | មធ្យម- អាចមានហានិភ័យ ដោយសារតែមានការផ្លាស់ប្តូរ | សមាសធាតុគន្លឹះនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈគឺការអនុវត្តគោលនយោបាយចំណូលដែលនឹងពង្រីកមូលដ្ឋានប្រមូលចំណូល និងពង្រឹងរដ្ឋបាលនិងការព្យាករណ៍ចំណូល ។ ត្រូវមានសូច |

| | | |
|---|---|---|
| ទម្រង់នៅកម្រិត | ប្រភពនៃវឌ្ឍនភាព | នាករដាក់លាក់ដើម្បីប្រាប់ឱ្យដឹងជាមុននៅពេលមានការផ្លាស់ប្តូរជាអវិជ្ជមានចំពោះបរិយាកាសនៃការប្រមូលចំណូល ។ |
| ការគ្មានភាពទន់ភ្លន់នៅក្នុងស្ថាប័នដែលរារាំងដល់ការធ្វើសមាហរណកម្មថវិកា និងភាពគ្រប់ជ្រុងជ្រោយរបស់ថវិកាបានបង្កឱ្យមានការលំបាកក្នុងការវិភាជន៍ធនធានឱ្យបានត្រឹមត្រូវ ។ | ខ្ពស់- ការទទួលខុសត្រូវត្រួតគ្នាដែលមាននៅតាមនាយកដ្ឋាននានារបស់ កហសវ និង នៅតាមវិស័យមួយចំនួនក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ ការត្រួតគ្នានេះហើយនិងការអនុវត្ត វិសហមជ្ឈការ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ អាចបង្កបញ្ហាដល់ការងារកែទម្រង់ | ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈគឺត្រូវកំណត់ឱ្យបានច្បាស់លាស់នូវ តួនាទី និង ការទទួលខុសត្រូវនៅក្នុងដំណាក់កាលនីមួយៗនៃវដ្ដថវិកា ។ ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក៏ជួយដល់ការគ្រប់គ្រងចំណូលតាមរយៈការធ្វើសមាហរណកម្មថវិកា និង វិសហមជ្ឈការ និង ស្វែងរកឱកាសនិងវិធីសាស្ត្រដើម្បីឱ្យអ្នកពាក់ព័ន្ធទាំងអស់បានយល់ដឹង និងចូលរួមក្នុងដំណើរការកែទម្រង់ ។ ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក៏ផ្តល់នូវឱកាសជាច្រើនដល់អ្នកពាក់ព័ន្ធកសាងសមត្ថភាពដើម្បីចូលរួមអនុវត្តការងារកែទម្រង់ ( ផែនការយុទ្ធសាស្ត្រថវិកា ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ថវិកាតាមកម្មវិធី ការគ្រប់គ្រង់ហិញ្ញវត្ថុតាមប្រព័ន្ធព័ត៌មានវិទ្យា ) ។ |
| ការអនុវត្តការគ្រប់គ្រងហិរញ្ញវត្ថុ តាមប្រព័ន្ធព័ត៌មានវិទ្យា មានផលប៉ះ-ពាល់ លើការត្រួតពិនិត្យ និង គណនេយ្យភាព | ខ្ពស់- បទពិសោធន៍ និង សមត្ថភាព ដើម្បីគាំទ្រដល់ការអនុវត្តប្រព័ន្ធព័ត៌មានវិទ្យានៅមានភាពទន់ខ្សោយ | ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈត្រូវធានាថាវិធីសាស្ត្រដែលយកមកអនុវត្តត្រូវមានភាពស្របគ្នាទៅនឹងមុខងារ និងសមត្ថភាពជាបណ្តើរៗ ។ ការកសាងសមត្ថភាពត្រូវធ្វើឡើងឱ្យបានទូលំទូលាយដើម្បីគាំទ្រដល់ការអនុវត្តការគ្រប់គ្រងហិរញ្ញវត្ថុតាមប្រព័ន្ធព័ត៌មានវិទ្យា ។ ការគ្រប់គ្រង និងជំនាញបច្ចេកទេសក្នុងដំណាក់កាលអន្តរកាល ត្រូវបានផ្តល់ដើម្បីជួយសម្រួលដល់ការរៀបចំ និងអនុវត្ត ។ |

| | | |
|---|---|---|
| | | ធនាគារពិភពលោក និងផ្តល់ការគាំទ្រផ្នែកបច្ចេកទេស គ្រប់ទិដ្ឋភាពទាំងអស់ នៃដំណើរការអនុវត្តការគ្រប់គ្រងហិរញ្ញវត្ថុតាមប្រព័ន្ធព័ត៌មានវិទ្យា។ |
| ការអភិវឌ្ឍសមត្ថភាព មិនគ្រប់គ្រាន់ធ្វើឱ្យប៉ះពាល់ដល់ការកែទម្រង់ ។ | ខ្ពស់- កិច្ចខិតខំប្រឹងប្រែងដើម្បី កសាងសមត្ថភាពនៅដំណាក់កាលទី១ នៅមានកម្រិត | ផែនការកសាងសមត្ថភាពនៅដំណាក់កាលទី២ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលរួមមានការបណ្តុះបណ្តាល ការគ្រប់គ្រងធនធានមនុស្ស ការផ្លាស់ប្តូរផ្នែកស្ថាប័ន និងការលើកទឹកចិត្ត ។ លើសពីនេះ ត្រូវផ្តោតការយកចិត្តទុកដាក់លើការកសាងសមត្ថភាពទាំងនៅក្នុង កសហវ និងក្រសួង-ស្ថាប័ននានា និងលើការបណ្តុះបណ្តាលគ្រូបង្គោលសម្រាប់ការបណ្តុះបណ្តាលរយៈពេលវែង ។ យកចិត្តទុកដាក់ក្នុងការអនុវត្ត និង តាមដានការអភិវឌ្ឍស្ថាប័ន ធនធានមនុស្ស និងគ្រប់គ្រងការផ្លាស់ប្តូរ ។ អ្នកជំនាញការដែលមានជំនាញលើកិច្ចការទាំងអស់នេះនឹងជួយក្នុងការរៀបចំ និងអនុវត្ត ។ |
| ការលើកទឹកចិត្តមិនគ្រប់គ្រាន់ដើម្បីគាំទ្រការកែទម្រង់ ( បៀវត្ស ប្រាក់លាភការបន្ថែម ដោយផ្អែកលើលទ្ធផលការងារ ) ។ | ខ្ពស់- គ្មានលទ្ធភាពពង្រីកគម្រោងប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារដែលបណ្តាលឱ្យការចូលរួមនៅក្នុងការកែទម្រង់មានកម្រិត | នៅក្នុងក្របខ័ណ្ឌថ្មីនៃគម្រោងប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារដែលបានឯកភាពនាពេលថ្មីៗនេះដោយរាជរដ្ឋាភិបាលកម្ពុជា កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រួមជាមួយនឹង កសហវ ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល និងដៃគូអភិវឌ្ឍន៍នឹងយល់ព្រមចំពោះការពង្រីកគម្រោងប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារ ដើម្បីគាំទ្រដល់មន្ត្រីរាជការនៅក្នុងកសហវ និង នៅតាមបណ្តាក្រសួង-ស្ថាប័ននានា ព្រមទាំងនៅតាមមន្ទីរជំនាញខេត្តក្រុង ។ បន្តកិច្ចខិតខំប្រឹងប្រែងដើម្បីគាំទ្រដល់ផ្សារភ្ជាប់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទៅនឹងកម្មវិធីកែទម្រង់មន្ត្រីរាជការស៊ីវិល ។ |

| | | |
|---|---|---|
| ការសម្របសម្រួលមិនទាន់គ្រប់គ្រាន់ | ខ្ពស់ - បញ្ហាប្រឈមក្នុងការសម្របសម្រួល និងទំនាក់ទំនងរវាងនាយកដ្ឋានរបស់កសហវ និងអង្គភាព ក្រសួង-ស្ថាប័ន នានាអាចជះឥទ្ធិពលអវិជ្ជមានចំពោះការរៀបចំ និងអនុវត្តថវិកា | ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនឹងបន្តគាំទ្រដល់កិច្ចខិតខំប្រឹងប្រែង ដើម្បី (ក) កែលម្អកិច្ចសហប្រតិបត្តិការក្នុងការអនុវត្តការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរវាងអ្នកពាក់ព័ន្ធទាំងអស់នៅគ្រប់កម្រិត (ខ) វិភាគមុខងារនៅក្នុងនាយកដ្ឋាននៃកសហវ ដើម្បីធានាឱ្យមានការសម្របសម្រួល និងទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព (គ) បង្កើតយន្តការ ក្រុមការងារ ដោយផ្អែកលើរចនាសម្ព័ន្ធនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលមានស្រាប់ (ឃ) អនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឱ្យបានទូលំទូលាយ ដើម្បីពង្រឹងស្ថាប័នថ្នាក់ជាតិ ( អាជ្ញាធរសវនកម្មជាតិ ក្រសួងផែនការ ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ) និង ក្រសួង-ស្ថាប័ន នានា ។ រៀបចំឱ្យមានយន្តការសម្របសម្រួលសមស្របនៅគ្រប់កម្រិត ។ បង្កើនការយល់ដឹងពីកម្មវិធីកែទម្រង់ដល់ក្រសួង-ស្ថាប័ន និងធានាថាក្រសួង-ស្ថាប័ន ដែលត្រូវធ្វើការសាកល្បងវិភាជន៍ធនធានដើម្បីគាំទ្រដល់ការកែទម្រង់ ។ |
| ការធ្វើប្រតិភូកម្មអំណាច និង ឯករាជ្យភាព ( ស្ថាប័នសវនកម្មផ្ទៃក្រៅ ) មានភាពគ្រប់គ្រាន់ | ខ្ពស់- វប្បធម៌ស្ថាប័នមាននិន្នាការលើកតម្កើងមជ្ឈការការធ្វើសេចក្ដីសម្រេចចិត្ត និងត្រួតពិនិត្យ ជាលម្អិត | ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនឹងធានាថាបរិយាកាសការងារថ្មី មានភាពស៊ីគ្នាទៅនឹងការទទួលខុសត្រូវ និង សិទ្ធិអំណាច ។ ត្រូវយល់ថាការធ្វើប្រតិភូកម្ម អំណាចមិនបានធ្វើឱ្យប៉ះពាល់ដល់ការត្រួតពិនិត្យនោះទេ ។ ធានាឱ្យមានការគាំទ្រផ្នែកនយោបាយ និងគ្រប់គ្រងដើម្បីបង្កើតនិងកែលម្អរចនាសម្ព័ន្ធជាថ្មី ។ |
| តម្រូវការពីខាងក្រៅ មានភាពគ្រប់គ្រាន់ ( សង្គម | មធ្យម- តម្រូវការពីខាងក្រៅ ដើម្បី | ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនឹងពង្រឹងសមត្ថភាព កសហវ ដើម្បីឆ្លើយតប |

| | | |
|---|---|---|
| ស៊ីវិល, អាជ្ញាធរសវនកម្មជាតិ, រដ្ឋសភា ) | ឱ្យការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មានប្រសិទ្ធភាព មានភាពទន់ខ្សោយ ទោះបីជាបានបង្ហាញឱ្យឃើញពីនិន្នាការកែលម្អ ក៏ដោយ | ទៅនឹងតម្រូវការពីខាងក្រៅតាមរយៈការបង្កើនតម្លាភាពនៅក្នុងការអនុវត្តធ្វើរបាយការណ៍វឌ្ឍនភាព និង ការពិភាក្សា ។ |
| មានការយល់ដឹងអំពី ការបង្កើតប្រព័ន្ធទំនាក់ទំនងតាមព័ត៌មានវិទ្យា ( យុទ្ធ-សាស្ត្រការថែទាំ និង និរន្តរភាព ) | មធ្យម- មិនទាន់មានគោលនយោបាយ ប្រព័ន្ធទំនាក់ទំនងតាមព័ត៌មានវិទ្យា នៅពេលបច្ចុប្បន្ននេះទេ | ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសា-ធារណៈនឹងជួយផ្តល់ជំនួយបច្ចេកទេសដើម្បីគាំទ្រដល់នាយកដ្ឋានព័ត៌មានវិទ្យា ដើម្បីធានាឱ្យមានការបង្កើតនិងអនុវត្តក្របខ័ណ្ឌយុទ្ធសាស្ត្រប្រព័ន្ធទំនាក់ទំនងតាមព័ត៌មានវិទ្យា។ ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក៏នឹងបន្តគាំទ្រដល់ការកសាងសមត្ថភាពផងដែរ ។ |
| យន្តការការសម្រាប់ប្រតិបត្តិការនៅមានភាពខ្សោយ ដើម្បីធានានូវការយកចិត្តទុកដាក់លើការកាត់បន្ថយភាព ក្រីក្រ និងយែនឌ័រ នៅក្នុងកម្មវិធីកែទម្រង់ | ខ្ពស់- ការយក ចិត្តទុកដាក់ទៅលើយែនឌ័រ នៅមានកម្រិត និង គ្មានសមភាព យែនឌ័រ | ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសា-ធារណៈនឹងចូលរួមចំណែកដើម្បីគាំទ្រផ្នែកនយោបាយដើម្បីឆ្លើយតបទៅនឹងគំនិតផ្តួចផ្តើមបង្កើតឱកាសឱ្យស្ត្រីមានការចូលរួមក្នុងកម្រិតខ្ពស់។ |